ថាច់ ត្វាន់

# ប្រវត្តិសាស្ត្រ ប្រជាជាតិខ្មែរ



*History of the Khmer People*

គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ

Editions Angkor

www.elibraryofcambodia.org

www.elibraryofcambodia.org

# ប្រវត្តិសាស្ត្រ ប្រជាជាតិខ្មែរ

www.elibraryofcambodia.org

www.elibraryofcambodia.org

© រក្សាសិទ្ធិគ្រប់យ៉ាងដោយ
គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ
ហាមថតចំលង និងបកប្រែ
នៅគ្រប់ប្រទេសទាំងអស់

ភ្នំពេញ
២០១០

www.elibraryofcambodia.org

PB.....2013.........

ឋាប់ ត្វាន់

# ប្រវត្តិសាស្ត្រ ប្រជាជាតិខ្មែរ



History
of the Khmer People

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ

00025166

២០១០

www.elibraryofcambodia.org

គ្រឹះស្ថានបោះពុម្ពផ្សាយ **អង្គរ**
EDITIONS ANGKOR

ISBN-13 : 978-99950-2-114-6

www.elibraryofcambodia.org

សៀវភៅនេះបានបោះពុម្ពផ្សាយជាភាសាបារាំងកាល ខែកុម្ភៈ ឆ្នាំ២០០៩ នៅក្រុងប៉ារីស ក្រោមចំណងជើងជា "Histoire des Khmers" ហើយបានទទួលការ សរសើរ និងសមានចិត្តដ៏ខ្ពង់ខ្ពស់ពី ៖

- ព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
- សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា

www.elibraryofcambodia.org

*Sa Majesté Preah Bat Samdech Preah Boromneath*
NORODOM SIHAMONI
ROI du CAMBODGE

au Professeur Thach Toan
Résidence Île-de-France
30 rue de France
06000 NICE
FRANCE

*Cher Professeur Thach Toan,*

*Je vous remercie infiniment de votre aimable lettre en date du 15 mars 2009 et du très instructif livre intitulé « Histoire des Khmers » que vous venez de faire publier.*

*Votre important livre sera très apprécié par tous ceux qui s'intéressent à notre Peuple et à son évolution depuis plusieurs millénaires.*

*Je vous en exprime mes sincères félicitations.*

*Avec mes fervents vœux de bonheur et de prestigieux succès, veuillez agréer, cher Professeur, l'assurance de ma haute et admiratioe considération.*

Norodom Sihamoni

*Phnom Penh, le 31 Mars 2009*

www.elibraryofcambodia.org

Samdech Akka Moha Sena Padei Techo HUN SEN
Premier Ministre du Royaume du Cambodge

Monsieur le Professeur Thach Toan
Résidence Ile-de-France
90, rue de France,
06000 NICE
FRANCE

Phnom Penh, le 6 avril 2009

Monsieur le Professeur,

Votre lettre du 15 mars 2009, accompagnée de votre livre intitulé "l'Histoire des Khmers ou l'Odyssée du peuple cambodgien", m'est bien parvenue.

Je vous remercie pour votre ouvrage que j'étudierai avec attention et plaisir.

Je tiens à vous adresser mes sincères félicitations pour avoir consacré votre temps et votre énergie à la réalisation de ce livre qui permettra de faire découvrir aux amis étrangers francophones notre peuple dont les éléments identitaires et culturels sont singuliers, d'autant plus qu'il s'agit d'une œuvre sur l'histoire des Khmers écrite par un Khmer.

Je vous souhaite ainsi qu'à votre famille, les quatre vœux du Bouddha : longévité, beauté, force et santé.

Veuillez agréer, Monsieur le Professeur, l'assurance de ma cordiale considération.

HUN Sen

www.elibraryofcambodia.org

" ជនជាតិណាដែលមិនយកចិត្តទុកដាក់រក្សាកំណត់ជីវប្រវត្តិរបស់ខ្លួន ជនជាតិនោះប្រាកដជាត្រូវជួបនឹងគ្រោះថ្នាក់ជាមិនខាន "

**មីកាអែលហ្សឺន**
ទេសាភិបាល ប្រទេសកាណាដា

www.elibraryofcambodia.org

<u>ជូនចំពោះ</u>

សុទ្ធ សុផានី  ភរិយាខ្ញុំ

នីផាណា នីផា នីផានី

<u>និងដល់</u>

*Cecilia* ទេវី

*Adriel* មុនីវណ្ណ

*Thach* សុវណ្ណ

*Noam* សច្ចៈ

*Joy* សុរិយា

www.elibraryofcambodia.org

**រក្សាសិទ្ធិគ្រប់យ៉ាង©**

"ការចំលងទាំងអស់ ឬ ផ្នែកណាមួយពីសៀវភៅនេះ ទោះជាតាមរបៀបណាក៏ដោយ បើគ្មានការអនុញ្ញាតពីគ្រឹះស្ថានបោះពុម្ពផ្សាយ **អង្គរ** គឺខុសច្បាប់ និងត្រូវមានទោសតាមផ្លូវច្បាប់" ។

www.elibraryofcambodia.org

# មាតិការឿង

បុព្វកថា ..... ១៥

វគ្គទី ១: ខ្មែរ ..... ១៩

វគ្គទី ២: ដើមកំណើតខ្មែរ ..... ២៥

វគ្គទី ៣: ស្រុកខ្មែរ ឬ នគរខ្មែរ ..... ៣៧

វគ្គទី ៤: ទូណរាន់ ឬ អង្គរបុរី ..... ៤៧

វគ្គទី ៥: ចិនឡា ឬ កម្ពុជា ..... ៥៧

វគ្គទី ៦: ឈីវយី សោមា និង សន្លឹកស្វល ..... ៦៧

វគ្គទី ៧: មត្តេយ្យកាខ្មែរ ..... ៧១

វគ្គទី ៨: លក្ខណៈពិសេសរបស់ខ្មែរ ..... ៧៩

វគ្គទី ៩: ជំនឿខ្មែរ ..... ៨៥

វគ្គទី ១០: សាសនាក្លឹង្គនៅស្រុកខ្មែរ ..... ៩៥

វគ្គទី ១១: ទេវរាជ ..... ១០៣

វគ្គទី ១២: លេខ ៥ ឬ លេខនិមិត្តរូបព្រះសិវៈ ..... ១១១

វគ្គទី ១៣: ភ្នំព្រះសុមេរុ ..... ១១៩

វគ្គទី ១៤: សិវៈលោកៈ និង ភ្នំបាខែង ..... ១២៥

វគ្គទី ១៥: វិស្ណុលោកៈ ឬ អង្គរវត្ត ..... ១៣៧

www.elibraryofcambodia.org

វគ្គទី ១៦: ជ័យស្រី ឬ អង្គរធំ ............................................................................. ១៤៧

វគ្គទី ១៧: ព្រះបាទនៅស្រុកខ្មែរ............................................................................. ១៥៧

វគ្គទី ១៨: ការពិត និង រឿងព្រេងខ្មែរ............................................................................. ១៦៣

វគ្គទី ១៩: ព្រាហ្មណ៍នៅស្រុកខ្មែរ .............................................................................១៧៣

វគ្គទី ២០: ស្តេចអង្គរ .............................................................................១៨៣

វគ្គទី ២១: ការសិក្សានៅអង្គរ............................................................................. ១៩៣

វគ្គទី ២២: ការបាត់បង់អង្គរ .............................................................................២០៥

វគ្គទី ២៣: ខ្មែរក្រោម ឬ ខ្មែរកូសាំងស៊ីន ............................................................................. ២១៥

វគ្គទី ២៤: សុទ្ធានុក្រម ខ្មែរ-ខ្មែរ .............................................................................២៣១

សេក្តីបញ្ចប់: ............................................................................. ២៤១

www.elibraryofcambodia.org

# បុព្វកថា

និយាយអំពីខ្មែរ លោកអាឡាំងផរេស្ត[9] បានសរសេរថា៖ "ខ្មែរជាជនជាតិមួយក្នុងចំណោមជនជាតិបន្តិចបន្តួច ដែលគេនឹកស្មានថាគេបានស្គាល់យ៉ាងច្បាស់ណាស់ [illegible] ដឹងស្គាល់អ្វីទាំងអស់ ហើយជា [illegible] និយាយភ្លាមបានថាខ្លួនជាអ្នក [illegible] នេះតើបានត្រឹមត្រូវពិតប្រាកដ ?

ការសិក្សានិងសៀវភៅ [illegible] ច្រើនណាស់ ។ ស្នាដៃរបស់មន្ទីរ [illegible] (E.F.E.O) មានភាពធំធេងមែន [illegible] បំផុត ។ ប៉ុន្តែជាការពិតដែរ [illegible] គេឯងច្រើន ។ ប្រាសាទអង្គរបានគេទទួលស្គាល់ថាជាវត្ថុអស្ចារ្យមួយនៅក្នុងលោក ។ ប្រាសាទអង្គរក៏មានធ្វើតាមវប្បធម៌ ក្លឹង្គ ដែរ ។ ភ្លាមៗនោះ អ្នកប្រាជ្ញទាំងឡាយគេថាអ្វីៗគឺមកពីក្លឹង្គទាំងអស់ បានន័យថាខ្មែរឥតមានគំនិតផ្ទាល់ខ្លួនទៅរៀបចំឲ្យបាន ប្រាសាទដ៏

---

[9] Alain Forest : Le culte des génies protecteurs au Cambodge. L'Harmattan. Paris 1992, p. 6.

www.elibraryofcambodia.org

ល្អអស់នោះទេ ។ លោកសើដែស[២] បានសរសេរថា "ខ្មែរបានធ្វើអ្វីៗទាំងអស់តាមកពីក្លិង្គ ហើយគេអាចនិយាយបានថា ខ្មែរជាភ្នងដែលបានទទួលលក្ខណៈ "ក្លិង្គ"... ប្រែមកថាបើឥតមានក្លិង្គទេ ខ្មែរនៅតែជាភ្នង គឺថាតាមពាក្យ លោកសើដែសដដែល "ពួកនេះនៅមានការរៀបចំសង្គមតាមរបៀបកុលសម្ព័ន្ធ គេកាត់សេចក្តីតាមទំនៀមទំលាប់ ដែលចេះមកពីពាក្យនិយាយ គេមានជំនឿលើព្រលឹងរបៀបល្ងិតល្ងង់ គេគ្មានតួអក្សរសម្រាប់សរសេរភាសារបស់គេទេ...។ល។" អ្នកណាក៏ដឹងដែរថានៅពេលដែលខ្មែរនិយមតាមវប្បធម៌ក្លិង្គយ៉ាងខ្លាំងនោះ គេមានឆ្លាក់ចារឹកអក្សរខ្មែរនៅក្បែរអក្សរសំស្រ្កឹតក្លិងផង នេះបើគ្រាន់តែនិយាយអំពីអក្សរសាស្រ្ត ។

គេមិនសូវស្គាល់ខ្មែរ និងស្រុកខ្មែរទេ ។ ភាពដែលមានបង្អាប់បន្ថោកពីអ្នកនិពន្ធខ្លះ មិនបានជួយឲ្យមានការយល់ស្គាល់បានច្រើនទេ ។ ការពិតមនុស្សភាពយ៉ាងច្បាស់លាស់របស់ខ្មែរមានរួចហើយ មុនពេលដែលក្លិង្គចូលមកទៀត ។ វប្បធម៌ខ្មែរ ដែលមានភាសា អក្សរសរសេរ ការត្រិះគិត និងជំនឿទំនៀមទំលាប់ ទាំងឡាយ មានអស់រួចហើយ មុននឹងខ្មែរទទួលបានវប្បធម៌ក្លិង្គ ។ វប្បធម៌ខ្មែរនេះក៏បាននៅដល់សព្វថ្ងៃទៀត ពីព្រោះខ្មែរមិនដែលបោះបង់ចោលទំនៀមទម្លាប់របស់ខ្លួនទេ ដូចលោកក្លូដហ្សាក់[៣] បានសរសេរមកស្រាប់ ។

---

[២] Georges Coedès : Les Etats hindouisés d' Indochine et d' Indonésie. De Boccard 1989, p.4.

[៣] Claude Jacques et Michaël Freeman : Angkor, Résidences des Dieux. Edition Olizane 1997.

www.elibraryofcambodia.org

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY


គេស្គាល់ច្បាប់សិល្បៈរបស់ខ្មែរ ។ តែគេបានស្គាល់អស់ទេ អំពីន័យនិងនិមិត្តរូបរបស់សិល្បៈទាំងនោះ? តើប្រាសាទអង្គរនៅមានលាក់ភាពអាថ៌កំបាំងដែរឬអ្វី? ការពិតគឺប្រហែលជាគ្មានអាថ៌កំបាំងអ្វីពីប្រាសាទទាំងអស់នោះទេ បើគេបានយកចិត្តទុកដាក់ឲ្យស្គាល់ការរិះគិត ហើយនិងការប្រែក្លាយក្នុងជំនឿខ្មែរ ។ ការបកស្រាយព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រដែលខុស ឬមិនបានត្រឹមត្រូវធ្វើឲ្យមានការខូចខាតដល់ប្រវត្តិសាស្ត្រនោះតែម្តង ។ យើងឥតមានបំណងមកបកស្រាយអ្វីទាំងអស់ ប៉ុន្តែតាមរយៈសៀវភៅនេះយើងសង្ឃឹមថាយើងអាចនាំពន្លឺខ្លះ មកលើការដែលគេនៅងឿងឆ្ងល់នៅឡើយ ។

ចំពោះខ្មែរខ្លួនឯងវិញ យើងឃើញថាបែបហួសសម័យទៅហើយបើប្រសិនណាយើងនៅតែទន្ទេញថាមហាក្សត្រទី១ ដែលគេបានស្គាល់ក្នុងប្រវត្តិសាស្ត្រមានព្រះនាមជា **លីវយី** ដែលការពិតគឺមិនមែនដូច្នេះសោះ ។ យើងឃើញដូចជាខុសពីធម្មតា ការដែលខ្មែរយើងនៅយល់ថាកំពូលប្រាំប្រាសាទអង្គរវត្ត (ប្រាសាទដែលខ្មែរស្រឡាញ់ជាទីបំផុតហើយដែលមាននៅលើទង់ជាតិខ្មែរគ្រប់របប) ជារូបភ្នំព្រះសុមេរុ ឬគ្រាន់តែជាដំណាងទិសទាំងប្រាំតែប៉ុណ្ណោះ ឯការពិតគឺផ្សេងពីនេះសោះ ។

ចំពោះខ្មែរទាំងអស់ យើងសូមឧទ្ទិសសៀវភៅនេះ និងទំព័រខ្លះដែលជាការពិតដើម្បីឲ្យស្គាល់នូវ អត្តសញ្ញាណខ្លួនឯង ហើយនិងឲ្យស្គាល់ច្បាស់ប្រទេសជាតិរបស់ខ្លួន។ **"ឯងត្រូវស្គាល់ខ្លួនឯងដោយខ្លួនឯង"** នេះគឺពាក្យរបស់ លោកសូក្រាត (Socrate) អ្នក

www.elibraryofcambodia.org

ទស្សនវិជ្ជាក្រិចម្នាក់កាលសតវត្សរ៍ទី៥ មុន គ.ស ។ ចំពោះខ្មែរដែរ យើងជឿជាក់ថា យើងបាននាំមកឲ្យខ្លះនូវយុត្តិធម៌ នូវភាពថ្លៃថ្នូរ និង ចិត្តខ្ពង់ខ្ពស់ដែលខ្មែរមិនដែលបោះបង់ចោលមួយដងណាឡើយ។

www.elibraryofcambodia.org

# វគ្គទី ១

# ខ្មែរ

តើអ្នកណាដែលគេហៅថាខ្មែរ ?

ហេតុដូម្ដេចបានជាគេឲ្យ ឈ្មោះថា ខ្មែរ ?

ពាក្យថា "ខ្មែរ" បានគេយកមកប្រើជាយូរណាស់មកហើយ។ ខ្មែរជាពាក្យមួយសម្រាប់សំគាល់ដល់ប្រជាជន ដែលមានកំណើតមកជាខ្មែរ ។ ដើមកំណើតរបស់ខ្មែរ គឺជនជាតិ "មុណ្ឌា:" ។ ខ្មែរចេញមកពីជាតិ "មុណ្ឌា:" ដែលជាជាតិមានជីវិតមុនគេបង្អស់ នៅលើទឹកដីប្រទេសឥណ្ឌា ។ ជនជាតិមុណ្ឌា: មានទំនៀមទំលាប់គោរពម្ដាយ និង គោរពឪពុក ។ ខាងផ្លូវនយោបាយជនជាតិមុណ្ឌា: កាន់របបមាតានិយម ប្រែមកថាមហាក្សត្រជនជាតិនេះជាស្ត្រីទាំងអស់ដែលគេទុកជាម្ដាយរបស់រដ្ឋ និង ម្ដាយរបស់ប្រជាជនទូទៅផង ។

ខ្មែរដែលចេញពីជនជាតិ "មុណ្ឌា:" ក៏គោរពម្ដាយ និងគោរពឪពុកដូចជាជនជាតិមុណ្ឌា:ដែរ ។ កាលពីដើមខ្មែរហៅម្ដាយថា មេ មិនមែនហៅថា "ម៉ែ" ទេ ។ ដោយហេតុនេះហើយបានជាគេនិយាយថាគោរពមេគោរពបា "ប្រាំពីរដងឪពុក" ។ ក្នុងរបប "មាតានិយម" នេះ អ្នកដឹកនាំធ្វើគ្រប់បែបយ៉ាងដើម្បីឲ្យខ្មែរទាំងអស់គ្នាជឿ

www.elibraryofcambodia.org

ថាមេជាធំ ឲ្យយើងទាំងអស់គ្នាគោរពមេ ឲ្យយើងទាំងអស់គ្នាស្ដាប់បង្គាប់មេ ។ ដើម្បីកុំឲ្យយើងភ្លេចគោលគំនិតសំខាន់នេះ គេឲ្យយើងទាំងអស់មាន ឈ្មោះថា "ខ្មេរ" ដែលយើងសព្វថ្ងៃនិយាយថាខ្មែរ ។

**ខ្មេរ មានន័យថា អ្នកគោរពមេ** ។ ក្នុងពាក្យ ខ្មេរ មាន ខ+មេ + រ ហើយសំឡេង "ខ" បង្ហាញឲ្យដឹងថាអ្នកនោះមានវណ្ណៈនៅខាងក្រោម នេះបើនិយាយតាមអ្នកប្រាជ្ញខាងភាសា ។ យ៉ាងណាវិញបើកាលណាយើងមានកូនស្រីមួយមានឈ្មោះថាវណ្ណី "យើងច្រើនហៅនាងថា អាខ្នី" មានន័យថា នាងនេះមានវណ្ណៈខាងក្រោមយើងទេ ។ ប៉ុន្តែពាក្យអាខ្នីនេះមិនមែនជាពាក្យមើលងាយអ្វីដែរ ។ ផ្ទុយទៅវិញ ពាក្យនេះមានការបង្ហាញឲ្យយើងនូវភាពស្រឡាញ់ភាពស្និទ្ធស្នាលរបស់គេ ។ ពាក្យ "ខ្មេរ" បានក្លាយនៅពេលថ្មីៗនេះទៅជា "ខ្មែរ" ។ ខ្មែរកម្ពុជាក្រោម ដែលទើបនឹងបែកចេញពីមាតុភូមិក្នុងសតវត្សរ៍ទី ២០ នោះ នៅតែងនិយាយថាខ្លួនជា "ខ្មេរ" រហូតមកដល់សព្វថ្ងៃ ។

បើយើងនិយាយថាយើងជាខ្មែរ នៅបរទេសពុំសូវមានអ្នកណាយល់បានទេ ។ នៅភពភាសាអង់គ្លេសគេស្គាល់តែ កាំបូឌាន (Cambodian) ទៅវិញ ។ គឺពួកអង់គ្លេសនេះឯង ដែលបានបង្កើតពាក្យ "កាំបូឌាន" មុនគេបង្អស់នៅទ្វីបអឺរ៉ុប ។ ពាក្យនេះពួកអង់គ្លេសបកប្រែពីពាក្យ **កម្ពុជៈ** (Kambuja) ដែលជាឈ្មោះរបស់នគរខ្មែរមួយនៅខាងកើតប្រទេសសៀមសព្វថ្ងៃ ។ នគរកម្ពុជៈ បានកើតឡើងដោយសារព្រាហ្មណ៍មួយអង្គមាននាមថា "កម្ពុ" ហើយកម្ពុជៈ មានន័យថា នគររបស់អ្នកដែល "កើតចេញពីកម្ពុ" ពាក្យ

www.elibraryofcambodia.org

សំស្ក្រឹត "ជៈ" ប្រែមកថា "កើតពី" ។ បារាំងក៏មិនស្គាល់ខ្មែរថាជាអ្វី ឲ្យច្បាស់ដែរ ។ ស្រុកយើងគេហៅថា **កាំបូដ** (Cambodge) ដែលគេ បកប្រែមកពីអង់គ្លេស កាំបូឌា ហើយជនជាតិយើងគេឲ្យ ឈ្មោះថា "កាមបូឌ្គាំង" (Cambodgien) ។

ពាក្យសំស្ក្រឹត "កម្ពុជៈ" ឲ្យមកខ្មែរថា **"កម្ពុជា"** ។ ដោយហេតុ នេះបានជាអ្នកខ្លះចង់ឲ្យខ្មែរមានឈ្មោះទៅជា "កម្ពុជា" ទៅវិញ មិន មែនខ្មែរទេ ។ និយាយរបៀបនេះ បើតាមប្រវត្តិសាស្ត្រ មិនសូវត្រូវ ទេដោយហេតុថា មិនមែនខ្មែរទេដែលកើតចេញពីព្រាហ្មណ៍កម្ពុ គឺ ព្រាហ្មណ៍កម្ពុនេះឯងដែលកើតចេញពីខ្មែរទៅវិញ ។ កម្ពុ ទើបនឹង មានជីវិតកាលពីសតវត្សរ៍ទី៣តែប៉ុណ្ណោះក្រោយពីព្រះយេស៊ូ ឯខ្មែរ មានជីវិតនៅលើទឹកដីកសព្វថ្ងៃតាំងពី ៦០០០ ឆ្នាំមុនគ្រិស្តសករាជ មកម្ល៉េះ ។ បើគិតឲ្យពិតទៅទៀត គេបានទទួលស្គាល់ថាខ្មែរដែល ចេញពីជាតិ មុណ្ឌៈ មានកំណើតតាំងពី ៣០០០០ ឆ្នាំមុនគ្រិស្ត សករាជនោះផង ។ ទទួលថាខ្មែរជាជាតិកម្ពុជា ហាក់ដូចជា យើងលុបចោលប្រវត្តិសាស្ត្រ ឬព្រលឹងជាតិយើងអស់ ៣០០០០ ឆ្នាំ ដែរ ។

ពាក្យ **"ខ្មែរក្រោម"** ជាពាក្យមួយដែលគេដាក់ឲ្យប្រជាជន ខ្មែរដែលរស់នៅប៉ែកខាងក្រោមទន្លេមេគង្គ បើយើងប្រៀបធៀប នឹងខ្មែរភ្នំពេញជាដើម ដែលនៅខាងលើទឹកទន្លេនេះ ។ បន្ទាប់មក ពាក្យខ្មែរក្រោមក៏បានទៅជាឈ្មោះខ្មែរទាំងអស់ ដែលនៅលើដែន ដីមានឈ្មោះថា **កូសាំងស៊ីន** (Cochinchine) បារាំង ចាប់តាំងពីខាង ជើងក្រុងព្រៃនគរទៅដល់ចុងខេត្តទឹកខ្មៅនៅខាងត្បូង ។ កាលឆ្នាំ

www.elibraryofcambodia.org

ឆ្នាំ ១៩៤៩ សភាជាតិបារាំងបានសម្រេចភ្ជាប់ទឹកដីនេះ ដែលកាលដើមនៅឡើយជាទឹកដីរបស់ខ្មែរ ទៅប្រទេសវៀតណាម ។ ចាប់ពីថ្ងៃនោះ មកខ្មែរក្រោមត្រឡប់ទៅជា "ខ្មែរនៅវៀតណាម" រួចទៅជា "ជាតិវៀតណាមមានដើមកំណើតខ្មែរ" ទៅវិញ! ។

ផ្ទុយនឹងពាក្យខ្មែរក្រោម សម្តេចព្រះនរោត្តមសីហនុបានបង្កើតពាក្យ **"ខ្មែរលើ"** សម្រាប់ជនជាតិច្រើនក្រុមដែលរស់នៅតំបន់ភ្នំតេនៈគីរី និងមណ្ឌលគីរី ដូចជាពួកស្ទៀង រ៉ាដែ ជាដើម ។ បើតាមស្មានមើលទៅ ជនជាតិទាំងអស់នេះបែបមិនបានត្រេកអរណាស់ទេដោយបានឈ្មោះថាខ្មែរលើនោះ ពីព្រោះគេមិនទទួលស្គាល់ថាគេជាខ្មែរសោះ ពិតមែនតែជនទាំងនោះមានដើមកំណើតជា **ខ្មែរ-មន** ហើយរស់នៅលើដែនដី ដែលខ្មែរគ្រប់គ្រងក៏ដោយ ។

ក្រៅពីពាក្យខ្មែរលើ និងខ្មែរក្រោម មានពាក្យ **"ខ្មែរកណ្តាល"** ទៀត ។ ពាក្យនេះគេប្រើឲ្យខ្មែរដែលនៅស្រុកខ្មែរយើងសព្វថ្ងៃ ដូចជាខ្មែរដែលនៅទីក្រុងភ្នំពេញជាដើម ។ ពាក្យថា "ខ្មែរកណ្តាល" ពុំសូវមានគេយកមកប្រើប៉ុន្មានទេ ។ ពាក្យ **"ខ្មែរដើម"** មានគេនិយមប្រើច្រើនម៉្យាង ។ ខ្មែរដើមគឺអ្នកដែលមានលក្ខណៈប្រាកដជាខ្មែរ ដូចកាលដើមដំបូងរៀងមក ។ គេច្រើនទទួលស្គាល់ជាខ្មែរដើម ខ្មែរដែលនៅជាប់ដីគោកជា ជួរជាប់នៅក្នុងតំបន់ព្រៃស្ងាត់ណាមួយ ។

ក្នុងឆ្នាំ ១៩៥០ ទៅឆ្នាំ ១៩៦០ សម្តេចព្រះនរោត្តមសីហនុបានបង្កើតពាក្យខ្មែរខ្លះទៀតដោយសំអាងទៅលើលក្ខណៈ សាសនា ឬ

www.elibraryofcambodia.org

នយោបាយមិនមែនលើលក្ខណៈពន្ធវិទ្យា (គឺវិទ្យាសាស្ត្ររៀនពីពូជជាតិមនុស្សទាំងឡាយក្នុងលោក) នោះទេ ។ ពាក្យទាំងនោះគឺ ៖

- ខ្មែរអ៊ិស្លាម
- ខ្មែរក្រហម
- ខ្មែរខៀវ

ពាក្យថា "ខ្មែរអ៊ិស្លាម" នេះមិនមែនចង់ថាខ្មែរដែលកាន់សាសនាអ៊ិស្លាមទេ ។ ពាកនេះគឺពាក្យកត់សំគាល់ដល់ជនជាតិ "ចម្ប៉ា" ដែលបានរត់មកជ្រកនៅប្រទេសខ្មែរ ក្រោយពីស្រុកគេត្រូវបានពួក វៀតណាមវាយយកអស់រលីងក្នុងឆ្នាំ ១៦៩៣ ។ តាមការពិតខ្មែរ អ៊ិស្លាម មានដើមកំណើតមកពីជាតិជ្វាទៅវិញទេ ។

"ខ្មែរក្រហម" គឺពួកដែលកាន់លទ្ធិកុម្មុយនិស្ត ។ តាមពាក្យនយោបាយគេហៅថាពួកខ្មែរកុម្មុយនិស្ត ។ គឺពួកនេះហើយដែលបានសម្លាប់ជនជាតិរបស់ឯង ដោយសាហាវជាទីបំផុតអស់ជាង ២ លាននាក់ ពីឆ្នាំ ១៩៧៥ ទៅឆ្នាំ ១៩៧៩ ។ ពួកនេះជាពួកដែលបានប្រព្រឹត្តនូវអំពើឧក្រិដ្ឋយ៉ាងធំ ចំពោះមនុស្សជាតិក្នុងសតវត្សរ៍ទី ២០។

ពាក្យ "ខ្មែរខៀវ" កត់សំគាល់ខ្មែរដែលប្រឆាំងនឹងលទ្ធិកុម្មុយនិស្ត ។ តាមផ្លូវនយោបាយគេហៅថាពួកខាងស្តាំ ផ្ទុយនឹងពួកកុម្មុយនិស្តដែលគេហៅថា "ពួកខាងឆ្វេង" ។ ពាក្យខ្មែរខៀវពុំបានគេយកមកប្រើប្រាស់ប៉ុន្មានទេ ហើយបានរលាយបាត់ពីប្រវត្តិសាស្ត្រខ្មែរទៅតែម្តង ។

www.elibraryofcambodia.org

www.elibraryofcambodia.org

# វគ្គទី ២

# ដើមកំណើតខ្មែរ

តើខ្មែរមានដើមកំណើតនៅឯណា ?
ខ្មែរមានជីវិតរស់នៅលើទឹកដីសព្វថ្ងៃតាំងពីដើមរហូតមក ឬ
មួយបានមកពីទីកន្លែងណាមួយផ្សេងទៅវិញ ?

ដោយគេបានឃើញជនជាតិចម្ប៉ាចេញមកពីស្រុកជ្វា នៅខាងត្បូងស្រុកខ្មែរ អ្នកខ្លះនឹកស្មានថាខ្មែរមានកំណើតចេញពីជនជាតិខាងត្បូងនេះដែរ ។ គេក៏ដាក់ខ្មែរក្នុងក្រុមជ្វា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងម៉េឡានេស៊ី ។ ការពិតជនជាតិទាំងនេះមានខ្សែស្រឡាយជាមួយគ្នា ដែលលោក**វីល្លៀមស្មីដ្ត**[9] ដាក់ឈ្មោះឲ្យជាពួក អូស្ត្រូណេស៊ីយាង (austronésien) ប្រែមកថា ជនជាតិនៅខាងត្បូងតែប៉ុណ្ណោះ ។ ខ្មែរឥតនៅក្នុងក្រុមនេះទេ ។ ខ្មែរនៅក្នុងក្រុមមួយទៀតដាច់តែឯងដែលគេហៅថាក្រុម "**មនខ្មែរ**" ឬ "**ខ្មែរមន**" ។ ជាតិខ្មែរ និងជាតិមនចេញមកពីគ្រួសារតែមួយ ។ ខ្មែរ និងមនមានកំណើតដើមនៅទ្វីបឥណ្ឌា ហើយចេញមកពីជាតិតែមួយគឺ ជាតិ "មុណ្ឌៈ" ។

---

[9] W.Schmidt : Les peuples môn-khmers. Texte traduit par Mme Marouzeau. BEFEO, T.VII. 1907 p.213-263.

www.elibraryofcambodia.org

លោកដាញ៉េឡូ[៦] បានសរសេរថា៖ "ជាតិខ្មែរនៅក្នុងក្រុម "មុណ្ឌៈ" ហើយការកសាង ការស្ថាបនាប្រាសាទអង្គរបានបង្ហាញឲ្យឃើញថា ខ្មែរមានសមត្ថភាពគ្រប់គ្រាន់ អាចបង្កើតបាននូវលក្ខណៈដ៏ពិសេស និងខ្ពង់ខ្ពស់បំផុតក្នុងសង្គម ។ លោក វីលៀមស្មីត្ត ក៏បានសរសេរថា៖ "ខ្មែរ និងជនជាតិមុណ្ឌៈ មានភាសាតែមួយ ហើយមានភាពរូបកាយ មានវប្បធម៌ដូចគ្នា ខុសឆ្ងាយពីពួកតាមូល ពួកអារ្យ និងពួកម៉ុងហ្គោល ។

**ជាតិមុណ្ឌៈ ជាជាតិដែលកើតមុនគេបង្អស់ នៅលើទឹកដីស្រុកឥណ្ឌា** ។ គេបានទទួលស្គាល់ ថាជនជាតិនេះមានជីវិតរស់នៅលើទ្វីបឥណ្ឌាយ៉ាងតិចណាស់ក៏ ៣០០០០ ឆ្នាំមុនគ្រឹស្តសករាជមកទៀត គឺមុនកំណើតព្រះយេស៊ូ ។ សព្វថ្ងៃគេឲ្យឈ្មោះ ជាតិនេះថា និស្ហាដា (Nishada) តែជនជាតិឥណ្ឌាច្រើនហៅថា **អធិវស៊ី** (adivasi) វិញដោយពាក្យនេះមានន័យថាជនជាតិដើម ឬជនជាតិដំបូង ។ នៅច្រើនពាន់ឆ្នាំមុនព្រះយេស៊ូ ជនជាតិមុណ្ឌៈ មានជីវភាព និងវប្បធម៌ យ៉ាងខ្ពង់ខ្ពស់រួចមកហើយ ។ ជនជាតិនេះឥតមានជំនឿលើសាសនា ឬព្រះមួយអង្គណាមួយទេ ។ គេកាន់របបមាតានិយម គេគោរពម្តាយនិងឪពុក គោរពដីគោរពទឹក ហើយមានជំនឿលើ "អ្នកតា" ។ លក្ខណៈទាំងអស់នេះ ខ្មែរបានយកមកប្រព្រឹត្តតាំងពីកាលនោះរហូតមកដល់សព្វថ្ងៃ ។

---

[៦] Alain Daniélou : Histoire de l'Inde. Fayard Paris 2005. p.24.

www.elibraryofcambodia.org

ខ្មែរច្រើនហៅអ្នកដែនឥណ្ឌាថាក្លិង្គ ។ ហេតុដែលនាំឲ្យគេហៅដូច្នេះ ព្រោះពួកឥណ្ឌាដែលមកស្រុកខ្មែរពីដំបូងនោះ បានចេញពីនគរមួយឈ្មោះ "កលិង្គៈ" (Kalinga) ដែលសព្វថ្ងៃគេហៅថា អូរិស្សៈ (Orissa) ។ ខ្មែរស្គាល់ថាមានក្លិង្គខ្មៅ និងក្លិង្គស ។ ក្លិង្គខ្មៅប្រហែលជាមកពីទ្វីបអាហ្វ្រិកទេ ។ ពួកគេបានមកដល់ទ្វីបឥណ្ឌាក្នុងរវាងឆ្នាំ ៩០០០០ មុនគ.ស ។ ខាងអឺរ៉ុបគេឲ្យឈ្មោះពួកនេះថា ទ្រាវិឌ (Dravidien) តែខ្លួនគេវិញគេថាគេជាសាសន៍ **តាមូល** ឬ តាមីល ។ ពួកក្លិង្គស្បែកសវិញបានចូលដល់ទ្វីបឥណ្ឌារវាងឆ្នាំ ២៨០០ មុនគ.ស ។ ពួកនេះបានមកពីតំបន់អាស៊ីកណ្ដាល ខាងលិចប្រទេសម៉ុងហ្គោលី ។ គេហៅខ្លួនគេថាជាតិ **អារ្យ** ប្រែមកថា អ្នកដែលមានពូជពង្សខ្ពង់ខ្ពស់ ។

នៅទ្វីបឥណ្ឌា មិនមែនមានតែជាតិមុណ្ឌៈ ជាតិតាមូល និងជាតិអារ្យនេះទេ ។ សឹងតែគ្រប់សាសន៍ នៅក្នុងពិភពលោកទាំងមូល បានចូលទៅលុកលុយដែនដីទ្វីបឥណ្ឌា ដូចជាសាសន៍ពែរ្ស (Perse) ក្នុងឆ្នាំ -៥២០ ជាតិក្រិក (Greec) ដឹកនាំដោយមហារាជាអធិរាជ អាឡិចសាំងឆ្នាំ -៣៦២ ពួកស៊ីរី -២០៦ ពួកសកៈឆ្នាំ +៧៨ រួចក្រោយមកមានជាតិ អ៊ីរ៉ាំង ទួរគី ម៉ុងហ្គោល...ល។ ដល់បញ្ចប់ទៅ មានពួកអឺរ៉ុបដូចពួកព័រទុយហ្គេ (Portugais) ហូឡង់ អង់គ្លេស និង បារាំងទៀត ។

ពួកដែលចូលទៅលុកលុយដែនដីឥណ្ឌាទាំងអស់នោះ មិនមែនចូលទៅដោយភាពស្លូតត្រង់ជាក់ទេ គឺមានការសម្លាប់បំផ្លាញយ៉ាងព្រៃផ្សៃ និងអាក្រក់ ។ ជនជាតិដែលចូលទៅក្រោយគេ សុទ្ធ

www.elibraryofcambodia.org

តែមានភាពព្រៃផ្សៃ លើសលប់ជាងជាតិដែលនៅទីកន្លែងនោះពីមុន ។ ប៉ុន្តែដល់រួចហើយ ពួកសាសន៍ពីមុននិងពួកសាសន៍ក្រោយក៏បានលាយគ្នា ហើយបង្កើតឡើងនូវវប្បធម៌ថ្មីតាមលក្ខណៈល្អត្រឹមត្រូវដែរ ។ ក្នុងហេតុច្របូកច្របល់នេះ មានតែជនជាតិមួយទេ ដែលមិនព្រមចុះចាញ់អ្នកណាទាំងអស់ មិនព្រមទទួលយកវប្បធម៌ជាតិណាមួយមកប្រើឡើយ ។ ជនជាតិនេះគឺជាតិ "មុណ្ឌៈ" ដែលជាជីដូនជីតារបស់ខ្មែរ ។ ដោយសារមានការគាបសង្កត់ខ្លាំងពេក ពីជាតិផ្សេងៗ ពួក "មុណ្ឌៈ" សុខចិត្តគេចខ្លួនចូលទៅរស់នៅតាមព្រៃ តាមភ្នំគ្រប់ទីកន្លែង ។ សព្វថ្ងៃនេះគេឃើញជាតិ "មុណ្ឌៈ" នៅពាសពេញក្នុងទ្វីបឥណ្ឌាពីជើងរហូតដល់ខាងត្បូង ពីព្រំដែនខាងកើតដល់ព្រំដែនខាងលិច ដូចជានៅអាស្សាម ឬភ្នំដែកកាំង ឬនៅជ្រោយកុមារីដែលសាសន៍អឺរ៉ុបហៅថាជ្រោយកូម៉ូរាំង ។ ជាតិ "មុណ្ឌៈ" សព្វថ្ងៃទោះនៅទីណាក៏ដោយក៏តែងតែរក្សាទំនៀមទំលាប់ និងវប្បធម៌បុរាណរបស់ខ្លួន ដោយឥតមានកែប្រែអ្វីទាំងអស់ ។ កាលពីជាតិឥណ្ឌាសព្វថ្ងៃបានឯករាជ្យ អ្នកដឹកនាំគេពេលនោះ មានការខ្លាចក្រែងពួក "មុណ្ឌៈ" ទាមទារសិទ្ធិផ្សេងៗ និងទឹកដីរបស់ខ្លួន ដោយមានឈ្មោះថាជនជាតិដើម ឬអធិវស៊ីនោះ គេក៏កែប្រែដាក់ឈ្មោះពួកនេះថា "វណ្ណាវស៊ី" វិញ ដែលមានន័យថាអ្នកនៅក្នុងព្រៃ ។ ក្នុងឆ្នាំ១៩៧៩ ការរាប់ប្រជាជនមួយនៅទ្វីបឥណ្ឌាបានឲ្យដឹងថាជនជាតិមុណ្ឌៈ មានទាំងអស់ ៥១ លាននាក់ (អ. ដាញេឡូ) ។ ជនជាតិ "មុណ្ឌៈ" មិនគ្រាន់តែគេចខ្លួនចូលព្រៃឡើងភ្នំប៉ុណ្ណោះទេ គេបានរត់ចេញផុតពីទ្វីបឥណ្ឌាទៀត ហើយបានទៅ

www.elibraryofcambodia.org

សុសសាយសឹងតែគ្រប់កន្លែងទាំងអស់ ក្នុងពិភពលោកទាំងមូល ។ ជនជាតិ មុណ្ឌៈ បានចេញតាមផ្លូវធំៗ ៣គឺ ៖

១- **ផ្លូវទៅទិសខាងលិច** ពួកមុណ្ឌៈ បានឆ្លងទៅនៅកោះ សូក្ត្រា ម៉ាដាហ្គាស្ការ ស្រុកអេហ្ស៊ីប និងបាប៊ីឡូនដែលជាស្រុកអ៊ីរ៉ាក់សព្វថ្ងៃ ។

២- **ផ្លូវខាងត្បូង** នាំជាតិមុណ្ឌៈ ទៅដល់កោះស្រីលង្កា ណីកូបារ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ម៉េឡាណេស៊ី អូស្ត្រាលី កោះ "ប៉ាក់" ហើយនឹងរហូតទៅដល់ស្រុកស៊ីលី នៅឯទ្វីបអាមេរិកខាងត្បូងទៅទៀត ។ ផ្លូវទី២នេះជាផ្លូវមួយដែលជនជាតិនៅទ្វីបឥណ្ឌាតែងតែយក គ្រប់ពេលដែលគេត្រូវគេចខ្លួនពីសត្រូវណាមួយ ។ ក្រោយពីពួក "មុណ្ឌៈ" ក្នុងសតវត្សន៍ទី៣មុនព្រះយេស៊ូ មានពួកតាមូលគឺ "ពួកឥណ្ឌាស្បែកខ្មៅជាច្រើន បានរត់ចេញពីនគរកលិង្គៈទៅតាមផ្លូវនេះ" ។ ពួកគេបានមកជ្រកតាមនគរទាំងឡាយ នៅអាស៊ីខាងត្បូង ។ នៅស្រុកខ្មែរជនជាតិខ្មែរហៅពួកនេះថាពួកក្លិង្គឬក្លែង្គ ពាក្យដែលខ្មែរក្រោមនៅប្រើរហូតមកដល់សព្វថ្ងៃ ហើយដោយសារថាពួកនេះមកពីនគរកលិង្គៈ ។ ក្រោយមកទៀតពួកឥណ្ឌាដែលកាន់ព្រះពុទ្ធសាសនាមហាយាន និង ពួកឥណ្ឌាសាសនា អ៊ីស្លាម ក៏បានរត់ចេញពីទ្វីបឥណ្ឌាតាមផ្លូវនេះដែរ ។ នគរម៉ាឡេស៊ីនិងឥណ្ឌូនេស៊ី ដែលមានឈ្មោះដូចសព្វថ្ងៃនេះ គឺមកពីពួកអង់គ្លេស និងពួកហូឡង់ដាក់ឲ្យ ក្នុងសតវត្សរ៍ទី១៨នោះទេ ។ កាលពីមុន នគរម៉ាឡេស៊ីមានជនជាតិសឹងតែក្លិង្គទាំងអស់ ហើយក្លិង្គបានត្រួតត្រានគរនេះអស់ជាង ១០០០ ឆ្នាំ ។ កោះណីកូបារ

www.elibraryofcambodia.org

ដែលជាដីឥណ្ឌាសព្វថ្ងៃ កំនៅយ៉ាងជិតបំផុតនិងស្រុកម៉ាឡេស៊ីដែរ ។ ស្រុកថ្វាឬហ្វ្រាក់ កាលពីដើមឡើយមានឈ្មោះថាស្រុកឡាំងកាសុកៈ ឯស្រុកស្រីលង្កាមានឈ្មោះដើមជានាគទ្វីបទៅវិញទេ ។

៣- **ផ្លូវទី៣** គឺជាផ្លូវគោក តាមជាយឈូងសមុទ្របង់ហ្គាល ។ ពួក"មុណ្ឌៈ" មកតាមផ្លូវនេះ តាមច្រាំងសមុទ្រ និងតាមដងទន្លេនានា ចុះរហូតមកដល់ពាមចុងផុតទន្លេមេគង្គ គឺដល់សមុទ្រចិនខាងត្បូងតែម្តង ។ ជន"មុណ្ឌៈ"បានបង្កើតនគរជាច្រើនតាមផ្លូវនេះ ដែលនៅរហូតមកដល់សព្វថ្ងៃ ដូចជានគរខាលីនៅតំបន់អាស្សាម នគរមីស្ហូនៅភ្នំមីស្ហូ នគរនាគទេសរបស់ពួកនាគ នគរមននៅប្រទេសភូមា និងនគរខ្មែរដែលនៅលើដីប្រទេសខ្មែរបច្ចុប្បន្ន ។ ដែលគេនិយាយថា**ខ្មែរ-មន** គឺមកពីអ្នកខ្លះនិយាយថាកាលដំបូងមានជាតិសាសន៍មួយនៅភ្នំទីបេ បានចុះមកខាងត្បូងក្នុងទ្វីបឥណ្ឌារួចបង្កើតបានជាតិមុណ្ឌៈ និងមួយក្រុមទៀតចុះមកខាងកើតដែលបានទៅជាជាតិខ្មែរ និងមន ។ និយាយរបៀបនេះមិនត្រូវទេ ។

ជនជាតិ "មុណ្ឌៈ" បានចាប់ផ្តើមចេញពីទ្វីបឥណ្ឌារវាងឆ្នាំ ១០០០០ មុនព្រះយេស៊ូ ក្រោយពេលដែលមានពួកតាមូលចូលមកលុកលុយ ។ ក្រុមដែលបង្កើតបាននគរថ្មីដែលហៅថានគរខ្មែរ និងជាតិមួយថ្មីហៅថាជាតិខ្មែរនោះ បានមកដល់កន្លែងទឹកដីសព្វថ្ងៃ រវាងឆ្នាំ ៦០០០ មុនគ.ស ។ ទោះតែមានឈ្មោះថ្មីថាខ្មែរក៏ដោយ ពួកនេះនៅតែថែរក្សា គោរពទុកទាំងអស់ នូវភាសា ទំនៀមទំលាប់

www.elibraryofcambodia.org

# ដំណើរខ្មែរមន ចេញពីទ្វីបឥណ្ឌា




បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

www.elibraryofcambodia.org

និងវប្បធម៌ដើមរបស់ជាតិ "មុណ្ឌៈ" ដែលជាជាតិជីដូនជីតារបស់ខ្លួន ។ គេគោរពយ៉ាងខ្ជាប់នូវជំនឿធំៗ ៣គឺ ៖

- **ការគោរពម្តាយ និងឪពុក**ដែលគេហៅថា "មេ" និង "បា"។ ក្នុងន័យនេះទៀត មេមានថ្នាក់ខ្ពស់ និងធំជាងបា ។ ខាងផ្នែក នយោបាយ គេធ្វើតាមរបបមាតានិយម ហើយមហាក្សត្រខ្មែរគឺតែងតែជាស្ត្រីរហូត ។
- **ការគោរពផែនដី និងទឹក**ដែលមាន នាងកង្ហីងនិងក្រពើ ជានិមិត្តរូប ហើយដែលគេតែងនិយាយថា នាងកង្ហីង ព្រះធរណី ។
- **ការគោរពអ្នកតា** ដែលខ្មែរជឿថាជាព្រលឹងដែលបិតនៅតាមដើមឈើធំៗ ឬតាមព្រៃភ្នំផ្សេងៗ ។

ខ្មែររក្សាយ៉ាងត្រឹមត្រូវនូវគុណសម្បត្តិទាំងអស់នេះ រហូតមកដល់ឆ្នាំ ៥០គ.ស ។ នៅក្នុងឆ្នាំនោះ ខ្មែរដែលខំគេចខ្លួនពីក្លឹង្គខ្មៅតាមួល ត្រូវបានក្លឹង្គស្បែកសគឺពួកអារ្យ (អានថា: អារីយៈ) មកតាមទាន់ម្តងទៀត ក្រោមការដឹកនាំរបស់ព្រាហ្មណ៍មួយអង្គឈ្មោះកៅណ្ឌិន្យ ។ អ្នកខ្លះនិយាយថាកៅណ្ឌិន្យបានមកពីស្រុកម៉ាឡេស៊ីដែលជាទឹកដីជនជាតិឥណ្ឌា នៅកាលពេលនោះដូចគេបានដឹងស្រាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រោយពីការចម្បាំងមួយយ៉ាងខ្លាំងក្លាតាមនាវាសមុទ្រ កៅណ្ឌិន្យបានជោគជ័យហើយបានទៅជាមហាក្សត្រស្រុកខ្មែរទាំងមូល ។ ពាក្យដែលគេផ្សាយថា មហាក្សត្រីខ្មែរ យាយលីវ ចង់ប្លន់នាវាកៅណ្ឌិន្យនោះ គឺគេបង្កើតឡើង ដើម្បីបន្ទាបបន្ថោកឬទ្ធានុភាពព្រះមហាក្សត្រី ខ្មែរ តែប៉ុណ្ណោះ ។ កៅណ្ឌិន្យបានលើកយាយលីវជាអគ្គមហេសី ហើយរៀបចំស្រុក ខ្មែរតាមវប្បធម៌ឥណ្ឌាទាំងអស់ ។ ព្រហ្មាញ្ញសាសនាបានទៅជាសាសនារបស់រដ្ឋខ្មែរ ភាសាសំស្ក្រឹតឥណ្ឌាបានទៅជាភាសាផ្លូវការរបស់រដ្ឋ ហើយជាភាសាក្នុងការសិក្សាផ្សេងៗទាំង

www.elibraryofcambodia.org

អស់ ។ ការរៀបចំក្នុងសង្គមបានបែងចែកប្រជាជនតាមវណ្ណៈ ៤ ថ្នាក់ដូចជា វណ្ណៈព្រាហ្មណ៍ និងវណ្ណៈក្សត្រ ជាដើម ។ ការរៀបចំផ្សេងៗ ក្នុងព្រះរាជវាំង ឬក្នុងការគ្រប់គ្រងនគរ គឺធ្វើឡើងតាមរបៀបឥណ្ឌាទាំងស្រុង ។ ប៉ុន្តែទោះជាមានការប្រែប្រួលតាមរបៀបឥណ្ឌាយ៉ាងណាក៏ដោយ ខ្មែរឥតមានបោះបង់ចោលវប្បធម៌ ឬទំនៀមទំលាប់របស់ខ្លួនឡើយ ជាពិសេសការគោរពមេ គោរពបា ការគោរពព្រះធរណីនិងទឹក ហើយនិងជំនឿលើអ្នកតា ។ ខ្មែរក៏ពុំបោះបង់ចោលភាសា និងអក្សរសាស្ត្ររបស់ខ្លួនដែរ ។

ពួក "មន" ដែលជាប្រជាជន "មុណ្ឌា" ដូចខ្មែរដែរនោះ បានមកតាមក្រោយខ្មែរ ហើយមកដល់ស្រុកភូមាសព្វថ្ងៃអាចឆ្នាំ ៣០០០ មុនគ្រិស្តសករាជ ។ ពួក "មន" បានបង្កើតនគរមួយមានឈ្មោះថា "សុវណ្ណភម្មិ" ដែលខ្មែរហៅថា"សុវណ្ណភូមិ" ។ រាជធានីមនគឺក្រុង "ថាតុន" នៅឈូងសមុទ្រម៉ាតាបាំង នៅខាងជើងក្រុងរង្គូន សព្វថ្ងៃ ។ មនក៏បានកសាងព្រះរាជាណាចក្រមួយទៀត នៅជិតក្រុងឡាំផុន ហើយដែលមានឈ្មោះថា "ហរិភុញជ័យ" ។ មនកាន់ព្រះពុទ្ធសាសនាថេរវាទ ដែលមនបានយកមកពីប្រទេសស្រីលង្កា ក្នុងសតវត្សរ៍ទីមួយក្នុងគ.ស. ។ មនបានរៀនសូត្រយ៉ាងខ្លាំងដែរ ហើយបានបង្កើតនូវការចេះដឹងយ៉ាងពិសេស នៅភពកណ្តាលប្រទេសសៀមសព្វថ្ងៃ ដែលគេឲ្យឈ្មោះថាលក្ខណៈពិសេស "ទ្វារវត្តី" ។ រាជធានី "ថាតុន" ត្រូវពួកបៀរម៉ាំង (Birman) ដែលជាភូមាសព្វថ្ងៃវាយកំទេចអស់ក្នុងឆ្នាំ១០៥៧ ហើយនគរមនដែលហៅថាសុវណ្ណភូមិ ក៏រសាយបាត់រហូតនៅពេលនោះទៅ ។ ពួកបៀរម៉ាំងឥតមានដើមកំណើតខ្មែរ-មន ឬមុណ្ឌាទេ ។ ពួកនេះចេញមកពីក្រុមមួយដែលគេហៅថាក្រុមទីបេ-បៀរម៉ាំង (Tibet-Birman) ដែលរស់នៅកាលដំបូង នៅខាងលិចភ្នំយុនណាន់ (Yunnan) ។ ជាតិបៀរ

www.elibraryofcambodia.org

ម៉ាំងបានចុះពីភ្នំនេះ រួចបានបង្កើតនគរមួយឈ្មោះព្រះរាជាណាចក្រ "ប៉ាហ្គាន់" ក្នុងឆ្នាំ ៨៤៩ ។ ក្រោយពីបានរំលាយមនរួចហើយ ពួកបៀរម៉ាំងយកវប្បធម៌មនទាំងអស់ មកធ្វើជាវប្បធម៌របស់ខ្លួន តាំងពីព្រះពុទ្ធសាសនាថេរវាទ ភាសា និងអក្សរសាស្ត្រ ។ ជនជាតិការ៉េនសព្វថ្ងៃ គឺជាកូនចៅពួកមននោះឯង ។ ចំណែកឯនគរហរិពុនជ័យ ពួកសៀមបានលេបយកនៅឆ្នាំ ១២៨១ ។

ក្នុងរឿងផ្សេងមួយទៀត តាមអាថ៌សាស្ត្រា គឺក្បួនវិទ្យាសាស្ត្រនយោបាយមួយយ៉ាងសំខាន់ ដែលព្រាហ្មណ៍កៅតិល្យរដ្ឋមន្ត្រីរបស់មហាក្សត្រភ្លឹង្គច័ន្ទ្រគុប្ត: (Chandragupta) បាននិពន្ធសរសេរកាលចុងសតវត្សរ៍ទី៣មុនគ.ស ហើយដែលបានលោកជាញ្ញេឡូលើកមករៀបរាប់គឺ កងទ័ពឥណ្ឌាត្រូវមាន ៤ ក្រុម ៖

១- ទាហានពេញលក្ខណ:របស់អ្នកដែលមានវណ្ណ:ជាក្សត្រ
២- ទាហានដែលគេរើសសម្រាប់តែមួយរយ:វេលាខ្លី
៣-ទាហានដែលនគរនៅក្រោមចំណុះបានបញ្ជូនមកឲ្យ
៤- អ្នកចម្បាំងដែលចេញមកពីក្រុមអ្នករស់នៅក្នុងព្រៃ

ពួកពលដែលជាអ្នកចេញពីព្រៃនេះ មានបេសកកម្មទៅរំខានសត្រូវគ្រប់បែបគ្រប់យ៉ាង ពីព្រោះពួកនេះជាអ្នកក្លាហាន ហើយមានការប៉ិនប្រសប់ជាងគេ ។

ក្នុងរឿងរាមកេរ្តិ៍ ដែលគេហៅថារាមាយាណ: គេយកទ័ពស្វាមកតំណាងឲ្យឃើញថាជាអ្នកដែលមកពីព្រៃ ។ ក្នុងរឿងនេះ សិតាដែលជាភរិយាព្រះរាម ត្រូវក្រុងរាពណ៍ចាប់ឆក់យកទៅលាក់ទុកនៅកោះលង្កា ។ ព្រះរាម ដែលមានន័យថា "ស្រស់ល្អ" ជាក្សត្រ

www.elibraryofcambodia.org

ក្រុងអយុធ្យា ក្នុងព្រះរាជាណាចក្រកូសុល: សព្វថ្ងៃហៅថារដ្ឋប៊ីហារ ។ ដោយមានជំនួយយ៉ាងខ្លាំងក្លាពីទ័ពស្វារបស់ហនុមាន ព្រះរាម សម្លាប់ក្រុងរាពណ៍បាន ហើយរំដោះព្រះនាងសិតាចេញរួចពីកោះលង្កា ។

ក្នុងយុទ្ធកថានេះ តាមលោកដាញេឡូ ទ័ពស្វាហើយនឹងហនុមានមិនមែនជាស្វាមែនទែនទេ ។ គេគ្រាន់តែតែងជាស្វាដើម្បីបង្ហាញឲ្យដឹងថាជាមនុស្សមកពីព្រៃ ស្របតាមក្បួន អាថ៌សាស្ត្រា ។ មនុស្សមកពីព្រៃនេះទៀត គឺពួកវណ្ណៈវស៊ី ឬជាតិមុណ្ឌាៈ នេះឯង ។

បញ្ចប់សេចក្តីទៅ ខ្មែរមានដើមកំណើតមកពី ២បុរេភព ៖

១- **តាមប្រវត្តិសាស្ត្រ** ខ្មែរចេញមកពីជាតិមុណ្ឌាៈ ដែលជាប្រជាជនមុនគេបង្អស់នៅទ្វីបឥណ្ឌា ។

២- **តាមរឿងព្រេងវិញ** ខ្មែរជាកូនចៅផ្ទាល់របស់ស្តេចហនុមាន ដែលជាអ្នកចម្បាំងខ្លាំងពូកែ ពុំដែលចាញ់អ្នកណាមួយឡើយ។

www.elibraryofcambodia.org

www.elibraryofcambodia.org

## វគ្គទី ៣

# ស្រុកខ្មែរ ឬ នគរខ្មែរ

រហូតមកដល់សព្វថ្ងៃ គេបានដឹងស្គាល់ប្រវត្តិសាស្ត្រខ្មែរ តាមតែសេចក្តីសរសេររបស់ចិន នៅក្នុងសៀវភៅប្រចាំឆ្នាំសម្រាប់ព្រះរាជវង្សាមហាក្សត្រតែប៉ុណ្ណោះ ។ ចិនបានសរសេរអំពីខ្មែរលើកដំបូងបង្អស់នៅសតវត្សរ៍ទី៣ ក្នុងគ.ស ក្រោយពីមានអ្នកទូតចិន២នាក់ លោកកងតាយ និងជូយីង ដែលបានមកបំពេញបេសកម្ម និងរស់នៅលើស្រុកខ្មែរអស់៥ឆ្នាំ ពី២៤៥ ដល់ឆ្នាំ ២៥០។ គឺសេចក្តីរាយការណ៍របស់លោកទូតទាំង២នេះហើយ ដែលគេចំលងទុកក្នុងក្បួនប្រចាំឆ្នាំក្នុងព្រះរាជវាំងរបស់គេ ។ ក្នុងសេចក្តីរាយការណ៍នេះ ចិនបានឲ្យឈ្មោះស្រុកខ្មែរជានគរ "ភូណាន់" ។ ដល់ពីរបីសតវត្សរ៍ក្រោយមក ចិនបាននិយាយទៀតអំពីនគរខ្មែរមួយ ដែលគេឲ្យឈ្មោះថានគរ "ចិនឡា" ហើយសម័យនោះគេអានថា "ចិន ឡប់" ។

www.elibraryofcambodia.org

ដោយសារថាមាននគរ "ភូណាន់" ផង នគរ "ចិនឡា" ផង អ្នកខ្លះមិនយល់ថានគរខ្មែរនោះជាអ្វីមួយណាទេ ។ នគរខ្មែរ គឺនគរ "ភូណាន់" ឬនគរ "ចិនឡា" ? តើខ្មែរមាននគរពីរ ឬអី ?

នៅខាងអឺរ៉ុប មានបារាំងជាដើម គេយល់ថាមាននគរមួយលុះណា ស្រុកនោះមានភាព ៣យ៉ាងគឺ៖ ដែនដីមួយ ព្រំដែនមួយ និងរដ្ឋធានីមួយ ។ កាលណាមានខ្វះភាពណាមួយក្នុងភាពទាំងបីនេះ គេមិនអាចយល់បាន ថាមាននគរអ្វីមួយឡើយ ។ ក្នុងគំនិតនេះលោកសាស្ត្រាចារ្យបារាំង "ហ្សាវីយេ ហ្គាឡង់"[៩] បានសរសេរថា "ហេតុដែលយើង (បារាំង) ទុកភូណាន់ជានគរមួយនោះ គឺមកពីចិន គេបន្លំធ្វើហាក់ដូចជាភូណាន់នេះ ជានគរមានលក្ខណៈត្រឹមត្រូវ ដើម្បីនឹងគេទទួលយកសួយសារអាករទេ ។ នៅពេលខ្លះទៀត អ្នកដឹកនាំខ្មែរតូចៗប្រជុំគ្នា ធ្វើដូចជាគេមានមេតែមួយដើម្បីនឹងថ្វាយសួយសារអាករឲ្យទៅចិនតែប៉ុណ្ណោះ" ។ ពាក្យសរសេរនេះបង្ហាញឲ្យឃើញថា គេឥតមានជឿថាខ្មែរចេះគ្រប់គ្រងដឹកនាំរៀបចំ ឲ្យស្រុករបស់ខ្លួនទៅជានគរមួយបានទេ ។ គេគិតស្មានថាខ្មែរមានការរស់នៅជាក្រុមតូចៗ ជាកុលសម្ព័ន្ធ (tribu) ដូចជន ស្បែកក្រហម នៅសហរដ្ឋអាមេរិក ។

ការយល់របៀបនេះជាការភាន់ច្រឡំមួយយ៉ាងធំ ហើយបង្ហាញឲ្យឃើញថាអ្នកនោះ មិនបានស្គាល់ស្រុកខ្មែរ ឬ ស្រុកចិន

[៩] Xavier Galand : Histoire de la Thailande. PUF. 1998, p. 24.

www.elibraryofcambodia.org

ជំនាន់ដើមឲ្យបានច្បាស់លាស់ទេ ។ តាមពិតសង្គមខ្មែរជាសង្គមមួយដែលគេបានរៀបចំត្រឹមត្រូវយូរណាស់មកហើយ យូរអង្វែងជាងការនឹកស្មានរបស់អ្នកខ្លះទៅទៀត ។ ខ្មែរបានរៀបចំនគររបស់ខ្លួន តាមគោលលក្ខណៈខ្មែរ តាមកាលៈទេសៈដែលខ្មែរបានជួបប្រទះតែប៉ុណ្ណោះ ។ ការរៀបចំនេះមានភាពខុសគ្នា ៖

១- នៅពេលមុនគ្រិស្តសករាជ

២- ពីសតវត្សរ៍ទី ១ ទៅសតវត្សរ៍ទី ១៤

៣- ក្រោយពីសតវត្សរ៍ទី ១៥

## ១. មុនគ្រិស្តសករាជ

នៅមុនគ្រិស្តសាសនា នគរខ្មែរបានទទួលការរៀបចំដូចនគរនានាក្នុងលោក នៅពេលសព្វថ្ងៃនេះដែរ ។ នគរខ្មែរជំនាន់នោះ គឺនគរតែមួយ របស់ជនជាតិតែមួយ និងមានរដ្ឋាភិបាលតែមួយ ។ របបអភិបាលរដ្ឋ គឺរបបរាជានិយម [illegible] មាតានិយម គឺថាមានក្សត្រីដែលជាអ្នកដឹកនាំរដ្ឋ ។ របបមាតានិយមនេះខ្មែរយកមកពីជនជាតិ "មុណ្ឌៈ" ដែលជាជីដូនជីតារបស់ខ្លួន ហើយដែលជារបបរបស់គេ កាលពីច្រើនរយសតវត្សរ៍រួចមកហើយ ។ ផ្ទៃដីនគរខ្មែរជំនាន់នោះមានទំហំធំខ្លាំង ខាងជើងទល់នឹងភ្នំយុនណាន់ ខាងត្បូងទល់ដល់នគរម៉ាឡេស៊ីសព្វថ្ងៃ ខាងកើតទល់ដល់សមុទ្រចិនខាងត្បូង ពីក្រុងព្រៃនគររហូតដល់ជ្រោយទឹកខ្មៅ ខាងលិចគឺឈូងសមុទ្របឹងហ្គាល ។ ទោះបីជាយ៉ាងណាក៏ដោយ នេះហើយគឺជាទឹបរបស់ខ្មែរ ពីព្រោះថាជាតិទាំងឡាយដែលនៅជុំវិញ

www.elibraryofcambodia.org

ខ្មែរសព្វថ្ងៃ ឥតទាន់មានមកនៅទីនោះទេ ។ ពួកសៀម ដែលចិនដាក់ឈ្មោះឲ្យថា **សាយ៉ាម** ឬ "ចោរព្រៃ" នោះ មានដើមកំណើតនៅខាងជើងទន្លេហ្វាងហូរ (ទន្លេលឿង) ទៅទៀត ។ ពួកនេះចុះមកខាងត្បូង បង្កើតបាននគរមួយ នៅខាងកើតភ្នំយុនណាន់មានឈ្មោះថានគរណាន់ចៅ រួចចូលមក ដល់ស្រុកខ្មែរលើកដំបូងបង្អស់នៅឆ្នាំ ១២៣៨ ឆ្នាំដែលពួកគេយក បានក្រុងសុខោទ័យ ។ ពួកវៀត ដែលហៅថាយួន មានស្រុករបស់ ខ្លួននៅខាងត្បូងទន្លេ "យ៉ាងត្សេកីយ៉ាង" (ទន្លេខៀវ) ហើយបានមក ដល់ដី តុងកឹងក្នុងឆ្នាំ ២៥៧ មុនគ.ស តែប៉ុណ្ណោះ ។ ចំណែកឯចាមវិញ គេមកពីស្រុកជ្វា និងម៉ាឡេស៊ី ហើយនគរចម្ប៉ាទើបនឹងបង្កើត បានក្នុងឆ្នាំ ១៩៧ ក្នុង គ.ស ដោយស្តេចស្រីម៉ារ៉ា ។

ជនជាតិដែលនៅជិតខ្មែរជំនាន់នោះ មានតែពួកយុនណាន់ពីខាងជើង និងពួកមននៅខាងលិច ។ ជនជាតិនៅយុនណាន់មិនទាន់មានឥទ្ធិពលខ្លាំងក្លានៅឡើយទេ ឯពួកមនវិញគេទៅជាបញ្ហាដល់ខ្មែរនៅក្រោយមកទៀត គឺនៅជំនាន់អង្គរ ។ ពួកចិនវិញមានព្រំដែននៅខាងត្បូងត្រឹមតែទន្លេ "យ៉ាងសេ" តែប៉ុណ្ណោះ ។ ក្រុងដែលចិនត្រួតត្រានៅខាងត្បូងជាងគេ គឺក្រុងកាំងតុងដែលមានឈ្មោះថាណាន់ហាយ ។ ឯមហារាជស៊ីន ដែលល្បីល្បាញយ៉ាងខ្លាំងក្នុងរវាងឆ្នាំ ២២១ មុនគ.សវិញ គេមានរាជធានីនៅក្រុងស៊ីយ៉ាង (Xian) ។ គឺឈ្មោះស្តេចស៊ីននេះដែរ ដែលបានទៅជា ឈ្មោះស្រុកចិន ដោយគេហៅថា ស្រុករបស់ស៊ីន ឬ ស្រុកចិន ។

www.elibraryofcambodia.org

ខ្មែរនៅជំនាន់នោះឥតមានចំណោទខាងក្រៅប្រទេសទេ ។ ដែនដីខ្មែរធំទូលាយ ចំនួនបណ្តាជនក៏តិច ប្រែមកគឺថាមានទឹកដីគ្រប់គ្រាន់ឲ្យអ្នកទាំងអស់គ្នារស់នៅ ។ ដោយហេតុទាំងអស់នេះហើយ បានជានគរខ្មែរឥតមានព្រំដែនទេ ។ ពាក្យថាព្រំដែននេះខ្មែរអត់ស្គាល់សោះ ព្រោះគេយល់តាំងតែពីដើមមកថា "កន្លែងណាដែលមានខ្មែររស់នៅ នោះគឺជាដីរបស់ខ្មែរហើយ ។

គេឥតបានដឹងថារាជធានីខ្មែរកាលពេលនោះឈ្មោះជាអ្វីទេ ឬនៅទីណាទេ ប៉ុន្តែយ៉ាងណាក៏ដោយខ្មែរតែងតែមានរាជធានីមួយ ដោយសារថា នោះជាទីកន្លែងដែលមហាក្សត្រីខ្មែរទ្រង់គង់នៅ ។ ផ្ទុយទៅវិញ គេបានស្គាល់ច្បាស់ណាស់ឈ្មោះរបស់នគរខ្មែរ ដែលគេហៅថា "ស្រុកខ្មែរ" ។ អ្នកបរទេសដែលបានសិក្សាពីរឿងខ្មែរតែងតែជួបប្រទះនឹងពាក្យ "ស្រុកខ្មែរ" ជានិច្ច តែគេមិនឲ្យតំលៃទៅលើពាក្យនេះទេ គេខំទៅរកឈ្មោះស្រុកខ្មែរពីចិនទៅវិញ ដូចជានគរភ្នំណាន់ ឬចិនឡាជាដើម ។ ខ្មែរមាននគររបស់ខ្លួនថាស្រុកខ្មែរនោះ ជាយូរណាស់មកហើយ ប្រហែលជានៅពេលដែលខ្លួនមកដល់ដីសព្វថ្ងៃ គឺរវាងឆ្នាំ ៦០០០ មុនគ.ស ។ សព្វថ្ងៃនេះទៀត ខ្មែរនៅតែប្រើពាក្យស្រុកខ្មែរ ទាំងតូច ទាំងធំ ទាំងចាស់ ទាំងក្មេងទាំងអស់គ្នា ទោះជានៅក្នុងស្រុក ឬក្រៅស្រុកក៏ដោយ ។ ពាក្យថាស្រុកខ្មែរមានន័យថាស្រុករបស់ខ្មែរ ប្រែមកថាស្រុករបស់ជនជាតិខ្មែរទូទៅ មិនមែនស្រុករបស់ក្រុមណាមួយ ឬរបស់ពូជពង្សស្តេចណាមួយទេ ។ ការដែលដាក់ឈ្មោះដូច្នេះ មិនមែនជាការចៃដន្យទៀត ហើយការនេះបានធ្វើឡើងស្របតាមនឹងការចេះដឹងយ៉ាងខ្ពង់

www.elibraryofcambodia.org

ខ្ពស់របស់ជន មុណ្ឌៈ ដែលបានបង្កើតសាធារណរដ្ឋជាង១០ រួចទៅហើយ កាលជាង ១០០០០ ឆ្នាំមុនគ.ស ។

## ២. ពីសតវត្សរ៍ទី ១ ទៅសតវត្សរ៍ទី ១៤

គឺជាសម័យព្រាហ្មណ៍សាសនានៅស្រុកខ្មែរ ។ នៅឆ្នាំ៥០ គ.ស ព្រាហ្មណ៍កៅណ្ឌិន្យដែលមានដើមកំណើតជាក្លឹង្គ បានទៅជាមហាក្សត្រខ្មែរ ។ ចាប់ពីពេលនោះមក ការរៀបចំទូទៅនៅស្រុកខ្មែរបានធ្វើឡើងតាមរបៀបព្រាហ្មណ៍សាសនាទាំងអស់ ។ ការរៀបចំរដ្ឋក៏ធ្វើដូចស្រុកក្លឹង្គកាលពេលនោះដែរ ហើយការរៀបចំនេះមានភាពខុសពីប្រទេសនានាទាំងអស់ ដូចជាចិន ឬនគរផ្សេងៗនៅទ្វីបអឺរ៉ុបជាដើម ។ **គេមិនអាចយល់ស្គាល់ នគរខ្មែរកាលពេលនោះបានទេ បើកាលណា គេមិនបានស្គាល់នគរទាំងឡាយ នៅទ្វីបឥណ្ឌា** ។ អាស្រ័យហេតុនេះ បានជាមានអ្នកខ្លះមិនទទួលស្គាល់ថាខ្មែរមានរដ្ឋមួយយ៉ាងត្រឹមត្រូវដូចគេឯងរាល់គ្នាទេ ហើយអ្នកខ្លះទៀតមិនយល់ថាហេតុអ្វីបានជាខ្មែរមាននគរពីរ ដូចនគរ "ភូណាន់" និងនគរ "ចិនឡា" ។

នគរក្លឹង្គ ឬនគរឥណ្ឌាដែលគេស្គាល់សព្វថ្ងៃ ហើយដែលមានទំហំពីភ្នំហិមាល័យាទៅដល់ជ្រោយកុមារី (Cap Comorin) ពីបញ្ជាប់ (Panjab) ទៅទល់ឈូងបឹងហ្គាល ហើយដែលមានក្រុងញូវដេលី (New Delhi) ជារដ្ឋធានីនោះ ឥតមានជារូបដូចច្នេះទេ នៅក្នុងប្រវត្តិសាស្ត្ររហូតដល់មកសតវត្សរ៍ទី ១៩ ។ នេះគឺជារបៀបមួយដែលពួកអង់គ្លេសបានបង្កើត ហើយនៅសល់ដដែល ក្រោយពី

www.elibraryofcambodia.org

អង់គ្លេសចាកចេញទៅ ។ មុននោះ ទ្វីបឥណ្ឌាមានការបែងចែកជានគរធំតូចជាច្រើនមែនទែន ពេលខ្លះមានចំនួនរហូតដល់ ៦០០ មាននគរខ្លះបានត្រួតត្រាលើនគរផ្សេងៗ មាននគរផ្សេងៗត្រូវនៅក្រោមការត្រួតត្រារបស់នគរខ្លះៗ ។ នៅទ្វីបឥណ្ឌាមានព្រះរាជានិងមហារាជា មានស្តេចពេញនូវអំណាច និងស្តេចត្រាញ់ដែលត្រូវនៅក្រោមចំណុះគេ ។ ការសំខាន់របស់នគរនីមួយៗ មិនមែនតម្រង់ទៅយកទឹកដីនគរជិតខាងរបស់ខ្លួននោះទេ គេគ្រាន់តែចង់ឲ្យនគរនៅជិតខាងនោះមកចំណុះ ហើយថ្វាយសួយសារអាករៀងរាល់ឆ្នាំតែប៉ុណ្ណោះ ។

តាមក្បួនរៀបចំរបស់ក្លឹង្គនេះ **គេយកឈ្មោះរបស់ពូជពង្សស្តេចដែលសោយរាជ្យ ឬឈ្មោះរាជធានី មកធ្វើជាឈ្មោះនគររបស់គេ** ។ ក្នុងរបៀបទីមួយ គេមានជាឧទាហរណ៍ នគរមោរ្យគុប្តៈ (Maurya Gupta) និងចលុក្យៈ (Calukya) ។ ឈ្មោះរាជធានីដែលទៅជាឈ្មោះនគរ មានដូចនគរកណោច្ឆ ឧត្តរជីនី វិជ័យនគរ ...ល។

ខ្មែរក្នុងសម័យព្រហ្មញ្ញាសាសនា បានរៀបចំនគររបស់ខ្លួនដូចក្លឹង្គសុទ្ធសាធ គឺថានៅស្រុកខ្មែរមាននគរធំតូចជាច្រើន មានមហាអធិរាជ និងមានស្តេចត្រាញ់ ។ ខ្មែរពេលនោះក៏បានយកឈ្មោះពូជពង្សក្សត្រធ្វើជាឈ្មោះនគរគេដែរ ដូចជានគរ "កម្ពុជៈ" ជាដើមដែលមានព្រាហ្មណ៍កម្ពុ ជាអ្នកបង្កើតនគរនោះឡើង ។ ខ្មែរក៏បានយកឈ្មោះរាជធានី មកធ្វើជាឈ្មោះនគរដែរ ។ ឧទាហរណ៍ក្នុងសភាពនេះ មានច្រើន ដូចនគរផ្សេងៗនៅខាងក្រោមនេះ ៖

www.elibraryofcambodia.org

| ឈ្មោះនគរ | ឈ្មោះសព្វថ្ងៃ |
|---|---|
| អង្គរបូរី | តាកែវ |
| ភាវបូរ៉ា | វត្តភូ |
| សម្បូរណ៍បូរ៉ា | ក្រចេះ |
| ឥន្ទ្របូរ៉ា | កំពង់ចាម |
| ឥសាណាបូរ៉ា | សម្បូណ៌ព្រៃគប់ |
| អនិនទិត្តបូរ៉ា | រលួស |
| ម៉ាឡាយ៉ាង | បាត់ដំបង |
| ឡាវ៉ូទ័យៈ | លុបបូរី |
| សុខោទ័យ | ឈៀងម៉ៃ |
| ចន្ទបូរី | ចាន់បូរី |
| នគររាជសីមា | ណាខនរក្សាសិម៉ា |
| នគររាជ | កុរ៉ាត |
| ប្រាចិនបូរី | ប្រាចិនបូរី |
| នគរស្រីធម្មរាជ | ណាខនសីធម្មរ៉ាត |

.... ។ល ។

(កាលជំនាន់សុរិយាវរ្ម័នទី២ នគរខ្មែរទាំងអស់មាន ចំនួន ៦០ )

រហូតមកដល់សតវត្សរ៍ទី៧ នគរដែលមានគុណភាពជាព្រះអធិរាជត្រួតត្រាលើគេនោះ គឺ**នគរអង្គបូរី** ដែលចិនហៅថានគរភូណន់ ។ នគរផ្សេងៗទាំងអស់ជានគរដែលមានស្តេចត្រាញ់

www.elibraryofcambodia.org

សោយរាជ្យ ។ ដល់ឆ្នាំ ៦៣០ នគរកម្ពុជៈ ដែលចិនឲ្យឈ្មោះថា នគរចិនឡា បានលេបយកនគរអង្គរបុរី ហើយក៏បានឡើងទៅជានគរត្រួតត្រាគេវិញ ។ ក្នុងការរៀបចំនេះ នគរដែលមានស្តេចគ្រាញ់ត្រួតត្រាត្រូវថ្វាយសួយសារអាករ និងបញ្ជូនក្រុមទាហានដល់ព្រះអធិរាជនៅពេលដែលមហានគរនោះត្រូវការ ។ ព្រះមហាអធិរាជមានករណីយកិច្ច ការពារនិងរក្សាសន្តិសុខឲ្យនគរតូចៗ ហើយជាអ្នកតំណាងនគរទាំងអស់នោះ នៅមុខនគរផ្សេងៗនៅបរទេស ។ ក្បួនរៀបចំនេះ ទោះខុសឬត្រូវក៏ដោយ ក៏បាននាំមកនូវជោគជ័យ និងឫទ្ធិយ៉ាងខ្ពង់ខ្ពស់ រហូតមកដល់សតវត្សរ៍ទី ១៤ ។

## ៣. រយៈក្រោយពីសតវត្សរ៍ទី ១៤

ចាប់ពីសតវត្សរ៍ទី១៤មកដល់សព្វថ្ងៃ គឺជាសម័យព្រះពុទ្ធសាសនាថេរវាទ ។ មានព្រឹត្តិការណ៍៣បានកើតឡើងនៅស្រុកខ្មែរ ៖

១. ព្រះពុទ្ធសាសនាថេរវាទ បានចូលជាសាសនាផ្លូវការរបស់ស្រុកខ្មែរ ។ ជាមួយគ្នានេះ ព្រហ្មញ្ញសាសនាក៏បាត់បង់ផុតទៅដែរ

២. ការផ្លាស់ប្តូរក្នុងពូជពង្សព្រះមហាក្សត្រ ។ ពួកស្តេច "វរ្ម័ន" ត្រូវបាត់បង់ទាំងអស់ ហើយមានពូជពង្សរាជាថ្មីដែលជាពូជពង្សក្សត្រខ្មែរសព្វថ្ងៃមកជំនួស

៣. ការចំរើនឡើងយ៉ាងខ្លាំងនូវឫទ្ធានុភាពរបស់ជាតិសៀម

www.elibraryofcambodia.org

ព្រឹត្តិការណ៍ទាំង៣នេះ មានភាពជាប់គ្នាទាំងអស់ ។ លទ្ធផលបញ្ចប់ទៅ គឺនគរខ្មែរមានការចុះខ្សោយជាទីបំផុតដែលនាំឲ្យពួកសៀមដណ្ដើមយកបាន នគរផ្សេងៗរបស់ស្ដេចត្រាញ់ទាំងឡាយនៅស្រុកសៀមទាំងមូល មានដូចជានគរឡវទ័យៈ នគរកម្ពុជៈ នៅតមបន់អ៊ូប៊ុន អ៊ូដន សុរិន និងរក្សាសីមា រហូតទៅដល់នគរតាំងព្រះលឹង្គ នៅព្រំដែននគរម៉ាឡេស៊ី ។ លទ្ធផលធំទៀត គឺ ការលុកលុយក្រុងអង្គរពីពួកសៀម នាំឲ្យខ្មែរបោះបង់ចោលរាជធានីរបស់ខ្លួន ។ មហានគរខ្មែររួញទៅរស់ ហើយនៅសល់តែមួយគត់រហូតមកដល់សព្វថ្ងៃ ។ ឈ្មោះកម្ពុជៈ នៅបានគេនិយមប្រើដដែល ហើយសព្វថ្ងៃគេហៅថា ព្រះរាជាណាចក្រកម្ពុជា ។

www.elibraryofcambodia.org

## វគ្គទី ៤

# ភូណាន់ និង អង្គរបុរី

នគរភូណាន់ជានគរខ្មែរដែល[illegible] ប្រវត្តិសាស្ត្រខ្មែរ ។ អ្នកខ្លះយល់[illegible] របស់ខ្មែរ ។ តាមពិតនគរភូណាន[illegible] នគរឈ្មោះនេះគ្រាន់តែជានគរ[illegible] និទានមុន គេនៅបរទេសជាពិ[illegible] ។

នគរភូណាន់ជានគរខ្មែរ[illegible] សាសនា ។ ព្រាហ្មណ៍កៅណ្ឌិន្យ[illegible] ខ្មែរ ។ អ្នកខ្លះបានសរសេរថា[illegible] ជាដែនដីក្លឹង្គនៅជំនាន់នោះ ។ តាមរឿងនិទានវិញ ព្រះអង្គមកពីស្រុកឥណ្ឌាតែម្តង ។ ទោះជាយ៉ាងណាក៏ដោយនៅឆ្នាំ ៥០ គ.ស ក្រោយពីបានច្បាំងឈ្នះក្សត្រីខ្មែរ យាយលីវ ហើយនិងបានយកយាយលីវធ្វើជាអគ្គមហេសី ព្រាហ្មណ៍កៅណ្ឌិន្យក៏បានទៅជាមហាក្សត្រខ្មែរ ។ ព្រឹត្តិការណ៍ទាំងនេះ ដែលក្លាយទៅជារឿងព្រេងមួយបានចិនកត់សំគាល់និទានក្នុងសៀវភៅរឿងពង្សាវតា មហាក្សត្ររបស់គេ ។ នៅនគរចាមក៏គេបានរៀបរាប់ឡើងក្នុងអក្សរចារឹក

www.elibraryofcambodia.org

ក្នុងប្រាសាទតំបន់មីសើង នៅខាងត្បូងក្រុងដាណាំងស្រុកវៀតណាមសព្វថ្ងៃ ។

កាលឆ្នាំ ២៤៥ ប្រតិភូទូតចិនដឹកនាំដោយកងតាយ និងជូយីង បានមកសំណាក់នៅស្រុកខ្មែររហូតដល់ឆ្នាំ ២៥០ ។ ក្រោយពីបេសកម្មនេះកងតាយ[១] បានសរសេរសេចក្ដីរាយការណ៍អំពីរឿងដូចតទៅ៖ " កាលដំបូង នគរភ្នំណាន់មានមហាក្សត្រជាស្ត្រីព្រះនាម យើលីវ។ នៅស្រុកម៉ុភូ នៅទ្វីបឥណ្ឌា មានបុគ្គលម្នាក់ឈ្មោះ "ហ៊ុនទៀន" បានគោរព និងស្រឡាញ់អ្នកតាមួយរូបយ៉ាងខ្លាំង ។ អ្នកតានោះមានសេចក្ដីពេញចិត្តជាច្រើន ។ នៅពេលយប់មួយ ហ៊ុនទៀនយល់សប្ដិឃើញ ថាមានមនុស្សម្នាក់ឲ្យធ្នូទិព្វមួយ ហើយបង្គាប់ឲ្យចេញតាមនាវាទៅតាមសមុទ្រ ។ ស្អែកឡើងហ៊ុនទៀនមុននឹងចូលទៅវិហារដើម្បីថ្វាយបង្គំព្រះ បានឃើញធ្នូមួយនៅក្រោមដើមឈើធំ ដែលអារក្សអ្នកតានៅទីនោះ ។ ហ៊ុនទៀនក៏រកបាននាវាមួយ ហើយក៏បើកក្ដោងចេញទៅសមុទ្រ ។ អ្នកតាតម្រង់ខ្យល់បក់នាំនាវាហ៊ុនទៀន ទៅរហូតដល់នគរភ្នំណាន់ ។ មហាក្សត្រី "យើលីវ" ឃើញនាវាប្លែកមក ក៏ចេញតាមនាវាខ្លួនឯងទៅស្ទាក់ចាប់ ។ ហ៊ុនទៀនយកធ្នូទិព្វមកបាញ់ ។ ព្រួញមួយ ធ្វើឲ្យធ្លាយនាវាមហាក្សត្រីពីម្ខាងទៅម្ខាង ។ មហាក្សត្រីមានការភ័យរន្ធត់ រួចក៏សុខចិត្តចុះចាញ់ ។ ហ៊ុនទៀនបានទៅជាមហាក្សត្រនគរភ្នំណាន់ទៅ ។

---

[១] K'ang Tai : Rapport d' une ambassade du Funan de 245 à 250 cité par Alain Daniélou dans "Histoire de l' Inde". Fayard Paris 1971, p. 229.

www.elibraryofcambodia.org

ក្នុងឆ្នាំ ៦៥៨ ស្ដេចចាម "ប្រកាសធម៌" បានឆ្លាក់អក្សរចារិករំឭករឿងព្រេងប្រហែលគ្នានេះដែរ នៅក្នុងប្រាសាទដំបន់មីសើង ហើយមានសេចក្ដីដែលលោកល្វីភីណូក [២] បកប្រែដូចតទៅ ៖

"បន្ទាប់ពីមានយល់សប្តិមួយ ព្រាហ្មណ៍ក្លិង្គឈ្មោះកៅណ្ឌិន្យ បានចាកចេញពីទ្វីបឥណ្ឌាតាមសមុទ្រ ហើយបានមកដល់ស្រុកខ្មែរ។ ចុះដល់ដីគោកភ្លាម ព្រាហ្មណ៍កៅណ្ឌិន្យគ្រវែងលំពែងដែលព្រះមហាព្រាហ្មណ៍អស្វត្ថម៉ន បុត្រាព្រះទ្រោណបានប្រទាន ។ កន្លែងដែលលំពែងធ្លាក់ដោត គឺជាកន្លែងដែល កៅណ្ឌិន្យ ស្ថាបនារាជធានីរបស់ព្រះអង្គ ។ រួចមកព្រះអង្គបានរៀបចំអាពាហ៍ពិពាហ៍ជាមួយមហាក្សត្រីខ្មែរព្រះនាម "សោមា" ដែលជាបុត្រីស្ដេចព្រះភុជង្គនាគ ។ ព្រះនាគរាជនេះក៏លេបយកទឹកនៅទីនោះទាំងអស់ នាំមកឲ្យគូរស្វាមីទាំងពីរ ដែនដីជានគរមួយយ៉ាងធំ" ។

អ្នកសិក្សាប្រវត្តិសាស្ត្រខ្លះ ឆ្ងល់ជាហេតុអ្វីក៏រឿងកំណើតនគរភ្នំមានភាពពីរយ៉ាងដែលមិនបានដូចគ្នាដូច្នេះ? ការពិតគឺសេចក្ដីរាយការណ៍របស់ទូតចិន "កងតាយ" នោះជារឿងដើមរបស់នគរភ្នំ ឯរឿងក្នុងអក្សរចារឹកនៅនគរចាមវិញ គេមានលាយខ្លះជាមួយរឿងដើមកំណើតនគរកម្ពុជៈ របស់ព្រាហ្មណ៍កម្ពុ ហើយដែលក្នុងរឿងនេះ គឺស្ដេចនាគរាជបានស្រេបលេបទឹកដើម្បីឲ្យកូនទាំងពីរមានដែនដីជានគរមួយធំ (អានវគ្គទី ៥៖ ចិនឡា ឬកម្ពុជា) ។ ហេតុដែលស្ដេចចាមសរសេរចារឹកដូច្នេះ មកពីព្រះមាតាព្រះអង្គជាខ្មែរគឺមហាក្សត្រីសារវណ្ណី បុត្រីមហាក្សត្រនគរកម្ពុជព្រះនាម

---

[២] Louis Finot : Les inscriptions de My son, BEFEO T4 p.923.

www.elibraryofcambodia.org

ឥសាណវរ្ម័ន ។ មហាក្សត្រនេះទៀតបានចុះមកពីស្តេចកម្ពុជៈ តាមខាងឪពុក និងពូជស្តេចភូណាន់តាមខាងម្តាយ ។ អក្សរចារឹកដែលមាន រឿងព្រេង ២ លាយគ្នានោះ បង្ហាញឲ្យឃើញថាស្តេចចាមបានចុះមកពីព្រះរាជវង្សខ្មែរ ២ គឺកៅណ្ឌិន្យ-សោមា មួយនឹងកម្ពុមេរៈមួយទៀត ។

ស្របតាមភូមិសាស្ត្រ នគរភូណាន់នៅខាងក្រោមទន្លេមេគង្គ ពីភ្នំពេញសព្វថ្ងៃរហូតដល់សមុទ្រ [illegible] ។ [illegible] ភូណាន់គឺទឹកដី "កូសាំងស៊ីន" [illegible] ហើយ [illegible] សព្វថ្ងៃបានត្រឡប់ទៅជានគរវៀត [illegible] ។ [illegible] ដែនដីនេះហើយ នៅវាលកក់នៃ [illegible] ជាង ២០០ គ.ម សម្រាប់ [illegible] យ៉ាងខ្លាំង ។ ខ្មែរក្រោមសព្វថ្ងៃ [illegible] រាជធានីនគរនេះគឺក្រុង "អង្គរបុរី" [illegible] ហ្សាក់[៣] បានបង្ហាញមិនមែនជា "វ្យាធបុរី" [illegible] ដែល សរសេរមកនោះទេ ។ [illegible] បរបាញ់នោះមិនត្រូវទេ ។ វ្យាធ ជាពាក្យសំស្ក្រឹតមួយដែលមានន័យថា ដោតឆ្លាយដោយព្រួញ ហើយវ្យាធបុរី គឺក្រុងដែលមានឥទ្ធិពល ឬកម្លាំងដូចព្រួញ ។ ដូចគ្នានេះដែរ សិង្ហបុរីមិនមែនមានន័យថាក្រុងនោះមានសត្វសិង្ហច្រើននោះទេ គឺជាក្រុង

[៣] Claude Jacques : Le Pays khmer avant Angkor. Journal des savants. Paris 1986. p. 60.

www.elibraryofcambodia.org

# នគរអង្គរបុរី
# ភូណាន់



នោះមានឫទ្ធិខ្លាំងដូចសត្វសិង្ហ ។ លក្ខណៈពិសេសរបស់នគរខ្មែរជំនាន់នោះមិនមែនបង្ហាញឲ្យគេស្រឡាញ់ទេ គឺបញ្ចេញរបរាងឲ្យគេខ្លាច ឲ្យគេញញើតដែលពេលសព្វថ្ងៃគេហៅថានយោបាល "រារាំង" (Politique de dissuasion) កុំឲ្យសត្រូវមានគំនិតមកឈ្លានពាន ។

នគរភ្នំណាន់ជានគរមួយ ដែលមានឫទ្ធានុភាព យ៉ាងធំស្ដែង ។ មហាក្សត្រនគរភ្នំណាន់ ជាព្រះអធិរាជមានអំណាចទៅលើនគរខ្មែរ ផ្សេងៗជាច្រើន មានដូចជានគរ "ចិនឡា" ជាដើម ។ នគរភ្នំណាន់ដំណាងនគរផ្សេងៗទាំងអស់ នៅមុខបរទេស ។ ដោយហេតុនេះ ហើយបានជានគរភ្នំណាន់មាន ការទាក់ទងមិនដាច់ជាមួយចិន និងជាមួយនគរខ្លះនៅទ្វីបឥណ្ឌា ។ កាលឆ្នាំ ៥០៣ មហារាជចិនបានទាំងតែងតាំងស្ដេចភ្នំណាន់កៅណ្ឌិន្យជ័យវរ្ម័ន ឡើងជាមហាសេនានគរចិនទៀតផង ។

កងតាយ បានសរសេរទៀតថា ៖ "អ្នកស្រុកមានរូបអាក្រក់សក់រួញ ហើយប្រុសៗដើរស្រាត ។ គេមិនចេះលួចប្លន់ទេ ។ ចានសំបែងដែលដាក់ម្ហូបម្ហាសុទ្ធតែគេធ្វើអំពីប្រាក់ទាំងអស់ ។ គេយកមាសប្រាក់ ត្បូងខ្យង ឬ គុជ និងទឹកអប់មកសម្រាប់បង់ពន្ធ ។ គេមានសៀវភៅ ព្រមទាំងបណ្ណាល័យសំរាប់ដាក់ឯកសារផ្សេងៗរបស់គេ" ....។ អ្នកខ្លះឃើញពាក្យថាស្រាត ហើយនិងពាក្យ "មនុស្សព្រៃ" ក៏ទុកថាខ្មែរជំនាន់នោះ មានភាពអន់ថយយ៉ាងខ្លាំង (ក្រែងតែយើងឆោតល្ងង់ណាស់ បានយើងយកពាក្យ "ព្រៃ"នេះ ថាជាព្រៃព្រឹក្សមែនទែន ។ ចិនប្រើពាក្យនេះ គ្រាន់តែសំរាប់បង្ហាញថាគេគ្រាន់បើជាងជាតិ ផ្សេងៗទាំងអស់តែប៉ុណ្ណោះ ។ ចំពោះស្ដេចចិន ក្រៅពីចិន អ្នកណាក៏

www.elibraryofcambodia.org

ជាមនុស្សព្រៃដែរដូច ខ្មែរ ម៉ុងហ្គូល ជប៉ុនជាដើម) ។ ខ្មែរដើរខ្លួនទទេដូចដែលគេឃើញតាមស្រុកស្រែសព្វថ្ងៃ មិនមែនជាការស្រាតអ្វីទេ ។ តាមពិតខ្មែរភ្នំណាន់មានភាពជឿនលឿនច្រើន ពីព្រោះគេចេះយកប្រាក់ធ្វើចានបរិភោគ យកមាសទឹកអប់មកបង់ពន្ធ ហើយជាពិសេសគេមានសៀវភៅ មានបណ្ណាល័យ និងមានបញ្ជីរឯកសារយ៉ាងត្រឹមត្រូវទៀត ។

មហាក្សត្រភ្នំណាន់ចុងក្រោយបង្អស់គឺ **រុទ្រវរ្ម័ន** ព្រះរាជបុត្ររបស់កៅណ្ឌិន្យ-ជ័យវរ្ម័ន ប៉ុន្តែព្រះមាតាព្រះអង្គមិនមែនជាអគ្គមហេសីទេ ។ រុទ្រវរ្ម័នបានឡើងសោយរាជ្យក្រោយពីបានធ្វើឃាតកម្មទៅលើព្រះអង្គម្ចាស់ **គុណវរ្ម័ន** ដែលជាព្រះរាជបុត្រាព្រះអគ្គមហេសី **"កុលប្រភាវតី"** ។ រុទ្រវរ្ម័ន កាន់ព្រះពុទ្ធសាសនាមហាយាន ហើយជាមហាក្សត្រខ្មែរទីមួយដែលយកព្រះពុទ្ធសាសនាមកធ្វើជាសាសនារដ្ឋ ។ ព្រឹត្តិការណ៍ទាំងអស់នេះនាំឲ្យមានការជ្រួលច្របល់ច្រើននៅក្នុងប្រទេស ។

រុទ្រវរ្ម័ន នៅសោយរាជ្យនៅឡើយកាលឆ្នាំ ៥៤៥ ព្រោះក្នុងឆ្នាំនោះព្រះអង្គបានទទួលប្រតិភូរទូតចិនមួយ មកសុំជំនួយអំពីខ្មែរដើម្បីនឹងបកប្រែក្បួនធម្មិព្រះពុទ្ធសាសនា ។ ព្រះអង្គយល់ព្រមនឹងការសុំរបស់ចិន ហើយបានបញ្ជូនព្រះសង្ឃ **"គុណរតនា"** ដែលមានដើមកំណើតជាភ្លឹង្គ ឲ្យទៅស្រុកចិនបំពេញបេសកម្មនេះ ។

រុទ្រវរ្ម័ន ឥតមានបុត្រាតរាជទេ ។ ដោយហេតុនេះហើយទើបរាជវង្សខាងគុណវរ្ម័នចង់ត្រឡប់មកយកព្រះរាជបល័ង្កវិញនៅ

www.elibraryofcambodia.org

ពេលដែលព្រះអង្គបានសុគតទៅ ។ **ភវវរ្ម័ន** ដែលជាមហាក្សត្រនគរ "ចិនឡា" ហើយដែលមាតាត្រូវជាបុត្រីរុទ្រវរ្ម័ន ក៏ទាមទារ និងចាប់ផ្តើមច្បាំងយកនគរភ្វណាន់ ។ ចិត្រាសេនា ប្អូនជីដូនមួយហើយដែលសោយរាជ្យក្រោយពីព្រះអង្គ ព្រះនាម**មហិន្ទ្រវរ្ម័ន** បានបន្តសកម្មភាពនេះតទៅទៀត ។ នៅពេលបញ្ចប់គឺមហាក្សត្រ**ឥសាណវរ្ម័ន** ព្រះរាជបុត្រារបស់មហិន្ទ្រវរ្ម័ន ដែលបានដណ្តើមយកនគរភ្វណាន់បាន ក្រោយពីបានឈ្នះនៅរាជធានីអង្គរបូរីក្នុងឆ្នាំ **៦៣០** ។ នគរភ្វណាន់ត្រូវបានចូលរួមជាមួយនគរ "ចិនឡា" (កម្ពុជា) ហើយបាត់បង់ឈ្មោះរហូតមកដល់សព្វថ្ងៃ ។

នគរភ្វណាន់ដែលគេបានដឹងមកនេះមានឈ្មោះ **ភ្វណាន់** ។ លោក សើដែស[6] សរសេរថា "ពាក្យភ្វណាន់មកពីពាក្យ "**ភ្នំ**" ហើយនគរខ្មែរមានឈ្មោះថា "**នគរភ្នំ**" ។ រាជធានីខ្មែរនៅស្រុក**បាភ្នំ**ក្បែរស្រុកបាណាម ។ ស្តេចខ្មែរក៏មានថានន្តរៈជាសៃលិន្ទ្រ[*] គឺជា**ស្តេចភ្នំ**ដែរ" ។ ការពិតមិនមែនមានតែមហាក្សត្រខ្មែរទេ ដែលមនាថានន្តរៈ ជាសៃលិន្ទ្រ ។ ក្សត្រឥណ្ឌូណេស៊ី និង ស្តេចក្លិង្គខ្លះក៏មានដូចច្នេះដែរ ហើយនគរគេឥតមានឈ្មោះជានគរ "ភ្នំ" ទេ ។ ម្យ៉ាងទៀត បាភ្នំនិងបាណាម មិនមែនមានន័យជាភ្នំដូចលោកសើដែស សរសេរនោះទេ ពីព្រោះពាក្យនេះបានមកពីពាក្យ បា ដែលខ្មែរគោរពតាមប្រពៃណី មេ-បា របស់ខ្មែរ ។ បាណាមទៅទៀតមិនមែន

---

[6] G. Cœdès : op.cit. p. 74.

(*) សៃលិន្ទ្រ គឺជាស្តេចភ្នំ ឬភ្នំដែលធំជាងគេបង្អស់ មិនមែនជាស្តេចគង់នៅលើភ្នំទេ ។

www.elibraryofcambodia.org

ភ្នំទេ គឺជា "ធ្មានាំ" ប្រែថា "ជានាំជាតិយើង" ។ ពាក្យបាក់បានគេដាក់ឲ្យទៅភ្នំ ពាន់ស៊ែរ ពាន់រ៉ែង ឬ ស្រុកបាភនៅឯស្រុកវៀតណាម ដល់ឈ្មោះសព្វថ្ងៃនៅឡើយដែរ ។

គេហៅនាមនគរខ្មែរជំនាន់នោះ បានរៀបចំតាមរបៀបភ្លឹង្គ គឺគេយកឈ្មោះមហាក្សត្រ ឬ ឈ្មោះរាជធានីមកធ្វើជាឈ្មោះនគររបស់គេ ។ ម៉ារីលីយ៉ា អាល់បាណេស្ស[៥] សរសេរថា ៖ "ចារឹកអក្សរខ្មែរ មិនដែលនិយាយអំពីភ្នំណាន់ ឬចិនឡាអ្វីសោះ គេយកឈ្មោះរាជធានីមកធ្វើជាឈ្មោះនគររបស់គេ" ។

ឈ្មោះភ្នំណាន់ ឬ ចិនឡា ដែលមិនមែនជាឈ្មោះមហាក្សត្រ ឬ ជាឈ្មោះរាជធានីខ្មែរ មិនមែនជាឈ្មោះនគរខ្មែរទេ ។ ប្រើពាក្យ "ភ្នំណាន់" តាមទម្លាប់របស់អ្នកប្រវត្តិវិទ្យាភ្នំណាន់មិនបានត្រឹមត្រូវទេ ។ ការពិតភ្នំណាន់ជាអក្សរចិន ដែលគេបង្កើតសម្រាប់ចិន ហើយមានន័យថា ទឹកដីនៅឆ្ងាយ ឆ្ងាយណាន់គឺសមុទ្រខាងត្បូង តាយណាន់គឺខាងត្បូងនៃចិន ។ល។

នគរខ្មែរមានឈ្មោះជាអ្វី ? រាជធានីជំនាន់នោះគឺអង្គរបុរី ។ នគរខ្មែរដែលចិនឲ្យឈ្មោះថាភ្នំណាន់ គឺ **នគរអង្គរបុរី** ។

---

៥ Marilia Albanése : Angkor, Splendeurs de l'Art khmer. Ed Gründ. Paris 2002. p.23.

www.elibraryofcambodia.org

www.elibraryofcambodia.org

## វគ្គទី ៤

# ចិនឡា ឬ កម្ពុជា

នគរដែលចិនហៅថា "ចិនឡា" ជានគរខ្មែរទី ២ ដែលគេបានស្គាល់នៅបរទេស ។ សាវតារនគរចិនឡាមានសភាពដូចនគរភ្នំណាន់ទាំងអស់ ឥតមានអ្វីខុសគ្នាបន្តិចបន្តួចឡើយ ចាប់តាំងពីកំណើតកើតដោយព្រាហ្មណ៍មួយអង្គ រហូតដល់រឿងព្រេងនិទានអំពីពង្សសាវតាមហាក្សត្រ ដល់ការរៀបចំសាសនារដ្ឋ និងសង្គមរបៀបក្លឹង្គកាលនៅពេលនោះ ។ នគរចិនឡា ជានគរមួយដែលមានទំហំយ៉ាងធំ ។ អ្នកខ្លះនឹកស្មានថានគរនេះមាននៅក្នុងតំបន់វត្តភូនៅខាងត្បូងប្រទេសលាវសព្វថ្ងៃ ។ តំបន់នេះទៀតដែលមានឈ្មោះថា ចម្ប៉ាសាក់ឬប៉ាសាក់នោះ កាលដើមឡើយជានគរស្តេចត្រាញ់ចាម ដែលចិនឡាបានលេបយកតាំងពីដំបូង នៅពេលដែលចិនឡាចាប់ផ្តើមពង្រីកដែនដីរបស់ខ្លួនតាមដំណើរចុះមកខាងត្បូង ។ តាមការសិក្សារបស់លោក **"អេរីកសៃដេនហ្វាដេន"**[១] និង

---

[១] Erik Saidenfaden : Inventaire descriptif des monuments du Cambodge pour les quatre provinceS du Siam oriental. BEFEO XXII. 1922. p.28.

www.elibraryofcambodia.org

លោក "ហង្រឹមាស្ប៉េរ៉ូ"[២] កាលសតវត្សរ ទី៥ និងទី៦ នគរចិនឡាតិ ៖ ភាគឦសានទាំងមូលនៃប្រទេសសៀម រួមនឹងពាក់កណ្តាលខាងត្បូងនៃស្រុកលាវ ហើយមួយផ្នែកធំនៅខាងជើងស្រុកខ្មែរសព្វថ្ងៃ ។ នៅស្រុកសៀម គឺមានខេត្តបួន ៖ អ៊ូដន់-អ៊ូបន-រយអេត-ណាខនរក្សាសីមា (នគររាជសីមា) ។ នៅស្រុកខ្មែរ គឺស្ទឹងត្រែង-ក្រចេះ-និងភាគខាងជើងកំពង់ធំ ។ ស្រុកកំណើតនគរចិនឡា គឺតំបន់ទន្លេរយអេត និងទន្លេ "មុណ" ដែលហូរចុះទៅទន្លេមេគង្គ ។ នគរនេះបានពង្រីកខ្លួនទៅខាងត្បូងរហូត ទាល់តែលេបបាននគរភ្នំណាន់អស់ទាំងមូលមកធ្វើជានគរតែមួយ ។

អ្នកបង្កើតនគរចិនឡាគឺព្រាហ្មណ៍ភ្លឹងមួយអង្គ ព្រះនាម "**កម្ពុស្វយំភូវៈ**" ។ ព្រះអង្គយកទេពអប្សរខ្មែរមួយរូប ឈ្មោះ "មេរៈ" ធ្វើជាអគ្គមហេសី ។ គូមហាក្សត្រ "**កម្ពុ-មេរៈ**" បានបង្កើតព្រះរាជវង្សមួយថ្មីហៅថា "**សុរិយវង្សា**" មានន័យថាចុះមកពីព្រះអាទិត្យ ឬសុរិយា ផ្ទុយនឹងព្រះរាជវង្សមហាក្សត្រនគរភ្នំណាន់ "**កៅណ្ឌិន្យ-សោមា**" ដែលចុះមកពីព្រះច័ន្ទ (សោមា=ព្រះច័ន្ទ) ។ នៅនគរចិនឡាគេគោរពមហាក្សត្រី "មេរៈ" ជាទីបំផុត តាមទំនៀមទំលាប់ខ្មែរដែលកាន់របបមាតានិយម តាំងពីច្រើនពាន់ឆ្នាំរួចមកហើយ ។ ច្រើនសតវត្សរ៍ក្រោយមកទៀត គេនៅតែគោរព "មេរៈ" ដដែល ដូចគេបានឃើញ ក្នុងចារឹកនៅប្រាសាទ "បក្សីចាំក្រុង" ឆ្នាំ ៩៤៨ ដូចតទៅ៖

---

[២] Henri Maspéro : Etudes d'Histoire d'Annam. BEFEO XVIII. T III. P.26-39.

www.elibraryofcambodia.org

"ខ្ញុំធ្វើសក្ការៈបូជា មេរៈ
ដែលមានកិត្តិនាមធំជាងទេពអប្សរទាំងអស់
ហើយដែល "ហារ" ព្រះគ្រូទាំងបីទ្វីប
ចង់បង្កើតការមួយល្អគ្មានខ្ចោះ
តាមប្រយោជន៍របស់ព្រះនេតទាំងបី
បានឲ្យទៅជាមហេសីមហារាជឥសីកម្ពុ"

**កំណាព្យវគ្គ ១២**

(បកប្រែតាមលោកហ្គ. សើដែស)

ហារ=សីវៈ ហារី=វិស្ណុ

ការបង្កើតនគរចិនឡាក៏បានគេប្រឌិតជារឿងព្រេងមួយ ហៅថារឿង "**ព្រះថោងនាងនាគ**" ដែលគេនិទានថា ៖ "នគរចិនឡាបានកើតឡើងដោយសារព្រះថោង ។ កាលនៅពេលយូរណាស់មកហើយនោះ ព្រះថោងដែលជាកូនពៅ ត្រូវព្រះរាជបីតាបណ្ដេញចេញពីនគរ ។ ព្រះថោងចុះទៅទិសខាងត្បូង ទៅដល់នគរមួយដែលមានមហាក្សត្រជាជាតិចាម ។ ព្រះថោងដេញក្សត្រចាមនេះចេញ ហើយក៏ឡើងសោយរាជ្យនៅទីនោះ ។ រួចមកព្រះអង្គយកនាងនាគ ដែលជាបុត្រីព្រះភុជង់នាគ មកធ្វើជាអគ្គមហេសី ។ មហាក្សត្រនាគ មាននគរនៅក្រោមកោះ "**គោកធ្លោក**" នៅជិតនោះដែរ ។ ព្រះអង្គលេបយកទឹកទាំងអស់នៅជុំវិញកោះនេះ ធ្វើឲ្យព្រះថោង និងនាងនាគបានដែនដីមួយយ៉ាងធំទូលាយមកសោយរាជ្យ ។ កោះគោកធ្លោក ក៏បានទៅជារាជធានី នៅកណ្ដាលព្រះរាជាណាចក្រថ្មីនេះដែរ" ។

www.elibraryofcambodia.org

រឿងព្រះថោងនាងនាគជារឿងផ្ទាល់របស់នគរចិនឡា ។ គេមិនត្រូវច្រឡំនឹងរឿងហ៊ុនទៀន ដែលជារឿងរបស់នគរភ្នំណាន់ទេ ពីព្រោះកាលដើមកំណើតនគរភ្នំណាន់ក្នុងឆ្នាំ ៥០ គ.ស នគរចាមអត់ទាន់មានជីវិតនៅលើដីរបស់គេនោះនៅឡើយទេ ។ នគរចាមបានស្តេចស្រីម៉ារ៉ាបង្កើតក្នុងឆ្នាំ ១៩៧ ។

ទោះបីជាយ៉ាងណាក៏ដោយ រឿងព្រេងទាំងអស់នេះ គឺជារឿងដែលគេចំលងតាមទំនៀមទំលាប់ក្លិង្គមកទេ ។ រឿងនាងនាគមានគេនិទាននៅក្នុងប្រវត្តិសាស្ត្ររបស់ពូជពង្សស្តេចក្លិង្គជាច្រើន ដូចជាពួក "បល្លវៈ" (Pallava) និងពួក "គុប្តៈ" ជាដើម ។ នៅស្រុកក្រិកទៅទៀត គេមានរឿងប្រហែលគ្នានេះដែរ ។ មហាក្សត្រី "អេឆិត្ណា" ជានាងនាគមួយរូប ដែលពាក់កណ្តាលខ្លួនខាងលើជាមនុស្ស ហើយពាក់កណ្តាលខ្លួនខាងក្រោមជានាគ មុននឹងបានទៅជាមហេសីស្តេច "ហេរ៉ាក្លែស" ជាដើម ។

នគរចិនឡាជានគរមួយនៅក្រោមចំណុះនគរភ្នំណាន់ រហូតមកដល់សតវត្សរ៍ទី៧ ។ នេះគឺគេធ្វើឡើងតាមរបៀបរៀបចំនគរស្រុកទេសខ្មែរទូទៅនៅពេលនោះ ។ នគរចិនឡាត្រូវថ្វាយសួយសារអាករជៀងរាល់ឆ្នាំដល់មហាក្សត្រនគរភ្នំណាន់ ។ ការទាក់ទងនេះពួកក្សត្រចិនឡាឲ្យឈ្មោះថា "ខ្សែសួយសារអាករ" ដែលគេតែងតែរករឿងផ្តាច់ចេញជានិច្ច ដូចគេបានឃើញក្នុងចារិកអក្សរនៅប្រាសាទបក្សីចាំក្រុងនៅអង្គរ ។ មហាក្សត្រធំៗ របស់នគរចិនឡាគឺ **សរុតវរ្ម័ន ស្រេស្តវរ្ម័ន** និង **វីរវរ្ម័ន** ប៉ុន្តែអ្នកដែលល្បីល្បាញជាងគេគឺមហាក្សត្រ**ភាវវរ្ម័ន** ដែលសោយរាជ្យពីឆ្នាំ ៥៥០ ទៅដល់ឆ្នាំ ៦០០ ។

www.elibraryofcambodia.org

# នគរ កម្ពុជៈ
# ចិនឡា




www.elibraryofcambodia.org

គឺមហាក្សត្រនេះហើយ ដែលជាអ្នកផ្តើមឲ្យបានការរួបរួមព្រះរាជវង្ស សុរិយវង្សា និង សោមាវង្សា ហេតុផលទាំងឡាយ ដែលនាំឆ្ពោះទៅការបង្កើតបានមហានុភាពអង្គរ ។

ភាវវរ្ម័នត្រូវជាចៅមហាក្សត្រ រុទ្រវរ្ម័ន នគរភ្នំពេញ តាមខាងព្រះមាតាព្រះអង្គ ដែលជាបុត្រីមហាក្សត្រនេះ ឯព្រះបីតាព្រះអង្គវិញ គឺព្រះមហាក្សត្រនគរចិនឡា វីរវរ្ម័ន ។ សេចក្តីទាំងនេះបានលោកអេរិកសៃដែនហ្វាដែន[៣] បង្ហាញត្រឹមត្រូវ តាមអក្សរចារិកនៅទន្លេ"មូណា" ។ ភាវវរ្ម័នមិនមែនជាព្រះរាជបុត្រក្សត្រនគរភ្នំពេញ ដូចលោក "សឺដែស"[៤] បានសរសេរ ហើយដែលលោក "ដោហ្វាំងម៉េណឹអេ"[៥] បានចម្លងតាមនោះទេ ។

ពេលដែលមហាក្សត្រភ្នំពេញសុគត ហើយដោយព្រះអង្គឥតមានបុត្រាណាផង ស្តេចភាវវរ្ម័នក៏ទាមទារយកនគរភ្នំពេញក្នុងនាមព្រះមាតារបស់ព្រះអង្គ ។ រឿងនេះនាំឲ្យមានការចម្បាំងយ៉ាងយូរនៅលើនគរភ្នំពេញ ។ ក្សត្រចិត្រាសេនា ប្អូនជីដូនមួយ ភាវវរ្ម័ន ដែលឡើងសោយរាជ្យបន្ទាប់មក ក្នុងព្រះនាមជាព្រះមហិន្ទ្រវរ្ម័ន បានបន្តបេសកកម្មនេះតទៅទៀត ។ នៅទីបញ្ចប់ **គឺឥសាណវរ្ម័នទី១** ព្រះរាជបុត្ររបស់មហិន្ទ្រវរ្ម័ន បានទទួលជោគជ័យលើរាជធានីអង្គរបុរី ហើយយកបាននគរភ្នំពេញនៅឆ្នាំ **៦៣០** ។

---

[៣] Erik Saidenfaden : op. cit. p.28.

[៤] Georges Cœdès : op. cit. p.128.

[៥] A. Dauphin Meunier : op.cit. p.28.

www.elibraryofcambodia.org

អ្នកទទួលតំណែងតពី ឥសាណវរ្ម័ន គឺ**ភាវវរ្ម័នទី២** (៦៣៩-៦៥៥) **ជ័យវរ្ម័ន១** (៦៥៥-៦៨៦) ហើយនឹងបុត្រីព្រះអង្គគឺមហាក្សត្រី **ជ័យទេវី** ដែលជាក្សត្រីតែមួយក្នុងសម័យអង្គរ ។ គឺមហាក្សត្រីនេះឯង ដែលបានប្រើពាក្យ "**ក្រោមល្អងធូលីជើង** កន់រ៉ាដែនអាញ់ (កន់ គឺពួក - រ៉ាដែង គឺអ្នកអស្ចារ្យ[illegible] ។ នៅក្នុងចារឹកមួយទៀតការ ឆ្នាំ៧១៣ ព្រះមហាក្សត្រី[illegible] ភាពជ្រួលច្របល់ក្នុង ព្រះរាជាណាចក្រ ហើយនឹងភ័[illegible]នៅពេលនោះ ។

**នគរចិនឡាជានគរខ្មែរ ដែលមានប្រជារាស្ត្រជាខ្មែរ** ។ តាមធម្មតា គេមាន "ប្រជាជនមួយ ស្រុកមួយ ព្រះរាជាណាចក្រមួយ" តែដល់នគរភ្នំណាន់ និងចិនឡាវិញ គេមាន "ប្រជាជនមួយគឺខ្មែរស្រុកពីរ និងព្រះរាជាណាចក្រពីរ ។ ភាពនេះធ្វើឲ្យអ្នកខ្លះដែលមិនបានស្គាល់ទំនៀមទំលាប់ក្លឹង្គ ដែលកៅណ្ឌិន្យនិងកម្ពុយកមកអនុវត្តនៅស្រុកខ្មែរ មានការមិនយល់ជាច្រើន ។ នៅទ្វីបឥណ្ឌា នគរអុជិន កលិង្គ ឬ គុប្តៈជាដើម គឺជានគរក្លឹង្គទាំងអស់ ។ នៅស្រុកខ្មែរនគរភ្នំណាន់នឹងនគរចិនឡា គឺជានគរខ្មែរទាំងអស់ដែរ ។ ការដែលនិយាយថាប្រជាជនភ្នំណាន់ជាជាតិឥណ្ឌាណេស៊ី ដើម្បីឲ្យឃើញភាពខុសគ្នាពីនគរចិនឡាតាមលោកស្រី **ម៉ាលីរីឡីយ៉ាអាលបាណែស្ស៍** [៦] មិនបានត្រឹមត្រូវទេ ។ ផ្ទុយទៅវិញ ពាក្យដែលលោក **ប.ផ គ្រោលីអេ** [៧] និយាយថាប្រជាជននគរចិនឡាជាជាតិឥណ្ឌូណេស៊ី ហើយខាងភ្នំណាន់ជាខ្មែរ នោះក៏មិនត្រូវដែរ ។

---

[៦] Marilia Albanèse : op. cit. p.28.

[៧] Bernard Philippe Groslier : Indochine. Albin Michel. Paris 1983.

www.elibraryofcambodia.org

នគរចិនឡាមានការទាក់ទងយ៉ាងជិតស្និតជាមួយចិនចាប់ពីសតវត្សរ៍ទី៦ ។ ព្រះអង្គម្ចាស់ចិត្រាសេនាខ្លួនឯង បាននាំប្រតិភូទូតមួយទៅស្រុកចិន ។ ព្រឹត្តិការណ៍ទាំងអស់នេះ ចិនបានសរសេរទុកក្នុងក្បួនពង្សាវតារមហាក្សត្រ "ស្វៃ" និងពូជពង្ស "តាំង"។ គឺចិននេះឯងដែលឲ្យឈ្មោះនគរខ្មែរថា "ចិនឡា" ដែលចិនគេអានថា "ចិនឡប់" ។ លោកប៉ូលប៉េឡ្យោត៍ អ្នកប្រាជបារាំងខាងភាសាចិនបានសរសេរថា ៖ រហូតមកដល់សព្វថ្ងៃ គេមិនដឹងថាចិនឡា ឬ ចិនឡប់នេះមានន័យយ៉ាងណាទេ ។ ចិនគឺប្រាកដជាចិន ហើយចិនឡប់នេះប្រហែលជាមានន័យថា "ចិនរាប" ដូចពាក្យ "សៀមរាប" ដែលជាឈ្មោះខេត្តមួយសព្វថ្ងៃ រួចមានន័យថាសៀមចាញ់ ។ ការពិតចិនឡប់ជាពាក្យខ្មែរទេ ។ ចិនសួរទៅអ្នកស្រុកថា ស្រុកអ្នកឯងឈ្មោះអ្វី ? ខ្មែរឆ្លើយថាចិនឡប់ គឺជាចិនឡប់ខួរក្បាល មិនមែនចិនចាញ់ទេ (ខ្មែរយើងចូលចិត្តកំប្លែងជាមួយចិនណាស់ ។ អ្នកទូតចិនជូតាក្វាន់ ឆ្ងល់ថាហេតុអ្វីអ្នកបម្រើស្រីនៅក្នុងព្រះរាជវាំងមានចំនួនដល់ទៅ ៤០០០នាក់ ។ ចិននេះក៏សួរទៅនាងមួយ ដែលចេញពីវាំងថាមុខងារនាងឯងជាអ្វី ? នាងនោះឆ្លើយថា ៖ "ចិនកៀឡាន់" ។ ជូតាក្វាន់ចម្លងពាក្យនេះទៅក្នុងសៀវភៅរបស់លោក ហើយបានបញ្ជាក់ថាលោកនៅតែមិនយល់ ។ រហូតមកដល់សព្វថ្ងៃ ឥតមានអ្នកប្រាជណាមួយដឹងថា "ចិនកៀឡាន់" គឺអ្វីទេ ។ បើគេគ្រាន់តែសួរទៅសិស្សខ្មែរណាមួយ គឺសិស្សនោះអាចប្រាប់បានទៅហើយ ៖ "ចិនកៀឡាន់" ប្រែថា "ក្តចិន" តែប៉ុណ្ណោះ) ។

**ទោះជាយ៉ាងណាក៏ដោយចិនឡា និងចិនឡប់មិនមែនជាឈ្មោះរបស់នគរព្រាហ្មណ៍កម្ពុទេ** ។ មហាក្សត្រនគរនេះ គេហៅនគរគេថា "កម្ពុជ:" គឺជានគរអ្នកដែលកើតមកពីព្រាហ្មណ៍កម្ពុ ឬ

www.elibraryofcambodia.org

នគរព្ធជពង្សកម្ពុ ។ ពាក្យកម្ពុជៈ នេះទៀត ប្រហែលជាគេបានចម្លង តាមឈ្មោះនគរកម្ពុជៈ ដែលមាននៅតំបន់កាបូលខាងលិចទ្វីប ឥណ្ឌា កាលសតវត្សរ៍ទី៦មុនគ.ស ហើយដែលរាជធានីគេមាន ឈ្មោះថា "រាជបូរី" ។ ឈ្មោះកម្ពុជៈខ្មែរបានគេឆ្លាក់ទុកជាលើកទី១ នៅលើសិលាប្រាសាទ "ពោនគរ" ស្រុកចម្ប៉ា នៅឆ្នាំ៨១៧ ដែល សព្វថ្ងៃមានឈ្មោះយួនថា ញ៉ាត្រាង ។

ចិនជូតាក្វាន់ ដែលមកនៅក្រុងអង្គរពីឆ្នាំ ១២៩៦ - ១២៩៧ ក៏បានឃើញថា នគរខ្មែរនេះមិនមែនមានឈ្មោះចិនឡាផងដែរ ។ លោកបានសរសេរថា ៖ អ្នកស្រុកបានហៅថានគរ "**កាន្ពុជៈ**"[*] ហើយក្នុងសៀវភៅធម៌នគរទីបេ ក៏បាននិយាយដែរថានគរនេះមាន ឈ្មោះ "**កាន្ពុជិ**" ឬ "**កាន្ពុជេ**" ។ បញ្ជាប់សេចក្ដីទៅចិនឡាមិនមែន ឈ្មោះពិតប្រាកដរបស់នគរខ្មែរនេះទេ ។ **នគរនេះឈ្មោះ កម្ពុជៈ** ។ ពាក្យខ្មែរសម័យគេថានគរ ឬ ព្រះរាជាណាចក្រកម្ពុជា ។

---

[*] កាន្ពុជៈ ដែលគេអានថាកាន្ពុជៈ នេះគឺជាត្រឹមត្រូវ ពីព្រោះភាសាសំស្ក្រឹត ឬបាលីស្រះ "ាំ" គេអាន "អាំង" ដូចជាពុទ្ធំ សរណំ គេអានថា ពុទ្ធាំង សារណាំង មិនមែនពុទ្ធម សារណម ទេ ។

www.elibraryofcambodia.org

www.elibraryofcambodia.org

## វគ្គទី ៦

# លីវយី សោមា និង សន្លឹកសូល

ប្រវត្តិសាស្ត្រខ្មែរឲ្យយើងដឹងថាមហាក្សត្រីទី ១ របស់យើងមានព្រះនាម "**លីវយី**" ពេលខ្លះទៀតគេហៅថា "ក្សត្រី **សោមា**" ។ នៅស្រុកបារាំងអ្នកប្រាជ្ញល្បីល្បាញរបស់គេនិយាយថា ក្សត្រី "**សន្លឹក សូល**" ដោយគេមានជំនឿច្រើនទៅលើអ្នកប្រាជ្ញទាំងនោះ ពាក្យលីវយីក៏បានគេយកមកប្រើសព្វសាយពេញសកលលោក ។

យើងឃើញថាជាប្រយោជន៍មួយដែរ បើយើងយករឿងនេះមកពិនិត្យ ឲ្យដឹងថាកំណើតរបស់ខ្មែរនោះនៅត្រង់ណា ។ គេបានដឹងស្គាល់ប្រវត្តិសាស្ត្រខ្មែរជំនាន់ដើមដោយសារការសរសេរកត់ទុកក្នុងក្បួនព្រះរាជវង្សមហាក្សត្រចិនចាប់តាំងពីសតវត្សរ៍ទី២ ទី៣ ក្រោយពីបេសកកម្មរបស់ "កាំងតាយ" និង "ជូយីង" ដែលបានមកសំណាក់នៅ ស្រុកខ្មែរពីឆ្នាំ ២៤៥ ដល់ ២៥០ ។ អ្នកទាំងពីរនេះបាននិទានក្នុងសៀវភៅ "ក្បិនធូ" ថាកាលដើមបង្អស់ក្សត្រស្រុកខ្មែរជាស្ត្រីមួយ មានឈ្មោះកាលនៅវ័យក្មេងជា "**យីលីយូ**" ។

www.elibraryofcambodia.org

មហាក្សត្រីខ្មែរមានព្រះនាម "យីលីយូ" ។ សំនួរដែលមាន គឺថាពាក្យនេះជាពាក្យចិន ឬមួយពាក្យចម្លងតាមសម្លេងភាសាខ្មែរ ? លោកប៉ូលប៉េឡិយ៉ោត៍ អ្នកជំនាញខាងភាសាចិននៅស្រុកបារាំង យល់ថា ពាក្យនេះជាពាក្យចិន មិនមែនជាពាក្យខ្មែរទេ ហើយគេបកប្រែមកដូចតទៅ ៖ យ៉ី=សូល និង លីយូ=ស្លឹក ។ លីយីយូប្រែមកថា "សូលស្លឹក" ។ អ្នកស្រីបារាំង អ.ប៉ុរ៉េម៉ាស្ប៉េរ៉ូ[១] សរសេរថា "សូលស្លឹក" នេះមិនសមរម្យទេ ត្រូវសរសេរថា **"ស្លឹកសូល"** វិញទើបមានន័យជាង ។ ស្លឹកសូលគឺ លីយូយី ដែលគេសរសេរសំរួលជា **"លីវយី"** តែម្តងទៅ ។ ដោយសារតែអ្នកស្រី ម៉ាស្ប៉េរ៉ូ យល់ថាមិនសម ខ្មែរយើងក៏បានមហាក្សត្រីមួយព្រះនាម "លីវយី" រហូតមកទៅ ។ សព្វថ្ងៃនៅគ្រប់ប្រទេស គេនិយាយថាមហាក្សត្រីខ្មែរដំបូងគឺ "លីវយី" ។ អ្នកប្រាជបារាំង គ.សឺដែស[២] ឲ្យឈ្មោះមហាក្សត្រីខ្មែរជា **"ស្លឹកដូង"** ដោយឥតមានបង្ហាញថាពាក្យនេះមកពីណា ឬក៏មានន័យដោយហេតុអ្វីនោះទៀតផង ។

ចំណោទមួយទៀត គឺថាស្រុកខ្មែរឥតមានដើមសូលទេ ។ ចិនជួតាក្វាន់បានសរសេរដូច្នេះដែរ ។ គេពិបាកជឿណាស់ថាក្សត្រីមានព្រះនាមជា "ស្លឹកសូល" ក្នុងនគរមួយដែលគេមិនស្គាល់ ថាសូលនោះជាដូចម្តេចផង ។ តាមការពិតពាក្យដែលចិនសរសេរថា "យីលីយូ" នេះ គឺមកពីពាក្យខ្មែរ **"យាយលីវ"** ។ ចិនអានពាក្យយាយមិនបាន ក៏និយាយថាយីទៅវិញ ។ ពាក្យយាយមានភាព

---

[១] E. Porée Maspéro : Etudes sur les rites agraires des Cambodgiens. Paris Lahaye Mouton et Cie, 3T. p. 795.

[២] G. Cœdès, op.cit. p.76.

www.elibraryofcambodia.org

គោរពត្រឹមត្រូវតាមទំនៀមទំលាប់ខ្មែរ ដែលគេគោរពមេគោរពបា ស្របទៅតាមតម្រា "**មត្តេយ្យកា**" ។ ពាក្យ "លីវ" គឺមកពីមហាក្សត្រី នៅលីវនៅឡើយ ដូចដែលចិនបានសំគាល់មកដែរ ។ ម្យ៉ាងទៀត គេត្រូវចាំថា ខ្មែរមិនហៅឲ្យចំឈ្មោះអ្នកណាដែលមានភាពធំជាង ខ្លួនគេនោះទេ ពីព្រោះជាសេចក្ដីគោរព ។ ហៅឈ្មោះអ្នកមានថ្នាក់ ខ្ពស់ជាង ក៏ដូចជាការមើលងាយដល់អ្នកនោះដែរ ។ ខ្មែរមិនដែល ហ៊ានហៅស្ដេចនរោត្តមសីហនុដូច្នេះទេ គេប្រើពាក្យសម្ដេចឪ ឬ សម្ដេចតាទៅវិញ ។ ពាក្យ "យាយលីវ" ដែលខ្មែរដាក់ឲ្យព្រះមហា ក្សត្រីខ្មែរ គឺជាការត្រឹមត្រូវជាទីបំផុត ។

ព្រះមហាក្សត្រីខ្មែរនេះមានព្រះនាមជា "សោមា" ឬ "សោមៈ" ដែរ ។ ឈ្មោះនេះជាឈ្មោះមួយយ៉ាងល្បីល្បាញ យ៉ាងអស្ចារ្យ ជា ឈ្មោះមួយសម្រាប់សម្គាល់ពូជពង្សក្សត្រខ្មែរទាំងអស់ រហូតមក ដល់ពេលបាត់បង់អង្គរតែម្ដង ដូចគេបានឃើញតាមចារឹក នៅ ប្រាសាទបក្សីចាំក្រុងរបស់មហាក្សត្ររាជិន្ទ្រវរ្ម័នក្នុងឆ្នាំ ៩៤៧ ។ ប្រសើរទៅទៀតឈ្មោះសោមា ក៏ជាឈ្មោះសំគាល់ពូជពង្សក្សត្រ ចាមដែរ ចាប់ពីស្ដេច **ប្រកាសធមិវិក្រាន្តវរ្ម័ន** មក ។ ចារឹកថ្មទាម ឆ្នាំ ៦៥៨ នៅមីសើងខាងត្បូងក្រុងដាណាំង ឲ្យដឹងថាមហាក្សត្រនេះ បានចុះមកពីពូជពង្សក្សត្រីសោមា ដោយសារថាព្រះមាតារបស់ ព្រះអង្គ គឺក្សត្រីខ្មែរ "**សារវ វណ្ណិ**" បុត្រីមហាក្សត្រខ្មែរឥសាណវរ្ម័ន ទី១ ។

សោមាជាឈ្មោះមហាក្សត្រីខ្មែរ ក្រោយពីព្រះអង្គបាន អភិសេកជាអគ្គមហេសីស្ដេចកៅណ្ឌិន្យ ហើយជាពាក្យសំស្ក្រឹត មានន័យជាព្រះច័ន្ទ ដែលជាអវតាព្រះក្រិស្ណ ។ ក្រិស្ណ ជាអវតាព្រះ

www.elibraryofcambodia.org

វិស្ណុ ហៅថា ព្រះនារាយណ៍ ។ ប៉ុន្តែទោះបីជាកៅណ្ឌិន្យបានទៅជាក្សត្រខ្មែរ ហើយព្រហ្មញ្ញសាសនាបានទៅជាសាសនានគរខ្មែរក៏ដោយ មហាក្សត្រីសោមានៅតែជាអ្នកបង្កើតព្រះរាជវង្សខ្មែរថ្មីឈ្មោះ "សោមា វាំង្សា" ឬ ពូជពង្សព្រះច័ន្ទ ។

បញ្ចប់សេចក្តីទៅ គេឃើញថាព្រះនាមមហាក្សត្រីទី១ របស់ខ្មែរមិនមែន "យីលីយូ" ឬ "លីវយី" ឬ "ស្លឹកសូល" នោះទេ ។ ហៅមហាក្សត្រីខ្មែរថា"ស្លឹកដូង" ដោយឥតហេតុឥតផលមិនមែនជាការសមរម្យអ្វីទាំងអស់ ។

-ព្រះនាមព្រះអង្គ ដែលប្រជារាស្ត្រនិយមប្រើគឺ "**យាយលីវ**"
-ព្រះនាមព្រះអង្គពេលសោយរាជ្យជាមួយស្តេចកៅណ្ឌិន្យគឺ "**សោមា**"
-ព្រះនាមព្រះអង្គកាលនៅលីវនោះជាអ្វីទៅ ? នេះគឺជាការសម្ងាត់មួយរបស់ខ្មែរ

www.elibraryofcambodia.org

## វគ្គទី ៧

# មាតេ្តយ្យកាខ្មែរ

មាតេ្តយ្យកាគឺ របបដែលទុកម្តាយឬស្ត្រីជាធំ ទុកម្តាយឬស្ត្រីជាអ្នកដឹកនាំ ។ បើតាមភាសាធម្មតាគេអាចថា "**មាតានិយម**" ដែរដូចគេនិយាយថារាជានិយម ដែលមានព្រះរាជា ឬស្តេច ជាអ្នកត្រួតត្រានោះឯង ។

អ្នកខ្លះស្មានថា នេះគ្រាន់តែជាសិទ្ធិមួយ អនុញ្ញាតឲ្យស្ត្រីមានសេរីភាពជ្រើសរើសរកគូស្នេហារបស់ខ្លួនតែប៉ុណ្ណោះ ពីព្រោះគេឃើញប្រទេសខ្លះដូច "ទីបេ" ជាដើម ស្ត្រីម្នាក់ៗ អាចមានប្តីច្រើនបាន ។ នៅរដ្ឋខ្លះ នៅឥណ្ឌាការប្រព្រឹត្តរបៀបនេះ ឥតមានជាការប្លែកអ្វីទេ ។ ក្នុងរឿងព្រេងក្លិង្គ "មហាភារតៈ" នាង "ទ្រៅបតី" មានប្តី៥ ដែលជាបងប្អូនបង្កើតឈ្មោះ "បាណ្ឌវៈ" ។ ក្លិង្គទុកការនេះជាការធម្មតាទាំងអស់ ។ នៅស្រុកខ្មែរវិញ ស្ត្រីឥតមានប្តីច្រើនជាមួយគ្នាទេ តែសេរីភាពសំរាប់ស្ត្រីមានច្រើន រហូតដល់សតវត្សរ៍ទី ១៤ ។ "ជូតាក្វាន់[១]" ដែលមកក្រុងអង្គរ កាលឆ្នាំ១២៩៦ បានសរសេរថា

---

[១] Tcheou Ta Kouan : op.cit. p. 17.

www.elibraryofcambodia.org

"ក្នុងគ្រួសារខ្មែរ កាលណាមានកូនស្រីមួយបានកើតមក ឪពុកនិងម្តាយកូននោះ មិនដែលភ្លេចបន់ស្រន់ឲ្យកូនថា **សុំឲ្យកូនទៅថ្ងៃក្រោយមានប្តីបានរាប់រយ រាប់ពាន់នាក់កុំឲ្យខាន**" ។

មត្តេយ្យកាខ្មែរ មិនមែនគ្រាន់ជាសេរីភាពរបស់ស្ត្រីខ្មែរប៉ុណ្ណោះទេ ។ មត្តេយ្យកាខ្មែរ គឺរបបសង្គមខ្មែរតាំងពីកំណើតរបស់ខ្មែរមកម្ល៉េះ ។ ខ្មែរបានទទួលរបបនេះជាមរតកពីជីដូនជីតាគេមកគឺជនជាតិ មុណ្ឌៈ ។ មត្តេយ្យកាខ្មែរ ផ្អែកទៅលើការដឹងគុណ និងគោរព "មេបា" គឺម្តាយនិងឪពុក ។ មត្តេយ្យកាខ្មែរមិនគ្រាន់តែជារបបគ្រប់គ្រងរដ្ឋទេ គឺជាមនោគមវិជ្ជារបស់ជាតិខ្មែរទាំងមូល ។ នៅស្រុកខ្មែរ ស្ត្រីឬម្តាយមានលក្ខណៈខ្ពង់ខ្ពស់ហើយធំជាងគេនៅគ្រប់កន្លែង ។ ចំពោះខ្មែរ ម្តាយជាមេដឹកនាំ ម្តាយជាមហាក្សត្រ ម្តាយជាព្រះទៀតផង ។

## ១. ម្តាយជាមេដឹកនាំ

ខ្មែរហៅម្តាយជា "មេ" ហើយក្នុងសង្គមខ្មែរម្តាយជាអ្នកដឹកនាំ ។ ដើម្បីកុំឲ្យខ្មែរទាំងអស់គ្នាភ្លេចថាម្តាយជាអ្នកដឹកនាំ គេឲ្យឈ្មោះម្តាយថា "មេ" តែម្តង ។ សព្វថ្ងៃពាក្យ "មេ" មានន័យពីរ ៖ មួយគឺមេជាម្តាយ មួយទៀតមេជាអ្នកដឹកនាំ ឬអ្នកត្រួតត្រា ។ ន័យទីមួយគេឃើញក្នុងពាក្យលោក "មេ" មេគង្គ (គង្គា=ទឹក ) មេមាន់ ។ ន័យទីពីរគេឃើញក្នុងពាក្យមេទ័ព មេស្រុក មេភូមិ មេឃ្លាំង ...ល ។ ម្យ៉ាងទៀតដើម្បីនឹងឲ្យខ្មែរកុំភ្លេចថាម្តាយ(មេ) ជាអ្នកដឹកនាំ គេឲ្យខ្មែរហៅខ្លួនឯងថា "ខ្មែរ" ( ខ + មេ + រ ) ប្រែមកថាអ្នកដែលនៅក្រោមអំណាចមេ (ម្តាយ) ។ របៀបធ្វើតាមចិត្តសាស្ត្រ នាំឲ្យខ្មែរទុក

www.elibraryofcambodia.org

ខ្លួននៅក្រោមបង្គាប់គេ ហើយដែលពេលខ្លះគេហៅថាលាងខួរក្បាលនោះ មិនមែនជាការម្ងួយប្លែកទេ ។ តាំងពីជំនាន់មុណ្ឌៈមកខ្មែរប្រើពាក្យ "អាញ់" សម្រាប់ហៅខ្លួនឯង ។ ពាក្យនេះគេនៅប្រើនៅឡើយកាលជំនាន់អង្គរ ។ ដល់ពេលដែលព្រះពុទ្ធសាសនាថេរវាទ ឬហីនយានបានទៅជាសាសនារដ្ឋ គេឲ្យខ្មែរហៅខ្លួនឯងថា "ខ្ញុំ" វិញ ឯខ្ញុំក៏មានន័យ ថាជាអ្នកបំរើគេដែរ ។ ព្រះសង្ឃខ្មែរឥតប្រើពាក្យខ្ញុំទេ គេនិយាយថា "អត្មា" វិញ ដែលជាពាក្យសំស្ក្រឹតមានន័យថាខ្លួនឯង ។

## ២. ម្តាយជាមហាក្សត្រី

របបនយោបាយខ្មែរកាលពីដើមមក គឺរបបរាជានិយមដែលមានមហាក្សត្រីជាអ្នកគ្រប់គ្រង ស្របតមរបៀបមត្តេយ្យការបស់ជាតិមុណ្ឌៈ ។ គេឥតបានដឹងប្រវត្តិសាស្ត្ររបស់ព្រះមហាក្សត្រីខ្មែរទាំងអស់នោះទេ តែគេបានដឹងច្បាស់អំពីមហាក្សត្រីចុងក្រោយបង្អស់ដែលនៅសោយរាជ្យនៅឡើយកាលឆ្នាំ៥០ ក្នុង គ.ស ហើយដែលប្រជាពលរដ្ឋខ្មែរឲ្យព្រះនាមជា "យាយលីវ" ។ គឺយាយលីវនេះហើយ ដែលអ្នកប្រាជ្ញបារាំងហៅដោយភាពច្រឡំថា "លីវយី ឬសន្លឹកស្វូល" ដែលលោកសើដែស ដាក់ឈ្មោះដោយខ្លួនឯងថា "សន្លឹកដូង" (!) ។

ទោះបីជាព្រាហ្មណ៍កៅណ្ឌិន្យ បានទៅជាមហាក្សត្រខ្មែរ និងយាយលីវទៅជាអគ្គមហេសីស្តេចនេះក៏ដោយ ស្ថានភាពស្ត្រីខ្មែរនៅតែខ្ពង់ខ្ពស់ដដែល ហើយរបបមត្តេយ្យកានៅតែមានឫទ្ធានុភាព

www.elibraryofcambodia.org

យ៉ាងច្រើន ។ មិនមែនស្តេចកៅណ្ឌិន្យទេ ដែលជាអ្នកបង្កើតព្រះរាជវង្សថ្មី តឹមហាក្សត្រីយាយលីវដែលជាអ្នកបង្កើតរាជវង្សនេះ មានឈ្មោះថា "សោមា វាំង្សា" តាមព្រះនាមថ្មី "សោមា" របស់ព្រះអង្គ ។

## ៣. ម្តាយជាព្រះមួយរូប

គេដឹងថាខ្មែរដូចជាតិមុណ្ឌៈដែរ ឥតមានសាសនាទេ ឥតមានជំនឿទៅលើព្រះអាទិទេពណាមួយទេ ។ ដូចជាតិមុណ្ឌៈ ខ្មែរ គោរព "ទេព-ព្រះ" គោរព "ទឹក-ដី" និង "អ្នកតា" ។ ដើម្បីឲ្យបានស្របតាមការប្រាជ្ញាស្វែងរកឧត្តមគតិរបស់ប្រជារាស្ត្រ ខ្មែរក៏លើក "មេ-បា" ឡើងដល់លក្ខណៈព្រះតែម្តង ។ ក្នុងន័យនេះ "ម្តាយ" បានគេនិមិត្តរូបជានាង កង្ហីង និង "បា" ឬឪពុក ជា "ក្រពើ" ដែលខ្មែរគោរពស្មើនឹងព្រះ ។ នៅស្រុកខ្មែរគេតំណាងនាងកង្ហីងជាស្ត្រីមួយរូប មានសក់យ៉ាងវែងចុះមកដល់កែងជើង ហើយក្រពើមានរូបជាក្រពើផង និងទង់ផង ដែលគេហៅថា **ទង់ក្រពើ** ។

របបមាតានិយម ឬ មត្តេយ្យកាខ្មែរ ដែលស្ត្រីមានលក្ខណៈជាម្តាយផង ជាមហាក្សត្រីផង និងជាព្រះផង មានភាព ចុះថយបន្តិចម្តងៗ ចាប់តាំងពីវប្បធម៌ពួកក្លិង្គអារ្យ ដែលចូលមកជាមួយនឹងព្រាហ្មណ៍កៅណ្ឌិន្យ ហើយបានបាត់បង់អស់កាលឆ្នាំ ១៣៣៦ ក្រោយពីព្រះ ពុទ្ធសាសនាបានទៅជាសាសនារបស់រដ្ឋខ្មែរ (ខ្មែរឥតមានជាប់ជាតិអ្វីមួយនឹងពួកអារ្យទេ ។ ពួកនេះជាពួកក្លិង្គសដែលមានដើមកំណើតនៅខាងលិចប្រទេស ម៉ុងហ្គោលី ។ គេឲ្យឈ្មោះខ្លួនគេថាអារ្យ ដែលមានន័យថាថ្លៃថ្នូរ ឬខ្ពង់ខ្ពស់) ។

www.elibraryofcambodia.org

ព្រហ្មញ្ញសាសនាបានមកជាសាសនាស្រុកខ្មែរពីឆ្នាំ ៥០ រហូតដល់ឆ្នាំ ១៣៣៦ ។ សាសនានេះឥតមានប្រកាន់អ្វីពីភាពស្ត្រីទេ ។ ផ្ទុយទៅវិញព្រះមួយអង្គៗ ក្នុងសាសនានេះ ទោះជាព្រះព្រហ្ម ព្រះវិស្ណុឬព្រះនារាយណ៍ និងព្រះសីវៈឬព្រះឥសូរ ព្រះអង្គនិមួយៗតែងមាន "មហេសី" មួយឬច្រើន ហែហមតាមព្រះអង្គជានិច្ច ។ ស្ត្រីដែលមានលក្ខណៈជាព្រះ មានច្រើនជាទីបំផុត ដូចជាទេវតា និងទេពអប្សរជាដើម ។ រូបចម្លាក់ទេពអក្សរជាង ២០០០ រូប នៅលើប្រាសាទវិស្ណុលោកៈ (អង្គរវត្ត) ក៏ជាភាពសំរាប់លើកកត្តិយសដល់ស្ត្រីយ៉ាងជាក់ស្តែងមួយដែរ ។

ក្នុងការរស់នៅជារៀងរាល់ថ្ងៃជំនាន់ព្រហ្មញ្ញសាសនា ស្ត្រីខ្មែរនៅមានសេរីភាពជាច្រើន ។ ចិនជូតាក្វាន់[២] បានសរសេរថា ៖ កាលណាគេមានវ័យជំទង់ រួចក្រោយពីបានធ្វើពិធីបុណ្យមួយហៅថា "ឆាន់ទាន" រួចហើយ ស្ត្រីខ្មែរអាចចេញទៅណាមកណាបានតាមចិត្ត ឥតមានអ្នកណាហាមឃាត់ ឬត្រួតត្រាអ្វីឡើយ ។ បុរសជាច្រើន បានរួមរូបកាយជាមួយនាងស្រីទាំងអស់នេះ មុននឹងបានរៀបអាពាហ៍ពិពាហ៍ជាមួយនាង ។ ទំនៀមទំលាប់ខ្មែរឥតទុកការនេះជារឿងអៀនខ្មាស់ ឬជារឿងអ្វីឲ្យជាការងឿងឆ្ងល់នោះទេ ។

ព្រាហ្មណ៍កៅណ្ឌិន្យ ដែលបានឡើងជាមហាក្សត្រស្រុកខ្មែរ ហើយដែលបានទុក "យាយលីវ" ជាអគ្គមហេសី បង្ហាញឲ្យឃើញថាព្រះអង្គមានបញ្ញាវាងវៃត្រឹមត្រូវជាទីបំផុត ពីព្រោះយាយលីវនៅលើព្រះរាជបល្ល័ង្គ គឺនិមិត្តរូបរបបមាតានិយម ចំពោះភ្នែក

---

[២] Tcheou Ta Kouan : Traduit par Paul Pelliot, op. cit. p. 18.

www.elibraryofcambodia.org

ប្រជារាស្ត្រខ្មែរ ។ ១៣ សតវត្សរ៍ [illegible] ស្តេចខ្មែរនៅ
តែថែរក្សា ទុកភាពបរកាយខ្លួន [illegible] ដូចជា [illegible]
បាតជើងពណ៌ក្រហម ដែល [illegible]
ដូចជាទុកក្នុងសក់លំអនឹងផ្កា [illegible] ឬ
សត្វត្រី ហើយនឹងប្រើភាសា [illegible] ដូចជាពាក្យ "[illegible]" ជំនួស
ពាក្យ "បាទ" ...ល ។ ក្នុងព្រះរាជវាំង [illegible]
ព្រះមហាក្សត្រចំនួន ៤០០ នាក់ [illegible]
អ្នកបំរើផ្សេងៗ ចំនួន ៤០០០ នាក់ នោះដែរ ។ សភាពទាំងអស់នេះ
គឺសម្រាប់ញេញបង្ហាញ ឲ្យប្រជារាស្ត្រឃើញថាអ្នកដឹកនាំនគរខ្មែរ
នៅតែគោរពរបបមាតានិយមរបស់ខ្មែរ ។

ព្រះពុទ្ធសាសនា បានទៅជាសាសនារដ្ឋខ្មែរចាប់ពីឆ្នាំ
**១៣៣៦** ។ ព្រហ្មញ្ញសាសនាដែលមានបរាជ័យត្រូវគេរំលាយចោល
ឥតមានសល់ ។ ព្រាហ្មណ៍ទាំងឡាយត្រូវគេសម្លាប់ ឬរត់ខ្ចាត់ខ្ចាយ
ឆ្ងាយពីប្រទេស ។ ចាប់ពីពេលនេះទៅដែរ ស្ថានភាពស្ត្រីឥតបាន
ដូចពីដើមទេ ។ ចំពោះព្រះពុទ្ធសាសនា ស្ត្រីជាដើមកំណើត ជាឫ
សគល់នៃការចំណង់ពុះពារ នៃ"តណ្ហា" ហើយតណ្ហាជាឫសគល់នូវ
"ទុក្ខ" ទាំងឡាយរបស់មនុស្សលោក ដែលគេត្រូវបោះបង់ចោល
ដែលគេត្រូវតែកំចាត់ជាដាច់ខាត ។ គេដឹងថានៅក្នុងវិន័យព្រះពុទ្ធ
សាសនា ភិក្ខុសង្ឃឥតមានច្បាប់សម្លឹងមើលស្ត្រីទេ ។ នៅក្នុង
សៀវភៅព្រះ ពុទ្ធសាសនាទាំងឡាយ គេសង្កេតឃើញថា ស្ត្រីឥត
បានគេលើកតម្លៃ ឬគោរពប៉ុន្មានដែរ ។ លោក **ហែរម៉ាណ្ណអូលដែន**

www.elibraryofcambodia.org

បែរត៍[៣] បាន សរសេរថា ៖ "ការបោកប្រាស់ ការរៀចបន្លំរបស់ស្ត្រី បានគេយកមកនិទានយ៉ាងច្រើន ក្នុងសៀវភៅទាក់ទងនឹងព្រះពុទ្ធសាសនា ហើយក្នុងសៀវភៅមួយនោះគេនិយាយថា សារៈជាតិរបស់ស្ត្រីមានភាពងងឹតកំបាំងដូចផ្លូវរបស់សត្វត្រីនៅក្នុងទឹក ។ ស្ត្រីជាចោរពោរពេញដោយគំនិតខិលខូច ដែលគេពិបាកនឹងជឿបាន ។ ចំពោះស្ត្រីការពិតក៏ដូចជាការភូតភរ ការភូតភរក៏ដូចជាការពិត... ។ល។"

ចំពោះមុខយោបល់លើស្ត្រីរបៀបនេះ គេយល់ច្បាស់ថា ហេតុអ្វីបានជាស្ត្រីខ្មែរបាត់អស់ឋានៈខ្ពង់ខ្ពស់របស់ខ្លួន ។ ដោយហេតុនេះឯង បានជារបបមាតានិយមរលត់បាត់បង់ពីជីវភាពសង្គមខ្មែរអស់រហូតមកពីពេលនោះតែម្តង។

---

[៣] Hermann Oldenberg : Bouddha , vie et religion. Ed. Jean de Bonnot. Paris 1998. p.201.

www.elibraryofcambodia.org

www.elibraryofcambodia.org

## វគ្គទី ៨

# លក្ខណៈពិសេសរបស់ខ្មែរ

នៅបរទេសគេកោតសរសើរខ្មែរ ដោយសារភាពល្អអស្ចារ្យ និងភាពធំត្រដែតរបស់ប្រាសាទអង្គរ ។ ប្រហែលជាគេកោតសរសើរខ្មែរដែរ ដោយសារខ្មែរមានវប្បធម៌ធំទូលាយ និងវិជ្ជាសិល្បៈយ៉ាងប៉ិនប្រសប់ ។ ប៉ុន្តែដែលគេមិនបានដឹង គឺថាខ្មែរមានលក្ខណៈពិសេស[១] របស់ខ្លួនដោយដាច់ឡែក ហើយប្លែកខុសគេ ។ ច្រើនសតវត្សរ៍មុនគ្រិស្តសាសនា ច្រើនសតវត្សរ៍មុនពេលក្លិង្គ និងវប្បធម៌ក្លិង្គអារ្យចូលមក សង្គមខ្មែរមានការរៀបចំយ៉ាងល្អិតល្អន់សមរម្យតាមគុណសម្បត្តិយ៉ាងខ្ពង់ខ្ពស់រួចហើយ ។ គំនិតខ្មែរបានគេយកមកពិចារណា រែកញែក និងទុកដាក់សម្រាប់ប្រតិបត្តិយ៉ាងហ្មត់ចត់ ។ គំនិតខ្មែរទាំងអស់ ខុសពីគំនិតអ្នកជិតខាងនៅពេលនោះ គឺក្លិង្គនិងចិន ។ និយាយឲ្យពិតទៅទៀត គំនិតខ្មែរខុសពីនគរផ្សេងៗទាំងអស់ក្នុងពិភពលោក ។ គេអាចឃើញលក្ខណៈពិសេសខ្មែរជាឧទាហរណ៍ ក្នុងចំណោះវិជ្ជា ៣ គឺ ៖

---

[១] សមត្ថភាពដែលអាចបង្កើតអ្វីៗដែលល្អ ហើយដែលខុសពីគេ

www.elibraryofcambodia.org

- គណិតសាស្ត្រ
- បរមត្ថវិជ្ជា
- សាសនា

## ១. គណិតវិជ្ជា

គឺវិទ្យាសាស្ត្រសិក្សាខាងលេខ និងការគិតគូរ កាត់វាស់ ។ លេខគឺតួអក្សរដែលសម្រាប់សរសេរ សំគាល់ចំនួន ។ លេខមានភាពខុសគ្នា តាមប្រជាជាតិនិមួយៗ ។ ជាតិបារាំងឥតមានលេខយកមកប្រើទេ ។ គេស្គាល់លេខ 1 2 3 4 5 6 7 8 9 ។ នេះគឺលេខរបស់សាសន៍អារ៉ាប់ ។ លេខសូន្យ "0" ជាលេខក្លឹង្គ ហើយកាលដំបូងគេតំណាង និងចំណុចមួយ "•" ហៅថា ពិន្ទុ (ល.រើណូ)[២] ។ គឺក្រោយមកទេ ដែលគេសរសេរជារង្វង់តូចមួយ "0" ដូចសព្វថ្ងៃ ។ សាសន៍រ៉ូមាំងប្រើលេខ ៧ គឺ I = ១ V=៥ X=១០ L = ៥០ C = ១០០ D = ៥០០ M = ១០០០ ។ គេសរសេរលេខ ១ = I ២ = II ៣ = III ៤ = IV ៥ = V ៦ = VI ៧ = VII ៨ = VIII ៩ = IX ១០ = X ....។ល។ ដើម្បីរាប់អ្វីមួយ ប្រជាជាតិសឹងតែទាំងអស់ប្រើរបៀបសំអាងទៅលើចំនួន ១០ ។ ១ គឺ ១ ភាគ ១០ និង ២ គឺ ២ ភាគ ១០ ហើយលេខគុណលើ ១០ មាន = ២០, ៣០, ៤០, ៥០, ៦០, ៧០....។ល ។ ក្លឹង្គនិងចិន រាប់ចំនួនសំអាងទៅលើ ១០ ដែរ ។

លេខខ្មែរមានតែ ៥ ទេ គឺ ១ ២ ៣ ៤ ៥ ។ លេខសូន្យ "0" ខ្មែរក៏បានមកពីក្លឹង្គដែរ ។ ខ្មែររាប់ថា មួយ = ១ ពីរ= ២ បី= ៣

---

[២] Louis Renou et Jean Filliozat : L'Inde classique. Manuel des études indiennes. EFEO Tome 2. Paris 2000, p.703.

www.elibraryofcambodia.org

បួន = ៤ ប្រាំ = ៥ ហើយ ប្រាំមួយ = ៥+ ១ ប្រាំពីរ=៥+ ២ ប្រាំបី = ៥ + ៣ ប្រាំបួន = ៥ + ៤ ។

ចិនផូតាក្វាន់បានសំគាល់ឃើញថា ការរាប់របស់ខ្មែរខុសពីចិននេះដែរ ។

## ២. បរមត្ថវិជ្ជា

គឺវិជ្ជាសាស្ត្រសិក្សាពីដើមហេតុដំបូង ដែលបង្កើតលោកយើងមក មានការសិក្សាពីព្រលឹងចិត្ត ពីព្រះអាទិទេព ពីជីវិតមនុស្សក្រោយពីស្លាប់ទៅ ....ល ។ មានតែជាតិដែលមានសេចក្តីជឿនលឿនទេ ដែលទុកពេលវេលាសម្រាប់សិក្សាវិជ្ជាផ្នែកខាងនេះ ។ ជាតិដែលពុំសូវបានជឿនលឿន ជឿតែត្រឹមអារក្ស អ្នកតា ឬអ្វីៗបន្តិចបន្តួចតែប៉ុណ្ណោះ ។

ខ្មែរជឿថាមាន "ព្រលឹង" ។ នេះមិនមែនជាការអ្វីឲ្យប្លែកពេកនោះទេ ពីព្រោះមានជាតិច្រើនណាស់ ដែលមានជំនឿយ៉ាងដូច្នេះ ។ ការដែលខ្មែរឥតមានដូចគេ គឺត្រង់ថាព្រលឹងនៅត្រង់កន្លែងណាទៅវិញទេ ។

ពួកសាសន៍អេហ្ស៊ីប (Egypte) ជឿថាព្រលឹងនៅក្នុងបេះដូង ។ ដោយហេតុនេះហើយ បានជានៅក្នុងសាជីជ្រុង ដែលជាផ្នូរឬម៉ុងខ្មោចមហាក្សត្រគេ ពួកអេហ្ស៊ីបគេដាក់បេះដូងក្សត្រក្នុងកែវមួយ នៅជិតរូបកាយព្រះមហាក្សត្រនោះ ។ ការធ្វើដូច្នេះមានន័យថា កាលណាក្សត្រនោះឡើងទៅលើមេឃ ព្រលឹងព្រះអង្គ ក៏អាចទៅតាមបាន ។ ជនជាតិក្លឹង្គ ហើយនឹងសាសន៍អឺរ៉ុប គេជឿថា

www.elibraryofcambodia.org

ព្រលឹងឋិតនៅក្នុងបេះដូងដែរ ។ នៅស្រុកបារាំង កាលពួកអ្នកបដិវត្តន៍កាត់ករស្ដេច "ល្វីទី១៦" ឆ្នាំ ១៧៨៩ គេក៏បានយកបេះដូងស្ដេចនេះដាក់ទុកក្នុងកែវមួយដែរ ។ ធ្វើរបៀបនេះ បានសេចក្ដីថា គេបានសង្គ្រោះព្រលឹងព្រះអង្គ ឲ្យបានចេញផុតពីការគ្រោះថ្នាក់ ។

ជនជាតិនៅកោះ "ប៉ាក់" (Pâques) កណ្ដាលមហាសមុទ្រ "ប៉ាស៊ីហ្វិក" ជឿថាព្រលឹងនៅក្នុងក្បាល ។ នៅពេលចម្បាំងគេកាត់ក្បាលរូបថ្មចម្លាក់ព្រះរបស់សត្រូវគេអស់ ។ ធ្វើនេះគឺមានន័យថា គេសម្លាប់ព្រលឹង របស់ព្រះពួកសត្រូវគេ ។

**ខ្មែរយល់ថាព្រលឹងឋិតនៅក្នុងថ្លើម** ។ មានតែខ្មែរទេ ដែលយល់យ៉ាងដូច្នេះ នៅក្នុងពិភពលោកយើងនេះ ។ កាលណាខ្មែរស្រឡាញ់អ្នកណាមួយខ្លាំង គេហៅអ្នកនេះថា "អាថ្លើម" ដូចបារាំងគេហៅអ្នកដែលគេស្រឡាញ់ថា "បេះដូង" គេនោះដែរ ។ ខ្មែរនិយាយថា ចិត្តមួយ-ថ្លើមមួយ ឲ្យដឹងថាគេមានមិត្តភាពខ្លាំងចំពោះអ្នកណាមួយ ។ ក្នុងភាសាខ្មែរ ពាក្យថ្លើមបានគេប្រើច្រើនដូចជា ៖

- ចិត្តមួយ-ថ្លើមមួយ = មិត្តភាពខ្លាំង
- អត់ថ្លើម = អត់ចិត្ត ឬអត់បេះដូង
- ថ្លើមធំ = ព្រហើន
- ថ្លើមខ្មៅ = ចិត្តអាក្រក់
- លូកថ្លើម = ប៉ះពាល់ដល់កិត្តិយស
- ស៊ីថ្លើម = សម្លាប់

ពាក្យថា "ស៊ីថ្លើម" នាំឲ្យអ្នកណាដែលមិនស្គាល់វប្បធម៌ខ្មែរច្បាស់លាស់ យល់ច្រឡំច្រើន ។ កាលសង្គ្រាមឆ្នាំ ១៩៧០-១៩៧៥

www.elibraryofcambodia.org

ទាហានខ្មែរមានវះពោះសត្រូវដែលគេបាញ់សម្លាប់ យកថ្លើមមួយដុំមកបរិភោគ ។ អ្នកសារព័ត៌មានអឺរ៉ុប ស្រែកឡើងថាខ្មែរជាអ្នកស៊ីសាច់មនុស្ស ។ ការពិតខ្មែរមិនមែនជាអ្នកស៊ីសាច់មនុស្សទេ ។ ទាហានស៊ីថ្លើមសត្រូវ មានន័យថាគេសម្លាប់ព្រលឹងសត្រូវគេ មុននោះគេបានសម្លាប់ "ខ្លួនកាយ" នឹងគ្រាប់កាំភ្លើងរបស់គេ ។ ស៊ីថ្លើមរបៀបនេះ ជាការមិនល្អមួយហើយ ប៉ុន្តែមិនមែនជាសេចក្តីស៊ីសាច់មនុស្សគ្នាឯងនោះឡើយ ។

## ៣. សាសនា

ខ្មែរមានជំនឿផ្ទាល់របស់ខ្លួន ។ ការសំខាន់គឺ ខ្មែរឥតជឿទៅលើព្រះអាទិទេពអ្វីណាមួយឡើយ ។ ព្រហ្មញ្ញសាសនា ដែលគ្របលើស្រុកខ្មែរ តាំងពីសតវត្សរ៍ទី ១ រហូតដល់សតវត្សរ៍ទី ១៣ ក៏មិនមែនជាសាសនារបស់ខ្មែរទេ គឺ ជាសាសនារបស់ ពួកភ្ញៀវអារ្យ ដែលចូលមកស្រុកខ្មែរកាលឆ្នាំ ៥០ ជាមួយព្រាហ្មណ៍ កៅណ្ឌិន្យ ។ ព្រះពុទ្ធសាសនា ក៏មិនមែនសាសនារបស់ខ្មែរដែរ គឺជាសាសនាភ្ញៀវអារ្យ ដូចព្រហ្មញ្ញសាសនា ។ ព្រះពុទ្ធសាសនាផ្នែកថេរវាទ ឬហីនយានបានទៅជាសាសនារដ្ឋខ្មែរ ជាសិទ្ធិដាច់មុខចាប់ពីឆ្នាំ **១៣៣៦** គឺក្នុងសតវត្សរ៍ទី ១៤ ។

ជំនឿខ្មែរមានភាពផ្អែកទៅលើសេចក្តីដឹងគុណចំពោះអ្នកមានគុណលើខ្លួនឯងទេ មិនមែនសំអាងទៅលើសេចក្តីគោរពដល់ព្រះណាមួយ ដើម្បីឲ្យព្រលឹងបានចេញផុតពីផលអាក្រក់ដូចនៅក្នុងសាសនាទូទៅនោះឡើយ ។ ក្នុងភាពនេះខ្មែរមានរក្សាការបូជាថ្វាយ ៖

www.elibraryofcambodia.org

- មេ-បា គឺជាម្ដាយនិងឪពុក
- ព្រះធរណី ឬដី ហើយនិងទឹក ដែលខ្មែរទុកនាងកង្ហីង និងក្រពើជានិមិត្តរូប
- អ្នកតាដែលជាអ្នកជួយការពារដល់ខ្មែរ

សព្វថ្ងៃនេះក៏ដោយ ការបូជាថ្វាយទៅដល់អ្នកមានគុណលើខ្មែរនេះ ឥតមានសាបសូន្យអ្វីពីដួងចិត្តខ្មែរទេ គ្រាន់តែគេប្រព្រឹត្តទៅក្នុងរបៀបជាផ្ទាល់ខ្លួន ក្នុងភាពសម្បូណ៌ហូរហៀរពាសពេញរបស់ព្រះពុទ្ធសាសនា ។

www.elibraryofcambodia.org

## វគ្គទី ៩

# ជំនឿខ្មែរ

ជាតិមុណ្ឌៈ កាន់របបមាតានិយម គោរពព្រះធរណី និងទឹក ហើយមានជំនឿលើអ្នកតា ។ ខ្មែរ ដែលចុះមកពីជាតិមុណ្ឌៈក៏រក្សាជំនឿទាំង ៣ នេះដែរ ។ សព្វថ្ងៃខ្មែរនៅមានការបូជាគោរពដល់ ៖

- មេ-បា
- នាងកង្ហីង និងក្រពើ
- អ្នកតា

### ១. ការគោរពមេ-បា

តាមពាក្យខ្មែរ "មេ" គឺម្ដាយ ហើយ "បា" គឺឪពុក ។ ការបូជាគោរពមេ-បា គឺដូចជាការគោរពម្ដាយនិងឪពុក ដែលបានផ្ដល់ជីវិតឲ្យខ្មែរទាំងអស់គ្នា ។ ចិនច្រឡំហើយសរសេរថា ខ្មែរបូជាគោរពជីដូនជីតាដូចចិនដែរ តែការពិតមិនមែនដូចគ្នាទាំងអស់ទេ ។

ខ្មែរកាន់ប្រពៃណីគោរព "មេ-បា" តាំងតែពីដើមកំណើត

www.elibraryofcambodia.org

របស់ខ្លួន គឺតាំងពីច្រើនរយសតវត្សរ៍មកហើយ ។ គេបានឃើញរួចថា តាមរបបមាតានិយម អ្វីៗដែលធំជាងគេ ឬនៅខ្ពស់ជាងគេ គេឲ្យឈ្មោះថា "មេ" ទាំងអស់ ។ ពាក្យ "បា" វិញ គេបានឲ្យទៅភ្នំនានា ដូចភ្នំបាខែង ភ្នំបាដែង ឬ បាភ្នំ ....ល ។ សព្វថ្ងៃខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា ប៉ុន្តែគេសំគាល់ឃើញថាឥតមានពេលបុណ្យទានណាមួយដែលខ្មែរមិនរំលឹកដល់គុណ "មេ និងបា" នោះទេ ។

គេឥតបានដឹងប្រាកដ អំពីរបៀបរៀបចំសំរាប់ធ្វើការបូជាគោរពមេបាឡើយ ប៉ុន្តែគេដឹងថាមានអ្នកពិសេស ដើម្បីរៀបចំបុណ្យថ្វាយមេបា គឺ "**តាជី**" និង "**យាយជី**" ។ អ្នកទាំងនេះមានសំលៀកបំពាក់ពណ៌ស ។ សព្វថ្ងៃគេនៅឃើញ "យាយជី" នៅតាមវត្តអារាមនានាដែរ តែយាយជីនេះគ្រាន់តែជាអ្នកជួយក្នុងកិច្ចការផ្សេងៗដល់ព្រះ សង្ឃតែប៉ុណ្ណោះ ហើយដែលជាការមួយឥតមានទាក់ទងអ្វីនឹងរឿងគោរពមេបារបស់ខ្មែរកាលដំបូងនោះឡើយ ។

## ២. ការបូជាគោរពនាងកង្ហីង និងក្រពើ

មានរឿងព្រេងខ្មែរមួយនិទានថា ៖ "កាលពីដើមប្រវត្តិសាស្ត្ររបស់មនុស្ស នៅលើផែនដីយើងមានសុទ្ធតែទឹកទេ ។ ថ្ងៃមួយ**នាងកង្ហីង** ដែលរស់ក្នុងបាតសមុទ្រយ៉ាងជ្រៅចេញមកឈរលើ**ក្រពើ**មួយឲ្យផុតពីរលក ហើយក៏បង្វិលគ្រវីសក់ នាំឲ្យបង្កើតបានដីដើម្បីឲ្យមនុស្សទាំងអស់ដែលមានខ្មែរដែរ អាចរស់នៅបានរហូតដល់សព្វថ្ងៃ ។ គូនេះ ខ្មែរហៅថា ៖ "នាងកង្ហីង-ក្រពើ" ដែលគេមិន

www.elibraryofcambodia.org

# នាងកង្កីង និង ក្រពើ



www.elibraryofcambodia.org

បំបែកចេញពីគ្នាទេ ហើយខ្មែរគោរពស្មើនឹងព្រះ ។ នាងកង្ហីង ដែលបានបង្កើតជីតី ព្រះធរណី ឯក្រពើវិញ គឺព្រះតំណាងទឹក ។ ខ្មែរទុកនាងកង្ហីងជា "មេ" ហើយក្រពើជា "បា" ។

ក្នុងការរស់នៅរៀងរាល់ថ្ងៃ គេតំណាងនាងកង្ហីងជារូបស្ត្រីម្នាក់មានសក់វែងធ្លាក់មកដល់កែងជើងនាង ឯក្រពើវិញមានរូបជាសត្វក្រពើដដែល ។ នៅស្រុកខ្មែរសព្វថ្ងៃ គេឃើញគូ "នាងកង្ហីងក្រពើ" នេះនៅគ្រប់ទីកន្លែងជារូបចម្លាក់ ឬជាគំនូរសិល្បៈគ្រប់បែបយ៉ាង ។

ក្រពើបានគេតំណាងជាទង់ដែរ ដែលមានរូបរាងប្រហែលនឹងសត្វក្រពើ ហើយមានពណ៌ផ្សេងៗយ៉ាងប្លែកៗ ។ ខ្មែរឲ្យឈ្មោះទង់នេះថា **"ទង់ក្រពើ"** ។ សព្វថ្ងៃគេអាចឃើញទ្រង់ក្រពើនៅគ្រប់កន្លែងទាំងអស់ ជាពិសេសនៅកន្លែងកាន់ សាសនាផ្សេងៗទោះជាព្រហ្មញ្ញសាសនា ឬព្រះពុទ្ធសាសនា ឬសាសនាណាមួយទៀតក៏ដោយ ។ ទង់ក្រពើមានឈ្មោះមួយទៀតដែរគឺ **"ទង់រលក"** ដែលជាឈ្មោះរំឭកឲ្យដឹងថាក្រពើជាព្រះ តំណាងទឹក ។

នៅតាមភូមិស្រុកនានា ខ្មែរតែងតែលើកទង់ក្រពើមួយមានពណ៌ "ស" នៅមុខផ្ទះដែលមានអ្នកស្លាប់ នេះបង្ហាញឲ្យដឹងថាព្រលឹងអ្នកស្លាប់បានចេញទៅតាមទង់នេះហើយ ទៅតាម "បា" គឺឪពុករបស់គេ ។ ដោយហេតុនេះដែរ បានជាគេឲ្យឈ្មោះទង់ក្រពើថា **"ទង់ព្រលឹង"** ទៀត ។ អ្នកខ្លះ ហៅទង់នេះថា **"ទង់ខ្មោច"** ដោយ

www.elibraryofcambodia.org

# ទង់ក្រពើ



នៅពេលហែរកឋិន តាមប្រពៃណី

ព្រះពុទ្ធសាសនា

www.elibraryofcambodia.org

សារមានខ្មោច គឺអ្នកស្លាប់នៅពេលនោះ ។ ពាក្យ "ទង់ខ្មោច" ពុំសូវបានគេយកមកប្រើទេ ដោយហេតុថាពាក្យខ្មោចមានភាពមិនល្អ ឬមានទុក្ខព្រួយ ។ ពាក្យទង់ខ្មោចនេះ ប្រហែលជាអ្នកសត្រូវនាងកង្ហីង-ក្រពើ គេដាក់ឲ្យទេ ។

ព្រះពុទ្ធសាសនា ក្រោយពីបានបំបាត់ព្រហ្មញ្ញសាសនាចេញពីស្រុកខ្មែរ ក៏ប្រឹងប្រែងធ្វើឲ្យ "នាងកង្ហីង-ក្រពើ" ដែលខ្មែរគោរពស្មើនឹងព្រះ មានភាពអាប់អោន កុំឲ្យខ្មែរគោរពតទៅទៀត ។ ក្នុងភាសាអ្នកកាន់ព្រះពុទ្ធសាសនា ក្រពើត្រឡប់ទៅជានិមិត្តរូប ជាតំណាងការក្បត់ក្បែរ និងការអកតញ្ញូទៅវិញ ។ កាលណាគេនិយាយថាអ្នកណាជា "ក្រពើ" គឺអ្នកនោះជាមនុស្សក្បត់ និងរមិលគុណហើយ ។

នាងកង្ហីងដែលគេបំបែកចេញពីក្រពើ មានព្រេងវាសនាមួយផ្សេង ដោយគេបង្កើតរឿងព្រេងថានាងកង្ហីងបានជួយព្រះពុទ្ធកាលមារមកផ្ចាញ់ផ្ចាល ។ ក្នុងរឿងមួយដែលមានចំណងជើងថា "ការទាញចិត្តឲ្យទៅផ្លូវខុស" (ល.រើណូ)[9] គេនិយាយថា ៖ "ដើម្បីនឹងធ្វើកុំឲ្យព្រះពុទ្ធបានត្រាស់ទៅនិព្វាន មារដណ្ដើមយកកៅអីធំដែលព្រះអង្គគង់សំណាក់ត្រិះរិះពិចារណាធម៌អារ រួចមារហៅឲ្យទាហានកងទ័ពខ្លួន មកធ្វើជាសាក្សី ថាកៅអីនោះជារបស់គេ ។ ព្រះពុទ្ធមានតែម្នាក់ឯង ព្រះអង្គក៏ចង្អុលទៅព្រះធរណី សុំឲ្យធ្វើសាក្សីព្រះអង្គ ។ ពេលនោះ ព្រះធរណីញ័ររង្គើឡើងយ៉ាងរន្ធត់ ទទូលធ្វើ

---

[9] Louis Renou et Jean Filliozat, op.cit. p. 476.

www.elibraryofcambodia.org

# ឈោខកខ្ម័ខ



ព្រះឡូឃអង្គ ក្នុងចំណោម ព្រះពុទ្ធទាំងឡាយនៅវត្តខ្មែរ

www.elibraryofcambodia.org

ជាសាក្សីឲ្យព្រះពុទ្ធ នាំឲ្យមារមានការភាន់ភ័យតក់ស្លុតយ៉ាងខ្លាំង ហើយទទួលបរាជ័យជាមួយកងទ័ព ដែលបានបែកបាក់ខ្ទេចខ្ទី អស់......" ។

នៅស្រុកខ្មែរ គេទុកព្រះធរណីក្នុងរឿងរបស់ព្រះពុទ្ធសាសនាក្លិង្គនេះជា "នាងកង្ហីង" តែម្តង ។ ដោយហេតុនេះហើយ បានជាអ្នកកាន់ព្រះពុទ្ធសាសនានៅស្រុកខ្មែរ បានរៀបចំរឿងព្រេងនេះ [illegible] ព្រះពុទ្ធទ្រង់ហៅព្រះធរណីមកជួយធ្វើសាក្សី [illegible] ព្រះធរណី ក៏បានចេញមក ហើយគ្រវីសក់ [illegible] ធ្វើឲ្យចេញទឹកពាសពេញរបៀបជោរជន [illegible] អស់តែម្តង ។ មារក៏បានទទួល [illegible]..." (តំ.ឡូវេនស្ទីន)[២] ។

[illegible] ដូច្នេះ នាងកង្ហីងក៏បានខ្មែរគោរព [illegible] នាងកង្ហីងក៏បាត់ថ្នាក់ជាអាទិទេព ដែល [illegible] ក្នុងរឿង "ព្រះពុទ្ធ និងមារ" នាងកង្ហីងរបស់ខ្មែរ [illegible] មិនសមពេកទេ ។ តាមធម្មតានាងកង្ហីងព្រះធរណីបង្កើតដី នៅពេលណាដែលនាងគ្រវីសក់ មិនមែនបង្កើតទឹកទេ ។ គឺដោយធ្វើរបៀបនេះឯង បាននាងកង្ហីងបង្កើតបានដីឲ្យខ្មែររស់នៅ ។ ក្នុងពុទ្ធសាសនាខ្មែរ គោលដៅធំមិនមែននៅត្រង់សម ឬមិនសមទេ គឺនៅត្រង់ ៖

---

២ Tom Loweinstein : L' Eveil de Bouddha. Tashen Gmbh. Köln 2001. p. 21.

www.elibraryofcambodia.org

- ការបំបែកនាងកង្ហីងពីក្រពើ ដែលជាទីគោរពរបស់ខ្មែរ ស្មើនឹងសាសនា ដូច "មេ-បា" ឬ ម្ដាយ និងឪពុក
- ការដាក់នាងកង្ហីង ឲ្យចុះក្នុងឋានៈជាអ្នកគ្រាន់តែបានជួយព្រះពុទ្ធតែប៉ុណ្ណោះ
- ការធ្វើយ៉ាងណា ឲ្យគេទុកព្រះពុទ្ធជាព្រះតែមួយ នៅក្នុងសង្គមខ្មែរ

សម ឬមិនសម មិនជាធំដុំអ្វីទេ ហើយទោះជាយ៉ាងណាក៏ដោយ ខ្មែរទៅ[illegible]ទាំងអស់ ។

## ៣. ការគោរពអ្នកតា

"អ្នកតា" គឺព្រលឹងដែលមាននៅក្នុងដើមឈើធំៗ នៅតាមភ្នំ ឬដែលមាននៅកន្លែងផ្សេងៗ តាមព្រៃ តាមស្រុក ។

គេតំណាងអ្នកតា និងដុំថ្មមួយ ឬច្រើនដុំ ដែលគេដាក់នៅគល់ឈើ នៅជើងភ្នំ ឬនៅកន្លែងណាមួយឆ្ងាយពីផ្ទះរបស់គេ ។ បើយ៉ាងល្អបំផុតគេគ្រាន់តែដំកល់ "ថ្មអ្នកតា" ក្នុងខ្ទមមួយដែលជាសំណង់យ៉ាងសង្ខេប ហើយដែលគេហៅថា "ផ្ទះអ្នកតា" ឬ "ខ្ទមអ្នកតា។

គេនៅចាំបានថា ស្ដេចកៅណ្ឌិន្យបានយល់សប្ដិឃើញមានគេប្រាប់ឲ្យទៅយកធ្នូមួយ នៅក្រោមដើមឈើនៅផ្លូវចូលទៅព្រះវិហារ មុននឹងមកច្បាំងយកបាននគរខ្មែរសោយរាជ្យ ។ ដល់ពេលភ្លាក់ឡើង ព្រាហ្មណ៍កៅណ្ឌិន្យ ក៏បានឃើញធ្នូនោះមែន ។

www.elibraryofcambodia.org

ព្រលឹងដែលនៅក្នុងដើមឈើ ហើយដែលបានឲ្យធ្វទៅកៅល្បិន្យ នេះ គ្មានជាអ្នកណាក្រៅពីអ្នកតាដែលឋិតនៅទីនោះទេ ។

តាមធម្មតាអ្នកតាមានចិត្តល្អណាស់ ។ អ្នកតាការពារអ្នក ស្រុក និងភូមិ តំបន់ទាំងឡាយឲ្យបានសុខសប្បាយ ។ អ្នកតា អាចជួយគេឯងបាន ដោយធ្វើឲ្យការបួងសួងអ្វីៗ ទាំងអស់បាន សេចក្ដីសំរេច ។

អ្នកតាជាព្រលឹងមួយដែលនៅតែមួយកន្លែង ។ អ្នកតា និមួយៗនៅជាប់នឹងកន្លែង ឬខ្ទមរបស់លោកទាំងអស់ ។ អ្នកតាមិន ដែលចាកចេញឆ្ងាយពីកន្លែង ឬខ្ទមលោកទេ ។ បើយើងចង់ជួប អ្នកតា ទាល់តែយើងទៅដល់ខ្ទមរបស់លោក ។

អ្នកតាឆាប់ខឹង ហើយប្រកាន់ចិត្តណាស់ ។ ការទាក់ទង ជាមួយអ្នកតាឥតមានអ្វីពិបាកទេ ។ គេគ្រាន់តែថ្វាយអំណោយ បន្តិចបន្តួចដូចជា បាយ មាន់ស្ងោរ ដូងខ្ចី ចេក ឬនំ និងទៀនធូប នោះគឺបានហើយ ។ ការដែលសំខាន់បង្អស់ គឺគេមិនត្រូវភ្លេចពាក្យ សន្យារបស់គេ ដែលបានធ្វើជាមួយអ្នកតា ។ គេក៏មិនត្រូវមានឫក ពារ ឬសំដីមើលងាយចំអកដល់អ្នកតាដែរ ដូចជាគេសើចនៅពេល ដែលមានអ្នកណាមួយនិយាយកំប្លែងពីអ្នកតា ។ មិនមែនអ្នកដែល កំប្លែងលើអ្នកតា ដែលត្រូវអ្នកតាដាក់ទោសទេ គឺជាអ្នកសើចអំពី រឿងកំប្លែងនោះទៅវិញ ។ ទណ្ឌកម្មអ្នកតាមានតែមួយ គឺធ្វើ ឲ្យចុកពោះប្រកាច់យ៉ាងរន្ធត់ ហើយដែលបាត់ទៅបានលុះណាតែ គេធ្វើកិច្ចបួងសួងមួយសំរាប់លុបលាងទោសកំហុសទាំងនោះ ។ ទោះ ជាយ៉ាងណាក៏ដោយ នេះជារឿងនិទានដែលចាស់បូរាណ បាន ប្រាប់មកដល់ខ្មែរគ្រប់ៗគ្នា ។

www.elibraryofcambodia.org

## វគ្គទី ១០

# សាសនាក្លិង្គនៅស្រុកខ្មែរ

គេនៅចាំបានថាខ្មែរដែលចុះមកពីពូជមណ្ឌៈ ឥតមានសាសនា ឬជំនឿទៅលើព្រះអាទិទេពណាមួយទេ ។ សាសនាផ្សេងៗ ដែលចូលមកស្រុកខ្មែរ **គឺជាសាសនាក្លិង្គទាំងអស់** ។ សាសនាក្លិង្គនេះមានជាពិសេស ៣ ៖ សាសនាវេទ ព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា ។

### ១. សាសនាវេទ

នេះគឺជាសាសនាមុនគេបង្អស់ ដែលកើតឡើងនៅស្រុកក្លិង្គ រវាង ១៥ សតវត្សរ៍ មុនគ.ស ។ កាលដំបូងអ្វីៗ ដែលមានភាពសំខាន់ក្នុងលោកគឺជា "ព្រះ" ទាំងអស់ ។ ទឹក ដី ភ្លើង ខ្យល់ ព្រះអាទិត្យ ព្រះច័ន្ទ ........ល ។ គឺសុទ្ធតែជាព្រះ ។ ហេតុដូច្នេះហើយបានជាព្រះក្នុងសាសនាវេទមានច្រើនណាស់ គេមិនអាចស្គាល់ អស់បានទេ ។ អ្នកដែលមានជំនឿ [illegible]ឯថា មានព្រះ

www.elibraryofcambodia.org

ដល់ ទៅ៣០០០០០ អង្គផង (ប.បូជួង)[១] ។ ប៉ុន្តែព្រះធំៗមានតែ **៣៣** អង្គគត់ ។ ព្រះធំៗ គឺព្រះឥន្ទ្រ ព្រះអគ្និឬអគ្គី (ភ្លើង) ព្រះអាទិត្យ (ថ្ងៃ) ព្រះច័ន្ទ ឬសោមៈ (លោកខែ) ព្រះវរុណ (ភ្លៀង-ទឹក) ព្រះវាយោ (ខ្យល់) ...ល. ។

**ព្រះឥន្ទ្រ** ជាព្រះធំជាងគេ មានធ្នូជាអាវុធដែលគេហៅថា "ឥន្ទនូរ" អាចបាញ់ឡើងចេញភ្លើង ផ្គរ រន្ទះ ធ្វើឲ្យគេស្ញើបខ្លាចយ៉ាងខ្លាំង ។ ព្រះឥន្ទ្រមានអាវុធមួយទៀត គឺលំពែងធ្មេញ ៣ ហើយគឺព្រះអង្គនេះ ដែលបានទៅព្រះធំជាងគេនៅស្រុកក្រិក មានឈ្មោះថា "ស្ញើស" (Zeus) និងនៅនគរពួករ៉ូម៉ាំងមានឈ្មោះថា "ព្រះហ្ស៊ីពីតែរ៍" (Jupiter) ។

**ព្រះអគ្គី** គឺជាព្រះមួយដែលគេបានគោរពមកជាយូរយារជាងគេ ដោយគេយល់ថាអ្វីៗទាំងអស់ គឺកើតមកពីភ្លើងដែលនៅក្នុងព្រះធរណី ហើយបើឥតមានព្រះអគ្គីទេ គឺឥតមានជីវិតអ្វីមួយនៅលើផែនដីយើងនេះដែរ ។ តាំងពីដើមក្នុងផ្ទះនិមួយៗ គេតែងតែមានចង្ក្រានភ្លើងមួយ ដែលគេដុតរ និងថែទាំមិនឲ្យរលត់ ។ ក្នុងភាសាបារាំង ទីលំនៅគេក៏មានន័យថា ចង្ក្រាន (Foyer) ដែរ រួចកាលណាគេនិយាយថាគេត្រឡប់ទៅ "ចង្ក្រាន" គឺថាគេត្រឡប់ទៅផ្ទះគេហើយ ។ ភាពនេះគឺជាសំណល់ពីសាសនាវេទ ។ ពួកក្លិង្គដែលក្រោយមក បានកាន់ព្រហ្មញ្ញសាសនា មិនបោះបង់ចោលសាសនាវេទទាំងអស់ទេ ។ **ខ្មែរក៏មានកាន់សាសនាវេទដែរ** ។ ខ្មែរគោរពព្រះឥន្ទ្រ នៅទុកថ្ងៃនិងលោកខែជាព្រះ ហើយគេ

---

[១] Bernard Baudouin : Le Védisme. Ed. De Vecchi. Italie 1997. p. 49.

www.elibraryofcambodia.org

និយាយថា ព្រះអាទិត្យនិងព្រះច័ន្ទ ។ ក្នុងពេលបុណ្យទាន ខ្មែរច្រើន រំឭកដឹងគុណព្រះ មេ បា និង មហាចង្ក្រាន ដែលជាព្រះអគ្គី ឬព្រះភ្លើងនេះឯង ។ អ្នកកាន់សាសនាវេទយល់ទៀតថា ព្រះអគ្គីដែលបង្កើតយើងមក លោកក៏យកយើងត្រឡប់ទៅវិញ នៅពេលដែលយើងស្លាប់ទៅដែរ ។ ការដែលគេដុតទៀនឬធូប គឺគេយកព្រះភ្លើងមកគោរព មិនមែនយកទៀន ឬធូបមកថ្វាយព្រះទេ ។ ពេលស្លាប់ ខ្មែរច្រើនយកសពទៅបូជា[*] មានន័យថាយកសពថ្វាយព្រះភ្លើង ។ សពដែលរលាយអស់ទៅបានន័យថា ព្រះលេបយកអស់ទៅវិញ

សាសនាវេទ ជឿថាមានព្រលឹងដែលអាចកើតឡើងវិញបាន ។ កាលណាគេធ្វើអាក្រក់ គេត្រូវកើតនៅជាតិក្រោយ ដើម្បីនឹងលាងលប់កម្មពៀររបស់គេ ។ គោលសេចក្ដី ៣ គឺ ព្រលឹង កម្មពៀរ និងការកើតបន្តៗ ដែលគេហៅថា "**សំសារ**" នោះ គឺសាសនាវេទ ដែលជាអ្នកបង្កើតមកទាំងអស់ ។

## ២. ព្រហ្មញ្ញសាសនា

ព្រហ្មញ្ញសាសនាមិនមែនជាសាសនាក្លិង្គថ្មីអ្វីពេកទេ គឺគ្រាន់តែជាសាសនាវេទ ដែលបានក្លាយរូបបន្ដិចម្ដងៗ ក្នុងរយៈពេល ១០០០ ឆ្នាំ ។ សាសនានេះ នៅរក្សាគំនិតធំៗ របស់សាសនាវេទ ដូចជាការទទួលស្គាល់ ព្រលឹង កម្មពៀរ និងភាពសំសរ ។

---

[*] ពាក្យបូជា មានន័យដើមថាឆាន់ ហូប ពិសា... មិនមែនថ្វាយព្រះទេ ហើយព្រះក្លិង្គចេះឆាន់ទាំងអស់ ដូចមនុស្សយើងដែរ។

www.elibraryofcambodia.org

ព្រហ្មញ្ញសាសនា នៅតែទទួលស្គាល់ថា មានព្រះច្រើនអង្គ ។ ព្រះធំៗមាន ៣ គឺ ព្រះព្រហ្ម ព្រះវិស្ណុឬនារាយណ៍ ព្រះសិវៈឬព្រះឥសូរ ដែលគេហៅថា "ត្រីមូតិ" ប្រែមកថា សភាព ៣ របស់ព្រះធំតែមួយ ។ មនុស្សទូទៅអាចគោរពព្រះមួយអង្គណាក៏បាន ពីព្រោះសំរេចទៅ គឺនៅតែព្រះដដែលដែរ ។ ព្រះវិស្ណុទៀតក៏មានប្រែក្លាយខ្លួនជារូបភាពផ្សេងៗ តាមកាលៈទេសៈ ដើម្បីនឹងបំពេញ "កិច្ចការ" អ្វីមួយ ហើយដែលគេហៅថា "**អវតារ**" ដូចជា **ក្រិស្ណ** ឬមនុស្សខ្មៅ **ព្រះរាម** ក្នុងរឿងរាមកេរ្តិ៍ **វរហ** ជ្រូកព្រៃ **កូមីរ** អណ្តើកទ្រភ្នំមន្ទារៈ **មត្សយៈ** ឬត្រីមច្ឆា ដែលជួយមនុស្សឲ្យចេញផុតពីទឹកជំនន់ **វាមនៈ**ឬមនុស្សតឿ ...ល ។ ក្រៅពីព្រះធំ ៣ អង្គនេះ មានព្រះផ្សេងៗយ៉ាងច្រើនទៀត ។ លក្ខណៈមួយដ៏ល្អរបស់ព្រហ្មញ្ញសាសនា គឺការអត់ឱនរបស់គេ គឺគេមិនទៅរំខានអ្វីដល់សាសនាផ្សេងៗ ដែលមាននៅជាមួយគ្នានោះទេ ។ កាលពេលដែលព្រហ្មញ្ញសាសនា មានភាពជាសាសនារដ្ឋរបស់ខ្មែរ គឺពីសតវត្សរ៍ទី ១ ទៅដល់សតវត្សរ៍ទី ១៤ ព្រះពុទ្ធសាសនា មានសេរីភាពយ៉ាងពេញលេញក្នុងស្រុកខ្មែរដែរ ។

ក្បួនគម្ពីរព្រហ្មញ្ញសាសនា គឺ "**គម្ពីរវេទ**" ដែលគេយកមកពីសាសនាវេទ ។ វេទ មកពីពាក្យ **វិទ** (វិទ្យ-វិទ្យា-វិទ្យាសាស្ត្រ) មានន័យថា "ការចេះដឹង" ។ វេទជាក្បួនគម្ពីរមួយខុសពីក្បួនសាសនាផ្សេងៗទាំងអស់ ទោះជាសាសនាណាក៏ដោយ ពីព្រោះការចេះដឹងដែលគេបង្ហាញក្នុងគម្ពីរនោះ មិនមែនមានតែការចេះដឹងសម្រាប់បូជា ថ្វាយព្រះ ឬទៅតាមព្រះទេ គឺមានការចេះដឹងទូទៅទាំងអស់ ដូចជានិតិសាស្ត្រឬវិទ្យាសាស្ត្រខាងច្បាប់ វិជ្ជាពេទ្យ

www.elibraryofcambodia.org

វេយ្យាករណ៍ គណិតសាស្ត្រ នយោបាយ .....ល. ។ **ព្រហ្មញ្ញសាសនាទទួលស្គាល់សភាពរដ្ឋ** ហើយបែងចែកមនុស្សក្នុងសង្គមជា ៤ វណ្ណៈ តាមមុខងាររបស់ក្រុមនិមួយៗ ។

ខាងផ្លូវចិត្តសាស្ត្រ គេបានឃើញហើយ ថាមានព្រលឹងកម្មពៀរ ដែលធ្វើឲ្យគេត្រូវកើតម្តងទៀត ដើម្បីលាងចេញឲ្យអស់ការ "បាប" ទើបគេអាចទៅដល់ "និព្វាន" ។ ដើម្បីទៅដល់ឋាននេះទៀត គេត្រូវគោរពបូជាថ្វាយព្រះនូវរបស់វត្ថុផ្សេងៗតាមរយៈព្រាហ្មណ៍ ។ **គេទៅដល់ឋានៈនិព្វាន កាលណាគេបានទៅដល់ឋានព្រះ ឬទៅដល់ព្រះបាទព្រះ ។**

## ៣. ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាមានកំណើតឡើង នៅស្រុកក្លិង្គក្នុងសតវត្សរ៍ទី ៦ មុនគ.ស ។ សព្វថ្ងៃបាន ២៥៥២ ឆ្នាំ ។ សាសនានេះក៏ចេញមកពីក្លិង្គ "អារ្យ" ដែរ នៅនគរ "កបិលពស្តុ" ជិតនគរនេប៉ាល់ពេលបច្ចុប្បន្ន ។ **ព្រះពុទ្ធ** អ្នកបង្កើតសាសនានេះ ជាព្រះរាជបុត្រពូជ "សាក្យៈ" មាននាមដើមថា "សិទ្ធត្ថ" កើតឆ្នាំ ៥៦៥ មុន គ.ស ហើយសុគតនៅឆ្នាំ ៤៨៦ មុន គ.ស ។

ព្រះពុទ្ធសាសនា សំអាងទៅលើគោលគំនិតដំបូងមួយធំគឺថា អ្វីៗក៏ដោយ ក៏ជាសេចក្តី "**ទុក្ខ**" ទាំងអស់ ៖ កើតមកក៏ជាទុក្ខ ចាស់ទៅជាទុក្ខ មានជម្ងឺជាទុក្ខ ស្លាប់ទៅជាទុក្ខ រួបរួមជាមួយអ្នកដែលគេមិនស្រឡាញ់ក៏ជាទុក្ខ និងឃ្លាតពីអ្វីដែលគេស្រឡាញ់ក៏ជាទុក្ខដែរ ។ ដើមហេតុនៃសេចក្តីទុក្ខទាំងអស់គឺ "**តណ្ហា**" គឺ

www.elibraryofcambodia.org

**ការស្រេកឃ្លាន ឬការចង់បានខ្លាំង** ។ គំនិតធំមួយទៀតគឺ ជំនឿថា មានកម្មពៀរ ហើយមនុស្សម្នាក់ៗ ត្រូវតែកើតឡើងជាតិក្រោយ ដើម្បីលប់លាងកម្មពៀររបស់ខ្លួន ។ នេះគឺទ្រឹស្តី "កម្ម សំសារ" ដែលព្រះពុទ្ធសាសនាយកមកពីព្រហ្មញ្ញសាសនា ដែលព្រហ្មញ្ញសាសនាយកមកពីសាសនា "វេទ" ហើយទោះជាព្រះពុទ្ធសាសនា មិនជឿថាមានព្រលឹងក៏ដោយ ។ **ព្រះពុទ្ធសាសនាឥតទទួលស្គាល់ថាមានព្រះអាទិទេពអ្វីមួយទេ** ។ ព្រះពុទ្ធអង្គខ្លួនឯងក៏មិនមែនព្រះអាទិទេពដែរ ។ ការដែលទៅបន់ស្រន់ព្រះពុទ្ធ ជាការឥតប្រយោជន៍សុទ្ធសាធ ។ ពេលជិតសុគត ដោយឃើញអានន្ទព្រួយ ហើយនិយាយថា "បន្តិចទៀតនេះយើងអស់មានព្រះគ្រូហើយ" ព្រះអង្គបន្ទូលថា "កុំនិយាយថាយើងឥតមានគ្រូ គឺព្រះធម៌នេះហើយ ដែលជាព្រះគ្រូឯង មិនមែនអញទេ" (ហ្ស-ម៉ាស្សុង)[២] ។ កាន់ព្រះពុទ្ធសាសនាបានន័យថា គោរពនិងប្រតិបត្តិតាមព្រះធម៌ដែលព្រះពុទ្ធបានបង្រៀនប្រដៅ និងទុកមកឲ្យ ។

គោលដៅតែមួយរបស់ព្រះពុទ្ធសាសនា គឺនាំឲ្យមនុស្សអាចចៀសផុតពី "ទុក្ខ" ។ ដោយសារថា "តណ្ហា" ជាឫសកែវ ជាដើមហេតុរបស់សេចក្តីទុក្ខទាំងអស់ គេអាចចៀសផុតពីទុក្ខបានលុះណាគេលប់ចោលតណ្ហារបស់គេបាន ។ ការដែលលប់តណ្ហាបានឬមិនបាន គឺអាស្រ័យលើកំលាំងចិត្តរបស់មនុស្សម្នាក់ៗទេ ឥតមានអ្នកណាអាចធ្វើជំនួសបានឡើយ ។ ត្រង់នេះហើយដែលមានអ្នកខ្លះយល់ច្រឡំ ហើយនិយាយថា "ខ្លួនទីពឹងខ្លួន" ហាក់ដូចជា

---

[២] Joseph Masson : Le Bouddhisme . Declée de Brouwer. Belgique 1975. p. 69.

www.elibraryofcambodia.org

អត់មានអ្នកណាមួយមកជួយគេបាន ។ ព្រះពុទ្ធគ្រាន់តែបង្ហាញផ្លូវឲ្យមនុស្សលោកចេញផុតពីទុក្ខទេ ។ ផ្លូវនោះគឺ "មគ្គៈ" ៨ យ៉ាង ៖

១- ការឃើញត្រូវ (សម្មាទិដ្ឋិ)
២- ការត្រិះរិះត្រូវ (សម្មាសង្កប្បៈ)
៣- វាចាត្រឹមត្រូវ (សម្មាវាចា)
៤- ការធ្វើត្រឹមត្រូវ (សម្មាកម្មន្ត)
៥- មធ្យោបាយរស់នៅត្រឹមត្រូវ (សម្មាអាជីវៈ)
៦- ការប្រឹងប្រែងត្រឹមត្រូវ(សម្មាវាយាម)
៧- សតិត្រឹមត្រូវ (សម្មាសតិ)
៨- ធ្វើសមាធិត្រឹមត្រូវ (សម្មាសមាធិ)

មគ្គៈ ៣ ដំបូងនាំទៅសភាពបញ្ញា ។ មគ្គៈ ២ បន្ទាប់មកនាំទៅដល់**សិល** ។ មគ្គៈ ៣ ចុងក្រោយ **គឺផ្លូវសមាធិ** ។ ព្រះពុទ្ធសាសនាទុកលោកយើងជា "ផ្ទះមួយកំពុងមានភ្លើងឆេះ" គេត្រូវគេចចេញ ហើយលះបង់កម្មសិទ្ធិទាំងអស់ ព្រមទាំងការអាពាហ៍ពិពាហ៍ទៀតផង ។ ការដែលប្រសើរបំផុត គឺត្រូវទៅជាភិក្ខុសង្ឃ ដែលបានបោះបង់ចោលនូវផ្ទះសម្បែង ទ្រព្យសម្បត្តិ គ្រួសារ សំលៀកបំពាក់ រហូតដល់ឈ្មោះត្រកូលផងទៀត ហើយទៅរស់នៅតាមរបៀបអ្នកសុំទាន ដែលគេហៅថា "បិណ្ឌបាត" (ភិក្ខុ ប្រែមកថា អ្នកសុំទាន) ។ ព្រះពុទ្ធមានបំណងជួយដល់មនុស្សលោកទាំងអស់ ឥតគិតថា សាសនាណា ជាតិណា ឬកុលសម្ព័ន្ធណាមួយទេ ។ ផ្ទុយនឹងព្រហ្មញ្ញសាសនា **ព្រះពុទ្ធសាសនាឥត**

www.elibraryofcambodia.org

ទទួលស្គាល់ស្រុកទេស ឬនគរអ្វីមួយទាំងអស់ ហើយដែលគេត្រូវ
បោះបង់ចោលជាមួយនឹង-លោក-យើងតែម្តង។

www.elibraryofcambodia.org

## វគ្គទី ១១

# ទេវរាជ

**ទេវរាជ = ស្ដេចជាព្រះ**

ពាក្យសំស្ក្រឹត "ទេវ" ប្រែថា "ព្រះ" និង "រាជ" មានន័យថាស្ដេច ។ ទេវរាជគឺ "ស្ដេចជាព្រះ" ។ គេអាចយល់បានថាមនុស្សណាក់ដោយ បើមិនបានទៅជាព្រះ ក៏ចង់[illegible] ជិតព្រះដែរ ដើម្បីឲ្យ បានការគ្របដណ្ដប់ពីព្រះអង្គ ។

ពីសតវត្សរ៍ទី ១ រហូតដល់សតវត្សរ៍ទី ១៥ [illegible] ខ្មែរសុទ្ធតែជាក្លឹង្គ ឬចុះមកពីពូជពង្សក្លឹង្គទាំងអស់ ។ [illegible] ចំរដ្ឋ គឺធ្វើតាមរបៀបក្លឹង្គ សាសនា[illegible] ហើយ[illegible] គឺជាព្រហ្មញ្ញសាសនា ។ ស្ដេចខ្មែរ[illegible] ព្រះមួយអង្គមកធ្វើជាព្រះផ្ទាល់ខ្លួនរបស់[illegible] ។ [illegible] យកព្រះនាមព្រះនេះ ធ្វើជា[illegible] ដោយមានបន្ថែមពាក្យ "វរ្ម័ន" ពីខាងក្រោយ ។ បើគេ[illegible] គេដាក់ឈ្មោះគេថា "ឥន្ទ្រវរ្ម័ន" ។ [illegible] "វរ + ម៉ាន" [illegible] វរ គឺការពារ និងម៉ាន គឺមនុស្ស [illegible] មិនមែនពាក្យសំស្ក្រឹតទេ ។ [illegible] ។

www.elibraryofcambodia.org

ឥន្ទ្រវរ្ម័ណ មានន័យថាមនុស្សដែលមានព្រះឥន្ទ្រការពារ ។ ដូចគ្នានេះដែរ សូរិយវរ្ម័ន គឺមនុស្សដែលមានព្រះសូរិយា ឬព្រះអាទិត្យការពារ ។ កាលជំនាន់ ព្រហ្មញ្ញសាសនា នៅស្រុកខ្មែរគេគោរពព្រះយ៉ាងខ្លាំងជាទីបំផុត ។ **មហាក្សត្រខ្មែរ ពិតមែនតែមានឋានៈជាទេវរាជមិនមែនជាព្រះទេ** ។ ព្រះនាមស្តេចជាម៉ាន បង្ហាញឲ្យឃើញច្បាស់ថាគេជាមនុស្សសោះ ហើយមានន័យធំគឺ គេនៅក្រោមថ្នាក់ព្រះទាំងអស់ ។

ព្រះសិវៈបានស្តេចខ្មែរច្រើនយកមកដាក់ជាព្រះនាមខ្លួន ។ ខ្មែរហៅ ព្រះសិវៈថា "ព្រះឥស្វរ" តែទោះសិវៈ ឬឥស្វរក្តី ឈ្មោះនេះមិនមែនឈ្មោះមែនទែនរបស់ព្រះអង្គទេ ។ សិវៈគ្រាន់តែមានន័យថា "អនុគ្រោះ" ឬ "កុសល" តែប៉ុណ្ណោះ នាមដើមព្រះអង្គគឺ "អាន" ។ ដោយគេគោរពខ្លាំង គេមិនហ៊ានហៅឈ្មោះ "អាន" ទេ ហើយគេឲ្យឈ្មោះផ្សេងៗច្រើន ដូចជាឥសាណ ស្រុទៈ រាជិន្ទ្រ មហិន្ទ្រ ...ល ។ ស្តេចខ្មែរក៏មាននាមជា ឥសាណវរ្ម័ន ស្រុទវរ្ម័ន រាជិន្ទ្រវរ្ម័ន និងមហិន្ទ្រវរ្ម័នដែរ ។

ក្រៅពីព្រះនាមព្រះ ស្តេចខ្មែរបានយកឈ្មោះផ្សេងៗ ទៀត ដែលមានគុណសម្បត្តិធំៗ មកដាក់ជាព្រះនាមព្រះអង្គ ដូចពាក្យ ជ័យ ពាវៈ ជ្រេស្ថៈ .....ដែលប្រែថា ជំនះក្នុងសង្គ្រាម អត្ថិភាព និងវណ្ណៈល្អ ....ល ។ ដោយហេតុនេះឯង បានជាស្តេចខ្មែរមានព្រះនាមថា ជ័យវរ្ម័ន ជ្រេស្ថវរ្ម័ន ពាវវរ្ម័ន ....ល ។

ឈ្មោះមហាក្សត្រខ្មែរទាំងអស់នេះទៀត ក៏មានគេប្រើនៅស្រុកក្លឹង្គក្នុងពូជពង្សស្តេចគុប្តៈ និង នគរវិជ័យៈ ហើយនៅនគរ

www.elibraryofcambodia.org

ផ្សេងៗ ដែលកាន់វប្បធម៌ក្លឹង្គ ដូចស្រុកចម្ប៉ា និងស្រុកឥណ្ឌូណេស៊ី ជាដើម ។

**ទេវរាជ = ស្ដេចជាព្រះ**

ក្នុងព្រហ្មញ្ញសាសនា ព្រះជាអ្នកគ្រប់គ្រងលើអ្វីៗទាំងអស់ ក្នុងសកលលោកទាំងមូល ។ ស្ដេចខ្មែរក៏មានបំណងចង់សោយរាជ្យក្នុងសកលលោកទាំងមូលដែរ ។ ការនេះអាចពន្យល់បានខ្លះ ថាមកពីហេតុនេះហើយ បានជាស្រុកខ្មែរឥតមានព្រំដែនទេ ដូចសកលលោកដែលឥតមានបន្ទាត់ខណ្ឌនោះឯង ។

នៅឆ្នាំ ៨០២ មហាក្សត្រជ័យវរ្ម័នទី ២ បានប្រកាសជាឱឡារិក ក្នុងពិធីបុណ្យមួយយ៉ាងធំថា ព្រះអង្គជា**ចក្រវាទិន** (ចក្រវទិន បានឲ្យពាក្យខ្មែរថាចក្រពត្តិ ដែលគេប្រែថាអ្នកអាណានិគមទៅវិញ ?) គឺជាស្ដេចលើសកលលោកទាំងមូល ។ ពិធីនេះគេធ្វើឡើងនៅលើភ្នំមហិន្ទ្របវត្ត (មហិន្ទ្រ = សិវៈ បវត្ត = ភ្នំ) ដែលសព្វថ្ងៃគេហៅថាភ្នំគូលែន ។ ចក្រប្រែមកថាកង់ ហើយ ចក្រវាទិន គឺជាអ្នកបង្វិលកង់ព្រះធម៌ របស់ព្រហ្មញ្ញសាសនានោះឯង ។

ជ័យវរ្ម័នទី ២ មិនមែនជាក្សត្រដែលមានឋានៈដ៏ធំខ្លាំងនេះតែម្នាក់ឯងទេ ។ ស្ដេចខ្មែរនៅអង្គរបូរី ក៏មានឋានៈរបៀបនេះដែរ ។ ស្ដេចរុទ្រវរ្ម័ន បានគេហៅថា "សារវភូម" គឺក្សត្រក្នុងសកលទាំងមូល ដូចដែលគេបានឃើញនៅលើចម្លាក់ចារឹកថ្មនៅមាត់ទន្លេ "មូណា" ខាងកើតស្រុកសៀម ។ តែចក្រវាទិនមុនដំបូងគេបង្អស់គឺ

www.elibraryofcambodia.org

ស្តេចក្លឹង្គ ឈ្មោះភរត្ត បុត្រាស្តេច ឬសភ អ្នកបង្កើតសាសនា "**ជេន**" (Jaïnisme) ដែលបានផ្តើមគំនិត "**អហិង្សា**" ឬ **សន្តិវិធី** ។

**ទេវរាជ = ស្តេចជាព្រះ**

ផ្ទៃរឿងទី ២ ជាមហាក្សត្រដំបូង ដែលមានឋានៈជា "ទេវរាជ" ។ លោក "ក្លូតហ្សាក់"[៧] បានប្រែមកថា "ព្រះជាស្តេច" ហើយអ្នកប្រាជ្ញបារាំងជាច្រើន បានសរសេរថា នៅស្រុកខ្មែរជំនាន់នោះគេទុកស្តេចជាព្រះអាទិទេព ។ ពាក្យនេះធ្វើឲ្យអ្នកទូទៅ ដែលមិនស្គាល់ច្បាស់នូវវប្បធម៌ខ្មែរក្នុង របបព្រហ្មញ្ញសាសនា យល់ខុសថាព្រះមហាក្សត្រខ្មែរមាន អំណាចផ្តាច់ការ ហើយធ្វើអ្វីៗបានតាមចិត្ត ។ គេបានឃើញហើយ ថាព្រះនាមស្តេចនីមួយៗ មានជាប់ពាក្យ "ម៉ាន" បង្ហាញឲ្យដឹងថា ស្តេចជាមនុស្សទេ ហើយគ្រាន់តែមានឋានៈជាព្រះតែប៉ុណ្ណោះ ។ **ការគោរពបូជាស្តេចស្មើនឹងព្រះ (Culte du Dieu-Roi) ឥតមាននៅ ជំនាន់នោះទេ** ។ តាមន័យពាក្យខ្មែរ ស្តេចជា "ទេវរាជ" គឺថាស្តេចមានដើមកំណើតជាប់ជាតិ និងព្រះអាទិទេពតែប៉ុណ្ណោះ ។ ស្តេចបានគេគោរពដូចព្រះ **តែស្តេចមិនមែនព្រះទេ** ។ ព្រះមែនទែនមានដែរ តែនៅលើមេឃ ។ ដោយហេតុនេះហើយ បានជាគេទុកសេចក្តី ស្លាប់របស់ស្តេច ជាដំណើររបស់ព្រះអង្គទៅជួបព្រះ ឬយ៉ាងតិច ណាស់ក៏ទៅដល់ឋានដែលព្រះគង់នៅដែរ ។ ក្នុងព្រហ្មញ្ញសាសនាទៅជួបព្រះគឺទៅដល់ជើងព្រះ ទៅដល់ព្រះបាទព្រះ ។ ព្រះនាមស្តេចអង្គរទាំងអស់បង្ហាញឲ្យឃើញថា ស្តេចខ្មែរបានទៅដល់ព្រះបាទព្រះ ឬ ទៅដល់ឋានព្រះ ។

---

[៧] Claude Jacques : op.cit. p. 62.

www.elibraryofcambodia.org

ស្ដេចជ័យវរ្ម័នទី ២ មានព្រះនាម "បរមឥន្ទ្រៈបាទ" ក្រោយពេលព្រះអង្គបានសុគតទៅ ហើយព្រះនាមនេះមានន័យថា "ស្ដេចដែលទៅដល់ព្រះបាទ (ជើង) ព្រះសិរៈ (ឥន្ទ្រៈ) ដ៏ធំអស្ចារ្យ (បរម៉ា) ។ ស្ដេចសុរិយវរ្ម័នទី ២ ដែលមានព្រះនាមថា "បរមវិស្ណុលោកៈ" គឺព្រះអង្គបានទៅ "ឋានព្រះសិរៈដ៏ប្រសើរអស្ចារ្យ ។ មហាក្សត្រជ័យវរ្ម័នទី ៧ ពិតមែនតែកាន់ព្រះពុទ្ធសាសនាមហាយាន ក៏មានព្រះនាមជា "មហាបរមសុគតបាទ" ដែរ គឺថាព្រះអង្គបានទៅដល់ព្រះបាទ (ជើង) ព្រះពុទ្ធ (សុគត គឺ ព្រះពុទ្ធ) ដែលជាមហាធំធេង ឬប្រសើរអស្ចារ្យ ។

**ទេវរាជ = ស្ដេចជាព្រះ**

ក្នុងរបបព្រហ្មញ្ញសាសនា មហាក្សត្រកាន់សាសនានេះយ៉ាងត្រឹមត្រូវខ្ជាប់ខ្ជួនជាទីបំផុត ហើយគោលបំណងផ្ទាល់របស់មហាក្សត្រទាំងអស់មានតែមួយគត់ គឺទៅ "**រួបរួមជាមួយព្រះ**" ដែលគេបានជ្រើសរើសមកជាព្រះផ្ទាល់ខ្លួន របស់គេ ។ ក្នុងក្បួន "ភាគវតគិតា" គេបានសរសេរថា ៖

"ឯងត្រូវនឹកមកដល់អញ"
"បូជាថ្វាយអញ បន់ស្រន់អញ"
"គឺអញនេះហើយដែលឯងត្រូវចូល"
"រួបរួមខ្លួនឯងនឹងខ្លួនអញ"
"ទាំងអស់ឲ្យបានមានតែអញ" (**គ្រិស្ដ.វគ. ៩** ភាគវតគិតា)[២]

---

[២] Bhagavad Gità : Traduit par Sylvain Lévy et Joseph Sticney. Lib d' Amérique et d' Orient. Paris 1975. p. 52.

www.elibraryofcambodia.org

រូបរួមជាមួយព្រះ តាមភាសាព្រហ្មញ្ញសាសនា (ស្រីអូរុបិន្ទូ)[៣] មានន័យថា គេបានទៅដល់ព្រះ គេបានគេចផុតពីជីវិតនៅលើឋានដីយើង គេចផុតពីកង់ "សំសារ" ពីការកើតស្លាប់តៗ មិនចេះឈប់ដែលជាទុក្ខវេទនារបស់មនុស្សទាំងអស់ ។ សង្ខេបសេចក្ដីទៅ បានរូបរួមនឹងព្រះ គឺបានទៅដល់និព្វាន កន្លែងដែលគេមានជីវិតឥតចេះស្លាប់ ។ ដើម្បីនឹងបង្ហាញឲ្យខ្មែរបានដឹងថា មហាក្សត្របានទៅដល់និព្វាន បានរូបរួមនឹងព្រះហើយ គេតែងតែឆ្លាក់រូបមហាក្សត្រនោះជាព្រះតែម្ដង ។ ព្រះវិស្ណុយ៉ាងធំមួយ ដែលគេតាំងនៅកំពូលប្រាសាទខ្ពស់ជាងគេ នៅអង្គរវត្ត ហើយដែលពួកកាន់ព្រះពុទ្ធសាសនា បានច្រានទម្លាក់ឆ្លាក់បាក់បែកអស់នោះ មិន មែនព្រះវិស្ណុទេ គឺជាមហាក្សត្រសុរិយវរ្ម័នទី ២ ក្នុងភាពព្រះអង្គដែលបានរូបរួមជាមួយព្រះវិស្ណុ ។ ដូចគ្នានេះដែរចម្លាក់ព្រះពុទ្ធមួយ អង្គ ដែលមានកំពស់ ៣,៦០ ម៉ែត្រ ដែលពួកកាន់សាសនាព្រះសិវៈ បានវាយបាក់បែក ហើយទម្លាក់ទៅក្នុងអណ្ដូងក្រោមប្រាសាទខ្ពស់ជាងគេនៅបាយ័ននោះ មិនមែនព្រះពុទ្ធទេ (ហ.ម៉ារហ្សាល)[៤] គឺជាមហាក្សត្រជ័យវរ្ម័នទី ៧ ក្នុងរូបជាអ្នកដែលបានចូលទៅដល់ព្រះពុទ្ធ ហើយដែលបានកាន់ព្រះពុទ្ធសាសនាយ៉ាងត្រឹមត្រូវ ។ ទំនៀមទំលាប់ខ្មែរក្នុងសិល្បៈចម្លាក់រូបស្ដេចជាព្រះ បានគេគោរពមកដល់សព្វថ្ងៃ ។ នៅវិហារព្រះកែវ ក្នុងព្រះរាជវាំងក្រុងភ្នំពេញ គេឃើញរូបស្ដេចនរោត្តមទី១ ឆ្លាក់អំពីមាសជាព្រះពុទ្ធទ្រង់ឈរក្នុងចំណោមព្រះពុទ្ធរូបផ្សេងៗ ច្រើនទៀត ។ រូបឆ្លាក់នេះ គ្រាន់តែ

---

[៣] Sri Aurobindo : Bhagavad Gità . Albin Michel. Paris 1970. p. 366.

[៤] Henri Marchal : Les Temples d'Angkor. Albert Guillot. Paris 1955. p.79.

www.elibraryofcambodia.org

បង្ហាញឲ្យឃើញ ថាស្ដេចនរោត្តមជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងត្រឹមត្រូវតែប៉ុណ្ណោះ ។ អ្នកបរទេសមិនសូវបានយល់ច្បាស់ន័យ ឬ "**ភាសារូបចម្លាក់ខ្មែរ**" ទេ ។ គេឃើញព្រះវិស្ណុ គេថាព្រះវិស្ណុមែនទែន ហើយគេយល់ច្រឡំ ថាប្រាសាទខ្មែរជាវិហារសម្រាប់គេឯងចូលមកបំពេញការគោរព បូជាថ្វាយព្រះទាំងអស់ ។ បារាំងគេឲ្យឈ្មោះប្រាសាទនៅអង្គរ ថា"Temples d'Angkor" គឺវិហារអង្គរ ។ នេះគឺជាការភ័នច្រឡំមួយយ៉ាងធំ ។

www.elibraryofcambodia.org

## ប្រស្នា

នៅក្នុងវិហារព្រះកែវ ក្នុងព្រះរាជវាំងក្រុងភ្នំពេញ មានរូបចម្លាក់ធ្វើអំពីមាសរបស់ស្ដេចនរោត្ដមទី១ តំណាងជារូបព្រះពុទ្ធទ្រង់ឈរក្នុងចំណោមព្រះពុទ្ធរូបផ្សេងៗទៀតជាច្រើន ។ ភាពនេះឲ្យនូវប្រស្នាដូចតទៅ ៖

- រូបចម្លាក់នេះគឺព្រះពុទ្ធឬអ្វី ?
- មិនមែនទេ ។ គឺព្រះករុណានរោត្ដមទី ១ ។
- ដូច្នេះនរោត្ដមទី១បានទៅជាព្រះឬអ្វី ?
- មិនមែនទេ ។ នេះគ្រាន់តែឲ្យដឹងថា ស្ដេចនរោត្ដមទី១ ជាអ្នកបានកាន់ព្រះពុទ្ធសាសនាយ៉ាងត្រឹមត្រូវ ។

នេះហើយដែលគេហៅថា ភាសាសិល្បៈចម្លាក់របស់ខ្មែរ។

www.elibraryofcambodia.org

## វគ្គទី ១២

# លេខ ៥ ឬ លេខនិមិត្តរូបព្រះសិវៈ

កាលឆ្នាំ ១៩៣១ និយាយអំពីគ្រួសារខ្មែរមួយ លោក "ហ្គ.ហ.ម៉ូណូដ៍" [១] បានសរសេរថា៖ "នៅថ្ងៃ ទី ៣ ក្រោយកំណើតកូនប្រុស ឪពុកកូននោះដុតទៀន ៥ ដើម យកមកដាក់ជារង្វង់ លើថាសស្ពាន់មួយ រួចអុជ ធូប ៥ ដើម ដែលគេកាន់ក្នុងដាយសំពះ និងថ្វាយដោយឱនលំទោនដល់ទេវតាទាំងបួនទិស ..." ។

ការនិយមគោរពលេខ "៥" មាននៅស្រុកខ្មែរជាយូរណាស់មកហើយ ។ កាលសតវត្សទី ៧ ចិនបានសរសេរក្នុងសៀវភៅរឿងព្រះរាជវង្សក្សត្រ "ស្វយ" ថា ៖ "ក្នុង ៣ ថ្ងៃម្តងស្តេចខ្មែរចេញគង់យ៉ាងឱឡារិក ក្នុងបន្ទប់សម្រាប់ទទួលប្រជារាស្ត្រ ហើយគង់នៅលើគ្រែមួយធ្វើអំពីឈើក្រអូប ៥ យ៉ាង តុបតែងដោយគ្រឿងមានតម្លៃ ៧ មុខ ។ រដ្ឋមន្ត្រីមានចំនួន ៥ ....ល។ ចិនរាប់រឿងនេះ គឺរឿងមហាក្សត្រ ឥសាណវរ្ម័ន ដែលគង់នៅរាជធានីឥសានបុរៈ

---

[១] G. H Monod : Le Cambodgien in " Des Français au Cambodge ". Anthologie de Dominique Bérard. Espace Bayon. Phnom Penh 1989. p.85.

www.elibraryofcambodia.org

ឥសាណបុរ៉ា (ឥសាណ = ព្រះសិវៈ - បុរ៉ា = ក្រុង) ដែលចិនអានថា "អ៊ីចូណា" សព្វថ្ងៃគឺ "សំបូរព្រៃគុក" នៅខាងជើងក្រុងកំពង់ធំ ។

ថ្មីៗនេះ លោក "ឃិនសុខ" [៦] បានរំឭកថា កាលសត្តវត្សទី ១៨ រដ្ឋមន្ត្រីខ្មែរនៅមានតែ ៥ នាក់ដដែលគឺ ៖

- ឧកញ៉ាទូល័ក្ខ រដ្ឋមន្ត្រីទីមួយ
- ឧកញ៉ាយោមរាជ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ឧកញ៉ាវាំង មន្ត្រីអភិបាលវាំង
- ឧកញ៉ាក្រឡាហោម រដ្ឋមន្ត្រីខាងនាវាចរណ៍
- ឧកញ៉ាចក្រី រដ្ឋមន្ត្រីខាងដឹកនាំជើងគោក ។

ទំនៀមទំលាប់ខ្មែរ ដែលមានរដ្ឋមន្ត្រី ៥ រូប នេះ បានខ្មែរគោរពរហូតមកដល់សតវត្សទី ២០។ ទោះជាយ៉ាងណាក៏ដោយ ខ្មែរគោរពលេខ៥ នេះនៅក្នុងឱកាសនិងកាលៈទេសៈផ្សេងៗជាច្រើន។ កាលឆ្នាំ ២០០៤ ក្នុងពិធីអភិសេកព្រះមហាក្សត្រនរោត្តមសីហមុនី គេបានសែងដង្ហែព្រះអង្គ ហើយមានឆត្រពណ៌ក្រហមបួន នៅពីមុខមានខ្លោះ (ឆត្រត្រួត) ៥ ជាន់ ។ គ្រឿងនិមិត្តរូបសំគាល់ភាពរាជាខ្មែរ ឬ រាជកកុធភណ្ឌ ក៏មាន ៥ ដែរគឺ ៖

- ម្កុដរាជធ្វើអំពីមាស ហើយមានដាំពេជ្រ
- ព្រះខ័នរាជ្យ
- អាវវែងនិងស្បែកជើង

[៦] Khin Sok : L' annexion du Cambodge par les Viêtnamiens au XIX[e] siècle. Ed. You Feng. Paris 2002. p.376.

www.elibraryofcambodia.org

- លំពែងដែលមរតករបស់តាត្រសក់ផ្អែម
- ប្រអប់ស្លាធ្វើអំពីមាស

កាលជំនាន់អង្គរ ខ្មែរមិនធ្វើអ្វីមួយដោយមិនបានគិតគូរយ៉ាងល្អិតល្អន់ទេ ។ រាជធានី "អង្គរធំ" ក៏មានទ្វារ ៥ ដែរ ។ ចិន "ជូតាក្វាន់" ដែលមកអង្គរកាលឆ្នាំ ១២៩៦ បានសំគាល់ឃើញសភាពនេះហើយ ។ ព្រះរាជវាំងនៅក្នុងអង្គរធំក៏មានទ្វារ ៥ ទ្វារពីរនៅខាងជើង ពីរទៀតនៅខាងត្បូង ហើយទ្វារទីប្រាំគឺទ្វារចេញ ទៅខាងកើត កាត់តាម "ខឿនដំរី" ទៅផ្លូវនិងទ្វារខាងក្រៅ ដែលមានឈ្មោះមហាក្យត្រ "ជ័យៈ" ទាំងអស់ ។ "បឹងធំ" ដែលនៅជ្រុង និរតីគឺ នៅជ្រុងខាងត្បូងនិងខាងលិចរាជធានី មានបំពង់ថ្ម ៥ ដែលគេបង្កប់នៅក្នុងដី ក្រោមកំផែងល្បងសម្រាប់ឲ្យទឹកក្រខ្វក់ហូរចេញបាន ។

លេខ ៥ ជាលេខមួយយ៉ាងពិសេសរបស់ខ្មែរ ។ តើលេខនេះជានិមិត្តរូបអ្វី ?

**លេខ ៥ គឺលេខនិមិត្តរូបព្រះសិវៈ** ។ តាមព្រហ្មញ្ញសាសនាក្នុងមួយកាល្បៗ ព្រះសិវៈដែលជាព្រះវិលាយអ្វីៗ ទាំងអស់និងជាព្រះផែលកសាងអ្វីៗ ទាំងអស់ដែរនោះ ចេញមកដុតឲ្យឆេះ ឲ្យរលាយសកលលោកទាំងអស់ គឺជាឲ្យរលាយអស់ដែរនូវ "កម្មពៀរ"ទាំងឡាយដែលមនុស្សលោកធ្វើឲ្យកើតឡើងដ៏ពោរពេញ ។ ការវិលាយអស់នេះគេហៅថា "មហាប្រសវៈ" ហើយពាក្យខ្មែរធម្មតាគេថា ភ្លើងឆេះកាល្ប (មួយកាល្ប គឺ រយៈវេលាដែលមានពីពេលកំណើត រហូតដល់ពេលរលាយអស់របស់សកលលោក ។ មួយកាល្ប ត្រូវនឹងមួយថ្ងៃរបស់ព្រះព្រហ្ម ហើយត្រូវនឹង ៤៣០០ លានឆ្នាំរបស់មនុស្សយើង) ។ ដល់វិលាយអស់ហើយ ព្រះសិវៈដែលជា

www.elibraryofcambodia.org

ព្រះបង្កើតលោកយើងផងដែរ កំបង្កើតសកលលោកនឹងមនុស្សសត្វអ្វីៗ ទាំងអស់ឡើងវិញ ដោយឥតមានជាប់ "កម្មពៀរ" ផ្សេងៗមកជាមួយទេ ។ ក្នុងការបង្កើតឡើងវិញនេះ ព្រះសិវៈយកវត្ថុធាតុ ៥ មុខ ដែលជាវត្ថុធាតុរបស់ខ្លួនព្រះអង្គគឺ ទឹក ដី ភ្លើង ខ្យល់ និង អាកាស ។ ធាតុចុងក្រោយនេះគឺ ធាតុ "ទទេ" ដែលនៅផុតពីមេឃជុំវិញផែនដី ។ បើនិយាយតាមរបៀបម្យ៉ាងទៀត គេអាចនិយាយបានថា "ធាតុទាំង ៥ នោះគឺព្រះសិវៈ" តែម្តង ។ ព្រោះហេតុនេះហើយបានជាពេលខ្លះ គេឆ្លាក់រូបព្រះសិវៈជាព្រះមានព្រះភក្ត្រ ៥ ដែលគេ ហៅថា ស្ថសីវៈ ។

មនុស្សយើងមានសេចក្តីគោរពព្រះសិវៈយ៉ាងខ្លាំង ហើយមានការខ្លាចផងដែរ ។ គេមិនហ៊ានហៅព្រះនាម ព្រះអង្គទេ ដែលមែនទែនគឺ "អាន" (ជាណឺអេឡ) ហើយឈ្មោះសិវៈគ្រាន់តែមានន័យថា "កុសល" ឬ អ្នកមាន ចិត្តអនុគ្រោះ មិនប្រកាន់ទោស។ ក្នុងរូបចម្លាក់គេប្រើរូបភាពផ្សេងៗ ដើម្បីតំណាងព្រះសិវៈដែរ ដូចជាលិង្គ ឬ គោ (ដែលជាយាន្តជំនិះព្រះ) ។ ទ្វារអង្គរទាំង ៥ ទ្វារកំពែងទាំង ៥ ខ្លោះ ៥ ជាន់ គ្រឿងនិមិត្តរូបព្រះរាជាខ្មែរទាំង ៥ គឺសុទ្ធតែជារូបព្រះសិវៈទាំងអស់ ។

ព្រះសិវៈមិនមែនគ្រាន់តែតំណាងធាតុ ៥ នេះទេ ។

ព្រះសិវៈជាតំណាងទិសទាំង ៥ ទៀត គឺជើង ត្បូង កើត លិច និង ទិសលើក្បាល (ម.អាលបាណែស)[៣] ។ ក្នុងសៀវភៅមួយផ្សាយចេញពីគណៈកម្មការខាងទំនៀមទំលាប់ នៅភ្នំពេញ គេបាន

[៣] Marilia Albanèse : op.cit. p. 66.

www.elibraryofcambodia.org

# ប្រាសាទខ្មែរ



ដែលគេឃើញមាន ៥ ជាន់

Maurice Glaize : Les monuments du groupe d'Angkor.
Librairie d'Amérique et d'Orient , Adrien Maisonneuve.
11 Rue Saint Sulpice , Paris VI eme , 1963 , planche II
3e Edition

www.elibraryofcambodia.org

សរសេរថា "ធូប ៥ ទៀន ៥" ដែលគេថ្វាយព្រះ ឬ ទេវតានោះគឺបង្ហាញប្រាប់ថា ទិសទាំង ៥ ។ ការពន្យល់នេះបានត្រឹមត្រូវ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ទេ គេត្រូវនិយាយបន្ថែមទៀត ថានេះជា ព្រះសិវៈ។

រូបព្រះសិវៈក្នុងន័យថាទិសទាំង ៥ ដែលស្តែងជាងគេ នៅស្រុកខ្មែរគឺកំពូល ៥ ប្រាសាទ "អង្គរវត្ត" ។ ប្រាសាទខ្ពស់ជាងគេបង្អស់ ចង្អុលទៅទិសនៅត្រង់លើក្បាលយើង ដែលជាទិសសំខាន់បំផុត ពីព្រោះជាទិសតម្រង់ទៅព្រះធំជាងគេ គឺព្រះព្រហ្ម ។ ទិសបួនទៀតគឺ ជើង ត្បូង កើត និង លិច ។ ប្រាសាទ ៥ នៅលើ កំពូលប្រាសាទបាខែង មេបូន ប្រែរូប ឬ តាកែវ មានន័យដូចកំពូលប្រាសាទអង្គរវត្តទាំងអស់ គឺសុទ្ធតែជារូបព្រះសិវៈ ។

ប្រាសាទតូចនីមួយៗ នៅលើកំពូលប្រាសាទទាំងឡាយមាន ៥ ជាន់ ដែរ ហើយជាន់លើបំផុត បានគេលំអដោយកម្រងផ្កាឈូក ។ ប្រាសាទនីមួយៗ ក៏ជារូបព្រះសិវៈមួយដែរ ក្នុងន័យជាព្រះដែលមានធាតុ ៥ គឺ ទឹក ដី ភ្លើង ខ្យល់ អាកាស ។ កាលឆ្នាំ ១៩៤៥ លោក ម៉ូរីសហ្គ្លេស្ស៍[6] បានរកឃើញនៅក្រោមប្រាសាទ "ថ្មបាយក្អែក" ស្លឹកឈើមាស ៥ សន្លឹក ហើយនៅសន្លឹកកណ្តាលមានចម្លាក់រូបគោ បង្ហាញច្បាស់ថានេះ ជាព្រះ សិវៈ ។

**លេខ ៥ គឺ លេខនិមិត្តរូបព្រះសិវៈ** ។ ប្រាសាទដែលបង្ហាញលេខ ៥ យ៉ាងឱឡារិក យ៉ាងអស្ចារ្យ គឺ ប្រាសាទ "សិវៈលោកៈ" នៅលើភ្នំបាខែង ដែលពីដើមគេហៅថា ភ្នំកណ្តាល ។ នៅប្រាសាទ

---

[6] Maurice Glaize : Les monuments du groupe d' Angkor. Lib. d' Amérique et d' Orient. Adrien Maisonneuve. Paris 1963, p. 102.

www.elibraryofcambodia.org

នេះ មានលេខ ៥ ពាសពេញទាំងអស់ ។ ទោះបីយ៉ាងណាគេនៅពីមុខ នៅពីលើ នៅពីក្រោម ខាងឆ្វេង ឬ ខាងស្តាំ គេឃើញ ប្រាសាទតូចៗ រៀបមកជាជួរ ៥-៥ ទាំងអស់ ។ ប្រាសាទសិរៈលោកៈ មានរូបជាសាជីជ្រុង មាន ៥ ជាន់ ។ នៅមុខម្ខាងៗ មានជណ្តើរមួយមាន ៥ ជាន់ដែរ ហើយអមដោយប្រាសាទតូច ៥ នៅទាំងពីរខាង ។ ជ្រុងប្រាសាទទាំង ៤ មានប្រាសាទតូចៗ ៥ ពីក្រោមទៅលើដែរ នៅកំពូលលើមានប្រាសាទ ៥ មួយនៅកណ្តាល ៤ នៅជ្រុងទាំងបួន ។ នៅប្រាសាទ "សិរៈលោកៈ" គេសំដែងបង្ហាញព្រះសិរៈគ្រប់បែបយ៉ាងទាំងអស់ ជាព្រះដែលមាន ជាវត្ថុធាតុ ៥ ផង ជាព្រះតំណាងទាំង ៥ ទិសផង ។

លេខ ៥ គឺលេខនិមិត្តរូបព្រះសិវៈ

គឺព្រះស្ថសិវៈ ។

www.elibraryofcambodia.org

www.elibraryofcambodia.org

## វគ្គទី ១៣

# ភ្នំព្រះសុមេរុ

តាមអ្នកឯកទេសពីប្រាសាទខ្មែរ អង្គរវត្តគឺភ្នំព្រះសុមេរុ ប្រាសាទបាយ័ន្តនៅអង្គរធំគឺភ្នំព្រះសុមេរុ ភ្នំបាខែងក៏ជាភ្នំព្រះសុមេរុដែរ ។ ដោយហេតុថាប្រាសាទទាំង ៣ នេះ មិនដូចគ្នាអ្វីសោះ ហើយនិយាយថាប្រាសាទទាំងនោះ ជាភ្នំព្រះសុមេរុដូចគ្នា ធ្វើឲ្យអ្នកស្រាវជ្រាវមានការងឿងឆ្ងល់ជាទីបំផុត ។

គឺអ្នកថតរូបជាតិអង់គ្លេសម្នាក់ឈ្មោះ "ហ្សូនធំសន់" ដែលបាននិយាយមុនគេថា អង្គរវត្តមានរូបជាភ្នំព្រះសុមេរុ ក្រោយពីពេលដែលគេបានមកអង្គរក្នុងឆ្នាំ ១៨៦៦ ។ តាមលោកធំសន់[១] "ប្រាសាទកណ្តាល គឺភ្នំទាំង ៧ របស់ភ្នំព្រះសុមេរុ ថ្នាក់ ៣ ជាន់របស់ប្រាសាទគឺ ឋានទឹក ឋានដី ឋានខ្យល់ ដែលទ្រទ្រង់ភ្នំព្រះសុមេរុ ហើយទឹកស្រះជុំវិញប្រាសាទគឺជាសមុទ្រ។ លោក "ប្រុយណូដាហ្សាង"[២] និយាយថា "ការពន្យល់របៀបនេះគេអាចយកមកផ្ដែកឡើងវិញបាន" ប្រែមកថានិយាយនេះមិនបានសមរម្យអ្វីទេ !

---

[១] [illegible]mson : cité par Maurice Glaize dans "Les monuments du groupe [illegible]", op.cit. p. 76.

[២] Bruno Dagens : La forèt de pierre. Galimard . Paris 1989. p. 43.

www.elibraryofcambodia.org

កាលឆ្នាំ ១៩៤២ លោក "សឺដែស"[៣] សរសេរទៀតថា៖ ប្រាសាទទាំង ៥ នៅលើកំពូល អង្គរវត្តគឺ ជា "កំពូល ៥ របស់ភ្នំព្រះសុមេរុ។ ចាប់ពីពេលនោះមក គេក៏បានទទួលជាផ្លូវការ ថាប្រាសាទ ៥ នៅលើអង្គរវត្ត គឺជាកំពូលភ្នំព្រះសុមេរុតែម្តង ។ ដោយហេតុនេះហើយបានជាលោក ម៉ូរីក្លេស៍ ពន្យល់ថា "ភ្នំព្រះសុមេរុ ជាភ្នំមួយមានរូបបួនជ្រុងខាងក្រោម ស្រួចឡើងខាងលើ ហើយមានកំពូលប្រាំ។ ថ្មីៗ នេះ លោក ក្លូដហ្សាក់[៤] បញ្ជាក់ថែមថា "ប្រាសាទខ្ពស់កណ្តាលគឺភ្នំព្រះសុមេរុ ហើយភ្នំនេះមានភ្នំអមជុំវិញបួនទៀត ពីព្រោះភ្នំព្រះសុមេរុជាភ្នំមានកំពូលប្រាំ" ។

តើមែនទែនអ្វីទៅដែលគេហៅថា ភ្នំព្រះសុមេរុ ? ភ្នំនេះមានរូបរាងដូចម្តេចទៅ ? ភ្នំនេះមានកំពូលប្រាំដែរឬ ? ភ្នំព្រះសុមេរុតំណាងអ្វី ជានិមិត្តរូបអ្វី ?

អ្នកដែលមានការសង្ស័យមុនគេ អំពីភ្នំព្រះសុមេរុមានកំពូលប្រាំ គឺលោក "ហ្សាំងឡូរ"[៥] ដែលសរសេរ ថា៖ "ប្រាសាទប្រាំនៅលើកំពូលអង្គរវត្ត គឺរូបធ្វើតាមភ្នំព្រះសុមេរុ តែគេឆ្ងល់ថាហេតុអ្វីស្រុកក្លិង្គ ដែលជាអ្នកបង្កើតរឿងភ្នំព្រះសុមេរុនេះ មិនមានសង់ប្រាសាទមានកំពូលប្រាំនៅលើដែនដីរបស់គេ ? "

**ការពិតភ្នំព្រះសុមេរុ ដែលក្លិង្គបានអធិប្បាយរៀបរាប់មកនោះ មិនមានរូបរាងបួនជ្រុងខាងក្រោម ហើយមានកំពូលប្រាំខាងលើទេ ។ តាមក្លិង្គ ភ្នំព្រះសុមេរុជាភ្នំមួយយ៉ាងសំខាន់ក្នុងសកល**

---

[៣] G. Cœdès : op.cit. p. 226.

[៤] Claude Jacques : op.cit. p. 40.

[៥] Jean Laur : Angkor. Temples et Monuments. Flammarion . 2002. p.60.

www.elibraryofcambodia.org

លោក ។ លោក "បែរណា បូដ្វាង" [៦] បញ្ជាក់ថា៖ សកលលោកមានភាពជាដុំមូល ដែលគេចែកជាពីរភាគ រួចមានរបៀបជាថាស សំប៉ែត នៅកណ្ដាល ៖

- ភាគខាងលើគឺ ភាគលើមេឃ គឺជាឋានរបស់ព្រះ ។ ឋានលើមេឃនេះមាន ៧ ជាន់ ព្រះធំនៅជាន់ខ្ពស់ ព្រះតូចនៅជាន់ក្រោម ។ ឋានទី ៧ ខ្ពស់ជាងគេគឺ ឋានរបស់ព្រះព្រហ្ម ព្រះធំជាងព្រះផ្សេងៗ ទាំងអស់ ។ នៅលើអាកាសជុំវិញឋានព្រះ ក៏មានព្រះផ្សេងៗ នៅដែរ តែនៅលើប្រាសាទអណ្ដែតលើមេឃ ដែលគេហៅថា "វិមានកាស" ។

- ភាគកណ្ដាល មូលសំប៉ែត គឺផែនដី គឺឋានរបស់មនុស្ស ។ នៅចំកណ្ដាលផែនដីនេះ មានភ្នំមួយយ៉ាងខ្ពស់ជាទីបំផុត ។ គឺភ្នំនេះឯងដែលគេហៅថាភ្នំព្រះសុមេរុ ។ ភ្នំព្រះសុមេរុជាភ្នំរបស់ឋានមនុស្ស មិនមែនឋានព្រះទេ ហើយព្រះឥតគង់នៅទីនេះទេ ។

- ភាគខាងក្រោម គឺឋាននៅក្រោមផ្ទៃដី នៅក្រោមដី ឬនៅក្នុងដី ។ នេះគឺឋាននរក ឋានដែលគេធ្វើទណ្ឌកម្មដល់មនុស្ស ក្រោយពេលស្លាប់ ។ ឋាននេះនៅក្រោមការអភិបាលរបស់ព្រះ "យោមៈ" ដែលខ្មែរហៅថា "យោមរាជ" ។ ឋាននរកមាន ៧ ជាន់ ដែរ ។ មនុស្ស

---

[៦] Bernard Baudouin : L' Hindouisme. op.cit. p. 54.

www.elibraryofcambodia.org

ណាធ្វើកម្មពៀរច្រើន មនុស្សនោះត្រូវចុះទៅជាន់រិតតែជ្រៅ ។

ក្នុងសេចក្ដីនិទានអំពីសកលលោកនេះ ក្លឹង្គបានបន្ថែមទៀតថាមានទ្វីប ៤ នៅជុំវិញភ្នំព្រះសុមេរុ (ល.វើណ្ណ)[៩] ស្របទៅតាមទិសទាំងបួនគឺ ៖

- ខាងត្បូង ជម្ពូទ្វីបមានរាងត្រីកោណ
- ខាងជើង ឧត្តរៈក្រុម រាងបួនជ្រុង
- ខាងកើត បូរាវិទេហៈ រាងមូលជារង្វង់កណ្ដាល
- ខាងលិច អបរគោយាន មានរាងមូល

តាមការពិត ក្លឹង្គដែលអធិប្បាយ រៀបរាប់សកលលោករបៀបនេះ គឺគេអធិប្បាយពន្យល់ឲ្យស្គាល់ ទ្វីបឥណ្ឌា តែប៉ុណ្ណោះទេ ។ ទ្វីបឥណ្ឌាមានរាងត្រីកោណ ឬ រាងមាន ៣ ជ្រុង ហើយនៅខាងត្បូងភ្នំហិមលយៈ ដែលខ្មែរហៅថា ភ្នំហិមពាន្ត។ ស្រុកក្លឹង្គគឺ "ជម្ពូទ្វីប" ហើយភ្នំហិមលយៈ គឺភ្នំព្រះសូមេរុ ។ ម្យ៉ាងទៀតដោយហេតុថាភ្នំហិមពាន្ត មានកំពស់ខ្ពស់ខ្លាំងពេក រហូតដល់ពពកទៅទៀត គឺអាចនឹងទៅដល់ឋានរបស់ព្រះទាំងឡាយ គេមានការខ្លាចនិង គោរពភ្នំនេះយ៉ាងខ្លាំង ។ គួរសំគាល់ថា កាលពេលដែលក្លឹង្គសរសេរអំពីភ្នំព្រះសូមេរុ ឬ ហិមពាន្តនោះ ឥតមានមនុស្សណាម្នាក់ដែលបានទៅដល់កំពូលភ្នំនេះទេ ។

---

៩ Louis Re[illegible] និង [illegible] Fillozart. op.cit. p.79.

www.elibraryofcambodia.org

ការអធិប្បាយអំពីភ្នំព្រះសុមេរុ មិនមែនចប់ត្រឹមនេះទៀត ។ ដល់យូរក្រោយមក ក្នុងក្បួនធម៌មួយហៅថា "បូរាណ" ដែលលោក "ប.បូដ្វាំង" (Bernard Baudouin) បានស្រង់មក គេនិយាយថា៖ "នៅជុំវិញភ្នំព្រះសុមេរុ មានទ្វីប ៧ ដាច់ពីគ្នា ដោយសារមានសមុទ្រ ៧ ដែរ ៖ មានសមុទ្រទឹកប្រៃមួយ សមុទ្រទឹកអំពៅមួយ សមុទ្រសុរាមួយ សមុទ្រខ្លាញ់ទឹកដោះគោថ្លាមួយ សមុទ្រខ្លាញ់ទឹកដោះគោកមួយ សមុទ្រទឹកដោះគោធម្មតាមួយ និង សមុទ្រទឹកត្រជាក់មួយ ។

សមុទ្រខាងក្រៅបង្អស់ មានភ្នំធំមួយឈ្មោះព័ទ្ធជុំវិញ ដែលមិនអាចអ្នកណាឆ្លងបានឡើយ ។ ទ្វីបទីមួយ ដែលនៅជិតភ្នំព្រះសុមេរុជាងគេនោះ គឺជម្ពូទ្វីប គឺទ្វីបឥណ្ឌា ។ ឋាននរកដែលនៅខាងក្រោមដីក៏មាន ៧ ជាន់ ដូចគេអធិប្បាយពីមុនមកដែរ ។ នៅទីជ្រៅទៅក្រោមបង្អស់ ក្រោមឋាននរកទី ៧ ទៅទៀត មាននាគមួយធំយ៉ាងអស្ចារ្យ មានក្បាល ៧ ឈ្មោះ "វាសុកិ" ឬ "វាសុក្រិ" ។ គឺនាគនេះហើយដែលទូលទ្រលើក្បាល ៧ ឋានទាំងអស់ មានឋាននរកទាំង ៧ ឋានមនុស្សជាមួយភ្នំព្រះសុមេរុផង នឹងឋានព្រះលើមេឃ ៧ ទៀតផង ។

នេះហើយគឺភ្នំព្រះសុមេរុ តាមសេចក្ដីពិតប្រាកដ តាមការអធិប្បាយពីដំបូងរបស់ក្លីង្គ ។ ភ្នំព្រះសុមេរុជាបង្គោលកណ្ដាលរបស់ផែនដី ដែលជាឋានរបស់មនុស្ស ។ ភ្នំព្រះសុមេរុឥតដែលមានរូបជាសាជីជ្រុង គឺថាមានភាពបួនជ្រុងស្មើនៅខាងក្រោម និងកំពូលស្រួចនៅខាងលើនោះទេ ។ ជាពិសេសទៀត ភ្នំព្រះសុមេរុ មិនដែលមានកំពូលប្រាំដែរ ! ភ្នំព្រះសុមេរុក៏មិនមែនជាកន្លែងដែលព្រះគង់នៅទៀត ពីព្រោះព្រះនៅឋានលើមេឃ ដែលមាន ៧ ជាន់ មិនមែននៅលើដីជាមួយមនុស្សលោកឡើយ ។

www.elibraryofcambodia.org

www.elibraryofcambodia.org

## វគ្គទី ១៤

# សិវៈលោកៈ និង ភ្នំបាខែង

យសោវរ្ម័នទី១ បានសោយរាជ្យនៅស្រុកខ្មែរពីឆ្នាំ ៨៨៩ ដល់ឆ្នាំ ៩០០ ។ ព្រះអង្គជាមហាក្សត្រមួយយ៉ាងធំក្នុងចំណោមមហាក្សត្រធំៗរបស់ខ្មែរ ។ ព្រះអង្គជាមហាក្សត្រខ្មែរទីមួយ ដែលបានមកបិតនៅតំបន់ដែលសព្វថ្ងៃគេហៅថា "**អង្គរ**" ។ ព្រះអង្គបង្កើតរាជធានីថ្មីមួយ ដែលព្រះអង្គយកឈ្មោះផ្ទាល់របស់ព្រះអង្គមកដាក់ឲ្យតាមទំនៀមទំលាប់ក្លីង្គ គឺថាក្រុង "**យសោធរៈបុរៈ**" (ធរៈ គឺការពារ បុរៈ គឺក្រុង) បានន័យថាក្រុងដែលគាំទ្រ "**យសោ**" ។ ព្រះអង្គយកភ្នំបាខែង ដែលមានកំពស់ ៧០ ម៉ែត្រ មកសំគាល់ឲ្យដឹងថាជាទីកណ្ដាលក្រុងរបស់ព្រះអង្គ ហើយដែលព្រះអង្គឲ្យឈ្មោះថា "**ភ្នំកណ្ដាល**" ។ នៅលើកំពូលភ្នំនេះ ព្រះអង្គស្ថាបនាប្រាសាទមួយថ្វាយព្រះសិវៈ គឺព្រះឥសូរ ហើយដែលមានឈ្មោះថា "**សិវៈលោកៈ**" បានសេចក្ដីថា "ឋានព្រះសិវៈ" ។

ប្រាសាទសិវៈលោកៈ បានធ្វើឡើងដោយគេឆ្លាក់កាត់កំពូលភ្នំបាខែងតែម្ដង រួចគេលំអរដោយគេយកថ្មឆ្លាក់ផ្សេងៗមករៀបគ្រប់

www.elibraryofcambodia.org

កន្លែងទាំងអស់ ។ ប្រាសាទនេះមានរូបសាជីជ្រុង គឺថាមានរាងបួនជ្រុងស្មើខាងក្រោម និង កំពូលស្រួចនៅខាងលើ ហើយមានទាំងអស់ ប្រាំថ្នាក់ ។

**រូបសាជី**




នៅជាន់ខាងលើបំផុត គេកាត់កំពូលភ្នំឲ្យរាបស្មើធ្វើជាខឿនបួនជ្រុងមាន ៩៧ ម៉ែត្រក្នុងមួយជ្រុង ។ នៅលើខឿននេះគេលើកជាថ្នើរទាបមួយទៀត របៀបជាបល្ល័ង្គ មានកំពស់ ១,៥៦ ម៉ែត្រ និង ៣១ ម៉ែត្រខាងមុខម្ខាងៗ ។ នៅលើថ្នើរនោះ មានប្រាសាទ ៥ មានមួយនៅកណ្តាល បួនទៀតនៅជ្រុងទាំងបួន ។

ប្រាសាទសិរៈលោកៈ មានបួនមុខ ។ នៅមុខនីមួយៗ មានជណ្តើរមួយនៅកណ្តាល មានសឹង្ហថ្មចម្លាក់អមទាំងសងខាងជាមួយប្រាសាទតូចៗទៀត ។ ដោយសារសិរៈលោកៈមាន៥ជាន់ ប្រាសាទតូចដែលអមជណ្តើរ ក៏មានចំនួន ៥ ដែរ នៅខាងជណ្តើរ ម្ខាងៗ គឺ

www.elibraryofcambodia.org

ទាំងអស់មានចំនួន ១០ ។ នៅតាមជ្រុងទាំងបួនក៏មានប្រាសាទតូច ៥ ទៀត ដូចគ្នានឹងប្រាសាទអមជណ្ដើរឡើងទៅកំពូលខាងលើ ។ ដល់សំរេចទៅប្រាសាទតូចៗ មាន ៖ តាមជណ្ដើរ ១០ x ៤ = ៤០ តាមជ្រុង ៥ x ៤ = ២០ គឺទាំងអស់ ៦០ ។

នៅជើងប្រាសាទសិវៈលោកៈ ដែលមានភាពបួនជ្រុងស្មើនឹងប្រវែង ៧៦ ម៉ែត្រខាងជ្រុងនីមួយៗ មានប្រាសាទ ៥ ទំហំខាងក្រោម ៧ x ៧ ម៉ែត្រ អមសាងខាងមាត់ជណ្ដើរ គឺមានទាំងអស់ ៣៦ ។ ជណ្ដើរនីមួយៗ មានប្រាសាទ ២ ទៀត អមនៅផ្លូវចូល ហើយទាំងអស់មាន ២ x ៤ = ៨ ។ នៅជើងដីនេះ ប្រាសាទតូចមាន ៣៦ + ៨ = ៤៤ ។

សរុបសេចក្ដីទៅ ប្រាសាទតូចៗ នៅសិវៈលោកៈមាន ៖

- កំពូល ៥
- ខ្លួនប្រាសាទ ៦០ **ទាំងអស់ ១០៩**
- ជើងប្រាសាទ ៤៤

**សិវៈលោកៈ ប្រែថាឋានព្រះសិវៈ** ។ ប្រាសាទនេះគឺ និមិត្តរូបឋានរបស់ព្រះសិវៈ ។ ក្នុងន័យនេះអ្វីៗទាំងអស់ ដែលមានក្នុងប្រាសាទ គឺសុទ្ធតែជាវត្ថុរំឮកដល់ព្រះសិវៈ ឬ ជាវត្ថុសម្រាប់ថ្វាយដល់ព្រះសិវៈ ។ គេសាងរូបព្រះសិវៈ ជាលិង្គមាសមួយ ដែលគេដាក់ដំកល់ក្នុងប្រាសាទនៅខ្ពស់ជាងគេបង្អស់ ។ ការតែងតាំងសំដែងព្រះលិង្គនេះ គឺជាទំនៀមទំលាប់មួយរបស់មហាក្សត្រខ្មែរដូចមហាក្សត្រ**ភវវរ្ម័នទី១** ដែលបានតាំងដំកល់លិង្គនៅលើភ្នំ ក្នុងតំបន់វត្ត "ភូ" សព្វថ្ងៃ និង ដូចមហាក្សត្រជ័យវរ្ម័នទី២ ដែលបានតាំង

www.elibraryofcambodia.org

លិង្គមាសមួយនៅលើភ្នំ "មហិន្ទ្របវ៌ត" ឬ ភ្នំគូលេន ។ ការដែលគេតំកល់លិង្គនៅលើកំពូលភ្នំដូច្នេះ គឺមានន័យតែមួយគត់ ៖ **តាមជំនឿព្រហ្មញ្ញសាសនា ព្រះគង់នៅលើមេឃ ហេតុនេះត្រូវតែគេតំកល់ព្រះនៅទីដែលខ្ពស់បំផុត ឲ្យដល់មេឃតែម្តង ។**

លិង្គមាសរបស់ស្តេច**យសោវរ្ម័នទី១** បានទទួលឈ្មោះថា "**យសោធរឥស្វរៈ**" ប្រែមកថា ព្រះសិវៈ (ឥស្វរៈ) ការពារ (ធរ) យសោ ។ លិង្គពិសេសនេះ បានគេទុកក្រោមការរក្សារបស់ព្រាហ្មណ៍ ដូចគ្រឿងរាជ កកុធភណ្ឌសព្វថ្ងៃដែលមានព្រាហ្មណ៍ហៅថា "បាគូរ" ថែទាំនោះដែរ ។ លិង្គនោះ គឺព្រះផ្ទាល់ខ្លួនរបស់មហាក្សត្រយសោវរ្ម័ន គឺព្រះដែលស្តេចជ្រើសរើសក្នុងចំណោមព្រះផ្សេងៗទៀត ហើយដែលក្លឹង្គឲ្យឈ្មោះថា**ឥស្តតៈ** (ishta) ។ លិង្គពិសេសនេះ ជាវត្ថុមួយដែលគេគោរពបូជាជាងគេបង្អស់ ក្នុងព្រះរាជាណាចក្រខ្មែរ ។

នៅស្រុកបារាំងលោកក្លូដហ្សាក់[១] នឹកស្មានថាលិង្គនេះ ជា "អ្នកតា" ហើយសរសេរថា ៖ "នេះគឺជាព្រះថ្មីមួយទៀត ផ្សេងពីព្រះទាំងឡាយរបស់ព្រហ្មញ្ញសាសនា" នេះហើយដែលគេឲ្យឈ្មោះថា "**ទេវរាជ**" ស្តេចរបស់ "អ្នកតា" ទូទៅ ដែលការពារទឹកដីស្រុកខ្មែរ ខុសពីព្រះផ្សេងៗ ដែលការពារមនុស្ស...! ។ អ្នកនិពន្ធបរទេសច្រើនទៀត បានបន្តនូវសេចក្តីអធិប្បាយ របស់លោកក្លូដហ្សាក់ ហើយផ្សាយតៗគ្នារៀងមកដល់សព្វថ្ងៃ ។ ថាអ្នកតា និងថាចម្លាក់ជាលិង្គ

---
[១] Claude Jacques : Angkor, Résidence des Dieux. op.cit. p. 62.

www.elibraryofcambodia.org

# លិង្គព្រះសិវៈ
## ឬ ព្រះឥសូរ



www.elibraryofcambodia.org

ផ្សាយតៗគ្នារហូតមកដល់សព្វថ្ងៃ ។ ថ្មអ្នកតា និងថ្មចម្លាក់ជាលិង្គព្រះសិវៈមិនដូចគ្នាទេ ខ្មែរណាក៏មិនច្រឡំរូបនេះដែរ ។

សិវៈលោកៈជាអ្វី ? មានអត្ថន័យយ៉ាងដូចម្តេច ? និមិត្តរូបអ្វីដែរ ?

នៅបរទេស គេឲ្យអត្ថន័យប្រាសាទនេះរបៀបយ៉ាងចំឡែក ។ លោកសាស្ត្រាចារ្យ "ម៉ារីឡីយ៉ា អាលបាណែស"[២] សរសេរថា ៖ "ប្រាសាទនៅភ្នំបាខែង គឺរូបភ្នំព្រះសុមេរុ ប៉ុន្តែនៅកន្លែងនេះពួកវិស្វករខ្មែរបានបង្ហាញនិមិត្តរូបផ្សេងៗទៀត តាមរបៀបយ៉ាងឆ្លាតដូចទិព្វ ។ ប្រាសាទតូចៗនៅភ្នំបាខែងមាន ១០៨ ដែលវិលជុំវិញប្រាសាទ ១ នៅកណ្តាល ។ លេខ ១០៨ គឺចំនួនទាំងអស់របស់សាកលលោក ។ ព្រះសិវៈ មានព្រះនាម ១០៨ ដែរ រីឯកម្រងកក្លឹង្គក៏មាន ១០៨គ្រាប់ទៀត ។ ប្រាសាទកណ្តាលខ្ពស់ជាងគេ គឺពិន្ទុ គឺកន្លែងកំណើតរបស់ "ពេលវេលា" និង "មេឃអាកាស" សរុបគឺកន្លែងកំណើតរបស់សកលលោកទាំងមូល ។

ក្នុងមួយជាន់ៗ មានប្រាសាទតូចចំនួន ១២ ហើយទាំងអស់មាន៦០ ។ ក្បួនហោរាសាស្ត្រចិន ដែលខ្មែរចម្លងមកមានសត្វ ១២។ ក្នុងក្បួនហោរាសាស្ត្រក្លឹង្គ ថ្ងៃព្រហស្បតិ៍វិលបានមួយជុំក្នុង ៦០ឆ្នាំ ដែលគេចែកជា **៥ រយៈ** ហើយរយៈនិមួយៗ មាន ១២ឆ្នាំ ។

ក្រៅពីយកលេខ យកចំនួនមកជានិមិត្តរូបផ្សេងៗ ប្រាសាទលើភ្នំបាខែងជានិមិត្តរូប សាសនាច្រើនទៀត ។ ប្រាសាទនេះមាន ៧ជាន់ ជាន់ទីមួយគឺកំពូលភ្នំបាខែង ៥ជាន់ទៀតគឺ ប្រាសាទមែន

---

[២] Marilia Albanése : Angkor. Splendeurs de l' Art khmer. op.cit. p. 164.

www.elibraryofcambodia.org

ទែន ជាន់ទី៧ គឺខឿនខាងលើបង្អស់ ដែលគេរាប់ប្រាសាទតូច ៥ ។ ភាព ៧ ជាន់នេះស្របត្រូវនឹងភ្នំព្រះសុមេរុ ដែលមាន ៧ជាន់ ហើយស្របទៅឋានទាំង ៧ របស់ព្រះក្លឹង្គផង ដែលគេហៅថា "**សប្តាលោកៈ**" ។ ដល់បញ្ចប់ទៅទៀត បើគេសម្លឹងមើលប្រាសាទចំពីមុខ ពីទិសខាងណាក៏ដោយ គេឃើញប្រាសាទតូចៗនោះតែ **៣៣** ទេ ឯព្រះធំៗ មានតែ **៣៣** ដែរ ។ ការអធិប្បាយនេះមានភាពអស្ចារ្យគួរឲ្យគេកោតសរសើរ ឲ្យគេមានការស្ងើចស្ងប់ស្ងែងពីប្រាជ្ញា និងការប៉ិនប្រសប់ ការឆ្លាតវៀងវៃរបស់ខ្មែរ (?) ... ។ រហូតមកដល់សព្វថ្ងៃ អ្នកប្រាជ្ញគ្រប់ស្រុកបានយល់ដូចលោកស្រី "អាលបាណែស" នេះទាំងអស់ ។

ការអធិប្បាយនៅបរទេស អំពីប្រាសាទលើភ្នំបាខែងនេះ មានការចំឡែកច្រើន ។ ប្រាសាទតូចៗដែលមាននៅទីនោះ មានទាំងអស់ **១០៩** មិនមែន **១០៨** ឬ **១០៨ + ១** ទេ ។ រឿងលេខ ១០៨ នេះទៀត ក៏ឥតបានន័យច្បាស់លាស់អ្វីផង បើនិយាយតាមអ្នកប្រាជ្ញទាំងនោះ ។ តាមលោកស្រី អាសបាណែស ១០៨ គឺ ជាចំនួនសាកលលោកទាំងអស់ (?) តាមលោក "ហ្សាំងឡោ"[៣] ១០៨ គឺមួយអាយុ (?) ដែលលោកច្រឡំនឹងមួយ "**កាល្ប**" ទៅទៀត ។ ការរំលឹកទៅដល់ព្រះធំៗ ៣៣ អង្គ មិនបានសមរម្យទេ ពីព្រោះព្រះ៣៣ គឺជាព្រះសាសនា"**វេទ**" (Vedisme) រីឯប្រាសាទលើភ្នំបាខែងជាប្រាសាទព្រហ្មញ្ញសាសនា ។ ការរាប់ថា ប្រាសាទនេះមាន ៧ជាន់ ដូចជាការ[illegible]មិនបានច្បាស់ទៀត ពីព្រោះគេរាប់ជើងប្រាសាទថា

---

៣ Jean Laur . op.cit. p. 116.

www.elibraryofcambodia.org

មួយជាន់ទៅហើយ យ៉ាងណាមិញ គឺថា បើគេសង់ផ្ទះនៅផ្ទាល់ដី គេមិនទុកថាផ្ទះនោះមាន ២ជាន់ទេ...ល ។

តាមការពិតរបស់ខ្មែរ សិវៈលោកៈ ជាឋានព្រះសិវៈ ឬព្រះឥសូរ ។ ប្រាសាទនេះគេសាងឡើង ដើម្បីថ្វាយព្រះសិវៈ ។ ទីមួយគឺអំពីរូបរាងប្រាសាទ ។ ប្រាសាទមានរូបរាងសាជី ហើយមានច្រើនជាន់ ។ ខ្មែរកាលជំនាន់នោះ គេឲ្យឈ្មោះថា "ភ្នំកៃលាស់" សំស្រ្កឹតថា "កៃលាសៈ"។ នៅលើផ្តាំងប្រាសាទ "បាយ័ន" ខាងឆ្វេងទ្វារចូលពីខាងកើត គេឃើញចម្លាក់ប្រាសាទមួយសំរៀបនេះ ហើយជាងឆ្លាក់ខ្មែរបានសរសេរបញ្ជាក់ថា "ភ្នំកៃលាស"។ រូបចម្លាក់ដដែលនេះ ដែលមានសរសេរថា "ភ្នំកៃលាស" មានម្តងទៀតនៅលើផ្តែរទ្វារខាងមុខប្រាសាទ "បន្ទាយស្រី" ([illegible]) ។ ប្រាសាទខ្មែររបៀបសាជី ហើយមានច្រើនថ្នាក់ គឺភ្នំកៃលាសទាំងអស់ នេះគឺតាមអ្នកសិល្បៈដែលបានធ្វើប្រាសាទ[illegible] ។ ភ្នំកៃលាស់ទៀតគឺអ្វី? គឺជាភ្នំដែលព្រះសិវៈគង់ [illegible] អង្គចុះពីលើមេឃមក ពីព្រោះ[illegible] ។ ការដែលគេសង់ប្រាសាទ តាមរូបភ្នំកៃលាស់ បានន័យថាគេសំដែងឲ្យឃើញថានេះ **គឺភ្នំរបស់ព្រះសិវៈ**។

ទីមួយទៀត គេបានដឹងថាព្រះសិវៈជាតំណាងវត្ថុធាតុប្រាំមាន "**ទឹក ដី ភ្លើង ខ្យល់ អាកាស**" និងទិសទាំងប្រាំគឺ "**កើត លិច ត្បូង ជើង និងខាងលើត្រង់**" ។ លេខ៥ គឺ លេខនិមិត្តរូបព្រះសិវៈ ។ នៅប្រាសាទសិវៈលោកៈ លេខ៥មាននៅគ្រប់ទីកន្លែងទាំងអស់ ។

---

[6] Henri Marshal. op.cit. p. 116.

www.elibraryofcambodia.org

ប្រាសាទសិរៈលោកៈ មាន ៥ ជាន់ (មិនមែន ៧ទេ) រួចប្រាសាទតូចៗបានគេសង់ដាក់ជាជួរប្រាំ-ប្រាំ មាន២ ជួរសង្ខាងទ្វារចូល ២ជួរអមជណ្ដើរនិមួយៗ ១ជួរពីក្រោម ឡើងទៅលើនៅមុំទាំងបួន ហើយនៅកំពូលខាងលើមានប្រាសាទតូចប្រាំ មួយនៅកណ្ដាលខ្ពស់ និងបួននៅទិសទាំងបួន ។ បូករួមមក គឺមានលេខ ៥ ៖

- ៨ ជួរនៅជើងប្រាសាទ
- ១២ ជួរនៅលើដងខ្លួនប្រាសាទ
- ១ នៅលើកំពូល

ទាំងអស់នេះសុទ្ធតែជានិមិត្តរូបព្រះសិវៈ ។ ប្រាសាទតូចៗមាន១០៩ (មិនមែន១០៨ ឬ ១០៨+១ ទេ) គឺជារូបព្រះសិវៈ១០៩អង្គ ពីព្រោះប្រាសាទតូចនិមួយៗ ក៏មានប្រាំជាន់ដែរ មានមួយជាន់មែនទែននៅខាងក្រោម បួនជាន់បញ្ឆោតនៅខាងលើ ដែលគេលំអរនឹងកម្រង ផ្កាឈូកមួយរង្វង់ ។

ព្រះសិវៈមានរូបជាលិង្គទៀត ពីព្រោះព្រះអង្គជាព្រះដែលបង្កើតជីវិតទូទៅ ។ នៅក្នុងប្រាសាទនៅលើកំពូល មានព្រះសិវៈជារូបលិង្គមាសមួយ ហើយក្នុងប្រាសាទ៤នៅជុំវិញនោះ ក៏មានគេតាំងលិង្គថ្ម៤ដែរ។

មហាក្សត្រយសោវរ្ម័នទី១ សាងប្រាសាទសិវៈលោកៈនេះ គឺព្រះអង្គទុកសម្រាប់គោរពបូជាដល់ព្រះសិវៈ ។ ប៉ុន្តែការស្ថាបនានេះមានន័យទីពីរមួយទៀត គឺថាប្រាសាទសិវៈលោកៈ ជាកន្លែងដែលគេបញ្ចុះសពមហាក្សត្រពេលដែលព្រះអង្គបានសុគតទៅ ។ ព្រះមហាក្សត្រយសោវរ្ម័នទី១ បានគេកប់នៅទីនេះមែន ដូចគេបាន

www.elibraryofcambodia.org

ឃើញផ្នូរព្រះអង្គនៅក្នុងប្រាសាទដែលខ្ពស់ជាងគេ ខាងក្រោមថ្មមានជម្រៅ២ម៉ែត្រ ។ ការដែលគេកប់សពមហាក្សត្រនៅទីនេះមិនមែនមានន័យថាប្រាសាទសិវៈលោកៈជាផ្នូរមហាក្សត្រទេ ។ នេះគ្រាន់ តែគេបង្ហាញឲ្យឃើញថា ព្រះមហាក្សត្របានចូលមកក្នុងឋានព្រះសិវៈហើយ ។ ដោយហេតុនេះឯង បានជាព្រះនាមមហាក្សត្រក្រោយពីសុគតគឺ "**បរមសិវៈ លោកៈ**" ប្រែមកថាព្រះអង្គដ៏ប្រសើរបានចូលដល់ឋានព្រះសិវៈ ។ តាមព្រហ្មញ្ញសាសនាចូលដល់ឋានព្រះ មានន័យថាអ្នកនោះមានជីវិតរហូតឥតស្គាល់សេចក្តីស្លាប់ទៀតទេ មានន័យថាអ្នកនោះចេញផុតពីកម្មពៀរទាំងឡាយ ចេញផុតពីកង់ "សំសារ" ចេញផុតពីឋានមនុស្សលោកហើយដែលអ្នកខ្លះនិយាយថា ទៅដល់ឋានសួគ៌ ឬទៅដល់ព្រះនិព្វាន ។ ការធ្វើដូច្នេះ ជាពិធីមួយស្របតាមព្រហ្មញ្ញសាសនាដែលមហាក្សត្រខ្មែរ ជំនាន់អង្គរតែងតែគោរពតាមគ្រប់ៗអង្គ ។

សរុបសេចក្តីទៅ សិវៈលោកៈមិនមែនភ្នំព្រះសុមេរុទេ ។ ប្រាសាទនេះ ជានិមិត្តរូបឋានរបស់ព្រះសិវៈដូចឈ្មោះដើមរបស់ប្រាសាទបានបង្ហាញមកស្រាប់ ។ ក្នុងប្រាសាទនេះគេបានកប់នៅកំពូលខាងលើបង្អស់ សពមហាក្សត្រយសោវរ្ម័នទី១ ដែលជាអ្នកស្ថាបនាប្រាសាទនេះឯង ។

www.elibraryofcambodia.org

# ផែនទីប្រាសាទ
# សីខៈលោកៈ ភ្នំបាខែង



គេឃើញលេខ ៥ នៅពាសពេញទាំងអស់

www.elibraryofcambodia.org

www.elibraryofcambodia.org

## វគ្គទី ១៨

# វិស្ណុលោកៈ ឬ អង្គរវត្ត

វត្តជាពាក្យមួយមកពីសៀម ហើយមានន័យថា លំនៅព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ។ អង្គរវត្តបានន័យថា វត្តព្រះពុទ្ធសាសនានៅអង្គរ ។

តាមការពិតអង្គរវត្តមិនមែនវត្តទេ ហើយអង្គរវត្តមិនមែនជារបស់ព្រះពុទ្ធសាសនាទាល់តែសោះ ។ ប្រាសាទនេះល្អជាងគេ និងល្បីល្បាញជាងគេ ក្នុងចំណោមប្រាសាទខ្មែរទាំងអស់ ហើយបានស្ថាបនាឡើងដោយព្រះមហាក្សត្រសុរិយវរ្ម័នទី២ ដែលគ្រងរាជពីឆ្នាំ១១១៣ ដល់ឆ្នាំ ១១៥០ ។

ឈ្មោះដើមប្រាសាទនេះគឺ "វិស្ណុលោកៈ" ប្រែមកថាឋាន ព្រះវិស្ណុ ឬព្រះនារាយណ៍ ដែលជាព្រះមួយអង្គធំរបស់ព្រហ្មញ្ញសាសនា ។

ក្រោយពីចម្បាំងសាសនាយ៉ាងសាហាវអស់រយៈ ១០០ ឆ្នាំ រវាងព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនាបានទទួលជោគជ័យបញ្ចប់ក្នុងឆ្នាំ ១៣៣៦ ។ ព្រហ្មញ្ញសាសនាត្រូវគេរលាយបាត់អស់ ។ ដល់ឆ្នាំ ១៤៣៤ ពញាយ៉ាតដែលសោយរាជ្យ

www.elibraryofcambodia.org

ក្នុងព្រះនាម **សុរិយោព៌្យ** យករាជធានីមកនៅភ្នំពេញវិញ ហើយបោះបង់ចោលអង្គរតែម្តង ។ ប្រាសាទទាំងឡាយឥតមានបានការថែទាំ ខ្លះត្រូវគេភ្លេចបាត់នៅក្នុងព្រៃ ខ្លះទៀតត្រូវលោកសង្ឃខាងព្រះពុទ្ធសាសនាយកមកធ្វើជាទីជម្រក ឬក៏ធ្វើក្លាយទៅជាវត្ត ។ ប្រាសាទវិស្ណុលោកៈ ក៏ត្រូវបានលោកសង្ឃចូលទៅគង់នៅដែរ ។ រូបចម្លាក់មហាក្សត្រ សុរិយវរ្ម័នទី២ ដែលគេឆ្លាក់ជាព្រះវិស្ណុ ហើយតាំងតំកល់ក្នុង ប្រាសាទខ្ពស់ជាងគេបង្អស់នោះ ត្រូវគេច្រានទម្លាក់បាក់បែក ខ្ទេចខ្ទីអស់មកខាងក្រោម ហើយគេយកព្រះពុទ្ធរូបមកដាក់ជំនួស ។ មានព្រះពុទ្ធរូបរាប់រយទៀត បានគេយកទៅតំកល់ពាសពេញក្នុងប្រាសាទវិស្ណុលោកៈ ។ នៅពេលដែលគេរៀបចំប្រាសាទនេះឡើង វិញ គេបានយកព្រះពុទ្ធរូបទាំងនោះ មកផ្តុំក្នុងកន្លែងមួយដែលសព្វថ្ងៃគេហៅថាច្រក "**ព្រះពាន់**" គឺថាមានព្រះមួយពាន់រូប ។ គេបានសង់វិហារពីរទៀត ដែលបាំងជិតផ្លូវចូលទៅប្រាសាទ នៅជាន់ខាងក្រោម ។ វិហារពីរនេះ ក៏បានគេយកចេញដែរ ហើយដែលសព្វថ្ងៃ គេអាចឃើញនៅក្រៅប្រាសាទមួយនៅខាងជើង មួយនៅខាងត្បូង ។ **គឺព្រះវិហារពីរនេះហើយដែលជាវត្ត** ហើយកាលពីដើមដំបូង គេហៅថា "**វត្តអង្គរ**" បាននិយាយថាវត្តនៅអង្គរ ។ ក្រោយមកទៀត វត្តអង្គរ ទៅជា "អង្គរវត្ត" រួចដល់ទីបំផុតអង្គរវត្តទៅជាឈ្មោះរបស់ប្រាសាទវិស្ណុលោកៈតែម្តង ។

នៅស្រុកបារាំង គេច្រើននិយាយថាអ្វីៗក៏ដោយ ដល់ចប់ទៅបានជាចម្រៀងទាំងអស់ ។ នៅស្រុកខ្មែរយើងអ្វីៗក៏ដោយ ក៏កើតមកពីរឿងព្រេងមួយជានិច្ច ។ អំពីប្រាសាទវិស្ណុលោកៈ នេះក៏គេបានពន្យល់មកតាមរឿងព្រេងមួយដែរ ។ កាលពីយូរណាស់មក

www.elibraryofcambodia.org

ហើយនោះ នៅស្រុកខ្មែរមានព្រះរាជបុត្រាមួយឈ្មោះ "កេតុមាលា" (កេតុ : គឺពន្លឺ មាលា គឺកម្រងឯក ហើយកេតុមាលាបានន័យថា កម្រងឯក ដែលភ្លឺខ្លាំង ) ដែលគេហៅថាព្រះកេតុមាលា ។ ក្សត្រាក្មេងនេះមានសម្រស់ល្អជាទីបំផុត ហើយមានវៃយ៉ាងឆ្លាតខ្លាំងទៀត ។ គុណភាពទាំងអស់នេះធ្វើឲ្យព្រះឥន្ទ្រ (*) សព្វព្រះហឫទ័យ ហើយព្រះអង្គយកព្រះរាជបុត្រានេះ ទៅគង់នៅជាមួយព្រះអង្គនៅឋានលើមេឃ ដែលមានប្រាសាទច្រើនល្អលើសលប់គ្មានអ្វីមកប្រៀបធៀបបាន ។ ដល់យូរក្រោយមក ព្រះកេតុមាលាក៏បានធំឡើង នាំឲ្យចំហាយមនុស្សរបស់ព្រះអង្គ ទៅរំខានអស់ដល់ទេវតីទេពអប្សរ និងព្រះស្ត្រីទាំងឡាយ ។ ព្រះឥន្ទ្រក៏ដាច់ព្រះហឫទ័យឲ្យព្រះកេតុមាលាយាងចុះមកស្រុកខ្មែរនៅឋានដីវិញ ។ ដោយសារព្រះឥន្ទ្រមានព្រះហឫទ័យស្រឡាញ់ព្រះកេតុមាលាពេក ព្រះអង្គប្រាប់មកព្រះកេតុមាលា ថាព្រះអង្គនឹងសាងប្រាសាទឲ្យមួយដូចនឹងប្រាសាទណាដែលព្រះកេតុមាលាពេញចិត្តទៅនោះ។ ដើម្បីនឹងកុំឲ្យគេថា ព្រះអង្គមានឫកស្មើនឹងព្រះ ព្រះកេតុមាលាជ្រើសរើស "**រោងគោ**" ព្រះឥន្ទ្រ ថានេះហើយជាប្រាសាទដែលព្រះអង្គចង់បាន។ ព្រះឥន្ទ្រក៏ចាត់ឲ្យព្រះពិស្ណុកា(**) ដែលជាវិស្វករឲ្យមកស្ថាបនា រោងគោនេះ ដែលគេហៅថារាជវាំង មានឈ្មោះថា "វិស្ណុ

---

(*) អ្នកខ្លះនិយាយថា ៖ ព្រះកេតុមាលា ជាបុត្រាព្រះឥន្ទ្រតែម្តង ដោយហេតុថាមានថ្ងៃមួយនោះ ព្រះឥន្ទ្រចុះមកយាងកំសាន្តក្នុងសួនច្បារនៅស្រុកខ្មែរ ហើយបានជួបនឹង ស្ត្រីខ្មែរម្នាក់ ដែលព្រះអង្គបានប្រទានសេក្តីស្នេហា នាំឲ្យកើតបានព្រះរាជបុត្រា នោះឯង ។

(**) ពិស្ណុកា មកពីពាក្យវិស្ណុលោកៈ ពីព្រោះអក្សរ "វ" សំស្ក្រឹតត្រូវនឹង "ព ឬ ភ" ខ្មែរ ដូច "វ្នំ" ទៅជាភ្នំ ។

www.elibraryofcambodia.org

លោកៈ" ។ នេះហើយជារឿងព្រេងដែលនាំឲ្យខ្មែរនិយាយថា ប្រាសាទ នេះបាន ព្រះឥន្ទ្រស្ថាបនាឡើង ។

វិស្ណុលោកៈមិនមែនព្រះរាជវាំងទេ ហើយមិនមែនជារោងគោដែរ ។ ប្រាសាទនេះគឺ ឋានព្រះវិស្ណុ ដូចមានឈ្មោះបង្ហាញឲ្យឃើញស្រាប់ ។ មហាក្សត្រសុរិយវរ្ម័នទី២ សាងប្រាសាទនេះក្នុងគោលបំណងពីរ ៖

- **បំណងទីមួយ** គឺសាងប្រាសាទថ្វាយព្រះវិស្ណុ ដើម្បីឲ្យបានបុណ្យក្នុងជាតិនេះផង ដល់ជាតិក្រោយផង ដោយហេតុនេះហើយបានជា ស្តេចបានរៀបចំធ្វើបុណ្យថ្វាយព្រះនៅទីនេះជាច្រើនដងដូចដែលគេបានឃើញចារឹកលើថ្មនៅទីនោះដែរ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ វិស្ណុលោកៈមិនមែនជាវិហារ ឬកន្លែង ដែលគេសម្រាប់ចូលមកគោរពបូជាព្រះ ដូចជាវិហារព្រះពុទ្ធសាសនានោះទេ ។

- **បំណងទីពីរ** គឺឲ្យបានទៅដល់ព្រះ ឬបានចូលទៅឋានព្រះកាលណាមហាក្សត្របានសុគតទៅ ។ ទៅដល់ព្រះគឺថា បានគេកប់នៅជិតព្រះ ។ ដោយហេតុនេះ ហើយបានជាមហាក្សត្រសុរិយវរ្ម័នទី២ បានគេបញ្ចុះធាតុព្រះអង្គនៅកណ្តាលប្រាសាទដែលខ្ពស់ជាងគេបង្អស់ ក្នុងវិស្ណុលោកៈ ។ ដោយហេតុនេះដែរ បានជាសុរិយវរ្ម័នទី២ បានទទួលព្រះនាមថា "**បរមវិស្ណុលោកៈ**" ក្រោយពេលសុគតទៅហើយ ដែលមានន័យថា "ព្រះអង្គដ៏ខ្ពង់ខ្ពស់អស្ចារ្យបានទៅឋានព្រះវិស្ណុ ( មហាក្សត្រខ្មែរមានព្រះនាម៣ គឺនាមកំណើតមួយ នាមពេលសោយរាជ្យមួយ និង នាមពេលសុគតទៅហើយមួយ ) ។ គេ

www.elibraryofcambodia.org

# វិស្ណុលោកៈ ឬ អង្គរវត្ត



ដែលមានកំពូល៥ យ៉ាងល្បីល្បាញ

www.elibraryofcambodia.org

បានដឹងហើយថា "ទៅដល់ឋានព្រះ ឬ រួបរួមជាមួយព្រះ" ក្នុងព្រហ្មញ្ញសាសនា បានន័យថាបានចេញផុតពីការកើតតៗ ដោយសារកម្មពៀរ បានចេញផុតពីកង់សំសារ ហើយបានចូលដល់ឋានមួយដែលឥតស្គាល់ការស្លាប់ ។ ដើម្បីនឹងបង្ហាញឲ្យឃើញថាមហាក្សត្របានរួបរួមជាមួយព្រះ គេឆ្លាក់រូបព្រះអង្គមួយយ៉ាងធំជា "ព្រះវិស្ណុ" ហើយគេតំកល់រូបនេះ ក្រោមកំពូលប្រាសាទខ្ពស់បង្អស់នៅវិស្ណុលោកៈ ។ អ្នកបរទេសច្រើនតែយល់ច្រឡំ ថារូបនេះជារូបព្រះវិស្ណុមែនទែន ហើយគេថាវិស្ណុលោកៈជាវិហារទៅវិញ។ នេះគឺមកពីការមិនបានស្គាល់ភាសាសិល្បៈចម្លាក់របស់ខ្មែរ ដែលខុសគេទាំងអស់ក្នុងពិភពលោក ។

និយាយអំពីរូបរាងប្រាសាទវិញ ខ្មែរស្ថាបនាតាមរបៀប ២ ៖ ប្រាសាទផ្ទាល់ដី និង ប្រាសាទមានកំពស់ដូចភ្នំ ។ ប្រាសាទផ្ទាល់ដីគឺប្រាសាទ ដែលគេតាំងឡើងលើខឿនទាបៗត្រឹម ០,៧០ ម៉ែត្រប៉ុណ្ណោះ ។ ប្រាសាទរបៀបនេះ មហាក្សត្រខ្មែរសង់សម្រាប់រំឭកដល់ មាតាបិតា ឬ ដល់ក្សត្រណាមួយពីមុន ។ ប្រាសាទព្រះគោ ឬប្រាសាទក្រវ៉ាន់ជាដើម សុទ្ធតែមានន័យរបៀបនេះ ។ ប្រាសាទដែលមានកំពស់ជាភ្នំ គឺប្រាសាទដែលស្ដេចស្ថាបនាឡើង សម្រាប់ខ្លួនឯងក្នុងពេលកំពុងសោយរាជ្យ ។ វិស្ណុលោកៈ ជាប្រាសាទរបៀបទី ២ ។ ប្រាសាទនេះជាប្រាសាទវិសេស ដែលល្អជាងប្រាសាទខ្មែរផ្សេងៗទាំងអស់ ។ ប្រាសាទនេះបានល្បីល្បាញពេញសាកលលោក ។ ប្រាសាទនេះមានកំពូល ៥ នៅយ៉ាងខ្ពស់ ដែលខ្មែរគ្រប់របបបានគោរព ហើយទង់ជាតិខ្មែរណាមួយក៏មានរូបប្រាសាទនេះ

www.elibraryofcambodia.org

ដែរ ។ គឺអ្នកថតរូបអង់គ្លេសម្នាក់ឈ្មោះ "ហ្សុនធំសន" ដែលសរសេរថា ប្រាសាទដែលខ្ពស់ជាងគេជាភ្នំព្រះសុមេរុ ហើយគឺលោក "សើដែស" ដែលបានអះអាងថា "កំពូលប្រាំនោះជាកំពូលភ្នំព្រះសុមេរុ ។ ការពិតប្រាសាទ ៥ នេះ ជានិមិត្តរូបព្រះសិវៈទេ ក្នុងន័យថា ព្រះអង្គជាតំណាងទិសទាំងប្រាំ ។ ប្រាសាទនីមួយៗ នោះក៏ជាព្រះសិវៈដែរក្នុងន័យថា ព្រះអង្គមានធាតុប្រាំ គឺ ទឹក ដី ភ្លើង ខ្យល់ និង អាកាស ។

វិស្ណុលោកៈ មានរូបភាពជាភ្នំ ដែលមានច្រើនជាន់ទៅលើ ។ ភ្នំនេះមានឈ្មោះថា "ភ្នំកៃលាស់" ដូចដែលអ្នកសិល្បករខ្មែរអង្គរបានបង្ហាញឲ្យដឹងតាមចម្លាក់លើផ្ទាំងប្រាសាទបាយ័ន និង លើខ្លោងទ្វារប្រាសាទបន្ទាយស្រី ។ ភ្នំកៃលាស់ គឺទីកន្លែងដែលព្រះសិវៈគង់ កាលពេលណាដែលព្រះអង្គចុះពីមេឃមក ។

វិស្ណុលោកៈ មិនមែនភ្នំព្រះសុមេរុទេ ។ រូបភាពប្រាសាទនេះមានន័យតាមសាសនា បង្ហាញឲ្យគេឃើញ និង គោរពព្រះសិវៈ ។ ការដែលគេគោរពព្រះសិវៈ ក្នុងប្រាសាទមួយដែលគេថ្វាយដល់ព្រះវិស្ណុ ឬព្រះនារាយណ៍ នោះឥតមានខុសអ្វីទាំងអស់ ចំពោះព្រហ្មញ្ញសាសនា ពីព្រោះព្រះវិស្ណុ ឬព្រះសិវៈ គ្រាន់តែជាភាពមួយរបស់ព្រះធំជាងគេគឺ "ព្រះព្រហ្ម" ។

គេមានការងឿងឆ្ងល់ច្រើនថា ហេតុអ្វីសិវៈលោកៈជាប្រាសាទតែមួយរបស់ខ្មែរ ដែលបែរមុខទៅខាងលិច ? តើមហាក្សត្រសុរិយវរ្ម័នទី២ ចង់បង្ហាញឲ្យដឹងថា ជាកន្លែងដែលគេកប់ធាតុព្រះអង្គ ? ក្រៅពីហេតុថាខាងលិចជាទិសព្រះវិស្ណុ តាមទំនៀម

www.elibraryofcambodia.org

ទំលាប់ខ្មែរខាងលិចគឺ ទិសខាងអ្នកស្លាប់ដែរ ។ ព្រះរាជវាំងជាដើម សុទ្ធតែបែរមុខទៅខាងកើតទាំងអស់ បែរទៅទិសព្រះអាទិត្យរះ ឡើង ។ លោកវេជ្ជបណ្ឌិតជាតិហុលឡង់ "បុស្សភ" (Bosch) បាន សំគាល់ឃើញថា ចម្លាក់លើជញ្ជាំងនៅជាន់ខាងក្រោមដែលរៀប រាប់ពីប្រវត្តិសាស្ត្រខ្មែរ និង រឿងព្រេងផ្សេងៗ បានគេឆ្លាក់មួយជុំ ប្រាសាទ ពីស្តាំទៅឆ្វេងផ្ទុយនឹងដំណើរម្ជុលនាឡិកា ។ បើគេចង់ មើលរឿងអ្វីៗឲ្យបានត្រឹមត្រូវ ឲ្យបានយល់ ទាល់តែគេចូលពីខាង លិច រួចដើរទៅខាងស្តាំ រួចទៅខាងកើត ហើយទៅខាងជើង រួចមក ខាងលិច មកដល់កន្លែងចូលវិញ ។ របៀបដើរជុំវិញនេះឲ្យឃើញ ដែរថា គេដាក់ដៃឆ្វេងទៅខាងក្នុងគឺ ខាងប្រាសាទធំកណ្តាល ហើយតាមទំនៀមទំលាប់ក្លិង្គគេហៅថា "ប្រសព្យ" ដែលគេធ្វើឡើង ក្នុងពិធីដង្ហែរសពខ្មោច ។ ប្រសព្យ មានន័យផ្ទុយពីប្រទក្សិណ ដែលគេហែរក្បួនជុំវិញព្រះ ហើយដែលគេទុកដៃស្តាំទៅខាងក្នុង គឺ ខាងព្រះ ។ ក្នុងពិធីដង្ហែរកឋិន គេធ្វើតាមរបៀបប្រទក្សិណ គឺគេ ដើរជុំវិញព្រះវិហារ ហើយគេដាក់ដៃស្តាំនៅខាងក្នុង ទៅខាងព្រះ ។

សម្រេចសេចក្តីទៅ អង្គរវត្តមិនមែនអង្គរវត្តទេ ។ ឈ្មោះ ពិតប្រាកដប្រាសាទនេះគឺវិស្ណុលោកៈ ។ ប្រាសាទនេះមិនមែនរបស់ ព្រះពុទ្ធសាសនាទេ គឺជា ប្រាសាទព្រហ្មញ្ញសាសនាសុទ្ធ សាធ ។ ប្រាសាទនេះមិនមែនជាវិហារ ឬ កន្លែងសម្រាប់គេទៅថ្វាយបង្គំព្រះ គោរពព្រះទេ ។ ប្រាសាទនេះជាការកសាងផ្ទាល់ខ្លួនរបស់មហា ក្សត្រសុរិយវរ្ម័នទី២ សម្រាប់ថ្វាយព្រះវិស្ណុ ដើម្បីឲ្យបានបុណ្យផល ដល់ព្រះអង្គ ។ ប្រាសាទនេះជានិមិត្តរូបឋានព្រះវិស្ណុនៅលើឋានដី មនុស្ស ។ ប្រាសាទវិស្ណុលោកៈ នៅទីបញ្ចប់គឺកន្លែងដែលត្រូវទទួល

www.elibraryofcambodia.org

សពមហាក្សត្រសុរិយវរ្ម័នទី២ ក្នុងន័យថាព្រះអង្គបានទៅដល់ឋាន ព្រះវិស្ណុ ព្រះអង្គបានចេញផុតពីសេចក្ដីស្លាប់ ចេញផុតពីកម្មពៀរ ទាំងឡាយ និង ពី "**ចំណងសំសារៈ**" ។

វិស្ណុលោកៈ ជាឋានព្រះវិស្ណុ ។

វិស្ណុលោកៈ ជាកន្លែងដែលទទួលធាតុមហាក្សត្រសុរិយ វរ្ម័នទី២ ។

www.elibraryofcambodia.org

www.elibraryofcambodia.org

## វគ្គទី ១៦

# ជ័យស្រី ឬ អង្គរធំ

គេដឹងថា ស្តេចខ្មែរកាលណាឡើងសោយរាជ្យគេយកនាមមួយថ្មី ហើយគេឲ្យនាមថ្មីនេះទៅអ្វីៗ ទាំងអស់ ដែលគេបានកសាងស្ថាបនាឡើងឲ្យតែរបស់នោះមានភាពជាសំខាន់ ។ ព្រះមហាក្សត្រជ័យវរ្ម័នទី ៧ ដែលសោយរាជ្យពីឆ្នាំ ១១៨១ ដល់ឆ្នាំ ១២២១ បានធ្វើរបៀបនេះដែរ ។ ព្រះអង្គសង់រាជធានីថ្មី លើកន្លែងរាជធានី ចាស់ដែលត្រូវបាក់បែកខូចខាតច្រើន ដោយសារមានការវាយប្រហារពីពួកចាម ក្នុងប៉ុន្មានឆ្នាំមុននោះ គឺនៅឆ្នាំ ១១៧៧ ។ ព្រះអង្គឲ្យឈ្មោះរាជធានីថ្មីនេះថា "ជ័យស្រី" មកពីព្រះនាមព្រះអង្គគឺ "ជ័យ" (ជ័យ គឺឈ្នះ ស្រី គឺខ្ពង់ខ្ពស់បំផុត ឬ ល្អអស្ចារ្យ ឬ សុភមង្គល) ។ ពាក្យសំស្ក្រឹតគេហៅក្រុងថា ន.គ.រ (អាន នៈ គៈ រៈ) ខ្មែរគេហៅថា នគរ។ ដោយសារថាក្រុងនោះធំខ្លាំង ប្រជារាស្ត្រខ្មែរក៏ឲ្យឈ្មោះថា "នគរធំ" ផ្ទុយនឹងវិស្ណុលោកៈដែលគេហៅថា "នគរតូច" ។ ដល់ទីបញ្ចប់ទៅនគរធំបានទៅជា "អង្គរធំ" ឈ្មោះដែលនៅរហូតមកដល់សព្វថ្ងៃ ។

គួរឲ្យកត់សម្គាល់ដែរថាពាក្យ "អង្គរ" មិនមែនពាក្យខ្មែរ ឬពាក្យសំស្ក្រឹតអ្វីទេ ទោះជាអ្នកខ្លះបាននិយាយថា ពាក្យនេះមកពី

www.elibraryofcambodia.org

ពាក្យសំស្ក្រឹត ន.គ.រ ក៏ដោយ ។ តាមលោក "ហាំងរីមារស្កាល"[១] គឺពួកអឺរ៉ុបនេះទេ ដែលបានប្រែក្លាយពាក្យនគរ ទៅជាអង្គរ ។ មុនដំបូងបង្អស់គឺលោកសង្ឃ អេសប៉ាញ៉ុល មួយអង្គឈ្មោះ "គ្រិស្តូវ៉ាលដឺហ្សាក់" (Cristoval de Jacque) បានសរសេរកាលឆ្នាំ ១៥៧០ ថា ក្រុងនោះឈ្មោះ "អង្គុយ" ដល់ឆ្នាំ ១៦៧២ លោកសង្ឃបារាំងមួយឈ្មោះ "ស្ហឺវ្រើល" (Chevreul) សរសេរថា ប្រាសាទនោះឈ្មោះ "អងកូ" ហើយល្អស្មើប្រាសាទសម្តេច ប៉ាបនៅក្រុងរ៉ូម ស្រុកអ៊ីតាលី ។ នៅឆ្នាំ ១៨៦១ បារាំងឈ្មោះ "ហាំងរីមូអោ" (Henri Mouhot) បានសរសេរអំពីប្រាសាទ "អុងកូរ" ដែលពួកអ្នកសារពត៌មានបារាំងប្រែជាទីបញ្ចប់ថា "អង្គរ" ក្នុងឱកាសពិពណ៌ក្រុង "បារីស" ឆ្នាំ ១៨៧៨ ។

ជ័យស្រី ឬ អង្គរធំ មិនមែនវិមាន ឬ ប្រាសាទទេ ជ័យស្រីជាក្រុង ។ ជ័យស្រីជាក្រុងមួយដែលមាន របៀបការពារដូចបន្ទាយទាហាន មានកំផែងថ្មខ្ពស់ ៨ ម៉ែត្រព័ទ្ធជុំវិញ ។ ទាំងអស់មានរាងបួនជ្រុងស្មើ ហើយជ្រុងម្ខាងៗ មានប្រវែង ៣ គីឡូម៉ែត្រ ។ នៅក្រៅកំផែងមានស្រះទឹកទទឹង ១០០ ម៉ែត្រព័ទ្ធជុំវិញទៀត ។ ក្រុងដែលពួកចាមបានបំផ្លាញប៉ុន្មានឆ្នាំមុននោះ ឥតមានស្រះព័ទ្ធជុំវិញទេ ហើយមានតែរបងឈើមួយតែ ប៉ុណ្ណោះ ។

ក្រុងជ័យស្រីមានទ្វារ ៥ ដូចៗគ្នាទាំងអស់ ។ មានទ្វារបួនទល់មុខគ្នា ពីជញ្ជាំងម្ខាងទៅជញ្ជាំងម្ខាង ហើយទ្វារនីមួយៗ នៅចំកណ្តាលកំផែងទាំងបួនទិស ។ ទ្វារខាងកើតបានទល់មុខនឹងទ្វារ

---

[១] Henri Marchal : Les Temples d' Angkor. Albert Guillot, Paris, op.cit. p. 24.

www.elibraryofcambodia.org

ខាងលិច ទ្វារខាងជើងបានទល់មុខនឹងទ្វារខាងត្បូង ។ ទ្វារទី ៥ នៅទិសខាងកើតដែរ ហើយនាំចូលត្រង់ទៅព្រះរាជវាំង ។ ទ្វារនេះមានឈ្មោះថា "ជ័យទ្វារ" មកពីពាក្យ "ជ័យៈ" ដែលជាព្រះនាមមហាក្សត្រជ័យវរ្ម័ន ។ បារាំងគេប្រែមកថា "**ទ្វារមានជ័យ**" (Porte de la Victoire) ។ នេះគឺមិនបានត្រឹមត្រូវទេ ពីព្រោះជ័យៈនេះមិនមែនចង់និយាយថា ឈ្នះនោះទេ ជ័យៈនេះគឺ ព្រះនាមមហាក្សត្រ ហើយទ្វារនេះត្រូវប្រែមកជា "ទ្វារជ័យៈ" ឬ "ព្រះរាជទ្វារ" ឬ "**ទ្វារជ័យវរ្ម័នទី ៧**" វិញ ។ ផ្លូវពីក្រៅចូលទៅទ្វារនីមួយៗ ត្រូវកាត់ឆ្លងស្រះ ដែលគេបានលប់ដីបំពេញនៅត្រង់នោះឲ្យមនុស្សដើរ ។ នៅសងខាងផ្លូវមានចម្លាក់ថ្មធំៗ អស្ចារ្យគួរឲ្យខ្លាច ជារូប "ទេពតា"ម្ខាងនឹងអសុរម្ខាងកំពុងទាញនាគមួយ ធំអស្ចារ្យដែរ ហើយដែលមានក្បាល ៧ ។ រូបទេពតា ទ្វារខាងកើតត្រូវទាញនាគផ្ទុយនឹងពួក "អសុរ" ទ្វារខាងលិច ហើយ "អសុរ" ទ្វារខាងលិចត្រូវទាញនាគទល់នឹងទេពតាទ្វារខាងកើត ។ ការតុបតែងទ្វារខាងជើងទល់នឹងទ្វារខាងត្បូង ក៏ដូចទ្វារខាងកើតនឹងខាងលិចដែរ ។

ខាងក្នុងក្រុង ផ្លូវពីទ្វារខាងកើតទៅទ្វារខាងលិច និង ផ្លូវពីទ្វារខាងជើងទៅទ្វារខាងត្បូង ខ្វែងគ្នានៅចំកណ្តាលក្រុងជ័យស្រី ហើយចែកក្រុងជា ៤ ភាគ បួនជ្រុងស្មើដែរ ។ ក្នុងភាគខាងជើងប៉ែកខាងលិច គឺកន្លែងព្រះរាជវាំង ។ វាំងមានទ្វារ ៥ ពីរខាងជើង ពីរខាងត្បូង ទ្វារទីប្រាំចេញមកចំ "ព្រះរាជទ្វារ" ខាងកើតដែលគេបានឃើញរួចហើយ ។ ផ្លូវចេញពីព្រះរាជវាំងនេះក៏មានឈ្មោះ "ជ័យៈ" ដែរ ដែលជាព្រះនាមមហាក្សត្រ ។ គេអាចហៅផ្លូវនេះថា "វិថីជ័យវរ្ម័ន" ឬ "ព្រះរាជវិថី" បាន មិនមែន "ផ្លូវមានជ័យ" ដូចបារាំងឲ្យ

www.elibraryofcambodia.org

នោះទេ ។ រនៅចំកណ្តាលក្រុង ដែលជាកន្លែងជួបជុំផ្លូវទៅពីទ្វារទាំងបួន គេបានសាងប្រាសាទមួយ ដែលសព្វថ្ងៃគេឲ្យឈ្មោះថា ប្រាសាទ "បាយ័ន" ។ មហាក្សត្រជ័យវរ្ម័នទី៧ កាន់ព្រះពុទ្ធសាសនាមហាយាន ។ ព្រះអង្គគោរពព្រះពុទ្ធផង គោរពព្រះពោធិសត្វផង ដែលជាអ្នកបានត្រះតាមព្រះពុទ្ធអង្គរួចហើយ ប៉ុន្តែមិនទាន់ចាកឋានមនុស្សទៅនិព្វានទេ ពីព្រោះចង់នៅឋាននេះ ដើម្បីជួយសង្គ្រោះដល់មនុស្សទូទៅ ។ ព្រះពុទ្ធសាសនាមហាយាន ទុកឋានលោកយើងជា "**ផ្ទះមួយកំពុងឆេះ**" ហើយពោធិសត្វជាអ្នកជួយយកមនុស្សចេញ ឲ្យផុតពីអណ្តាតភ្លើង ។ នៅប្រាសាទបាយ័ន ចម្លាក់ព្រះភក្ត្រចំនួន ២១៦ នៅលើកំពូល គឺសុទ្ធតែជាព្រះពោធិសត្វទាំងអស់ ដែលគេសំដែងគោរព ។ ពោធិសត្វនេះគេហៅថា "លោកេស្វរៈ"(*) ។ ជ័យវរ្ម័នទី៧ ពិតមែនតែកាន់ព្រះពុទ្ធសាសនា ព្រះអង្គគោរពព្រហ្មញ្ញសាសនាយ៉ាងច្រើន ។ នៅបាយ័នគេឃើញរូបចម្លាក់ព្រះទាំងឡាយរបស់ព្រហ្មញ្ញសាសនា ដូចជាព្រះវិស្ណុ និង ព្រះសិវៈជាដើម ដែលជាការមួយធ្វើឲ្យអ្នកបរទេសងឿងឆ្ងល់យ៉ាងខ្លាំង ។ ព្រះអង្គមានមហេសីមួយ ដែលជាបុត្រីព្រាហ្មណ៍មួយអង្គ មកពីស្រុកក្លិង្គ ។ ព្រាហ្មណ៍នោះបានទៅជាបូរោហិត និង ព្រះគ្រូមហាក្សត្រទៀតផង។

ហេតុអ្វីបានជាមហាក្សត្រជ័យវរ្ម័នទី៧ សាងប្រាសាទ "បាយ័ន" ? នេះក៏ជាទំនៀមទំលាប់ព្រហ្មញ្ញសាសនាដែរ ផ្ទុយគ្នានឹងសុរិយវរ្ម័នទី២ ដែលសាងវិស្ណុលោកៈ ។ ដើមហេតុទីមួយគឺ សង់

(*) "អវលោកិតេស្វរៈ" ជាពោធិសត្វមួយដែលហែរព្រះពុទ្ធនៅស្រុកជប៉ុន ហៅថា "អាមិដា" ឬ "ក្វាណន់"។ ពោធិសត្វខ្មែរមាន ឈ្មោះថា "លោកេស្វរៈ" ពីយរ៉ង្ស៊ុះ"។

www.elibraryofcambodia.org

សម្រាប់ថ្វាយព្រះ ដែលជាព្រះពុទ្ធនឹងពោធិសត្វទាំងឡាយ ដើម្បីឲ្យបានបុណ្យកុសលផ្សេងៗ ។ ហេតុទីពីរគឺ ព្រះអង្គបានគេកប់ធាតុព្រះអង្គនៅក្នុងប្រាសាទនេះ ដែលជាឋានរបស់ព្រះពុទ្ធ ហើយមានន័យថាព្រះអង្គបានចេញផុតពីកម្មពៀរទាំងអស់ ផុតពីកង់សំសារ សង្ខេបមកថាព្រះអង្គបានទៅដល់និព្វាន ។ មហាក្សត្របានគេបញ្ចុះធាតុព្រះអង្គមែន នៅកំពូលប្រាសាទខ្ពស់ជាងគេទាំងអស់ ដូចសុរិយវរ្ម័នទី២ នៅកំពូលប្រាសាទវិស្ណុលោកៈដែរ ។ ដូចសុរិយវរ្ម័នទី២ទៀត គេបានសាងរូបព្រះអង្គមួយយ៉ាងធំ ជារូបព្រះពុទ្ធគង់នៅលើនាគ "មុចិលិន្ទ" ក្បាល ៧ ដែលគ្របបាំងព្រះអង្គ កុំឲ្យត្រូវភ្លៀងខ្យល់ ហើយដែលគេតំកល់នៅក្រោមកំពូលប្រាសាទខ្ពស់ជាងគេទាំងអស់ ក្នុងប្រាសាទបាយ័ន ។ រូបថ្មចម្លាក់ជ័យវរ្ម័នទី ៧ ដែលមានកំពស់ ៣,៦០ ម៉ែត្រត្រូវគេវាយបាក់បែក ហើយទម្លាក់ក្នុងអណ្តូងក្នុងប្រាសាទ កាលពេលប្រឆាំងសាសនានៅស្រុកខ្មែរ ។ ក្នុងឆ្នាំ ១៩៣៥ លោក "ស្ហរត្រុវ៉េ" (Georges Trouvé) បានរកឃើញចម្លាក់ថ្មបាក់បែកនេះ ហើយលោកបានផ្គុំផ្សំឡើងវិញ ។ រូបនេះបានគេតាំងសព្វថ្ងៃ នៅខាងជើងផ្លូវចេញពីព្រះពធរាំងដែលមានឈ្មោះថា "វិថីជ័យវរ្ម័នទី៧" ។

អ្នកខ្លះយល់ច្រឡំថា រូបចម្លាក់ថ្មនេះ ជាព្រះពុទ្ធរូប ។ រូបនេះជារូបមហាក្សត្រជ័យវរ្ម័នទី៧ ទេ ។ ក្នុង "ភាសាសិល្បៈចម្លាក់ខ្មែរ" រូបមហាក្សត្រជាព្រះពុទ្ធមានន័យថាព្រះអង្គជាអ្នកកាន់ព្រះពុទ្ធសាសនាបានត្រឹមត្រូវ ហើយព្រះអង្គបានទៅតាមព្រះពុទ្ធក្រោយពេលសុគត ។ ដោយហេតុនេះឯង បានជាដល់សុគតទៅជ័យវរ្ម័នទី៧ មានព្រះនាមថា "**មហាបរមសុគតបាទ**" ប្រែមកថា ព្រះអង្គបាន

www.elibraryofcambodia.org

ទៅដល់ "ជើងព្រះពុទ្ធដែលជាអ្នកប្រសើរអស្ចារ្យ" ។ ក្នុងន័យនេះទៀត ប្រាសាទបាយ័នក៏ជាកន្លែងដែលគេបញ្ចុះធាតុព្រះមហាក្សត្រជ័យវរ្ម័នទី ៧ ដែរ ។ បញ្ចប់សេចក្ដីទៅ "ប្រាសាទបាយ័នគឺឋានព្រះពុទ្ធ" ហើយនៅក្នុងនោះគេបានកប់ធាតុជ័យវរ្ម័នទី៧ (*) ។

ខាងផ្នែកសិល្បៈសំណង់វិញ ជ័យស្រីជានិមិត្តរូប ២ យ៉ាង៖

- ជ័យស្រីជារូបសកលលោកមួយ ។
- ជ័យស្រីជាក្រុងតំណាងកន្លែងដែលផ្ដល់ឲ្យភាពមិនស្លាប់ ឬភាពអមត ដល់ជាតិខ្មែរទាំងមូល ។

**១- ជ័យស្រីជានិមិត្តរូបសាកលលោក ៖**

ជ័យវរ្ម័នទី ៧ ស្ថាបនាជ័យស្រីតាមរូបសកលលោក ។ តាមព្រហ្មញ្ញសាសនាក្នុងក្បួនធម៌ឈ្មោះ "ក្បួនបុរាណ" សាកលលោកមានភ្នំព្រះសុមេរុនៅកណ្ដាល ជុំវិញមានទ្វីប ៧ ដែលមានសមុទ្រចែកដាច់ពីគ្នា ។ នៅខាងក្រៅបំផុតមានភ្នំមួយជួរយ៉ាងខ្ពស់បាំងបិទឥតមានអ្វីមួយឆ្លងបានទេ ។

នៅជ័យស្រី ៖

- ប្រាសាទបាយ័ននៅកណ្ដាលគឺ ភ្នំព្រះសុមេរុ
- ទឹកស្រះជុំវិញកំផែងក្រុងគឺ សមុទ្រ
- កំផែងក្រុងជុំវិញគឺ ភ្នំជុំវិញសកលលោក

---

(*) បាយ័ន : ហៅប្រាសាទនេះថាផ្នូរខ្មោចមិនត្រូវទេ ។ នៅស្រុកបារាំង គេមានកប់ក្សត្រគេ ក្នុងវិហារជាច្រើន ហើយគេឥតហៅវិហារនោះថាផ្នូរទេ។

www.elibraryofcambodia.org

# ផែនទីជ័យស្រី
# អង្គរធំ




www.elibraryofcambodia.org

គឺមហាក្សត្រជ័យវរ្ម័នខ្លួនឯង ដែលបានឲ្យឈ្មោះស្រះនេះថា **ជ័យសន្ទុ** (សន្ទុគឺសមុទ្រ) ដែលមានជម្រៅទៅដល់ឋាន "នាគ" គឺឋានរបស់វាសុកិ ហើយនិងកំផែងក្រុងជា "**ជ័យគិរី** (គិរីគឺភ្នំ) ដែលមានកំពូលឡើងទៅដល់មេឃ" ។ ពាក្យទាំងអស់នេះគេបានឃើញលើចារឹកសីមាក្នុងប្រាសាទជ្រុង ដែលនៅបួនមុំក្រុងជ័យស្រី ។

**២- ជ័យស្រីជាកន្លែងផ្តល់ភាពឥតស្លាប់ដល់ខ្មែរ ៖**

ជ័យស្រីជានិមិត្តរូប "កន្លែងគេបង្វិលចម្រាញ់សមុទ្រទឹកដោះគោយកទឹកអម្រឹត" ។ គឺលោក "ប្រុណោដាហ្សាំង" កាលឆ្នាំ ២០០៥ ដែលបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ភាពនិមិត្តរូបនេះ ។ ក្រុងជ័យស្រី បង្ហូរទឹកអម្រឹតឲ្យមហាក្សត្រខ្មែរ ឲ្យព្រះរាជាណាចក្រខ្មែរ និងប្រជាជនខ្មែរទាំងអស់ ឲ្យបានគេចផុតពីសេចក្តីស្លាប់តែម្តង ។

តាមរឿងព្រេង "មហាភារតៈ" ដែលល្បីល្បាញអស្ចារ្យពីបូរាណកាលក្លឹង្គមក គេដឹងថាមានមួយថ្ងៃនោះ ព្រះវិស្ណុបង្គាប់ទេវៈ និង ពួកអសុរៈ ឲ្យរួបរួមគ្នាម្តងទៅ ដើម្បីនឹងបង្វិលចម្រាញ់សមុទ្រទឹកដោះគោឲ្យបានទឹក "អម្រឹត" ដែលធ្វើឲ្យគេចេញផុតពីសេចក្តីស្លាប់ កាលណាគេបានផឹកទឹកនេះ ។ នៅក្រុងជ័យស្រី ៖

- ប្រាសាទបាយ័នគឺ តំណាង "**ភ្នំមន្ទរៈ**" ដែលជាបង្គោលសម្រាប់បង្វិលចម្រាញ់ទឹកដោះគោ ។
- នាគក្បាល ៧ នៅទ្វារនីមួយៗ គឺនាគ "**វាសុកិ**" ដែលបានទទួលយកខ្លួនឯងឲ្យទេវៈ និង អសុរៈ ធ្វើជាខ្សែ

www.elibraryofcambodia.org

របៀបខ្សែព្រួរជុំវិញប្រាសាទបាយ័ន(*) ដើម្បីនឹងគេទាញចុះទាញឡើងចម្រាញ់ទឹកដោះគោ ។ អណ្ដើកមួយឈ្មោះ "គូមិ" អវតារព្រះវិស្ណុដែលទ្រភ្នំមន្ទរៈនៅលើខ្នងនៅខាងក្នុងដីទេ ហេតុនេះហើយបានជាគេមើលមិនឃើញ ។

<u>បញ្ចប់សេចក្ដីទៅគឺៈ</u>

អង្គរធំមិនមែននគរធំទេ ។ អ្នកស្រុក ហៅថា នគរធំ ។ ឈ្មោះដើមគឺ "ជ័យស្រី។ ជ័យស្រី គឺជា រាជធានី ។ ជ័យស្រី គឺជាក្រុង ។ ជ័យស្រីបានគេស្ថាបនាមកជា រូបសកលលោកផង និង រូបទីចម្រាញ់សមុទ្រទឹកដោះគោផង ។ ប្រាសាទបាយ័ន ជានិមិត្តរូបភ្នំព្រះសុមេរុ និង ភ្នំមន្ទរៈ ។

---

(*) ក្នុងសៀវភៅមួយឈ្មោះ "Pour mieux comprendre Angkor" លោក "សើដេស" សរសេរថាទ្វារអង្គរនីមួយៗគឺជាភ្នំ មន្ទរៈ ហើយនាគបានរុំខ្លួនលើទ្វារនោះ ។ នេះគឺជាការច្រឡំ ។

www.elibraryofcambodia.org

www.elibraryofcambodia.org

## វគ្គទី ១៧

# ព្រះបាទនៅស្រុកខ្មែរ

នៅស្រុកខ្មែរ ជើង មានភាពសំខាន់យ៉ាងខ្លាំង ។ ខ្មែរហៅជើងថា "បាទ" ពីព្រោះពាក្យនេះចេញមកពីពាក្យសំស្ក្រឹត "បាទៈ" ភាសាក្លីង្គប្រែមកថាជើងដូចគ្នា ។ កាលណាជើងមានតម្លៃច្រើន មានភាពសំខាន់ខ្លាំង មានការឲ្យគេគោរពខ្លាំង គេដាក់ពាក្យ "ព្រះ" នៅពីមុខ ហើយជើងបានទៅជា "ព្រះបាទ" ។

តាមការពិតព្រះបាទ គឺ "ជើងរបស់ព្រះ" ។ ក្នុងព្រហ្មញ្ញសាសនា គេច្រើននិយាយថា "ព្រះគ្រប់គ្រងលើសកលលោកទាំងមូល ហើយព្រះអង្គសម្រាកជើងលើក្បាលអ្នកដែលកាន់សិល កាន់ធម៌ត្រឹមត្រូវ" ។ ក្នុងព្រហ្មញ្ញសាសនានេះទៀត ដើម្បីនឹងចេញផុតពីសេចក្តីស្លាប់ ពីកម្មពៀរទាំងឡាយ ពីចំណងកង់សំសារ ទាល់តែគេបានទៅដល់ឋានរបស់ព្រះ ឬ មួយទៅដល់ព្រះបាទរបស់ព្រះ ។ ទៅដល់ជើងព្រះ គឺទៅដល់ឋានសួគ៌ហើយ ។ ហេតុនេះបានជាក្នុងព្រហ្មញ្ញសាសនា អ្នកណាក៏ចង់ទៅដល់ជើងព្រះដែរ ដូចអ្នក

www.elibraryofcambodia.org

កាន់សាសនាកាតូលិក ដែលគេប្រាថ្នាឲ្យបានទៅដល់ខាងស្ដាំព្រះរបស់គេ ។

នៅស្រុកខ្មែរ ពីសតវត្សរ៍ទី ១ ដល់សតវត្សរ៍ទី ១៤ ខ្មែរកាន់ព្រហ្មញ្ញសាសនា ។ សាសនានេះជាសាសនារបស់រដ្ឋ របស់មហាក្សត្រ ។ ដល់ពេលសុគតទៅ មហាក្សត្រខ្មែរតែងតែទៅឋានសួគ៌គ្រប់ៗអង្គ គឺថា "**បានទៅដល់ព្រះបាទព្រះ**" ។ សេចក្ដីទាំងអស់នេះ គេឃើញច្បាស់ក្នុងព្រះនាមមហាក្សត្រនីមួយៗ ក្រោយពេលដែលព្រះអង្គសុគតទៅ ។ ជ័យវរ្ម័នទី ៥ ក្រោយពេលសុគតមានព្រះនាមជា "បរមសិវៈបាទ" ប្រែមកថា ព្រះអង្គបានទៅដល់ព្រះបាទព្រះសិវៈដ៏ប្រសើរខ្ពង់ខ្ពស់ ។ មហាក្សត្រជ័យវរ្ម័នទី៨ ដែលព្រះនាមជា "**បរមឥស្វរៈបាទ**" មានន័យដូចគ្នាដែរ គឺថាព្រះអង្គបានទៅដល់ "ព្រះបាទព្រះសិវៈដ៏ប្រសើរខ្ពង់ខ្ពស់ (ឥស្វរ = សិវៈ)" ។ មហាក្សត្រ យសោវរ្ម័នទី១ មានព្រះនាមក្រោយពេលសុគតជា "បរមសិវៈលោកៈ" គឺថាព្រះអង្គបានទៅដល់ឋានព្រះសិវៈដ៏ប្រសើរ (លោកៈ = ឋាន) ។ មហាក្សត្រសុរិយវរ្ម័នទី ២ ដែលមានព្រះនាម "បរមវិស្ណុលោកៈ" មានន័យថាព្រះអង្គបានទៅ "ឋានព្រះវិស្ណុដ៏ប្រសើរខ្ពង់ខ្ពស់" ។ គេបានឃើញរួចមកដែរ ថាទៅដល់ឋានរបស់ព្រះ ឬ ទៅដល់ព្រះបាទព្រះ មានន័យដូចគ្នា ។

ជំនាន់ព្រហ្មញ្ញសាសនា នៅស្រុកខ្មែរមានមហាក្សត្រខ្លះកាន់ព្រះពុទ្ធសាសនាដែរ ដូចមហាក្សត្ររុទ្រវរ្ម័ន និង ជ័យវរ្ម័នទី ៧ ជាដើម ។ ព្រះពុទ្ធសាសនានៅពេលនោះគឺ ព្រះពុទ្ធសាសនាមហាយាន ដែលគោរពទំនៀមទម្លាប់ព្រហ្មញ្ញសាសនាច្រើន ។ ដោយ

www.elibraryofcambodia.org

ហេតុនេះបានជាមហាក្សត្រជ័យវរ្ម័នទី ៧ ក៏បានទៅជា "ព្រះបាទ" ព្រះដែរ នៅពេលព្រះអង្គសុគតទៅ ។ ព្រះនាមក្រោយពេលសុគត របស់ជ័យវរ្ម័នទី ៧ គឺ "មហាបរមសុគតបាទ" ប្រែមកជាព្រះអង្គបាន ទៅដល់ព្រះបាទព្រះពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់(*) ។

ជំនាន់ព្រហ្មញ្ញសាសនា គេដាក់ពាក្យ "ព្រះបាទ" ឲ្យមហាក្សត្រតែក្រោយពីពេលមហាក្សត្របានសុគតរួចទេ ពីព្រោះព្រះបាទនេះគឺជើងរបស់ព្រះ ហើយមហាក្សត្របានទៅដល់ជើងព្រះ ។ ក្រោយជំនាន់អង្គរ គេយកពាក្យ "ព្រះបាទ" ដាក់ឲ្យមហាក្សត្រខ្មែរទាំងអស់ ក្នុងពេលព្រះអង្គនៅរស់ នៅសោយរាជ្យនៅឡើយ ។ មហាក្សត្រខ្មែរសព្វថ្ងៃជាដើម មានព្រះនាមថា **"ព្រះបាទ សម្តេចព្រះបរមនាថនរោត្តមសីហមុនី"** ។ ព្រះបាទនេះ មិនមែនជើងព្រះទៀតទេ ព្រះបាទនេះគឺជើងរបស់មហាក្សត្រ ។

ហេតុដែលមានភាពពីរខុសគ្នានេះ មកពីក្នុងព្រាហ្មញ្ញសាសនាមហាក្សត្រមិនមែនព្រះទេ ហើយចុះពីព្រះគឺមកដល់ព្រាហ្មណ៍សិន ទើបដល់ក្សត្រ ។ សង្គមមនុស្សបានគេចែកជាបួនវណ្ណៈ គឺ ព្រាហ្មណ៍ ក្សត្រ វៃស្យ សូទ្រ ។ អ្នកបរទេសជាច្រើនយល់ច្រឡំថា ស្តេចអង្គរជាព្រះអាទិទេព ដោយសារគេឲ្យងារថា "ទេវរាជ" ។ មហាក្សត្រមានព្រះនាមជា **"ម៉ាន"** ឬ **"ម័ន"** គឺ

---

(*) សុគត គឺពាក្យសំស្ក្រឹតមានន័យថាព្រះពុទ្ធ ។ ខ្មែរកាន់ព្រះពុទ្ធសាសនា យកមកប្រើក្នុងន័យថា "ស្លាប់" សម្រាប់ស្តេច ឬ ព្រះសង្ឃ ។ និយាយថា ស្តេចសុគត មានន័យត្រឹមត្រូវថាស្តេចបានយាងទៅដល់ព្រះពុទ្ធ ។ នេះជាទំនៀមទំលាប់ព្រហ្មញ្ញសាសនាដែរ ។

www.elibraryofcambodia.org

មនុស្សទាំងអស់ដូចឥសានវរ្ម័ន យសោវរ្ម័ន ឬ ជ័យវរ្ម័ន ..ល។ ដល់ពេលសុគតមហាក្សត្រទាំងអស់ ក៏បានទៅដល់ "ព្រះបាទព្រះ" គ្រប់ៗអង្គ។ ក្នុងព្រះពុទ្ធសាសនា "ហ៊ិនយាន" គេឥតទទួលថាមានព្រះទេ។ ព្រះព្រហ្មណ៍ ព្រះនរាយណ៍ ព្រះឥសូរ មិនមែនព្រះទៀតទេ ។ ព្រះពុទ្ធអង្គខ្លួនឯងក៏មិនដែលទុកព្រះអង្គជាព្រះផងដែរ ។ ក្រោយអង្គរ ក្នុងរបបព្រះពុទ្ធសាសនា "ហ៊ិនយាន" ឥតមានព្រាហ្មណ៍ ទៀត ។ ដោយហេតុថា ឥតមានព្រាហ្មណ៍ និង ឥតមានព្រះ មហាក្សត្រក្រោយអង្គរបាននៅកន្លែងខ្ពស់ជាងគេទាំងអស់ គឺជាកន្លែងព្រះ ហើយព្រះបាទពេលនេះគឺ "ព្រះបាទរបស់មហាក្សត្រ" ។

ពិតមែនតែលែងមានភាពជាជើងព្រះទៅទៀតក៏ដោយ នៅស្រុកខ្មែរ "ព្រះបាទ" នៅតែមានតម្លៃអស្ចារ្យ ។ "ព្រះបាទ" គឺនិមិត្តរូបរបស់កម្លាំងខ្លាំង របស់មហាឫទ្ធានុភាព ។ ដោយហេតុនេះដែរ បានជាមានតែក្សត្រសោយរាជ្យទេ ដែលមានព្រះនាមថា "ព្រះបាទ" ។ ក្នុងព្រះរាជាណាចក្រខ្មែរ គ្មានអ្នកណាមួយអាចមានឈ្មោះថា "ព្រះបាទ" បានទេ ទោះជាអ្នកនោះមានវណ្ណៈខ្ពស់យ៉ាងណាក៏ដោយ ។ ព្រះរាជបុត្រាស្ដេចក៏គ្មានសិទ្ធិ ឲ្យគេហៅថា "ព្រះបាទ" ដែរ ។

ព្រះបាទគឺ "ជើង" ។ តាមសេចក្ដីគោរព កាលណាខ្មែរមានការទាក់ទងជាមួយមហាក្សត្រ គេនិយមចង្អុលបង្ហាញខ្លួនគេថា "ខ្ញុំក្រោមល្អងធូលីព្រះបាទ!..." ប្រែមកថាគេជាអ្នកបម្រើនៅក្រោមល្អងធូលីជើងមហាក្សត្រនោះ ។ ឃ្លានេះក៏មិនមែនទើបនឹងមាននោះដែរ ។ កាល "ព្រះបាទ" នៅជាជើងព្រះនៅឡើយ ក្នុងឆ្នាំ ៦០៦

www.elibraryofcambodia.org

ហើយក្នុងបំណងនឹងសងសឹកឲ្យបងព្រះអង្គ ដែលត្រូវគេលួចសម្លាប់ មហាក្សត្រក្លឹង្គ"ហសិរវធនៈ" បានស្បថថា ៖ នៅក្រោមល្អងធូលីព្រះបាទរបស់ព្រះ ខ្ញុំសូមស្បថថា បើក្នុងប៉ុន្មានថ្ងៃខាងមុខនេះ ខ្ញុំមិនបានកំចាត់ពួក "គ្លោដ" នៅនគរ "បងក្តាល" ឲ្យចេញផុតពីផែនដីទេ ខ្ញុំនឹងលោតចូលភ្លើងឲ្យស្លាប់ដូចសត្វល្អិត ដែលលោតចូលភ្លើងចង្កៀងដែរ "អ.ដាញ៉េឡូ"[៦] ។ នៅស្រុកខ្មែរ កាលឆ្នាំ ៧១៣ មហាក្សត្រជ័យទេវី ច្រើនប្រើពាក្យថា "ក្រោមល្អងធូលីជើង **កន់រ៉ាដែង** អញ្ញ"[*] ។

ក្នុងការរស់នៅរៀងរាល់ថ្ងៃ ខ្មែរមានប្រើពាក្យ "ព្រះបាទ" ច្រើនដែរ ។ កាលណាខ្មែរសុខចិត្តអ្វីមួយ គេឆ្លើយថា "បាទ" ។ ជាមួយអ្នកដែលមានថ្នាក់ខ្ពស់ជាងខ្លួនគេ គេនិយាយថា "ព្រះបាទ" ។ ដែលគេប្រើពាក្យ "បាទ" នេះមានន័យថា គេសុខចិត្តដាក់ក្បាលគេនៅក្រោម "ជើង" អ្នកដែលនិយាយជាមួយគេនោះឯង ។ ដាក់ក្បាលនៅក្រោមជើងគឺទទួលយល់ព្រម គឺទទួលថាអ្នកនោះមានភាពខ្ពស់ជាង ។ ភាពនេះគឺគ្រាន់តែបង្ហាញការគោរពរបស់គេទេ ដូចគេដាក់ក្បាលគេក្រោមព្រះបាទរបស់ព្រះ ។ ភាពនេះមិនមែនជាការអន់ទាបអ្វីទេ ដូចគេបានឃើញចម្លាក់ថ្មនៅអង្គរពីព្រះអគ្គមហេសី **"ជ័យរាជទេវី"** ដែលដាក់ប្រគេសព្រះអង្គក្រោមជើងមហាក្សត្រជ័យវរ្ម័នទី ៧ ។ គេត្រូវសំគាល់ដែរថា ក្សត្រខ្មែរឥតឆ្លើយថា **"បាទ"**

---

[៦] Alain Daniélou : op.cit. p. 198.

[*] កន់រ៉ាដែង គឺពួកអ្នកអស្ចារ្យ។ រ៉ាដែង មកពីពាក្យស្តែង ចែង ...ល ។ អ្នកបរទេសឥតស្គាល់ពាក្យនេះទេ ។

www.elibraryofcambodia.org

ទេ គេឆ្លើយថា "ចាស" វិញ ដែលជាពាក្យមួយដូចបាទដែរ តែសម្រាប់ស្ត្រី ឬ ភេទស្រី ។ ស្តេច ឬ ក្សត្រខ្មែរប្រើពាក្យសម្រាប់ស្ត្រីនេះ គឺមកពីការគោរពទំនៀមទំលាប់ដើមរបស់ខ្មែរ ដែលកាន់របបមាតានិយម ហើយដែលស្តេចសុទ្ធតែជាស្ត្រី ។

ភាពមួយយ៉ាងទៀតគឺ ជើងមិនមែនគ្រាន់តែជានិមិត្តរូបវិទ្ធានុភាពទេ ។ ចំពោះខ្មែរជើងក៏ជានិមិត្តរូប "ភាពថ្លៃថ្នូរ" ដែរ ។ កាលជំនាន់ដើម ខ្មែរមិនឲ្យកិត្តិយសទៅដល់អ្នកណាដែលឥតមានជើងទេ ។ អ្នកដែលអត់មានម្រាមជើង ក៏ដូចអ្នកដែលអត់មានជើងដែរ គឺឥតមានតម្លៃអ្វីទាំងអស់ ។ ចិន "ជូតាក្វាន់" បានសរសេរថា "កំផែងក្រុងមានទ្វារប្រាំ ហើយគេហាមឃាត់ មិនឲ្យចូលតែសត្វឆ្កែ និងឧក្រិដ្ឋជនដែលគេកាត់ម្រាមជើងនោះទេ" ។ ជូតាក្វាន់ដដែលនេះបានសរសេរទៀតថា "មហាក្សត្រ"សព្វថ្ងៃ(*) ជាកូនប្រសារមហាក្សត្រពីមុន ។ ដើមឡើងព្រះអង្គជាអ្នកកាន់ទ័ព ។ មហាក្សត្រមុនស្រឡាញ់ ព្រះ រាជបុត្រីណាស់ ។ ព្រះរាជបុត្រីលួចព្រះខ័នរាជ្យឲ្យទៅព្រះស្វាមីដែលបានឡើងសោយរាជ្យទៅ ។ ព្រះរាជបុត្រមហាក្សត្រអត់បាន ទទួលរាជជាកេរ្តិ៍ទៀត ។ មហាក្សត្រថ្មីកាត់ម្រាមជើងព្រះរាជបុត្រនោះអស់ រួចដាក់ព្រះអង្គក្នុងបន្ទប់មួយយ៉ាងងងឹត ។ បញ្ចប់សេចក្តីទៅក្សត្រអត់ម្រាមជើង ក៏អត់បានឡើងសោយរាជ្យដែរ ។

---

(*) អ្នកខ្លះយល់ថាមហាក្សត្រនេះជា "តាត្រសក់ផ្អែម" ដែលបានសម្លាប់ឪពុកក្មេក ព្រះបាទសិរីហរិនុមហារាជាធិរាជ ប៉ុន្តែឆ្នាំ ១២៩៥ មិនបានស្របត្រឹមត្រូវតាមប្រវត្តសាស្ត្រ និងតាមចារឹកអក្សរខ្មែរទេ ។

www.elibraryofcambodia.org

## វគ្គទី ១៨

# ការពិត និង រឿងព្រេងខ្មែរ

និយាយអំពីជាតិក្លិង្គ លោក ម.គ្លេស (Maurice Glaize) សរសេរកាលឆ្នាំ ១៩៥៣ ថា "គេចូលចិត្តរឿងព្រេងជាទីបំផុត ពីព្រោះគេមិនដឹងថា អ្វីដែលជាការពិតរបស់ប្រវត្តិសាស្ត្រទេ។ ចំពោះជាតិនេះរឿងនិទាន និង ការពិតគឺដូចគ្នា ។ ជួនកាលរឿងព្រេងបានគេយល់ថាជាការពិត ជួនកាលការពិត គេនិទានទៅជារឿងព្រេងទៅវិញ ។ ពាក្យទាំងនេះគេអាចនឹងយកមកប្រើជាមួយខ្មែរបានដែរ ពីព្រោះខ្មែរក៏មានដើមកំណើតនៅក្នុងទ្វីបឥណ្ឌា រួចបានធ្វើតាមវប្បធម៌ក្លិង្គយ៉ាងល្អិតល្អន់ជាង ១៣ សតវត្សរ៍ទៀត ។ ប៉ុន្តែបើគេពិនិត្យឲ្យបានហ្មត់ចត់ គេអាចនឹងរកឃើញការពិតនៅក្នុងរឿងព្រេង ឬ រឿងព្រេងនៅក្នុងការដែលគេថាពិតដែរ ។ រឿងខ្លះៗ ខាងក្រោយនេះ បង្ហាញឲ្យឃើញរបៀបខ្មែរ ហើយឲ្យគេកុំភ្លេចថាការអ្វីមួយដែលគេយល់ថាមិនសម មិនមែនមានន័យថាជាការខុសទេ ។

### ១. នាគឈ្មោល ឬនាគញី ?

រឿងនេះជារឿងដែលចិនជូតាក្វាន់សរសេរ ហើយដែលលោក "ប៉ូល ប៉េឡឺអូត៍" ប្រែមកជាភាសាបារាំង ដែលមានន័យដូចតទៅ ៖ ក្នុង

www.elibraryofcambodia.org

ព្រះរាជវាំងមានប្រាសាទកំពូលមាសមួយ ។ នៅពេលយប់ មហាក្សត្រឡើងទៅទទួលដំណេកនៅទីនោះ ។ អ្នកស្រុកនិយាយថាក្នុងប្រាសាទមាននាគមួយក្បាល ៩ ដែលជាម្ចាស់ទឹកដីទាំងអស់ក្នុងនគរ ។ គ្រប់រាល់យប់នាគនេះក្លាយខ្លួនចេញមកជាស្ត្រីម្នាក់ ។ មហាក្សត្រ "រួបរួមខ្លួនកាយ" ហើយផ្ទំដំណេកជាមួយនាគ ។ ដល់កណ្តាលយប់មហាក្សត្រទើបយាងចេញ ហើយព្រះអង្គអាចនឹងចូលទៅផ្ទំដំណេកបានជាមួយមហេសី ឬជាមួយនាងស្នំណាមួយ។ បើមានយប់ណាមួយដែលស្តេចមិនបានមកទេ នោះគឺជាមានគ្រោះអាក្រក់មួយមកដល់ជាមិនខាន ។ បើយប់ណាមួយនាគនោះមិនបានចេញមកទេ នេះគឺពេលអស់ជីវិតរបស់ស្តេច មកដល់ហើយ ។

មានអ្នកនិពន្ធជាច្រើនឆ្ងល់ថាតើនាគនោះឈ្មោល ឬ ញី ។ អ្នកខ្លះទៀតថានាគិនី ។ ការងឿងឆ្ងល់នេះ ពុំសូវមានន័យអ្វីទេ ម្យ៉ាងទៀតអ្នកស្រុកបាននិយាយយ៉ាងច្បាស់ថា "នាគបានខ្លែងខ្លួនជាស្ត្រីមួយ" ។ ការពិត ប្រាសាទនេះជាទីសំខាន់មួយធំ ចំពោះមហាក្សត្រខ្មែរនៅអង្គរ ។ ក្សត្រខ្មែរកាន់ព្រហ្មញ្ញសាសនា គេធ្វើបុណ្យថ្វាយព្រះដោយដង្ហែរក្បួន ដាក់ទានដល់ព្រាហ្មណ៍ ហើយនិងបូជាវត្ថុ ឬ សត្វផ្សេងៗ ។ ប្រាសាទនេះឈ្មោះ **"ភិមានាកាស"** ។ ប្រាសាទនេះជាកន្លែងសម្រាប់រំឮកដល់វិញ្ញាណក្ខន្ធ ម្តាយ-ឪពុកដែលជាទំនៀមទំលាប់ខ្មែរ ពីបូរាណកាលមក រំឮកដល់អ្នកបង្កើតនគរខ្មែរ និងពូជពង្សស្តេច គឺយាយលីវ ដែលមានព្រះនាមថា "សោម៉ា" ក្រោយពីបានទៅជាអគ្គមហេសីកោណ្ឌិន្យ ។ គេនៅចាំបានថា

www.elibraryofcambodia.org

មហាក្សត្រីនេះ ជាបុត្រីស្តេចនាគ ដែលសោយរាជនៅបាតាលមហាសមុទ្រ ។

## ២. ឆាន់ថាន

នេះក៏ជារឿងមួយដែលអ្នកសមាជិកទូតចិន "ជូតាក្វាន់" សរសេរដែរ ។ ខាងក្រោមនេះគឺ សេចក្តី សង្ខេបដែលលោក "ប៉ូល ប៉េឡីអូត៍" បកប្រែមក ៖

"ក្នុងគ្រួសារអ្នកមាន កាលណាកូនស្រីគេមានអាយុពី ៧ ទៅ ៩ ឆ្នាំ គេនិមន្តព្រះសង្ឃមួយអង្គ មកបង្ខូចព្រហ្មចារីយ៍ ។ កូនស្រីគ្រួសារក្រត្រូវចាំដល់អាយុ ១១ ឆ្នាំ ។ បុណ្យនេះគេហៅថា **"ឆាន់ថាន"** ។ ព្រះសង្ឃថ្នាក់ខ្ពស់ៗ បានគ្រួសារនាម៉ឺន មន្ត្រី និង គ្រួសារអ្នកមានទ្រព្យសម្បត្តិច្រើន និមន្តបញ្ជាំទុកយូរខែយូរឆ្នាំរួចហើយ ។ ចំណែកអ្នកក្រវិញ គេឥតមានភ័ព្វសំណាងនឹងជ្រើសរើសអ្វីទេ ហើយគេនិមន្តព្រះសង្ឃណា ដែលនៅសល់នោះទៅ ។ គ្រួសារនាម៉ឺន មន្ត្រី និង គ្រួសារអ្នកមានគេប្រគេនដល់ព្រះសង្ឃរបស់ផ្សេងៗ ដូចជា ស្រូវ អង្ករ ស្រា ក្រណាត់សូត្រ ស្លាម្លូ គ្រឿងប្រាក់ .... ដែលមានតម្លៃច្រើន មានរហូតដល់ ២០០ ឬ ៣០០ ជំឡឹងប្រាក់ចិន ។

ព្រះសង្ឃមួយអង្គមានសិទ្ធិ ប៉ះពាល់ដល់កូនស្រីតែមួយទេក្នុង ១ ឆ្នាំ ។ ពេលយប់នោះគេរៀបចំ ការជប់លៀងភោជនាហារមួយយ៉ាងអឺកធឹក មានភ្លេង មានស្គរគ្រប់បែបយ៉ាង ។ ល្ងាចឡើងគេនិមន្តព្រះសង្ឃ ដែលគេសែងដង្ហែមកជាមួយអង្រឹងស្នែង មាន

www.elibraryofcambodia.org

ខ្លោះ មានភ្លេង កំដរហែរហែរតាមផ្លូវ ។ យប់ឡើងព្រះសង្ឃគង់នៅក្នុងបន្ទប់កូនស្រី ។ ដល់ពេលមកដល់ លោកយកម្រាមដៃលូកបង្ខូចព្រហ្មចារីយ៍នាង រួចត្រងយកឈាម ដាក់ក្នុងកែវស្រាមួយ ។ អ្នកខ្លះថា ឪពុកម្ដាយ និង បងប្អូនជិតខាងយកឈាមនោះមកលាបលើថ្ងាស ។ អ្នកខ្លះទៀតថា អ្នកទាំងនោះក្រេបភ្លក់ឈាមនាងគ្រប់ៗគ្នា ។ អ្នកខ្លះទៀតនិយាយថា ព្រះសង្ឃរួបរួមខ្លួនកាយជាមួយកូនស្រីតាមរបៀបមែនទែន តែមានអ្នកផ្សេងថាមិនមែនដូច្នេះទេ នាំឲ្យគេមិនអាចដឹងបាន ថាការពិតប្រាកដនោះនៅត្រង់ណា ។ ដល់ពេលថ្ងៃរះឡើង គេដង្ហែរជូនព្រះសង្ឃទៅវត្តវិញ មានអង្រឹងស្នែង ឆ័ត្រ ខ្លោះ ភ្លេង ស្គរ ហែហាមដូចកាលពេលលោកនិមន្តមក។ រួចទៅគេត្រូវទិញកូនស្រីពីព្រះសង្ឃមកវិញ ដោយប្រគេនលោកនូវក្រណាត់អំបោះ និង ក្រណាត់សូត្រយ៉ាងច្រើន បើពុំនោះទេកូនស្រីត្រូវទៅជាសម្បត្តិផ្ទាល់របស់លោកសង្ឃ ហើយមិនអាចនឹងយកប្ដីណាមួយបានឡើយ។ ពេលយប់ "ឆាន់ថាន" ជូនកាលគេឃើញមានគ្រួសារជាង ១០ ក្នុងផ្លូវតែមួយ ដែលបានរៀបចំពិធីបុណ្យនេះ ។

រឿងនេះជាការពិត មិនមែនរឿងព្រេងទេ ប៉ុន្តែព្រះសង្ឃខ្មែរសព្វថ្ងៃមិនមានធ្វើដូច្នេះទេ ។ ក្នុងរឿងនេះមានតែឈ្មោះ "ឆាន់ថាន" ទេ ដែលគេមិនយល់រហូតមកដល់សព្វថ្ងៃ ។ លោក សើដែស[២] និយាយថា "គេប្រើពាក្យងងឹតមួយ ដើម្បីបង្ហាញពិធីបុណ្យបង្ខូចព្រហ្មចារីណ៍ស្ត្រីទើបនឹងបានអាយុល្មមរៀបការ" ។ លោក "ប៉ូលប៉េឡីអូត៍" ខ្លួនឯងក៏មិនយល់ដែរ ហើយនិយាយថា "ឆាន់ថាន" នេះ

---

[២] G. Cœdès : op.cit. p.228.

www.elibraryofcambodia.org

ប្រហែលជា "ចិនតាន" ទេ រួចមិនដឹងថាចិនតាននោះជាអ្វីទៀត ។ ការពិតពាក្យ **ឆាន់ថាន** នេះជាពាក្យខ្មែរទេ ។ ចិនសរសេរ ឆាន់ថាន តាមពាក្យខ្មែរថា **"ឆាន់ទាន"** ហើយគេដឹងថា ឆាន់ គឺពិសាតាមពាក្យប្រើសម្រាប់ព្រះសង្ឃ និង ទាន គឺអ្វីៗដែលគេប្រគេនលោក ។ ឆាន់ទានប្រែមកថា លោកបរិភោគរបស់ដែលគេប្រគេនឲ្យ ។ នៅបរទេសគេមិនដឹងថា ខ្មែរមានប្រើពាក្យ ខុសៗគ្នាច្រើន សម្រាប់ថាពិសានេះ ដូចជាមួយស្ដេចគេថា សោយ ជាមួយព្រះសង្ឃគេថា ឆាន់ ជាមួយអ្នកធំគេថា ពិសា ឬ ហូប ជាមួយអ្នកស្មើគ្នាគេថា ញ៉ាំ ឬទទួលទាន ឬបរិភោគ ជាមួយអ្នកមានថ្នាក់ក្រោមគេថា ស៊ី ...ល។

## ៣. ស្ដេចគំលង់

ខ្មែរដឹងរឿង "ស្ដេចគំលង់" គ្រប់ៗគ្នា ។ អ្នកនិពន្ធបរទេសច្រើនបាននិទានរឿងនេះ ជាពិសេសមាន លោក "ហង់រីម៉ារស្កាល" (Henri Marchal) កាលឆ្នាំ ១៩៥៥ ។ តទៅនេះគឺ សេចក្ដីសង្ខេបរឿង "ស្ដេចគំលង់" ៖ កាលពេលយូរណាស់មកហើយ នៅនគរមួយនោះមានស្ដេចមួយអង្គ មានឥទ្ធិពលយ៉ាងអាស្ចារ្យ បានសោយរាជ្យ លើប្រជាពលរដ្ឋ ដែលមានចំនួនយ៉ាងច្រើន ។ ថ្ងៃមួយ នៅពេលដែលព្រះអង្គកំពុងជិះសេះ ទតមើលក្រុង ជាមួយអ្នកអង្គរក្សបន្តិចបន្តួច ស្រាប់តែមានយាយចាស់ម្នាក់ ស្ទុះមកចាប់ខ្សែរបង្ហៀរសេះរបស់ព្រះអង្គ ។ សេះភ្ញាក់ខ្លួនខ្លាំង ងើបឈរជើងពីរឡើងលើ ធ្វើឲ្យស្ដេចធ្លាក់មកដី ។ ភ្លែតនោះភ្លាម មុននឹងគេឯងចូលជួយមហាក្សត្រ យាយចាស់ស្ទុះទៅខ្ទាំស្ដេចពាសពេញខ្លួន ហើយយកដំបៅដៃ និងក្រចកមកធ្វើឲ្យប្រឡាក់ស្ដេចពាសពេញអស់ ។ គេទាញស្ដេចចេញ

www.elibraryofcambodia.org

បានហើយ យាយនោះត្រូវគេកាប់រាប់រយកាំបិត និងចាក់រាប់រយលំពែង ។ ការពិតយាយចាស់នេះចង់សងសឹកកូនស្រីគាត់ដែលពីប៉ុន្មានឆ្នាំមុន ស្ដេចជាចៅស្រុកចាប់យកធ្វើជាស្រីស្នំ នៅក្នុងវាំង ។ យាយនោះកើតឃ្លង់ ហើយដែលគាត់ខាំស្ដេច គឺគាត់ចង់ចម្លងជម្ងឺទៅដល់ស្ដេចនោះឯង ។

ក្រោយរយៈបន្តិចមក ស្ដេចកើតជម្ងឺឃ្លង់មែន ។ គេនាំគ្នាទៅជួបរាជឥសី ដើម្បីសុំថ្នាំមកព្យាបាលរោគ ។ តារាជឥសីឲ្យក្មួននេនមួយដែលជាសិស្ស យកថ្នាំស្លឹកឈើទៅថ្វាយស្ដេច ហើយលោកឲ្យបណ្ដាំថា ៖ "ត្រូវយកស្លឹកឈើនេះពាក់កណ្ដាលទៅដាក់ក្នុងទឹក រួចដាំទឹកឲ្យពុះ ។ ដល់ទឹកពុះហើយ ស្ដេចត្រូវចូលក្នុងឆ្នាំង រួចគេយកស្លឹកឈើដែលនៅសល់មកបង់ទៅក្នុងឆ្នាំងនេះទៀត ។ ធ្វើដូច្នេះស្ដេចនឹងបានជាស្រឡះពីរោគឃ្លង់ ។ ស្ដេចបញ្ជាឲ្យគេដាំទឹកមួយឆ្នាំងធំ ជាមួយនឹងសន្លឹកឈើពាក់កណ្ដាល ។ ដល់ពេលទឹកពុះឡើង ស្ដេចមានការញញើតនឹងចូលក្នុងទឹកក្ដៅនេះ ព្រះអង្គក៏ឲ្យលោកនេនចូលមើល ។ លោកនេនចូលក្នុងទឹកក្ដៅ រលាយខ្លួនបាត់ ។ ស្ដេច មិនទុកចិត្តលើឆ្នាំងថ្នាំនេះ ក៏ឲ្យគេចាក់ចោលអស់ទៅ ។ លោកនេន ក៏បាត់ខ្លួនទៅជាមួយទឹកនោះដែរ ។ ដឹងរឿងនេះឡើង តារាជឥសីទ្រង់ខ្ញាល់យ៉ាងខ្លាំង ហើយឲ្យទំនាយថា "ពីថ្ងៃនេះទៅ ជម្ងឺឃ្លង់ឥតមានអ្នកណាមើលជាទេ!" ។ រួចពីនោះស្ដេចក៏មើលខ្លួនព្រះអង្គមិនជាដែរ ។ ព្រះអង្គសុគតនៅក្នុងរូងភ្នំដែលព្រះអង្គទៅជ្រកជាមួយស្ត្រីប្អូនប្រាំនាក់ ដែលមានសេចក្ដីស្មោះស្ម័គ្រជាទីបំផុតចំពោះព្រះអង្គ។

www.elibraryofcambodia.org

# ស្តេចគំលង់



ដែលមិនមែនស្តេចគំលង់

(ព្រះយមរាជ)

www.elibraryofcambodia.org

ខ្មែរទូទៅមានជំនឿលើរឿងនេះមែនទែន ។ គេទុករឿងនេះជារឿងពិតមួយរបស់ប្រវត្តិសាស្ត្រខ្មែរ ។ បន្ថែមពីនេះទៀត គេយល់ថា ស្តេចគម្លង់នេះគឺជាមហាក្សត្រជ័យវរ្ម័នទី ៧ តែម្តង ។ ការនឹកស្មាននេះ បានកើតឡើងជាយូរអង្វែងណាស់មកដែរ ពីព្រោះកាលឆ្នាំ ១២៩៦ ចិន ជូតាក្វាន់ បានសរសេររួចហើយថា "នៅស្រុកខ្មែរមានស្តេចមួយបានកើតជម្ងឺឃ្លង់" ។ ចំពោះខ្មែររូបចម្លាក់ថ្មមួយនៅអង្គរ ដែលមានឈ្មោះថា "**ស្តេចគំលង់**" នោះគឺជាមហាក្សត្រជ័យវរ្ម័នទី ៧ ។ ការពិតចម្លាក់ថ្មនេះ មិនមែនរូបមហាក្សត្រជ័យវរ្ម័នទី ៧ ទេ ។ តាមលោក ម.គ្លែស (Maurice Glaize) មានចារឹកអក្សរនៅលើជើងរូបនេះ ឲ្យដឹងថា នេះជា "**ធម្មរាជា គឺជាស្តេចដែលឲ្យគេគោរពច្បាប់ទាំងឡាយ** ហើយដែលគេស្គាល់ថា **ព្រះយមៈ ឬ យោម ឬ ព្រះយោមរាជ**" ដែលសោយរាជ្យនៅលើឋាននរកទាំងអស់ ។ អំពីរឿងកើតឃ្លង់វិញ ស្នាំនៅលើខ្លួនរូបចម្លាក់នេះគ្រាន់តែជាស្នាំផ្សិតដែលដុះបន្តិចបន្តួចលើថ្មនោះតែប៉ុណ្ណោះ ។

រឿងស្តេចគំលង់ជារឿងព្រេង មិនមែនជារឿងពិតមែនទែនទេ ។ រឿងនេះជារឿងព្រេងក្លិង្គទៅទៀត មិនមែនជារឿងខ្មែរផង ។ រឿងនេះបានគេយកមកឆ្លាក់បង្ហាញនៅប្រាសាទបាយ័ន លើជញ្ជាំងខាងក្នុង ប៉ែកខាងជើងផ្លូវចូលពីទិសខាងកើត ។ ខាងក្រោមនេះគឺ សេចក្តីអធិប្បាយពីចម្លាក់ថ្ម ពីលោក "**ហាំងរីមារស្គាល**"[៣]៖ "មុនដំបូងគេឃើញស្តេចនៅក្នុងព្រះរាជវាំង កំពុងកំសាន្តមើលរបាំល្ខោន មានស្ត្រីរាំពីរនាក់ ហើយមានភ្លេងពិណមួយយ៉ាងធំ កំដរ

---

[៣] Henri Marchal : Les Temples d' Angkor. op.cit. p. 20 et p. 111.

www.elibraryofcambodia.org

តាម ។ នៅសង្ខាងស្តេច មានអ្នកបម្រើប្រុសពីរនាក់ កាន់ផ្លិតបក់រុយ ។ អគ្គមហេសីស្តេច និងក្សត្រីផ្សេងទៀតនៅក្នុងប្រាសាទដោយខ្លួននៅពីខាង ។ រួចមកគេឃើញស្តេចកំពុងប្រយុទ្ធជាមួយពស់មួយយ៉ាងធំ ដែលមុននឹងងាប់មានចេញឈាម ខ្ទាតមកលើខ្លួនស្តេច ។ ដោយហេតុនេះហើយបានជាស្តេចកើតឃ្លង់ ។ បន្ទាប់មកទៀតគេឃើញ ស្តេចនៅលើគ្រែ មានស្ត្រីបម្រើពិនិត្យមើលបាតដៃស្រាមដៃ ហើយគេដឹងថា ស្តេចមានជម្ងឺឃ្លង់ ។ គេបញ្ជូនមនុស្សម្នាក់ទៅសុំយោបល់ពីរាជឥសី នៅក្នុងព្រៃភ្នំយ៉ាងជ្រៅដែលចេះមើលជម្ងឺផ្សេងៗ ។ រាជឥសីប្រាប់របៀបឲ្យគេធ្វើតាម ដើម្បីព្យាបាលរោគស្តេច ។ រួចគេឃើញមានក្បួនដង្ហែ នាំស្តេចទៅកន្លែងសំខាន់មួយដើម្បីគេថែរក្សាព្រះអង្គ ។

គួរកត់សំគាល់ថា ចម្លាក់និទានរឿងស្តេចគំលង់នេះ មានមួយទៀត នៅលើក្លោងទ្វារប្រាសាទ "តាកែវ" ដែលមហាក្សត្រជ័យវរ្ម័នទី ៥ បានស្ថាបនាកាលឆ្នាំ ១០០០ គ.ស គឺ ២០០ ឆ្នាំមុនប្រាសាទ "បាយ័ន" របស់ ជ័យវរ្ម័នទី ៧ ទៅទៀត ។ បញ្ចប់សេចក្តីទៅ ការដែលជឿថា មហាក្សត្រជ័យវរ្ម័នទី ៧ មានជម្ងឺឃ្លង់ ជាកាច្រឡំមួយយ៉ាងធំ ។ បើក្សត្រនេះកើតជម្ងឺឃ្លង់មែន ហេតុអ្វីព្រះអង្គបញ្ចេញត្រដាងជម្ងឺព្រះអង្គនៅលើជញ្ជាំងប្រាសាទបាយ័ន ដែលព្រះអង្គស្ថាបនា ? គេមិនអាចជឿបានដែរ ថាព្រះអង្គឲ្យគេឆ្លាក់រូបព្រះអង្គជា "ស្តេចគំលង់" ហើយយកមកតាំងយ៉ាងស្អែងនៅលើខឿនមួយខ្ពស់នៅមុខវាំង ! ស្តេចជ័យវរ្ម័នទី ៥ ដែលឆ្លាក់រឿងស្តេចគំលង់មិនអាចនឹងដឹងថា ជ័យវរ្ម័នទី ៧ ដែលកើត ២០០ ឆ្នាំ ក្រោយព្រះអង្គ អាចនឹងមានជម្ងឺឃ្លង់ទេ ។ រឿងព្រេងថាមហាក្សត្រជ័យ

www.elibraryofcambodia.org

វេ្ទនទី ៧ កើតឃ្លង់បង្ហាញឲ្យយើងដឹងថា ព្រះអង្គមានសត្រូវដែលមិនបានដំកើងកេរ្តិ៍ឈ្មោះព្រះអង្គដែរ ។ តែនេះជារឿងផ្សេងមួយទៀត ។

www.elibraryofcambodia.org

## វគ្គទី ១៩

# ព្រាហ្មណ៍នៅស្រុកខ្មែរ

សព្វថ្ងៃនៅស្រុកខ្មែរ គេឃើញមានព្រាហ្មណ៍តែមួយគ្រួសារគត់ ។ គេឲ្យឈ្មោះថា "បាគូរ"(*) ។ គ្រួសារនេះជាអ្នកថែរក្សាវត្ថុពិសេស ហៅថា "រាជកកុធភណ្ឌ" របស់ស្តេចខ្មែរ ហើយជាអ្នករៀបចំពិធីបុណ្យផ្សេងៗ ក្នុងព្រះរាជវាំងតាមទំនៀមទំលាប់ របស់ព្រហ្មញ្ញសាសនា ។ តាមពិតគឺ ព្រាហ្មណ៍នេះហើយដែលជាអ្នក នាំឲ្យនគរខ្មែរមានភាពខ្ពស់ខ្ពស់ និងមានឈ្មោះល្បីល្បាញយ៉ាងធំ រវាង ១៤ សតវត្សរ៍ ។ គេដឹងដែរទេថា អ្នកបង្កើតនគរខ្មែរដែលចិនស្គាល់មុនគេ ហើយដែលចិនឲ្យឈ្មោះថា "ភ្វូណាន់" នោះគឺព្រាហ្មណ៍កៅណ្ឌិន្យ ? គេនៅចាំទេថា អ្នកបង្កើតនគរខ្មែរមួយទៀតដែលមានឈ្មោះថា "កម្ពុជៈ" ឬ កម្ពុជា នោះគឺព្រាហ្មណ៍ "កម្ពុស្វយំភុវ" ? ។ ការដែលគេភ្លេច ឬ គេលប់ចោលអស់អនុស្សាវរីយ៍ព្រាហ្មណ៍ទាំងនោះ គឺជាការមួយដែលគួរឲ្យស្តាយយ៉ាងខ្លាំង ។

---

(*) ដើម្បីកុំឲ្យខ្មែរនឹកឃើញដល់ព្រហ្មញ្ញសាសនា គេកែពាក្យព្រាហ្មណ៍ទៅជាបាគូរវិញ ។

www.elibraryofcambodia.org

អ្នកណាទៅដែលគេហៅថាព្រាហ្មណ៍ ? ប្រវត្តិសាស្ត្រព្រាហ្មណ៍សាសនាដើមកំណើតនៅទ្វីបឥណ្ឌា ហើយបានចេញមកពីគម្ពីរធំ "វេទ" ។ សាសនានេះឥតមានវត្ត ឬមានវិហារអ្វីទេ ។ កាលណាគេធ្វើបុណ្យ គេយកទីធ្លាណាមួយ ហើយគេធ្វើបុណ្យនៅទីនោះ ។ គេសែនព្រេនភ្លើង រួចដុតអស់អ្វីៗដែលគេរៀបចំ ក្នុងន័យជាការបូជាដល់ព្រះ ។ ពិធីបុណ្យនេះគឺ ព្រាហ្មណ៍ជាអ្នករៀបចំ ។ ព្រហ្មញ្ញសាសនាដែលកើតមកពីសាសនាវេទ ដាក់ព្រាហ្មណ៍នៅថ្នាក់លើគេបង្អស់ក្នុងសង្គម ។ គេចែកមនុស្សជាវណ្ណៈ មានបួនគឺ ៖ ព្រាហ្មណ៍ ក្សត្រ វៃស្យៈ សូទ្រៈ ។ ការរៀបចំសង្គមនេះសំអាងនៅលើ "កំណើត" និង "មុខងារ" របស់ក្រុមនិមួយៗ ។ ក្រិស្ណ អវតារព្រះវិស្ណុបាននិយាយថា ៖ របៀបចែកមនុស្សជាវណ្ណៈ គឺអាញ់ជាអ្នកបង្កើត ធ្វើតាមការចែកមុខងារឲ្យទាំងអស់គ្នា (ភាគវតគិតា IV-១៣) ។ តាមការបែងចែកនេះគឺ ៖

- **ព្រាហ្មណ៍** : មានករណីពីរ ។ មួយគឺ រៀន និងបង្រៀនគម្ពីរធម៌ "វេទ" ។ ពីរគឺរៀបចំពិធីបុណ្យផ្សេងៗ ថ្វាយព្រះឲ្យបានតាមគន្លងទំនៀមទំលាប់របស់ព្រហ្មញ្ញសាសនា ។ ព្រាហ្មណ៍មានសិទ្ធិទទួលអំណោយ ហើយមិនត្រូវមានមុខរបរអ្វីក្រៅពីនេះទេ ។

- **ក្សត្រ** : ត្រូវរៀនក្បួន "វេទ" ការពារព្រះធម៌ ហើយនឹងនគរគ្រប់ដណ្តប់រាស្ត្រហើយនឹងធ្វើទានដល់ព្រាហ្មណ៍ ។

- **វៃស្យៈ** : ជាជនដែលទទួលខុសត្រូវខាងផ្នែកសេដ្ឋកិច្ចត្រូវបំពេញករណីកិច្ចខាងហិរញ្ញិក ខាងជំនួញ ខាងកសិកម្ម ហើយនឹងខាងចិញ្ចឹមសត្វ ។

www.elibraryofcambodia.org

- **សូទ្រ** : មានមុខងារជាអ្នកបម្រើពួកអ្នកនៅក្នុងវណ្ណៈ ៣ ខាងលើ ។

ក្រៅពីវណ្ណៈបួននេះ មានពួកខ្លះទៀតដែលមានភាពទាបជាងគេបង្អស់ ហើយដែលគេឲ្យឈ្មោះថា អ្នកឥតវណ្ណៈ ឬពួក "ប៉ារិយៈ" ។

វណ្ណៈមនុស្សម្នាក់ៗ មានតាមកំណើតអ្នកនោះ គឺថាគេបានទៅជាព្រាហ្មណ៍លុះណាតែគេកើតមកពីព្រាហ្មណ៍ ។ ការផ្លាស់ប្តូរពីវណ្ណៈមួយទៅវណ្ណៈមួយ មិនអាចនឹងធ្វើឡើងបានទេ ក្រៅពីពេលខ្លះ បន្តិចបន្តួច ដែលព្រាហ្មណ៍ត្រូវទទួលរាជ ហើយទៅជាក្សត្រ ។ គេឃើញច្បាស់ថា ក្នុងការបែងចែកមនុស្សជាវណ្ណៈដែលព្រះវិស្ណុបានធ្វើមកនេះ គឺព្រាហ្មណ៍នៅខ្ពស់ជាងគេ នៅខ្ពស់ជាងក្សត្រ ជាងស្តេចទៅទៀត ។ ព្រាហ្មណ៍ជាអ្នកបានអំណាចមកពីព្រះ ហើយព្រាហ្មណ៍ជាអ្នកនៅជិតព្រះជាងស្តេច ។ ដោយហេតុនេះហើយ បានជាជួនកាលគេហៅព្រាហ្មណ៍ថា **ព្រះនៅលើដី** ។ នៅក្នុងនគរ ព្រាហ្មណ៍ជាមនុស្សមានភាពឯកច្ឆ័ន្ទពីស្តេច ហើយមិនមែនជា រាស្ត្រនៅក្រោមស្តេចដូចរាស្ត្រផ្សេងៗ ទេ ។ ក្នុងឋានៈជា "សង្ឃ" ព្រាហ្មណ៍ជាអ្នកអភិសេកក្សត្រឲ្យបានសោយរាជ្យ(*) ឲ្យទៅជាស្តេច ប៉ុន្តែស្តេចនេះមិនមែនស្តេចរបស់ព្រាហ្មណ៍ទេ ។ ពេលអភិសេកស្តេចរួចហើយ ព្រាហ្មណ៍បង្ហាញស្តេចដល់ប្រជា

---

(*) សោយរាជ្យ : សោយនេះមិនមែនស៊ី ឬញ៉ាំទេ។ ពាក្យនេះមកពីសំស្ក្រឹត "រាជសុយៈ" ប្រែថាបង្កើតស្តេច ។ ស្តេចសោយរាជ្យ គឺស្តេចដែលគេបានបង្កើតពេញច្បាប់ ។

www.elibraryofcambodia.org

ក្សត្រ ហើយប្រកាសថា ៖ នេះគឺជាស្តេចរបស់ប្រជារាស្ត្រទាំងអស់ ឆ្នា ស្តេចរបស់ព្រាហ្មណ៍ គឺ "សោម:" (ហែរ៉្មន្ន អូលដែនប៊ែគ)[1] ។ ហេតុដែលព្រាហ្មណ៍មិនមែនជារាស្ត្ររបស់ស្តេច មានន័យថាស្តេចគ្មានសិទ្ធិធ្វើទោសអ្វីមួយដល់ព្រាហ្មណ៍ដែរ ជាពិសេសគឺទណ្ឌកម្មទាក់ទង នឹងអង្គកាយ ដូចជាវាយនឹងដំបងជាដើម ។ អ្នកដែលអាចធ្វើទោសព្រាហ្មណ៍បាន មានតែស្តេចរបស់ព្រាហ្មណ៍ទេ ហើយស្តេចនេះឥតនៅលើឋានដីយើងទៀតផង ។

សកម្មភាពធម្មតារបស់ព្រាហ្មណ៍មាន ៣ គឺ រៀនក្បួនវេទ បង្រៀនក្បួនវេទ ហើយនឹងបំពេញករណីកិច្ចជាព្រះ "សង្ឃ" ។

ពេលក្មេងព្រាហ្មណ៍ត្រូវរៀន ហើយជាពិសេសត្រូវ "ស្តាប់" ពីព្រោះការបង្រៀនតាមទំនៀមទំលាប់របស់គេ គេច្រើនធ្វើតាមរបៀបនិយាយ មិនមែនរបៀបសរសេរទេ ។ អត្ថបទទាំងឡាយនៅក្នុងក្បួនគម្ពីរវេទ គេទុកជាព្រះផ្តល់ឲ្យទាំងអស់តាមរយៈពួក "រាជឥសី" ហើយក្នុងក្បួននោះ **មានវិជ្ជាគ្រប់មុខ** ដូចជា វេយ្យាករណ៍(*) នីតិសាស្ត្រឬច្បាប់ គណិតសាស្ត្រ វិទ្យាសាស្ត្រពីឋានភាព វិជ្ជាពេទ្យ នយោបាយ.... មិនមែន គ្រាន់តែធម៌សម្រាប់ថ្វាយបង្គំព្រះទេ ។

ដល់ធំឡើង ព្រាហ្មណ៍ដែលមានចំណេះវិជ្ជាហើយ បានទៅជា "គ្រូបង្រៀន" អស់មួយជីវិតនៅតាមភូមិ តាមស្រុក ក្នុង

---

[1] Hermann Oldenberg : op.cit. p.21.

(*) ប៉ានិនិ ដែលបានសរសេរក្បួនវេយ្យាករណ៍សំស្ក្រឹត ៥០០ ឆ្នាំមុន គ.ស ត្រូវគេទុកជារាជឥសីមួយដែរ ។

www.elibraryofcambodia.org

អាស្រម ឬក្នុងព្រៃ ។ មន្តអាគមសម្ងាត់ព្រាហ្មណ៍អាចនឹងបង្រៀនបានដល់សិស្សណាដែលគួរឲ្យទទួលបាន ។ ករណីផ្ទាល់ខ្លួនខាងផ្លូវធម៌ ព្រាហ្មណ៍ប្រព្រឹត្តដោយសូត្រអត្ថបទផ្សេងៗ ក្នុងក្បួន "វេទ" គ្រប់ពេលរាល់ៗថ្ងៃ ។

ក្នុងឋានៈជា "សង្ឃ" គឺខាងផ្លូវសាសនា ព្រាហ្មណ៍ទទួលខុសត្រូវក្នុងអាស្រម ។ អ្វីៗដែលគេថ្វាយព្រះ គេត្រូវធ្វើតាមរយៈព្រាហ្មណ៍ទាំងអស់ ។ ការបូជាទាំងឡាយ ព្រាហ្មណ៍ធ្វើឡើងតាមរបៀបសាសនាយ៉ាងល្អិតល្អន់ ។ ការបូជាថ្វាយព្រះហៅថា "យជ្ញ" គឺជាពិធីមួយដែលគេទុកជាបុណ្យយ៉ាងសំខាន់ ។ ពិធីនេះគឺការថ្វាយចំណីអាហារផ្សេងៗដល់ព្រះ ដែលគេធ្វើឡើងនៅវាលធ្លាមួយតាមរបៀបទម្លាប់សាសនាក្នុងក្បួនវេទ ។ អ្នកម្ចាស់បុណ្យមានសិទ្ធិនៅកន្លែងនោះរហូតក្នុងពេលបុណ្យ ហើយត្រូវធ្វើអំណោយដល់ព្រាហ្មណ៍ ។

ពីសតវត្សរ៍ទី ១ ដល់សតវត្សរ៍ទី ១៤ ស្រុកខ្មែរនៅក្រោមរបបព្រហ្មញ្ញសាសនា ប៉ុន្តែការប្រតិបត្តិវិន័យសាសនា មិនមានភាពតឹងរ៉ឹងដូចនៅស្រុកក្លិង្គទេ ។ ការបែងចែកសង្គមមនុស្សជាបួនវណ្ណៈមិនបានច្បាស់លាស់ពេកដែរ មានតែព្រាហ្មណ៍ និងក្សត្រទេ ដែលមានថ្នាក់ពិតប្រាកដ ហើយព្រាហ្មណ៍នៅស្រុកខ្មែរក៏បានវណ្ណៈខ្ពស់ជាងក្សត្រដូចនៅស្រុកក្លិង្គដែរ ។

ព្រាហ្មណ៍ខ្មែរគឺ ជាក្លិង្គទាំងអស់ ឬមួយក៏មានដើមកំណើតជាក្លិង្គ ។ ព្រាហ្មណ៍ដែលមានឈ្មោះល្បីជាងគេ គឺព្រាហ្មណ៍ដែល

www.elibraryofcambodia.org

បានទៅជាមហាក្សត្រខ្មែរ ស្តេចកៅណ្ឌិន្យទី ១ អ្នកបង្កើតនគរដែលចិនហៅថា "ភូណាន់" មហាក្សត្រកៅណ្ឌិន្យទី ២ ហើយនឹង "**កម្ពុស្វយំភុវ**" អ្នកបង្កើត "នគរ កម្ពុជ:" ឬកម្ពុជា ។ កាលជំនាន់នោះការទាក់ទងរវាងខ្មែរនឹងនគរក្លឹង្គខ្លះមានជាអចិន្ត្រៃយ៍ ហើយព្រាហ្មណ៍ដែលចុះឡើងពីស្រុកក្លឹង្គមកស្រុកខ្មែរ ពីស្រុកខ្មែរទៅស្រុកក្លឹង្គបានឈប់តែនៅពេលដែលរបបព្រហ្មញ្ញសាសនា បានបាត់បង់ពីស្រុកខ្មែរទេ ។ លោក "ព្រុណោដាហ្សាំង"[2] បានសរសេរថា៖ ដើមកំណើតក្លឹង្គ អាចនាំឲ្យព្រាហ្មណ៍ទទួលបានបុណ្យសក្តិធំ បានកិត្តិយសខ្ពង់ខ្ពស់ ឬពិសេស ហើយបានចូលទៅក្នុងព្រះរាជវង្សទៀតផង ។ នៅស្រុកខ្មែរ អាពាហ៍ពិពាហ៍ រវាងព្រាហ្មណ៍និងក្សត្រមានជាធម្មតា ។ កូនរបស់ព្រាហ្មណ៍គេហៅថា "ធម្មជ:" គឺថាកូនរបស់ករណីកិច្ច ឯកូនអ្នករាល់គ្នាគឺ ជាផលរបស់កម្មគុណហើយគេហៅថា "កម្មជ:" ។ ចារឹកអក្សរលើថ្មនៅអង្គរ ឲ្យយើងដឹងថាកាលសតវត្សរ៍ទី ៧ ព្រាហ្មណ៍ឈ្មោះ "**ទុគ្គស្វមិន**" មកពីស្រុក "ដេកាំង" បានទៅជាកូនប្រសារមហាក្សត្រ ឥសានវរ្ម័នទី ១ រួចដល់សតវត្សរ៍ក្រោយមក ព្រាហ្មណ៍ឈ្មោះ"**សក្រស្វមិន**" កើតនៅ "មធ្យទេស:" បានចូល អាពាហ៍ពិពាហ៍ជាមួយបុត្រីមហាក្សត្រជ័យវរ្ម័នទី ១ ។ ក្នុងសតវត្សរ៍ទី ១០ ព្រាហ្មណ៍ "**ទិវាករភត**" ដែលកើតនៅតំបន់ទន្លេ "យមុន" បានទៅជាប្អូនថ្លៃមហាក្សត្រជ័យវរ្ម័នទី ៥ ក្រោយពីបានទៅជាស្វាមីក្សត្រី "**ឥន្ទ្រលក្ស្មី**" ។ ផ្ទុយទៅវិញកាលសតវត្សរ៍ទី ១២ មហាក្សត្រជ័យវរ្ម័នទី៧ បានទទួលជាមហេសីបុត្រីរបស់ព្រាហ្មណ៍ "**ហរិជឥសីកេសា**" ដែលមានកំណើតនៅស្រុកក្លឹង្គក្នុងក្រុមពួកភារ

---

[2] Bruno Dagens : op.cit. p. 82.

www.elibraryofcambodia.org

ទ្វាជ ។ គេបានដឹងទៀតថា មានព្រាហ្មណ៍ផ្សេងទៀតដែលមិនសូវបានល្បីឈ្មោះទេ ហើយដែលមកពីស្រុកក្លឹង្គដែរ ដូចព្រាហ្មណ៍ក្លឹង្គ ២ នាក់បងប្អូន ដែលបានទិញដីសំរាប់សាងវិហារ (វិហារធំដែលព្រះឥស្សរាសាង គឺជាកន្លែងផ្ទាល់ខ្លួនរបស់ ព្រាហ្មណ៍ មិនមែនជាទីសក្ការសាធារណៈទេ) តាមសេចក្តីចារឹកថ្មនៅស្តុកកុកធំ (ក្ធ.សើដែ ៩៥)[3]។

នៅស្រុកខ្មែរ ក្រៅពីមានមុខងារទាក់ទងនឹងសាសនាព្រាហ្មណ៍មានមុខងារផ្សេងបន្តិចបន្តួចខ្លះដែរ ដូចជាចៅក្រមអភិបាលខេត្ត ឬជាអ្នកដឹកនាំកងទ័ព ។ ប៉ុន្តែគឺកិច្ចការនៅជិតមហាក្សត្រទេ ដែលជាសំខាន់ជាងគេ ។ ក្នុងឋានៈជា "សង្ឃ" ព្រាហ្មណ៍មានឈ្មោះថា "**បុរោហិត**" គឺជាអ្នករៀបចំអ្វីៗទាំងអស់ខាងផ្នែកសាសនា សម្រាប់មហាក្សត្រ ។ ព្រាហ្មណ៍ជា "**គ្រូ**" គឺជាអ្នកអប់រំ បង្ហាត់បង្រៀនព្រះរាជបុត្រាបុត្រី ជាពិសេសព្រះរាជបុត្រដែលថ្ងៃក្រោយត្រូវឡើងសោយរាជ្យ ។ ជួនកាលព្រាហ្មណ៍បានឈ្មោះ ថា "**ព្រះគ្រូ**" ឬធំជាងគេទៅទៀតគឺ "**រាជគ្រូ**" ។ ពេលស្តេចឡើងសោយរាជ្យ គឺព្រះគ្រូនេះឯងដែលជាអ្នកធ្វើការអភិសេកឲ្យស្តេចរួចហើយគឺព្រះគ្រូ ជាអ្នកទទួលខុសត្រូវក្នុងកិច្ចការថែរក្សាបូជាវត្ថុសំខាន់ដែលសំគាល់ទុកថាមហាក្សត្រ ដូចជា "**លិង្គមាស**" ដែលគេសន្មត់ថាមានព្រលឹងស្តេចនៅក្នុងនោះ ។ អ្នកបរទេសខ្លះដូចលោក "ក្លូដ ហ្សាក" មិនយល់គំនិតដើមរបស់ខ្មែរ បានសរ

---

[3] Georges Cœdès : Inscriptions de Sdok Koh Thom. BFEO XV. T2. p. 94

www.elibraryofcambodia.org

សេរថា "លឹង្គនេះជាអ្នកតា" ! ។ ទីបំផុតទៀត ព្រាហ្មណ៍ក៏មានទៅជា "ទី ប្រឹក្សា" មហាក្សត្រដែរដែលគេហៅថា "**មន្ត្រិន**" (*) ។

ព្រាហ្មណ៍ក្នុងឋានៈជាគ្រូ ឬ ព្រះគ្រូ ឬ បូរោហិត ឬ មន្ត្រិន មានសិទ្ធិចូលរួមក្នុងគណៈរដ្ឋមន្ត្រីគ្រប់ពេលវេលា ។ ព្រះគ្រូជាអ្នកទទួលសេចក្តីសម្រេចទាំងឡាយរបស់ស្តេច ដើម្បីឲ្យគេប្រតិបត្តិតាម ។ ក្នុងភាពនេះ ព្រះគ្រូក៏បានដូចជានាយករដ្ឋមន្ត្រីសព្វថ្ងៃនេះដែរ ។

ក្នុងរបៀបរៀបរយតាមជាន់ថ្នាក់ក្នុងនគរ ព្រាហ្មណ៍បាននៅថ្នាក់បន្ទាប់ពីមហាក្សត្រ មុនព្រះរាជបុត្រដែលត្រូវឡើងសោយរាជ្យទៅថ្ងៃក្រោយ មុនព្រះរាជបុត្រាបុត្រី ព្រះរាជវង្សា មន្ត្រី និងសេនាបតីទាំងអស់ ។

ក្នុងកិច្ចការដែលព្រាហ្មណ៍បំពេញនេះ ព្រាហ្មណ៍អាចទទួលបាននូវរង្វាន់ធំៗ ដូចជាឋានៈជា "រាជគ្រូ" ដែលជាថ្នាក់ខ្ពស់ជាទីបំផុត ។ ព្រះគ្រូ "**ទិវករបណ្ឌិត**" ជាគ្រូរបស់មហាក្សត្រខ្មែរ ៥ អង្គហើយស្ករយាវវ្ម័នទី ២ តែងតែចុះពីអង្រឹងសែងមកថ្វាយបង្គំព្រះអង្គមុនអោនិច្ច ។ ក្រៅពីបុណ្យសក្តិ ព្រាហ្មណ៍អាចទទួលទ្រព្យសម្បត្តិគ្រប់មុខ ដូចអង្រឹងស្នែងមាស ភ្លិតមាស ឆត្រមានដងមាស សេះដំរី និងដី ភូមិ តូចធំ ។ ប្រាសាទ "**ត្រីភូវនមហិស្វរ**" ដែលគេនិយម

---

(*) មន្ត្រិន : ន័យដើមគឺអ្នកឲ្យមន្ត ឲ្យអាគម ។ ពាក្យនេះបានឲ្យសព្វថ្ងៃពាក្យ មន្ត្រី ដូចអនុមន្ត្រី ឧត្តមមន្ត្រី ... ។

www.elibraryofcambodia.org

ហៅថា "បន្ទាយស្រី" គឺជាប្រាសាទដែលព្រាហ្មណ៍ "យជ្ញវរហ" បានសាងកាលឆ្នាំ ៩៦៧ ជាមួយនឹងប្អូនព្រះអង្គឈ្មោះ "វិស្ណុកុមារ" នៅលើទឹកដីផ្ទាល់ខ្លួនរបស់ព្រះអង្គ នៅស្រុកហៅថា "ឥសាណបុរៈ" ។ ព្រាហ្មណ៍ "យជ្ញវរហៈ" ជាបុរោហិតរបស់មហាក្សត្ររាជេន្ទ្រវរ្ម័ន រួចជាព្រះគ្រូព្រះរាជបុត្ររបស់មហាក្សត្រនេះទៀត ដែលក្រោយមកបានឡើងសោយរាជ្យក្នុងនាមជាជ័យវរ្ម័នទី ៥ ។

ព្រាហ្មណ៍ត្រូវបាត់អស់ពីស្រុកខ្មែរ កាលពីកណ្ដាលសតវត្សរ៍ទី ១៤ ។ ដើមហេតុការបាត់បង់នេះគឺ ព្រះពុទ្ធសាសនាហិនយាន ។ ចម្បាំងសាសនាអស់ ១០០ ឆ្នាំ គឺពី ១២៣៨ ដល់ ១៣៣៦ រវាងព្រះពុទ្ធសាសនាហិនយាន និងព្រហ្មញ្ញសាសនា បានឲ្យជ័យជំនះដល់ព្រះពុទ្ធសាសនា ។ អ្វីៗដែលជាព្រហ្មញ្ញសាសនាត្រូវបាត់បង់ ខូចខាតទាំងអស់ ។ ព្រះទាំងឡាយរបស់ព្រហ្មញ្ញសាសនា ត្រូវគេបោះបង់ចោល ព្រាហ្មណ៍ត្រូវបាត់ខ្លួន ឬរត់ចេញផុតពីស្រុកខ្មែរ រហូតដល់គ្មាននៅសល់មួយអង្គ ភាសាសំស្ក្រឹតត្រូវគេចោល ហើយគេយកភាសាបាលីមកជំនួស រហូតមកដល់សព្វថ្ងៃនេះ ។ ក្សត្រកាន់សាសនាព្រាហ្មណ៍ក្រោយគេបង្អស់គឺជ័យវរ្ម័នទី ៩ (១៣២៧-១៣៣៦) ដែលបាត់ទៅកាលឆ្នាំ ១៣៣៦ ។ នេះគឺស្ដេចក្នុងក្រោយបង្អស់ដែលមានឈ្មោះជា "វរ្ម័ន"[៣] ។ ព្រះរាជវង្សថ្មី ដែលមានមហាក្សត្រគ្រប់គ្រងខ្មែរ រហូតមកដល់សព្វថ្ងៃ ជាន...

[៣] វរ្ម័ន ៖ មហាក្សត្រនរោត្តមសីហនុ ជាស្ដេចតែមួយក្នុងព្រះរាជវង្សសព្វថ្ងៃ ដែលមានព្រះនាមថា វរ្ម័ន ប៉ុន្តែការនេះឥតមានអ្វីទាក់ទងសោះឡើយ ដល់ប្រវត្តិសាស្ត្រខ្មែរទេ ។

www.elibraryofcambodia.org

មកជំនួសព្រះរាជវង្សស្តេច "វរ្ម័ន" ។ ១៦ ឆ្នាំគត់ ក្រោយពីបាត់ស្តេច វរ្ម័ន គឺ នៅឆ្នាំ ១៣៥២ ក្រុង "អង្គរ" បានធ្លាក់ជាលើកដំបូងក្នុងដៃ ពួកសៀម របស់ស្តេច "រាមាធិបតី" ។

www.elibraryofcambodia.org

# វគ្គទី ២០

# ស្តេចអង្គរ

កាលណាមហាក្សត្រទ្រង់យាងចេញ គេឃើញមានទ័ពដង្ហែរពីខាងមុខ រួចមានទង់តូចទង់ធំ ហើយមានភ្លេងគគ្រឹកគគ្រេង។ បន្ទាប់មកមានស្រីបំរើព្រះរាជវាំងចំនួន ៣០០ ទៅ ៥០០ នាក់ ស្លៀកពាក់សំពត់ពណ៌ មានរូបផ្កា រូបសន្លឹកឈើ ដៃកាន់ទៀនដែលគេអុជទោះជានៅថ្ងៃត្រង់ក៏ដោយ ។ ស្ត្រីទាំងអស់នេះអាចធ្វើជាកងទ័ព មួយតែឯងបាន ។ បន្ទាប់មកទៀត មានស្ត្រីក្នុងវាំងជាច្រើន ទ្រកាន់ឥវ៉ាន់គ្រឿងគ្រៅរបស់ក្សត្រធ្វើពីមាស ពីប្រាក់ ព្រមទាំងគ្រឿងលំអផ្សេងៗច្រើនទៀត ដែលមានរូបភាពខុសៗគ្នា ។ ក្រោយមកមានស្រីក្នុងវាំងជាច្រើន ដែលជាពលរក្សាផ្ទាល់ព្រះមហាក្សត្រ ដៃកាន់ខែលកាន់លំពែង មានភាពជាកងទ័ពមួយដាច់តែឯងដែរ ។ ក្រោយទៀតមានរទេះពពែ រទេះសេះ តុបតែងដោយគ្រឿងសុទ្ធតែមាស ។ មន្ត្រី និង ក្សត្រាក្សត្រីទាំងអស់ ជិះលើដំរីមានខ្លោះពណ៌ក្រហម ដែលគេអាចឃើញបានពីចម្ងាយ មានចំនួនយ៉ាងច្រើនរាប់មិនអស់ ។ ក្រោយពីនោះ គឺដល់មហេសីជាច្រើន និង ស្រីស្នំផ្សេងៗ ។ អ្នកខ្លះបានគេសែងនឹងអង្រឹងស្នែង អ្នកខ្លះ

www.elibraryofcambodia.org

ជិះរទេះ ឬ ជិះសេះ ជិះដំរី ។ គេមានខ្លោះពណ៌ស បន្តក់ពណ៌មាស ដែលគេឃើញយ៉ាងតិចក៏ជាង ១០០ដែរ។ ពីក្រោយនេះគឺព្រះមហាក្សត្រ ព្រះអង្គទ្រង់ឈរលើខ្នងដំរី ដែកាន់ព្រះខ័នរាជ្យ ។ ភ្លុកដំរីបានគេដាក់ស្រោមមាស ។ នៅជុំវិញមានក្លស់ "ស" បន្តក់ពណ៌មាសចំនួនជាង២០ ហើយមានដងធ្វើពីមាស ។ មានដំរីជាច្រើនអមជុំវិញ រួចបន្ទាប់មកមានទ័ពធំ ដង្ហែរការពារ ព្រះអង្គទៀត...... ។

រឿងនេះដែលបានបកប្រែមកភាសាបារាំង ដោយលោក "ប៉ូលពេលីយ៉ោត៍"[១] គឺចិនជូតាក្វាន់ ដែលមកទីក្រុងអង្គរកាលឆ្នាំ ១២៩៦ បានសរសេរ ។ រឿងនេះមានឡើងនៅអង្គរ ហើយមហាក្សត្រនេះគឺស្រីឥន្ទ្រវរ្ម័ន ។ គេឃើញថា ៧៥ ឆ្នាំ ក្រោយពីព្រះមហាក្សត្រជ័យវរ្ម័នទី ៧ ស្តេចខ្មែរនៅមានឫទ្ធិនៅជាមហាក្សត្រមួយយ៉ាងខ្លាំងអស្ចារ្យ ។ ការចេញដំណើរមានគេហែរហមតាមភាពខ្ពង់ខ្ពស់នេះ បង្ហាញឲ្យឃើញយ៉ាងច្បាស់ ។ នៅក្រៅពីនោះទៀតគេដឹងថាស្តេចខ្មែរជា "ទេវរាជ" ហេតុដែលឲ្យអ្នកខ្លះនិយាយថាស្តេចខ្មែរជាព្រះអាទិទេព ។

ពិតមែនហើយ ស្តេចអង្គរជាក្សត្រយាងខ្ពង់ខ្ពស់ ហើយមានឥទ្ធិពលយ៉ាងខ្លាំង ។ តែព្រះអង្គជាម្ចាស់ផែនដី មានអំណាចផ្តាច់ការទាំងអស់ក្នុងស្រុកខ្មែរឬទេ ? ព្រះអង្គជាព្រះអាទិទេពនៅលើឋានដី ឬ អ្វី? ការពិតគឺ មិនមែនដូច្នេះទាំងអស់ទេ ។

---

[១] Tcheou Ta Kouan : Traduit par Paul Pelliot. op. cit. p. 34-35.

www.elibraryofcambodia.org

ធម្មតាបើសំអាងទៅលើទ្រឹស្តី ស្តេចជាបុគ្គលទី១នៅក្នុងនគរ ។ ប៉ុន្តែនគរខ្មែរកាលជំនាន់កាន់ព្រហ្មញ្ញសាសនា គឺពីសតវត្សន៍ទី១ ដល់សតវត្សន៍ទី ១៤ ក្នុងគ.ស ជានគរមួយដែលកាន់របប **"ទេវធិបតេយ្យ"** ។ ពិតមែនថានគរខ្មែរឥតមានព្រាហ្មណ៍ចេញមុខជាអ្នកដឹកនាំ ព្រាហ្មណ៍ដែលជា"សង្ឃ" នៅតែជាអ្នកមានសិទ្ធិអំណាចច្រើនជាងគេ ។ រដ្ឋធម្មនុញ្ញនគរខ្មែរគឺក្បួន **"វេទ ឬ វិទ្យ"** ដែលអ្នកណាក៏ដោយត្រូវតែគោរព ។ តាមក្បួនវេទ ក្សត្រនៅក្រោមព្រាហ្មណ៍ទេ វណ្ណៈក្សត្រជាវណ្ណៈទី២ បន្ទាប់ពីវណ្ណៈព្រាហ្មណ៍ដែលនៅថ្នាក់ទី១ ក្នុងសង្គម ។ លោក "ហ. អូលដេនប៊ែរ្គ"[៦] បានសរសេរថា **"ច្បាប់ធម្មជាតិដែលព្រះអាទិទេពឲ្យមក សំគាល់ថាអ្នកតំណាងព្រះនៅលើដី គឺព្រាហ្មណ៍"** ។ ចំណេះវិជ្ជានឹងអំណាចទាំងអស់ត្រូវនៅលើព្រាហ្មណ៍ ។ គ្មានឆន្ទៈមនុស្សណាមួយហ៊ានមកអង្រួនច្បាប់ ដែលព្រះបានរៀបចំ ហើយដែលប្រគល់ប្រជារាស្ត្រ ទៅក្រោមអំណាចរបស់ស្តេច ប្រគល់ស្តេចទៅក្រោមអំណាចរបស់ព្រាហ្មណ៍ ។

**ស្តេចអង្គរមិនមែនព្រះអាទិទេពទេ** ទោះជាគេគោរពស្តេចស្មើអាទិទេពក៏ដោយ ។ បើគេទុកស្តេចជា "ទេវរាជ" នេះគ្រាន់តែគេសំគាល់ថាស្តេចមានជាប់ធាតុព្រះប៉ុណ្ណោះទេ ។ ព្រះនាមស្តេចទាំងអស់បង្ហាញយ៉ាងច្បាស់ ថាស្តេចជាមនុស្សមិនមែនព្រះ ។ ស្តេច **"សុរិយវរ្ម័ន"** ជាដើមមានន័យថា "មនុស្សនោះបានសុរិយ" គឺ ព្រះអាទិត្យការពារ (ម័ន= មនុស្ស, វរៈ=ការពារ, សុរិយ= ព្រះអាទិត្យ)

---

[៦] Hermann Oldenberg : op. cit. p. 18-19.

www.elibraryofcambodia.org

ជ័យវរ្ម័នមានន័យថា "មនុស្សដែលមានជ័យជំនះការពារ" ។ ព្រះនាមស្តេចក្រោយពីសុគតទៅ ក៏បង្ហាញឲ្យឃើញថាស្តេចជាមនុស្សដែរ ពីព្រោះស្តេចសុគត គឺស្តេចបានទៅជួបព្រះ ទៅដល់ឋានរបស់ព្រះ ឬ ទៅដល់ព្រះបាទជើងព្រះ ។ ស្តេចជ័យវរ្ម័នទី២ ពេលសុគតមានព្រះនាមថា "បរមឥស្វរបាទ" ប្រែមកថាព្រះអង្គបានទៅដល់ "ជើងព្រះឥស្វរដ៏ប្រសើរខ្ពង់ខ្ពស់" (បាទ= ជើង ឥស្វរ = ព្រះឥស្វរ បរម = ប្រសើរខ្ពង់ខ្ពស់) ។ ស្តេចសុរិយវរ្ម័នទី២ មានព្រះនាមថា "មហាបរមវិស្ណុលោកៈ" គឺព្រះអង្គបានទៅដល់ "ឋានព្រះវិស្ណុដ៏មហាខ្ពង់ខ្ពស់" (លោកៈ = ឋាន) ។

**តឹស្តេចខ្មែរក្រោយអង្គរទេ ដែលជាព្រះអាទិទេព** ពីព្រោះនៅលើស្តេចឥតមានព្រាហ្មណ៍ ឬ ព្រះទៀតទេ ។ ព្រះពុទ្ធសាសនាឥតមានព្រះឡើយ ហើយព្រះពុទ្ធអង្គក៏មិនទុកព្រះអង្គជាព្រះដែរ ។ ស្តេចខ្មែរមានឋានៈខ្ពស់ជាងគេបង្អស់ដូចព្រះ ហេតុនេះហើយបានជា "ព្រះបាទព្រះ" បានទៅជា "ព្រះបាទស្តេច" ទៅវិញ រួចព្រះនាមស្តេចមានពាក្យព្រះបាទនៅពីមុខជានិច្ច ។ ស្តេចខ្មែរក្រោយអង្គរមានព្រះនាមជា "ព្រះបាទ" ពេលនៅមានជីវិត មិនមែនពេលសុគតរួចទេ ។ មហាក្សត្រនរោត្តមសីហនុជាដើម មានព្រះនាមជា "ព្រះបាទសម្តេចព្រះនរោត្តម សីហនុ" ។

កាលពេលនៅកុមារ គេប្រគល់ក្សត្រដែលត្រូវសោយរាជ្យឲ្យទៅព្រាហ្មណ៍អ្នកប្រាជមួយអង្គ ដើម្បីអប់រំ បង្ហាត់បង្រៀន ។ ព្រាហ្មណ៍នេះគឺជាគ្រូ ហើយគឺគ្រូនេះឯងដែលជាអ្នកអធិបតីក្នុងពិធីអភិសេកក្សត្រនោះ ឲ្យទៅជាស្តេច ។ ព្រាហ្មណ៍នេះក៏បានទៅជាព្រះគ្រូ ឬ រាជគ្រូហើយនិងបុរោហិតទៀត ។ ដោយសារការសិក្សា

www.elibraryofcambodia.org

យ៉ាងច្បាស់លាស់នេះ ស្តេចអង្គរសុទ្ធតែជាអ្នកមានវិជ្ជាត្រឹមត្រូវទាំងអស់ ។ លោក " ប្រុណូដាហ្សាំង"[៣] បានសរសេរថា ៖ ជ័យវរ្ម័នទី៧ ទុកព្រះអង្គស្មើនឹងប៉ានីនី ដែលជាអ្នកវេយ្យាករណ៍ធំជាងគេបង្អស់នៅស្រុកក្លឹង្គ ។ រាជិន្ទ្រវរ្ម័ន ចេះវិទ្យាសាស្ត្រដល់ទៅ១៤មុខ ហើយសុរិយាវរ្ម័នទី១ ជានិមិត្តរូបនៃចំណេះវិជ្ជាទាំងអស់.....។ ចម្លាក់ថ្មដែលមានពាសពេញ នៅលើជញ្ជាំងប្រាសាទនៅអង្គរ បង្ហាញឲ្យឃើញនូវភាពចេះដឹង និងវប្បធម៌ខ្ពង់ខ្ពស់របស់ស្តេចអង្គរ ហើយនឹងរបស់អ្នកដឹកនាំប្រទេសនៅពេលនោះ ។ រូបចម្លាក់អំពីទ័ពរបស់មហាក្សត្រសុរិយវរ្ម័នទី២ នៅលើជញ្ជាំង "អង្គរវត្ត" ឬ "វិស្ណុលោកៈ" នេះគឺគ្រាន់តែជាការចម្លង តាមកងទ័ពពេញលក្ខណៈ ដែលគេបាននិទានក្នុងសៀវភៅនយោបាយមួយ ឈ្មោះថា "អាថិសាស្ត្រា" រៀបរៀងដោយព្រាហ្មណ៍ "កៅតិល្យៈ" ជាង២សតវត្សន៍មុន គ.ស ទៅទៀត ។

ក្នុងការគ្រប់គ្រងរដ្ឋ តាមការពិតស្តេចអង្គរជាស្តេចនៅក្រោម "**រដ្ឋធម្មនុញ្ញ**" ហើយរដ្ឋធម្មនុញ្ញនោះគឺ "ព្រះធម៌ ឬ ក្បួនវេទ" ដែលព្រះអាទិទេពប្រទានឲ្យ ។ លោក "គ្លូ. សឺដែស"[៤] សរសេរថា ៖ "ស្តេចជាតំណាងអំណាចទូទៅទាំងអស់ ប៉ុន្តែកុំនឹកស្មានថាស្តេចសោយរាជ្យនៅអង្គរជាស្តេចប្រើអំណាចផ្តាច់ការ ធ្វើអ្វីៗបានតាមចិត្ត ។ ផ្ទុយទៅវិញ ដោយសារមានករណីកិច្ចក្នុងវណ្ណៈជាក្សត្រ ដោយសេចក្តីគោរពសុភាសិតនយោបាយជាតិ ស្តេចអង្គរគឺជាអ្នក

---

[៣] Bruno Dagens : op. cit. p. 85.

[៤] Georges Coedes : op. cit. p. 221.

www.elibraryofcambodia.org

រក្សាការពារ "ព្រះធម៌" និង របៀបរៀបរយក្នុងសង្គម" ....។ **ករណីស្តេចតាមព្រះធម៌គឺ ៖ រៀនក្បួនវេទ ការពារព្រះធម៌ ប្រទេសជាតិ និងប្រជារាស្ត្រ ហើយធ្វើអំណោយដល់ព្រាហ្មណ៍** ។ នេះគឺច្បាប់សម្រាប់វណ្ណៈ "ក្សត្រ" ។ ក្នុងការប្រព្រឹត្តទូទៅ អ្នកនិពន្ធជាច្រើនបានសំគាល់ឃើញថា ការសម្រេចចិត្តរបស់ស្តេច ដែលនៅលើថ្មស៊ីមានៅតាមអាស្រមកាលរាជ យសោវរ្ម័នទី១ ឬ នៅក្នុងច្បាប់សម្រាប់ឲ្យគេប្រព្រឹត្តក្នុងមន្ទីរពេទ្យកាលស្តេច ជ័យវរ្ម័នទី៧ គឺសុទ្ធតែជាច្បាប់ស្របតាមភាពនិតិប្រតិបត្តិទាំងអស់ មិនមែនជាច្បាប់តាមរបៀបនិតិបញ្ញត្តិទេ ។

ការរៀបចំគ្រប់គ្រងរដ្ឋជំនាន់អង្គរបានស្តេចធ្វើឡើងដោយត្រឹមត្រូវ ។ រដ្ឋមន្ត្រីដែលគេហៅថាមន្ត្រិន សុទ្ធតែជាអ្នកមានវិជ្ជាខ្ពង់ខ្ពស់ ។ អ្នកខ្លះបានល្បីល្បាញដោយបានចេះធម្មសាស្ត្រា អ្នកខ្លះទៀតដោយចេះស្ទាត់អ៊ាថសាស្ត្រា ដែលជាក្បួនវិទ្យាសាស្ត្រខាងនយោបាយ ។ អស្ចារ្យទៀត គឺ រដ្ឋមន្ត្រីមួយរបស់មហាក្សត្រជ័យវរ្ម័នទី៥ ដែលគេដឹងថាលោកចេះទាំងអស់ វិជ្ជាទាំងឡាយក្នុងក្បួនវេទ ។ ខេត្តទាំងអស់ដែលមានចំនួន ៩០ កាលពេលដែលចិនជូតាក្វាន់បានទៅដល់ មានការត្រួតត្រាយ៉ាងត្រឹមត្រូវពីអ្នកអភិបាលដែលគេជ្រើសរើស ក្នុងព្រះរាជវង្សានុវង្ស ឬក្នុងអ្នកសម្ព័ន្ធមិត្ត ។ កាលឆ្នាំ ១០១១ ស្តេចសុរិយវរ្ម័នទី១ បានឲ្យអ្នកមន្ត្រីទាំងនោះមកស្បថជានិច្ចារិក ហើយឈ្មោះ ព្រមទាំងមុខងារ អ្នកនោះទៀត បានគេឆ្លាក់ទុកនៅលើជញ្ជាំងប្រាសាទតូច ដែលជាទ្វារចូលទៅព្រះរាជវាំងនៅអង្គរ ។ កងទ័ពក៏បានគេរៀបចំស្រួលបួលដែរ មានមេ

www.elibraryofcambodia.org

# មហានគរខ្មែរ កាលសតវត្សទី១៣




www.elibraryofcambodia.org

បញ្ញាការតូចធំ ដូចឧត្តមសេនីយ ដែលគេហៅថា "សេនាបតី" ឬ "សេនាបតីបតី" ដែលជាមេបញ្ជាការធំបង្អស់ ។ ពេលដែលធ្វើដំណើរកងទ័ពតែងមានភ្លេង មានស្គរ មានអ្នកហក់ មានអ្នកលោតហៃរហាមកំដរ ព្រមទាំងរបស់ភស្តុភារផ្សេងៗ គ្រប់បែបយ៉ាង ។ ស្តេចជាអគ្គមេបញ្ជាការធំជាងគេទាំងអស់ ។ ស្តេចអង្គរគឺជាមេទ័ពមែនទែន មិនមែនដូចប្រមុខរដ្ឋសព្វថ្ងៃទេ ហើយពេលចម្បាំងស្តេចតែងនៅមុខទ័ព ដូចដែលគេបានឃើញក្នុងចម្លាក់ លើជញ្ជាំងប្រាសាទវិស្ណុលោកៈ ។ នៅក្នុងព្រះរាជវាំង ស្តេចមានក្រុមទាហានផ្ទាល់រក្សាព្រះអង្គ ចំនួន ៤០០ នាក់ សុទ្ធតែជាស្ត្រីដែលមានការក្លាហានឥតសង្ស័យបាន ។

ឫទ្ធានុភាពខ្លាំងក្លារបស់ស្តេចអង្គរ ក៏ស្របអាស្រ័យជាមួយសេដ្ឋកិច្ចយ៉ាងចម្រើនរុងរឿងដែរ ។ ខាងផ្លូវសេដ្ឋកិច្ច ស្តេចបានគិតគូរយ៉ាងត្រឹមត្រូវ ហើយសេដ្ឋកិច្ចនោះ គឺកសិកម្ម ។ សុភាសិតជំនាន់អង្គរមួយបាននិយាយថា **"ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងស្រូវ"** ប្រែមកថាបើឥតមានទឹក ធ្វើស្រែមិនបានទេ ហើយបើអត់ស្រូវទេ គេមិនអាចការពារនគរបានដែរ ។ ការយល់របៀបនេះនាំឲ្យស្តេចអង្គរទាំងអស់ ទុក **"នយោបាយទឹក"** គឺជាការជីកស្រះ ជីកបារាយណ៍ ជីកស្ទឹង ជីកព្រែក ជីកប្រឡាយទឹកផ្សេងៗ ជានយោបាយសំខាន់មុនគេ ។ គឺក្នុងន័យនយោបាយទឹកនេះហើយដែលយសោវរ្ម័នទី១ (៨៨៩-៩១០) បានសាងបារាយណ៍ខាងកើតឈ្មោះ **"ឥន្ទ្រតាតកៈ"** ដែលមានបណ្តោយ ៧,១០គ.ម និងទទឹង ១,៨ គ.ម ។ ស្តេចសុរិយវរ្ម័នទី១ (១០០២-១០៥០) បានជីក

www.elibraryofcambodia.org

បារាយណ៍ខាងលិច មានបណ្តោយ ៨ គ.ម និងទទឹង ២ គ.ម ។ ជ័យវរ្ម័នទី៧ ក៏សាងបារាយណ៍មួយដែរ ដែលមានប្រាសាទ "នាគពាន់" នៅចំកណ្តាល ហើយដែលមានឈ្មោះថា "ជ័យតាតកៈ" ។ ស្រះផ្សេងៗទៀត មាននៅពាសពេញទាំងអស់ក្នុងស្រុកខ្មែរ ដូចស្រះលលៃនៅរលួស ស្រះតាព្រហ្មណ៍នៅបាទីជិតភ្នំពេញ និងស្រះជិតភ្នំជីសូរនៅតាកែវ ។ ស្រះតូចៗទៀត មានដូចបឹងមាលា នៅព្រះខាន់កំពង់ស្វាយ នៅបន្ទាយឆ្មារ និង ស្រះគួរនៅខេត្តព្រះត្រពាំង.........ល ។ នៅវាលកក់ ជិតស្វាយរៀង ខាងកម្ពុជាក្រោមសព្វថ្ងៃ ស្តេចកៅណ្ឌិន្យជ័យវរ្ម័ន (៤៨០-៥១៤) បានជីកប្រឡាយទឹកជាង ២០០ គ.ម សម្រាប់ធ្វើស្រែ ។ ការកាន់បានត្រឹមត្រូវនយោបាយទឹក បានឲ្យផ្តល់ស្រូវដល់ទៅ ៣ ឬ ៤ រដូវក្នុងមួយឆ្នាំ តាមពាក្យរបស់ចិនជូតាក្វាន់ ហើយដែលបានចិញ្ចឹមប្រជាពលរដ្ឋយ៉ាងតិចក៏ ១៥លាននាក់ដែរ (អ.ដ.មើនិអេ)[៥] ក្នុងនោះមាននៅតំបន់អង្គរជាង ១ លាននាក់ (ហ្ស.ឡោរ)[៦] ។

ស្តេចអង្គរជាអ្នកការពារសង្គម និងការពាររាស្រ្ត ។ ព្រះអង្គបានបំពេញកិច្ចការល្អច្រើន ដែលគួរឲ្យគេកត់សំគាល់ ។ ស្តេចចេញថ្លៃឲ្យទាំងអស់ក្នុងការសិក្សារបស់សិស្សច្រើនពាន់នាក់ នៅគ្រប់វិទ្យាល័យដែលគេហៅថា **អាស្រម** ហើយនិងនិស្សិតរាប់ពាន់នាក់ទៀតនៅក្នុងមហាវិទ្យាល័យ ។ ស្តេចចេញឲ្យទាំងអស់ចំណាយរបស់អ្នកជម្ងឺ ក្នុងមន្ទីរពេទ្យដែលមានចំនួនដល់ ១០២

---

[៥] A. Dauphin Meunier : op. cit. p. 110.

[៦] Jean Laur : Angkor, op. cit. p. 178.

www.elibraryofcambodia.org

កាលក្សត្រជ័យវរ្ម័នទី៧ ។ ការថែទាំសាលាសំណាក់ជាង ១២០ នៅតាមផ្លូវទៅឆ្ងាយៗ ធ្វើឲ្យអ្នកដំណើរអាចសម្រាកកាយបាន នៅពេលទៅណាមកណា ។

នេះគឺស្តេចអម្ចាស់ ព្រះអង្គមិនមែនជាព្រះអាទិទេពនៅឆ្ងាយលើសនេះទេ ។ ព្រះអង្គជាបុគ្គលមួយ ដែលទទួលខុសត្រូវ ជាអ្នកការពារព្រះធម៌ ធម្ម និង ប្រជារាស្ត្រ ដូចដែលក្បួនគម្ពីរវេទបានបញ្ជារមក ក្នុងក្របខណ្ឌសាសនា របស់ព្រះអង្គ គឺព្រហ្មញ្ញសាសនា។

www.elibraryofcambodia.org

## វគ្គទី ២១

# ការសិក្សានៅអង្គរ

កាលឆ្នាំ ១២៩៦ ជូតាក្វាន់ដែលមកបំពេញបេសកកម្មនៅអង្គរ បានសរសេរថា ៖ "កូនអ្នកគ្រហស្ថទៅរៀន ហើយនៅជាមួយលោកសង្ឃ ។ ដល់ពេលធំឡើងគេត្រឡប់ទៅជាគ្រហស្ថវិញ......។ ចំណែកឯព្រាហ្មណ៍ គេឥតមានអ្វីដែលអាចនឹងហៅថាសាលា ឬជាកន្លែងរៀនសូត្របានទេ ។ គេពីបាកដឹងដែរ ថាសៀវភៅណាទៅដែលពួកព្រាហ្មណ៍មើល ?" (ប៉ូលបេលីអូត៍) ។

តាមការពិត នៅអង្គរខ្មែរមានរបៀបរៀបចំការសិក្សា ដែលលោកជូតាក្វាន់មិនបានដឹងឲ្យច្បាស់លាស់ ដោយសារលោកជាជនបរទេស ហើយដោយសារលោកសំណាក់នៅស្រុកខ្មែរតែមួយពេលយ៉ាងខ្លី ។ ការស្ថាបនាប្រាសាទរាប់រយ ការសង់ក្រុង និងកំផែង ផ្លូវស្ពាន មន្ទីរពេទ្យ អាចនឹងធ្វើឡើងបានលុះណាតែគេមានចំណេះវិជ្ជាយ៉ាងមាំមួន ហើយដែលគេបានចែកឲ្យកូនចៅតៗទៅ ។ ការពិតមួយទៀតគឺថា ការសិក្សាជំនាន់នោះគេធ្វើតាមតែការចេះដឹងតាមជំនឿ និង ការត្រូវការនៅពេលនោះទេ ។ នេះជាការធម្មតា តែ

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធីខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ សៀង ស៊ីវ៉ាន់
ខែធ្នូ ឆ្នាំ២០១៦
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្វៅ យុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org